18K-CA078-柬埔寨文：阿毗達摩概論-字.pdf 1 2019/8/6 上午 08:55:30

As this is a Dhamma text,
we request that it be treated with respect.
If you are finished with it,
please pass it on to others or
offer it to a monastery, school or public library.
Thanks for your co-operation.
**Namo Amitabha!**

《柬埔寨文：阿毗達摩概論 Abhidhammatthādhippāya》
財團法人佛陀教育基金會 印贈
Printed for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Website: www.budaedu.org ; overseas@budaedu.org,
**This book is for free distribution, it is not to be sold.**
សម្រាប់ចែកជាធម្មទាន
Printed in Taiwan
CA078

CA078 អភិធម្មត្ថាធិប្បាយ Abhidhammatthādhippāya

# អភិធម្មត្ថាធិប្បាយ

**សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា**
ព្រះនាម **ល្វី-ឯម** វជិរប្បញ្ញោ
ប្រែនិងរៀបរៀង
តាមគម្ពីរបាលី អដ្ឋកថាដីកា យោជនាអភិធម្ម
ពី ព.ស. ២៤៨៥-គ.ស. ១៩៤២
គណៈរដ្ឋមន្ត្រីនិងសម្តេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

**ភ្នំពេញ**
**ការផ្សាយរបស់អង្គការមូលនិធិវត្តបញ្ញាធំ**

**ព.ស. ២៥៦៣** **គ.ស. ២០១៩**



# ឆាយាលក្ខណ៍ សម្តេចព្រះធម្មលិខិត ល្វី-ឯម

ជាតៈ ថ្ងៃចន្ទ ៥ កើត ខែពិសាខ ឆ្នាំរោងទោស័ក ព.ស. ២៤២២

មតៈ ថ្ងៃអង្គារ ៩ កើត ខែពិសាខ ឆ្នាំរកានព្វស័ក ព.ស. ២៥០០

# ជីវប្រវត្តិសង្ខេប

# នៃសម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សាគណៈមហា-និកាយ អតីតចៅអធិការវត្តលង្កា សង្កាត់លេខ៦ក្រុងភ្នំពេញ

*សម្តេចជាបុត្រ នៃបិតានាម* **ល្វីជោ-មាន់** *និងលោកស្រី* **ទ្រាក់** *កើតនៅថ្ងៃចន្ទ ៥ កើត ខែពិសាខ ឆ្នាំរោងទោស័ក ព.ស. ២៤២២ គ.ស. ១៨៧៩ នៅក្រុងភ្នំពេញ បានសិក្សារៀនអក្សរសាស្ត្រខ្មែរចេះចប់ លុះដល់អាយុ ១៥ ឆ្នាំបានបួសជាសាមណេររៀនសូត្រព្រះត្រៃ-បិដកក្នុងវត្តឧណ្ណាលោម លុះដល់ ព.ស. ២៤៤៣ គ.ស. ១៩០០ បានឧបសម្ប័ទជាភិក្ខុក្នុងសំណាក់សម្តេចព្រះមហាសង្ឃរាជព្រះនាម* **ជិល-ទៀង** *ជាព្រះឧបជ្ឈាយ៍ មាននាមឆាយាជា “***វជីរប្បញ្ញោ***” នៅសំណាក់អាស្រ័យនឹងព្រះតេជគុណព្រះមហាវិមលធម្ម នាម* **ថោង** *ចាងហ្វាងទី១ នៃសាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ។*

*លុះដល់ ព.ស. ២៤៤៥ គ.ស. ១៩០២ មានឧបាសកឈ្មោះ បញ្ញា-ចាប នៅឃុំស៊ីធរ បានចូលមកកាន់សំណាក់សម្តេចព្រះមហា-សង្ឃរាជនិងព្រះតេជព្រះគុណព្រះមហាវិមលធម្ម សុំនិមន្តទៅធ្វើជាចៅ-អធិការ នៅវត្តស៊ីធរ ឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល*

ក្នុងគ្រានោះឯង ។

ភិក្ខុ **ល្វី-ឯម** បានទទួលព្រះមហាថេរបញ្ជាទាំងពីរព្រះអង្គ ហើយ ក៏និមន្តទៅធ្វើចៅអធិការ វត្តស៊ីធរ ខំប្រឹងបម្រើព្រះពុទ្ធសាសនា បង្រៀនព្រះបរិយត្តិធម៌, បង្ហាត់សូត្រធម៌ឲ្យត្រឹមត្រូវ, ចាត់ការឲ្យបង្រៀនអក្សរសាស្ត្រ, រៀបចំវត្តអារាមឲ្យបានទៅតាមអនាម័យល្អរុងរឿងឡើង ប្រឹងសម្ដែងធម៌ទេសនាបំភ្លឺពួកពុទ្ធបរិស័ទឲ្យមានសេចក្ដីជ្រះថ្លាជឿស៊ប់ក្នុងព្រះពុទ្ធសាសនាអស់រយៈពេល ៩ ឆ្នាំ[១] ។

ចៅអធិការ **ល្វី-ឯម** កំពុងតែគង់នៅជាសុខសប្បាយរីករាយជាមួយនឹងសិស្សគណ ឧបាសក ឧបាសិកា វត្តស៊ីធរ ឃុំស៊ីធរអស់រយៈកាលបាន ៩ វស្សា ពេលនោះលោកអ្នកឧកញ៉ាយោមរាជ ម៉ែន លោកជំទាវ ព្រាប បានចូលបង្គំទូលព្រះករុណាស៊ីសុវត្ថិមុនីវង្ស កាលដែលទ្រង់គង់នៅជាព្រះអង្គម្ចាស់អធិបតីនៅឡើយ សូមឲ្យទ្រង់មេត្តាមានបញ្ជាឲ្យនិមន្តលោកចៅអធិការ **ល្វី-ឯម** ពីវត្តស៊ីធរមកធ្វើជាចៅអធិការវត្តលង្កានេះ ស្រាប់តែមានលិខិតព្រះមហាវិមលធម្ម នាម ថោង ទទួលព្រះបញ្ជា ពីសម្ដេចព្រះមហាសង្ឃរាជ ឲ្យនិមន្តចៅអធិការ **ល្វី-ឯម** មកភ្នំពេញ, ពេលនោះសិស្សគណ ឧបាសក ឧបាសិកា

---

១- តាមសេចក្ដីពិតរបស់លោកអតីតមេឃុំ គុជ-លុក ឃុំស៊ីធរថា ១៤ ឆ្នាំ ។

ក៏ស្រាប់តែស្រងាកចិត្តគ្រប់គ្នា លោកក៏ចម្រើនពរលាចេញចាកអារាមវត្ត ស៊ីធរនោះ ពី ព.ស. ២៤៥៤ គ.ស. ១៩១១ ត្រឡប់មកធ្វើជាចៅអធិការ វត្តលង្កានេះ ប៉ុន្តែនៅមានព្រះទ័យប្រកបដោយមេត្តាករុណា មិនបាន កាត់អាល័យបោះបង់ចោលកេរដំណែលវត្តស៊ីធរនោះឡើយ តែងបាន ជួយទំនុកបម្រុងជាដរាបរហូតដល់អស់ព្រះជន្មាយុ ។

ចៅអធិការ **ល្វី-ឯម** ដែលបានទទួលឋានៈជានេវាសិកាធិបតី ចៅអាវាសវត្តលង្កានេះ ពីព.ស. ២៤៥៤ គ.ស. ១៩១១ កាលគ្រានោះ មានតែភិក្ខុសង្ឃប្រហែល ១៨ អង្គប៉ុណ្ណោះ ចាត់ការរៀបចំស្ទូចយកព្រះ បដិមាអង្គធំដែលកប់នៅក្នុងរណ្តៅដី ដែលគេចាក់ក្នុងវិហារលើកឡើង តម្កល់លើបល្ល័ង្កជាដំបូង ។

លុះដល់ ព.ស. ២៤៥៦ គ.ស. ១៩១៣ ចៅអធិការ **ល្វី ឯម** បានទទួលឋានៈជាព្រះគ្រូ **វិមលបញ្ញា**, ដល់ព.ស. ២៤៥៧ គ.ស. ១៩១៤-១៥ បានទទួលសមណស័ក្តិជា **ព្រះញាណបវរវិជ្ជា** ផង ជាសាស្ត្រាចារ្យនៃសាលាបាលីជាន់ខ្ពស់ផង ។

លុះដល់ ព.ស. ២៤៧២ គ.ស. ១៩២៩ បានឡើងជាចាងហ្វាង សាលាបាលីជាន់ខ្ពស់ បានកសាងធម្មសភា ១ ខ្នង, ដល់ ព.ស. ២៤៧៣

គ.ស. ១៩៣០ បានឡើងនាទីជាអធិបតីក្រុមជំនុំប្រែព្រះត្រៃបិដក, គ.ស. ១៩៣២ បានឡើងសមណស័ក្តិជាព្រះសិរីសម្មតិវង្ស, នៅថ្ងៃពុធ ១៤ រោច ខែផល្គុន ឆ្នាំរកាបញ្ចស័ក ព.ស. ២៤៧៧ គ.ស. ១៩៣៤ បានកសាងកំផែងវត្តព័ទ្ធពីទីឧបចារៈខាងជើង រហូតដល់ទីឧបចារៈខាងកើត ទុកជាកំណត់ព្រំដែន ។ ដល់ព.ស. ២៤៨៥ គ.ស. ១៩៤២ បានសមណស័ក្តិជាព្រះធម្មលិខិត សង្ឃមន្ត្រីសម្រាប់ឯក, បានសាងធម្មកុដិ ១ ខ្នង ពី ព.ស. ២៤៩០ គ.ស. ១៩៤៧ ដោយការរួបរួមជាមួយនឹងពុទ្ធបរិស័ទនៅស្រុកជិតឆ្ងាយ សម្រាប់សង្ឃគង់នៅក្នុងសាសនា, ដល់ ព.ស. ២៤៩៤ គ.ស. ១៩៥១ បានឡើងជាទីសម្តេចព្រះធម្មលិខិតឧត្តមប្រឹក្សាគណៈមហានិកាយ, លុះដល់ ព.ស. ២៤៩៧ សម្តេចបានប្រជុំភិក្ខុសង្ឃក្នុងវត្តនិងឧបាសកឧបាសិកា ចាត់ការរុះរើវិហារចាស់ហើយកសាងវិហារថ្មី នៅថ្ងៃពុធ ១៥ កើត ខែកត្តិក ត្រូវនឹងថ្ងៃទី ១០ ខែវិច្ឆិកា ១៩៥៤ ។

ការកសាងវិហារថ្មីនេះ អស់រយៈកាលជាង ៣ ឆ្នាំ មិនទាន់ហើយស្រេច ក៏សម្តេចមានអាពាធជាទម្ងន់ ទ្រាំនឹងអាពាធនោះពុំបាន ក៏អនិច្ចធម្មទៅកាន់លោកខាងមុខ នៅថ្ងៃអង្គារ ៩ កើត ខែវិសាខ ឆ្នាំរកានព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ៧ ឧសភា គ.ស. ១៩៥៧

*ពេលម៉ោង ៩ និង ៤០ នាទីក្តី, អស់កិច្ចជីវប្បវត្តិរបស់សម្តេចត្រឹមប៉ុណ្ណេះ ។*

*បើគិតដល់គុណសម្បត្តិនិងគុណធម៌ របស់សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា គណៈមហានិកាយ ដែលបានបម្រើព្រះពុទ្ធសាសនាអស់រយៈកាល ៦៣ ឆ្នាំ ឃើញថាច្រើនហួសនិស្ស័យដែលនាំមករៀបរាប់ថ្លៃងជីវប្បវត្តិនោះ ឲ្យសព្វគ្រប់ក្នុងទីនេះបាន ព្រោះហេតុនោះពួកពុទ្ធបរិស័ទជាទីស្នេហាទាំងឡាយ បានកសាងរូបសំណាកស្ថិតសិទ្ធដោយស្អាន់តម្កល់ទុកជាអនុស្សាវរីយ៍ នៅទីវត្តលង្កានេះទុកជាទីគោរពតទៅ ។*

ព្រះពុទ្ធវង្ស កៅ-ស៊ឹម
ចៅអធិការវត្តលង្កា ជាសិស្សផ្ទាល់
បានរៀបរៀង

# បញ្ជីមាតិការឿង


| បញ្ហា | | ទំព័រ | បន្ទាត់ |
|---|---|---|---|
| | អារម្ភកថា | ១ | ១ |
| | នមស្សការ | ៥ | ១ |


## អភិធម្មត្ថាធិប្បាយ


| | | | |
|---|---|---|---|
| | អភិធម្មុប្បត្តិហេតុកថា | ៦ | ២ |
| ទី១ | សួរអំពីពាក្យថាអភិធម្ម | ៦ | ៩ |
| ទី២ | សួរអំពីអភិធម្មអ្នកណាសម្ដែងទុកមក | ៦ | ១៧ |
| ទី៣ | ព្រះអរហំសម្មាសម្ពុទ្ធត្រាស់បានប៉ុន្មានវស្សាសម្ដែងអភិធម្ម | ៧ | ៧ |
| ទី៤ | ព្រះជិនស្រីសម្ដែងអភិធម្មប្រោរព្ធព្រះសិរិមហាមាយា | ៨ | ៥ |
| ទី៥ | អំពីព្រះសិរិមហាមាយាស្ថិតនៅក្នុងឋានណា | ៩ | ៨ |
| ទី៦ | អំពីសិរិមហាមាយាស្ថិតនៅឋានតុសិតជាដើម | ៩ | ១៥ |
| ទី៧ | អំពីព្រះអនាវរណញ្ញាណប្រកបដោយកតញ្ញូធម៌ | ១០ | ១១ |
| ទី៨ | អំពីហេតុទី៤ ដែលព្រះពុទ្ធមាតាបុះមកដោយផ្លូវឆ្ងាយ | ១៥ | ១៦ |
| ទី៩ | អំពីផលានិសង្សព្រះសិរិមហាមាយាស្ដាប់ព្រះអភិធម្ម | ១៧ | ១៣ |
| ទី១០ | អំពីព្រះសម្មាសម្ពុទ្ធគង់លើផែនថ្មបណ្ឌុកម្ពលសិលាសនៈ | ២០ | ១០ |
| ទី១១ | អំពីកិច្ចព្រះអរហំសម្មាសម្ពុទ្ធក្នុងវស្សន្តរដូវបីខែ | ២១ | ៦ |
| ទី១២ | សួរបញ្ជាក់អំពីព្រះសម្មាសម្ពុទ្ធមានបិណ្ឌបាតជាដើម | ២២ | ២ |
| ទី១៣ | អំពីព្រះទសពលញាណយាងបុះមកកាន់ជម្ពូទ្វីប | ២៤ | ៦ |
| ទី១៤ | អំពីព្រះសម្មាសម្ពុទ្ធយាងទៅបិណ្ឌបាតឧត្តរកុរុទ្វីប | ២៥ | ១០ |
| ទី១៥ | អំពីព្រះសម្មាសម្ពុទ្ធសម្ដែងបរមត្ថអភិធម្មបែកជាបករណៈ | ២៨ | ៧ |
| ទី១៦ | អំពីព្រះសម្មាសម្ពុទ្ធ សម្ដែងអភិធម្មកំណត់ ៩០ ថ្ងៃ | ៣០ | ១៥ |
| ទី១៧ | អំពីព្រះដ៏មានព្រះភាគសម្ដែងអភិធម្មក្នុងឋានតាវត្តិង្ស | ៣៣ | ១២ |

| *បញ្ហា* | | *ទំព័រ* | *បន្ទាត់* |
|---|---|---|---|
| ទី១៨ | អំពីសម្ដែងអភិធម្មក្នុងឋានសួគ៌មានតែពួកទេវតា | ៣៤ | ៦ |
| ទី១៩ | អំពីសម្ដែងអភិធម្មក្នុងវស្សន្តរដូវជាមួយគ្នាមិនមុនមិនក្រោយ | ៣៥ | ១១ |
| ទី២០ | អំពីការឈ្វេងយល់ឧបនិស្ស័យភិក្ខុទាំង ៥០០ អង្គ | ៣៧ | ១៤ |


## អភិធម្មត្ថាធិប្បាយបរមត្ថកថា


| | | | |
|---|---|---|---|
| ទី២១ | អំពីរួបរួមកងធម៌កំណត់ឲ្យឈ្មោះគម្ពីរធម្មសង្គណីជាដើម | ៤០ | ១១ |
| ទី២២ | អំពីកុសលត្តិកមាតិកា | ៤៣ | ៤ |
| ទី២៣ | ពាក្យថាធម៌និងធម្មសត្វ | ៤៦ | ១១ |
| ទី២៤ | សេចក្ដីឆ្ងល់ត្រង់ពាក្យថាអកុសលធម៌ | ៤៨ | ១ |
| ទី២៥ | អំពីហេតុបណ្ដាលឲ្យកើតជាកុសលកម្មជាដើម | ៥២ | ២ |
| ទី២៦ | ពាក្យថាចិត្តុប្បាទប្រកបដោយលក្ខណៈ ៤ យ៉ាង | ៥៣ | ៣ |
| ទី២៧ | ចិត្តសត្វប្រែ អធិប្បាយដូចម្ដេច | ៥៥ | ១២ |
| ទី២៨ | ការហ្វឹកហ្វឺនចិត្តឲ្យចម្រើនទៅតាមថ្នាក់ទាបខ្ពស់ | ៥៨ | ៤ |
| ទី២៩ | ការឆ្ងល់អំពីបទភាជនីយៈ | ៦០ | ៥ |
| ទី៣០ | អំពីចិត្ត ៤ យ៉ាង ចំនួនដោយសង្ខេបនិងពិស្ដារ | ៦២ | ៧ |
| ទី៣១ | អំពីកាមាវចរចិត្ត ៥៤ | ៦៣ | ១១ |
| ទី៣២ | ពាក្យថាអកុសលចិត្តជាដើម អធិប្បាយ | ៦៤ | ២ |
| ទី៣៣ | ចិត្តប្រកបដោយហេតុ ព្រមទាំងអធិប្បាយ | ៦៦ | ៧ |
| ទី៣៤ | អំពីកុសលចិត្តនិងអកុសលចិត្តសម្បយោគដោយហេតុ | ៦៧ | ១១ |
| ទី៣៥ | អំពីព្រះសយម្ភូញាណទ្រង់ជ្រាបច្បាស់នូវវារៈចិត្តនៃសត្វ | ៧២ | ៤ |
| ទី៣៦ | អំពីសោភណចិត្ត ៣០ បែកទៅតាមពួកតាមក្រុម | ៧៣ | ១១ |
| ទី៣៧ | អំពីអកុសលវិបាក អហេតុកចិត្តទាំង ៧ | ៧៤ | ៦ |
| ទី៣៨ | អំពីកុសលវិបាក អហេតុកចិត្តទាំង ៨ | ៨០ | ១៤ |

| បញ្ហា | | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ទី៣៩ | អំពីអហេតុកកិរិយាចិត្តទាំង ៣ | ៨៣ | ១៣ |
| ទី៤០ | សេចក្តីសង្ស័យពីអារម្មណ៍ដែលមានឈ្មោះផ្សេងគ្នាទាំង ៤ | ៨៩ | ១៦ |
| ទី៤១ | សេចក្តីសង្ស័យពីអារម្មណ៍ទាំង ៦ ក្នុងកាមាវចរចិត្ត | ៩៤ | ១៤ |
| ទី៤២ | អំពីសោភណចិត្ត ៥៩ | ១០៤ | ៩ |
| ទី៤៣ | អំពីចិត្តតែមួយឲ្យឈ្មោះផ្សេងគ្នាជា ៣ យ៉ាង | ១០៥ | ១៣ |
| ទី៤៤ | អំពីកាមាវចរកុសលចិត្ត ៨ ផ្សេងគ្នាដោយវេទនាប៉ុន្មាន | ១១០ | ១ |
| ទី៤៥ | អំពីកាមាវចរកុសលចិត្ត ៨ ផ្សេងគ្នាដោយវេទនា ២ | ១១១ | ៥ |
| ទី៤៦ | បុគ្គលធ្វើបុណ្យដោយកុសលចិត្តជាញាណសម្បយុត្តជាដើម | ១២០ | ៤ |
| ទី៤៧ | កាមាវចរកុសលចិត្តប្រកបដោយសោមនស្សនិងឧបេក្ខាវេទនា | ១២១ | ១៦ |
| ទី៤៨ | សប្បុរសឲ្យទានបំពោះបុគ្គល-សង្ឃដោយកាមាវចរកុសលចិត្ត៨. | ១២៦ | ២ |
| ទី៤៩ | ពាក្យថាបុណ្យជាអសង្ខេយ្យ បែកនិងឧបមាដូចម្តេច | ១៣២ | ៦ |
| ទី៥០ | អំពីរូបាវចរកុសលចិត្តទាំង ៥ | ១៣៤ | ១៤ |
| ទី៥១ | អំពីពាក្យថាសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋាន | ១៣៩ | ១៤ |
| ទី៥២ | អំពីចរិតទាំង ៦ | ១៥៧ | ៩ |
| ទី៥៣ | កម្មដ្ឋាន ៤០ អនុលោមតាមចរិតទាំង ៦ | ១៦០ | ១០ |
| ទី៥៤ | អំពីភាវនា ៣ និមិត្ត ៣ សមាធិ ៣ | ១៦១ | ១៥ |
| ទី៥៥ | អំពីបាលីសូមអារាធនាមុន ដែលពុំទាន់ភាវនាកម្មដ្ឋានណាមួយ | ១៦៥ | ៣ |
| ទី៥៦ | អំពីវសីទាំង ៥ | ១៦៨ | ២ |
| ទី៥៧ | អំពីលោកុត្តរសោភណចិត្ត ៨ សម្តែងដោយធម្មាធិដ្ឋាន | ១៧០ | ១ |
| ទី៥៨ | បុគ្គលភេទ បែក-អធិប្បាយ | ១៧៥ | ៩ |
| ទី៥៩ | ព្រះអរិយបុគ្គល ៤ ពួក លះបង់សំយោជនធម៌ជាដើម | ១៧៦ | ១០ |
| ទី៦០ | បុថុជ្ជនបុគ្គលទាំង ២ ពួក | ១៨០ | ៤ |

| បញ្ហា | | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ទី៦១ | អំពីបុគ្គលទី ២-៣-៤ ដែលផ្សេងគ្នា | ១៨២ | ១១ |
| ទី៦២ | អំពីសកិទាគាមិបុគ្គលទី ២ ផ្សេងដោយឈ្មោះ ៥ យ៉ាង | ១៨៦ | ១២ |
| ទី៦៣ | ធម៌ ៥២ ឈ្មោះថាចេតសិកចែកតាមពួកមាន ៣ | ១៨៩ | ១០ |
| ទី៦៤ | អំពីអញ្ញសមានាចេតសិកពួកទី ១ | ១៩០ | ៥ |
| ទី៦៥ | អំពីអកុសលចេតសិកពួកទី ២ | ១៩៤ | ៤ |
| ទី៦៦ | អំពីសោភណចេតសិកពួកទី ៣ | ១៩៧ | ៨ |
| ទី៦៧ | ពាក្យថារូបសត្វ-ប្រែ-អធិប្បាយ | ២០៤ | ៨ |
| ទី៦៨ | អំពីសភាវធម៌ ២ យ៉ាងគឺមហាភូតនិងឧបាទាយ | ២០៦ | ៤ |
| ទី៦៩ | មហាភូតរូបចំនួន-ប្រែ-អធិប្បាយ | ២០៨ | ៣ |
| ទី៧០ | អំពីឧបាទាយរូប ២៤ | ២១០ | ៣ |
| ទី៧១ | អំពីរូប ២៨ មានឈ្មោះផ្សេងៗ គ្នាជាគូៗ | ២១៣ | ១ |
| ទី៧២ | អំពីរូបកលាបៈសំណុំរូបទាំង ២១ ពួក | ២១៧ | ១៤ |
| ទី៧៣ | អំពីរូបទាំង ៤ មានកម្មជរូបជាដើម | ២២២ | ១០ |
| ទី៧៤ | អំពីសត្វដែលកើតក្នុងភពទាំង ៣ មានរូបតិចច្រើនផ្សេងៗគ្នា | ២២៥ | ៦ |
| ទី៧៥ | អំពីអនុបាទិន្នករូប | ២២៦ | ១១ |
| ទី៧៦ | អំពីកំណើតសត្វទាំង ៤ យ៉ាង | ២៣២ | ១ |
| ទី៧៧ | អំពីកាយកោដ្ឋាសចំណែកកាយទាំង ៣ កំណាត់ | ២៣៩ | ១១ |
| ទី៧៨ | បកិណ្ណកសង្គហៈក្នុងចិត្ត ៨៩ ដួងមានវេទនា ៥ | ២៤១ | ៤ |
| ទី៧៩ | ក្នុងហេតុសង្គហចិត្ត ៨៩ | ២៤៣ | ៦ |
| ទី៨០ | ចិត្តនិងចេតសិកញុំាងកិច្ចទាំង ១៤ ឲ្យសម្រេច | ២៤៥ | ១១ |
| ទី៨១ | អំពីឋានជាទីនៅនៃចិត្តប្បាទមានបដិសន្ធិចិត្តជាដើម | ២៤៨ | ៤ |
| ទី៨២ | ទ្វារសង្គហៈ សួរអំពីទ្វារនិងវីថិចិត្ត | ២៥១ | ១ |

| បញ្ហា | | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ទី៨៣ | សួរក្នុងអារម្មណ៍សង្គហៈ ........................................ | ២៥២ | ១៤ |
| ទី៨៤ | សេចក្ដីសង្ស័យអំពីវត្ថុនិងវិញ្ញាណធាតុ ........................................ | ២៦១ | ៨ |
| ទី៨៥ | សួរក្នុងវិសយប្បវត្តិសង្គហៈ........................................ | ២៦៤ | ១ |
| ទី៨៦ | អំពីអារម្មណ៍ប្រព្រឹត្តទៅក្នុងទ្វារ ៥ ........................................ | ២៦៤ | ១៤ |
| ទី៨៧ | អំពីខណចិត្តធំទាំង ១៧........................................ | ២៦៥ | ៨ |
| ទី៨៨ | អំពីអារម្មណ៍ ៤ មានអតិមហន្តារម្មណ៍ជាដើម ........................................ | ២៧០ | ១ |
| ទី៨៩ | បញ្ជាក់សេចក្ដីអំពីអារម្មណ៍ទាំង ៤........................................ | ២៧៦ | ៦ |
| ទី៩០ | វិភូតារម្មណ៍និងអវិភូតារម្មណ៍ ........................................ | ២៧៩ | ១២ |
| ទី៩១ | ជវនសម្ភវរបស់បុថុជ្ជន-សេក្ខនិងអសេក្ខបុគ្គល........................................ | ២៨០ | ១៥ |
| ទី៩២ | បដិសន្ធិចតុក្កៈប្រជុំបដិសន្ធិទាំង ៤........................................ | ២៨៧ | ១០ |
| ទី៩៣ | កម្មចតុក្កៈប្រជុំកម្ម ៤ ដោយអាការមាន ៤ៗ ........................................ | ២៩៤ | ៤ |
| ទី៩៤ | កុសលកម្មនិងអកុសលកម្មឲ្យផលជាអហេតុកបដិសន្ធិ............ | ៣០៤ | ៥ |
| ទី៩៥ | ឧក្កដ្ឋកម្មនិងឱមកកម្មឲ្យផលផ្សេងៗ គ្នា........................................ | ៣០៦ | ៩ |
| ទី៩៦ | អំពីរឿងព្រះនិព្វានមាន ១-២........................................ | ៣១៩ | ៨ |
| ទី៩៧ | អំពីឋានព្រះនិព្វាន........................................ | ៣២៣ | ៤ |
| ទី៩៨ | ពាក្យថា ទីបំផុតលោក-ភពមាន ៣ ........................................ | ៣២៥ | ១១ |
| ទី៩៩ | ឋានព្រះនិព្វានស្ថិតនៅទីបំផុតលោក-ភពណា ឧបមា................ | ៣២៧ | ៤ |
| ទី១០០ | ព្រះខីណាស្រពរលត់ខន្ធចូលកាន់ព្រះនិព្វានយូរនិងឆាប់ ............ | ៣២៩ | ៩ |
| ទី១០១ | អំពីលោកុត្តរមហានគរ-លោកិយមហានគរ ........................................ | ៣៣១ | ២ |
| ទី១០២ | អំពីសោយសុខក្នុងព្រះនិព្វានឧត្ដមជាងសុខជាលោកិយ ............ | ៣៣៤ | ១០ |
| ទី១០៣ | អំពីឈ្មោះព្រះនិព្វាន ........................................ | ៣៣៧ | ៩ |
| ទី១០៤ | បុគ្គលទៅកាន់មហានគរ គឺព្រះនិព្វានដោយយានជំនិះអ្វី ........... | ៣៤៥ | ៣ |

# សេចក្តីអនុញ្ញាត

សៀវភៅ "អភិធម្មត្ថាធិប្បាយ" ដែលជាស្នាព្រះហស្តរបស់ព្រះសពសម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សាគណៈមហានិកាយ អតីតចៅអធិការវត្តលង្កា ក្រុងភ្នំពេញ ឲ្យចំពោះចៅកែ ជឹង-ប៉ោ-ហួត ផ្ទះលេខ ១៨០ ជាពាណិជ្ជករ ក្រុងភ្នំពេញ បោះជាថ្មីចំនួន ២០០០ ក្បាល ជាលើកទី ២ ហើយមិនបានអនុញ្ញាតច្បាប់នេះឲ្យបោះតទៅទៀតទេ ។

ចៅកែរូបនេះបានចូលមកសុំអនុញ្ញាតបោះពុម្ពសៀវភៅនេះ ចំពោះព្រះឃោសធម្ម ចៅអធិការវត្តលង្កា ជាសិស្សផ្ទាល់របស់សម្តេច ដោយបានជឹងថា "ព្រះសពសម្តេចកាលគង់ព្រះជន្មនៅ មានបំណងចង់បោះពុម្ពសៀវភៅនេះជាលើកទី ២ បំណងនេះមិនទាន់បានសម្រេច ក៏ព្រះអង្គលោកអនិច្ចធម្មទៅ សៀវភៅនេះក៏ទ្រឹងដរាបមកដល់សព្វថ្ងៃនេះ, ទើបតែឥឡូវនេះ ចៅកែ ជឹង-ប៉ោ-ហួត សុំអនុញ្ញាតបោះពុម្ពជាថ្មី ដើម្បីជាប្រយោជន៍ឲ្យសមតាមបំណងរបស់ពុទ្ធសាសនិក អ្នកត្រូវការសិក្សាប្រតិបត្តិក្នុងព្រះពុទ្ធសាសនា ។

ដូច្នេះ ការបោះពុម្ពសៀវភៅនេះ មិនបានអនុញ្ញាតឲ្យរើរុះដកចោលឬដាក់សេចក្តីបន្ថែមបំពេញនោះឡើយ ត្រូវតម្កល់ទុកសេចក្តីដើមឲ្យនៅដូចដើមដដែល ។

*សូមឧទ្ទិសកុសលនេះ ប្រគេន ចំពោះព្រះសពសម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា សូមឲ្យបានប្រកបដោយសេចក្តីសុខចម្រើនក្នុងទេវលោកកុំបីឃៀងឃ្លាត ។*

ភ្នំពេញ ថ្ងៃ ១៦-៩-៦៥

ព្រះឃោសធម្ម

# អារម្ភកថា

ការដែលបានផ្ដើម ឲ្យកើតសៀវភៅ អភិធម្មត្ថាធិប្បាយនេះឡើង ដោយសារយើងបានសិក្សារៀនគម្ពីរព្រះអភិធម្មសង្គណិបាលី ព្រមទាំង អដ្ឋកថានិងគម្ពីរព្រះអភិធម្មត្ថសង្គហបាលី ព្រមទាំងមហាដីកា, អនុដីកា, និស្ស័យ និងយោជនា លោកសម្ដែងប្រាប់ពន្យល់ធម្មរសនិងអត្ថរស ចំពោះបរមត្ថព្រះអភិធម្ម មានចិត្ត ចេតសិក រូប និងនិព្វានជាដើម នោះយើងបានរៀនរំពឹងជញ្ជឹងពិនិត្យពិចារណាមើល ធម្មរសនិងអត្ថរស ឲ្យសមគ្នា, ចំពោះបរមត្ថព្រះអភិធម្មតាមពុទ្ធភាសិត តាំងពីយើងបួសជា សាមណេរបាន ៤ វស្សាដរាបមកដល់ឥឡូវនេះបាន ៤២ ឆ្នាំហើយ ក៏នៅ តែពុំទាន់អស់សេចក្ដីព្យាយាមនៅឡើយ រឹងរឹតតែមានឧស្សាហ៍ព្យាយាម ក្លៀវក្លាខ្លាំងឡើងថែមទៀត ដោយយើងតាំងចិត្តជាកណ្ដាល មិនបាន ប្រើសទ្ធាខ្លាំងជាងបញ្ញា មិនបានប្រើបញ្ញាខ្លាំងជាងសទ្ធា គឺយកសតិជាធំ ចាប់ចង មនោជាខ្សែទាញទប់នឹមទាំងសងខាង គឺសទ្ធានិងបញ្ញាឲ្យ នឹងនៅស្មើគ្នា មិនឲ្យល្អៀងម្ខាងៗ ឬថាយកមនោជាខ្សែចងទាញទប់សេះ ទាំងគូ គឺសទ្ធានិងបញ្ញាឲ្យត្រាច់ទៅស្មើគ្នា មិនឲ្យវៀចវេរបែរទៅម្ខាងៗ ដើម្បីនឹងរក្សាផ្លូវត្រង់តាមសេចក្ដីពិតសមគួរដល់ពុទ្ធឱវាទ ។

មួយទៀត យើងខំប្រឹងព្យាយាមរៀនរៀងៗ មក តាំងពីអាយុ

១៦ ឆ្នាំ ដែលបានបួសជាសាមណេរ ដរាបដល់បានឧបសម្បទាជាភិក្ខុ-ភាវៈក្នុងព្រះពុទ្ធសាសនាកំណត់អាយុ ៦៣ ឆ្នាំគត់ កិច្ចដែលខំប្រឹងប្រែងព្យាយាមរៀន គឺមើលសាស្ត្រាបាលីសុទ្ធ ហើយខំត្រិះរិះគិតរំពឹងសញ្ជឹងពិចារណារឿយៗ ដោយច្រើនដងណាស់ កំណត់សង្កេតយកសេចក្ដីអត្ថរសបរមត្ថព្រះអភិធម្មឲ្យសមគ្នាតាមបាលី អដ្ឋកថា មហាដីកា អនុដីកា និស្ស័យ និង យោជនា ដើម្បីរក្សារោគគឺសេចក្ដីវិបត្តិអត្ថរសព្រះអភិធម្មដែលប្រែប្រួលឃ្លៀងឃ្លាតសេចក្ដីទៅផ្សេងៗ ឲ្យបានជារោគគឺឲ្យបានអត្ថសម្បត្តិពេញបរិបូរ ដោយអត្ថរសសមគួរដល់ពុទ្ធភាសិតោវាទជាប្រក្រតីវិញ ដូចជាអ្នករៀនវិធីពេទ្យចេះយ៉ាងវិសេស ដើម្បីនឹងរក្សាមនុស្សមានរោគឲ្យជារោគប៉ុណ្ណោះឯង ។ ក៏កាលដែលរាជការបានតាំងឲ្យមានព្រះរាជបណ្ណាល័យឡើងជាដំបូងនោះ យើងមានសេចក្ដីសោមនស្សត្រេកអរដ៏ក្រៃលែង បានខំប្រឹងប្រែងព្យាយាមរៀបរៀងសេចក្ដីបរមត្ថព្រះអភិធម្ម ៤ យ៉ាងគឺ ចិត្ត ១ ចេតសិក ១ រូប ១ និងនិព្វាន ១ ប្រមាណជាមួយឆ្នាំទើបចប់ ហើយបានយកទៅប្រគេនព្រះតេជព្រះគុណ ព្រះសពព្រះមហាវិមលធម្ម ព្រះនាម (ថោង) ចាង-ហ្វាងសាលាបាលីជាន់ខ្ពស់ សូមឲ្យលោកពិនិត្យផ្ទៀងផ្ទាត់ឲ្យ លោកក៏

មានព្រះទ័យរីករាយបានផ្ទៀងផ្ទាត់ដរាបដល់ចប់ រួចបានបញ្ជូនទៅព្រះរាជបណ្ណាល័យសុំឲ្យប្តឹងរាជការតាមក្រសួងសូមអនុញ្ញាតបោះពុម្ព រាជការក៏បានអនុញ្ញាតឲ្យជាស្រេច ទុកក្នុងមន្ទីរព្រះរាជបណ្ណាល័យ មានសេចក្តីបំណងនឹងបោះពុម្ពផ្សាយទៅដោយពិត តែបែរជាអាក់ខានបោះពុម្ពទៅវិញ សៀវភៅច្បាប់នោះក៏បាត់ទៅរកពុំឃើញ ហេតុដែលអាក់ខានបោះពុម្ពនឹងបាត់សៀវភៅច្បាប់ទៅដូច្នោះ ក៏យើងមិនបានទោមនស្សតូចចិត្តអ្វីឡើយ យើងរឹតតែមានសេចក្តីសោមនស្សត្រេកអរច្រើនឡើងដោយហេតុដែលយើងបានពិនិត្យសេចក្តីនោះ ថែមទៀតដោយការរំពឹងគិតរឿយៗ ទៅឃើញថាសៀវភៅច្បាប់នោះនៅមានវិបត្តិឃ្លៀងឃ្លាតអត្ថ-រសខ្វះដោយអន្ទើៗ ពុំទាន់បានត្រឹមត្រូវគ្រប់គ្រាន់ពេញលេញនៅឡើយ ហេតុហ្នឹងហើយបានជាយើងមានឧស្សាហ៍ព្យាយាមខ្លាំងឡើង មិនបានគិតសេចក្តីលំបាកនឿយហត់ ទោះបីចាស់ជរាគ្របសង្កត់ក៏ខំអត់ទ្រាំរៀបរៀងសៀវភៅអភិធម្មត្ថាធិប្បាយនេះ ឲ្យកើតឡើងដើម្បីរក្សាអត្ថរសឲ្យត្រឹមត្រូវសមគួរតាមពុទ្ធភាសិត តែថាពុំបានអធិប្បាយហួរហែ តាមរបៀបបរិច្ឆេទទាំង ៩ ក្នុងគម្ពីរអភិធម្មត្ថសង្គហៈឲ្យសព្វគ្រប់ទាំងអស់នោះទេ ព្រោះសេចក្តីវែងពិស្តារពេកមានទាំងលោកអ្នកប្រាជ្ញ សៀម-ខ្មែរបាន

ប្រៀបរៀងសេចក្ដីបរមត្ថព្រះអភិធម្ម ៩ បរិច្ឆេទបោះពុម្ពផ្សាយទៅដោយច្រើនសព្វគ្រប់ហើយ ក៏ក្នុងបរិច្ឆេទទាំង ៩ នោះ យើងពិនិត្យជ្រើសរើសដកស្រង់ យកតែសេចក្ដីបរមត្ថដែលមានអត្ថរស ដ៏ល្អិតជ្រាលជ្រៅក្រៃពេកនាំឲ្យកំបាំងប្រាជ្ញា កុលបុត្រអ្នកសិក្សាច្រើនតែភ័ន្តច្រឡំ នាំឲ្យទាល់គំនិតគិតពុំយល់ ម៉្លោះហើយគិតតែយកសេចក្ដីស្មានៗ ទៅដោយមិនបានច្បាស់លាស់ យើងនឹងជីកកកាយអត្ថរសទាំងឡាយដ៏ជ្រាលជ្រៅនោះយកមកអធិប្បាយ ឲ្យរាក់ងាយសេចក្ដីឡើង ដូចជាទីងងឹតហើយអុជប្រទីបឲ្យមានពន្លឺឡើង ដើម្បីជាប្រយោជន៍ដល់សាធុជនដែលមានសទ្ធាមុតមាំនឹងសិក្សាបានដឹង អត្ថរស បរមត្ថ ព្រះអភិធម្ម ដោយងាយតែការដែលនឹងអធិប្បាយនោះ យើងកំណត់ឲ្យមានពាក្យសួរប្រស្នាពាក្យឆ្លើយតបប្រស្នា ដូចភិក្ខុពីររូប គឺមហាថេរ អនុត្ថេរជាធម្មកថិកធ្វើធម្មសាកច្ឆា សាកសួរធម៌អាថ៌ ជជែកតវ៉ាគ្នាទៅវិញទៅមក ដើម្បីនឹងជីករំលើងអត្ថរសយកសេចក្ដីពិតជាវត្តប្រតិបត្តិក្នុងព្រះពុទ្ធសាសនា យើងបានកំណត់អ្នកសួរប្រស្នាថា ធម្មវាទី អ្នកឆ្លើយតបប្រស្នាថា អត្ថវាទី គឺថាធម្មវាទី ជាអ្នកសួរប្រស្នាបញ្ជាក់សេចក្ដី អត្ថវាទី ជាអ្នកឆ្លើយតបប្រស្នាអធិប្បាយតាមពាក្យសួរដោយពិត ដូចមានសម្ដែងសេចក្ដីទៅខាងមុខ ។

ចប់អារម្ភកថា

# នមស្សការ

## នមាមិ រតនត្តយំ

ខ្ញុំព្រះករុណាសូមបង្អោនកាយ វាចា ចិត្ត ថ្វាយបង្គំនឹករឭកចំពោះប្រជុំនៃព្រះរតនៈគឺព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ ដែលជាកែវដ៏ឧត្តមខ្ពង់ខ្ពស់បំផុតនឹងរកកែវអ្វីដទៃក្នុងលោកនេះ យកមកប្រៀបផ្ទឹមឲ្យត្រឹមស្មើពុំបានឡើយ ដោយត្បូងសិរសា ដោយសេចក្តីគោរព ។

តស្សានុភាវេន សព្វន្តរាយោ នស្សតុ សូមឲ្យសេចក្តីអន្តរាយទាំងអស់វិនាសបាត់បង់សាបរលាបអស់ទៅ ដោយអំណាចអានុភាពនៃគុណព្រះរតនត្រ័យនោះឯង ។

ចប់នមស្សការ ។

# អភិធម្មត្ថាធិប្បាយកថា

## អភិធម្មុប្បត្តិហេតុកថា

*សម្ដែងហេតុព្រះអភិធម្មដែលកើតឡើងក្នុងលោកជាដំបូងកំណត់ឲ្យមានពាក្យសួរពាក្យឆ្លើយ គឺជាសួរបញ្ជាក់សេចក្ដីបរមត្ថ អត្ថព្រះអភិធម្មដ៏ជ្រាលជ្រៅ ជីកគាស់កកាយសេចក្ដីដ៏កំបាំងជ្រាលជ្រៅនោះឲ្យរាក់ឡើង ដើម្បីជាប្រយោជន៍ដល់អ្នកសិក្សា បានស្ដាប់បានរៀនដឹងអត្ថរសព្រះអភិធម្មដោយងាយ ដូចយើងបានកំណត់ទុកក្នុងអារម្ភកថារួចហើយ នឹងសម្ដែងតទៅខាងក្រោយនេះ៖*

១- ធម្មវាទី *សួរប្រស្នាអត្ថវាទីថា លោក ពាក្យថាអភិធម្ម ៗ នោះអធិប្បាយបានដូចម្ដេចខ្លះ?*

អត្ថវាទី *ឆ្លើយតបប្រស្នាថា ពាក្យថា អភិធម្មៗ នោះ អធិប្បាយថាធម៌ក្រៃលែងក៏បាន ថាធម៌មានគុណានុភាពដ៏ល្អិត គឺមនុស្សនិងទេវតាព្រមទាំងពួកព្រហ្មគប្បីគោរពបូជាក៏បាន, ថាធម៌សម្ដែងប្រាប់ពន្យល់បរមត្ថមានអត្ថរសដ៏ជ្រាលជ្រៅក្រៃលែង ជាហេតុបណ្ដាលឲ្យកើតឡើងជាបុណ្យនិងបាបក្នុងសន្ដានសព្វសត្វក៏បាន, សេចក្ដីដែលបានអធិប្បាយមកជាសង្ខេបប៉ុណ្ណោះជាដើម បានឈ្មោះថាព្រះអភិធម្មដោយពិត ។*

២- ធម្មវាទី *ពោលថា អើអត្ថវាទី លោកអធិប្បាយពាក្យថា ព្រះ*

អភិធម្មមកនេះយើងស្តាប់បានហើយ ចុះព្រះអភិធម្មនោះ អ្នកណាគឺសមណៈ ឬព្រាហ្មណ៍ មនុស្សឬទេវតា យក្សឬព្រហ្ម សម្តែងតែងតាំងទុកមក?

អត្ថវាទី ឆ្លើយអធិប្បាយតបថា ព្រះអភិធម្មនោះនឹងថា សមណៈ ព្រាហ្មណ៍ មនុស្ស ទេវតា យក្ស ព្រហ្ម ឬអ្នកប្រាជ្ញណាមួយសម្តែង តែងតាំងទុកមកក៏ទេ, ព្រះអភិធម្មនេះពិតជាអង្គព្រះអរហំសម្មាសម្ពុទ្ធទ្រង់ សម្តែងតែងតាំងទុកមកដោយព្រះអង្គឯងពិត ។

៣- ធម្មវាទី ពោលថា អើអត្ថវាទី ប្រស្នានេះយើងស្តាប់បាន ហើយ ចុះព្រះអរហំសម្មាសម្ពុទ្ធកាលព្រះអង្គទ្រង់សម្តែងព្រះអភិធម្មនោះ ព្រះអង្គបានត្រាស់ជាអង្គសព្វញ្ញូកន្លងទៅបានប៉ុន្មានវស្សាហើយ? ដល់ វស្សាជាគម្រប់ប៉ុន្មានទើបទ្រង់សម្តែង? ព្រះអង្គទ្រង់សម្តែងនៅកន្លែងណា? ប្រារព្ធនូវបុគ្គលឈ្មោះអ្វី?

អត្ថវាទី ឆ្លើយតបថា ព្រះសព្វញ្ញូសម្មាសម្ពុទ្ធព្រះអង្គបានត្រាស់កន្លង ទៅ ៦ វស្សាហើយ ដល់វស្សាជាគម្រប់ ៧ ព្រះអង្គទ្រង់សម្តែងយមកបាដិ-ហារ្យផ្ចាញ់ពួកតិរ្ថិយទាំងឡាយមានពួកនិគ្រន្ថជាដើម ឲ្យបាក់បបខ្ចបខ្ចាច អំណាចបុណ្យសម្ភារព្រះបារមីព្រះអង្គហើយ ទ្រង់យាងទៅគង់ចាំវស្សា នៅនាបណ្តុកម្ពលសិលាសនៈក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងឋានតាវត្តឹស-

ពិភព ដែលជាទីប្រជុំនៃទេវតាទាំងមួយម៉ឺនលោកធាតុចូលមកប្រជុំក្នុងទីនោះ ទើបព្រះអង្គទ្រង់សម្ដែងបរមត្ថព្រះអភិធម្មប្រារព្ធចំពោះព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតាព្រះអង្គ ក្នុងទីប្រជុំនៃទេវតាទាំងមួយម៉ឺនលោកធាតុនោះឯង ។

៤- ធម្មវាទី ទទួលថា អើ! អត្ថវាទី លោកអធិប្បាយរឿងនេះមកយើងស្ដាប់បានសព្វគ្រប់ហើយ, ចុះអង្គសម្ដេចព្រះមុនិន្ទជិនស្រីជាម្ចាស់ទ្រង់ត្រាស់សម្ដែងបរមត្ថព្រះអភិធម្ម ប្រារព្ធចំពោះព្រះសិរិមហាមាយាទេវ-បុត្រជាពុទ្ធមាតារបស់ព្រះអង្គនោះ តើនិម្មិតវត្ថុអ្វី? ទ្រង់រំពឹងពិចារណាយល់ឃើញដូចម្ដេចខ្លះ?

អត្ថវាទី វិសជ្ជនាតបថា ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងបរមត្ថព្រះអភិធម្មប្រារព្ធចំពោះព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតានោះ និម្មិតមាតុគុណវត្ថុ គឺព្រះអង្គទ្រង់សម្ដែងតបស្នងសងគុណទឹកក្សីរសម្ដេចព្រះមេរបស់ព្រះអង្គ ដែលព្រះអង្គនៅជាព្រះពោធិសត្វនៅឡើយ តែងទទួលសោយរសទឹកក្សីរនៃព្រះមាតារបស់ព្រះអង្គមកច្រើនជាតិណាស់ហើយ ព្រោះព្រះអង្គបានត្រាស់កន្លងទៅ ៦ វស្សាហើយទ្រង់រំពឹងពិចារណាឃ្វេងយល់ឃើញច្បាស់ថា ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ក្នុងវស្សា

ជាគម្រប់ ៧ តែងយាងទៅគង់ចាំវស្សានៅនាផែនថ្មបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សដ៏ឋានតាវត្តឹសទេវលោក ហើយតែងលើក បរមត្ថព្រះអភិធម្មមកសម្ដែងតបស្នងសងគុណព្រះពុទ្ធមាតា ជាធម្មតា រៀងៗមក គ្រប់ព្រះអង្គទាំងអស់, ឯព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ទាំងឡាយទ្រង់យល់ហេតុដូច្នេះហើយ បានជាព្រះអង្គទ្រង់យាងទៅចាំព្រះ វស្សាឯឋានតាវត្តឹសពិភពក្នុងវស្សាជាគម្រប់ ៧ ដូចព្រះសម្មាសម្ពុទ្ធទាំងឡាយ នោះឯង ។

៥- ធម្មវាទី ពោលថា អើអត្ថវាទី ប្រស្នានេះលោកវិសជ្ជនាមក យើងស្ដាប់បានហើយ, ចុះព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតាទ្រង់ គង់នៅឋានណា?

អត្ថវាទី វិសជ្ជនាតបថា ព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតា ទ្រង់គង់នៅឋានតុសិត ដែលជាឋានមនោរម្យជាទីតម្រេកត្រេកអរនៃ លោកអ្នកមានបុណ្យវាសនាធំៗ មានសព្វញ្ញុពោធិសត្វជាដើម តែងទៅ កើតសោយសុខជាទិព្វក្នុងឋានតុសិតនោះឯង ។

៦- ធម្មវាទី ពោលថា អើអត្ថវាទី ប្រស្នានេះយើងស្ដាប់បានហើយ តែយើងនៅមានសង្ស័យតទៅទៀតថា បើព្រះសិរិមហាមាយាទេវបុត្រ

ជាពុទ្ធមាតាគង់ឯឋានតុសិតឆ្ងាយកន្លងទាំងឋានយាមាមួយទៀតផង បើឆ្ងាយដល់ម្ល៉េះ ដូចម្តេចព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតានឹងស្តាប់បរមត្ថព្រះអភិធម្មបាន ឬមួយព្រះពុទ្ធមាតាយាងចុះមកស្តាប់ឯឋានតាវត្តឹស-ទេវលោកចំពោះព្រះភក្ត្រឬដូចម្តេច?

អត្ថវាទី វិសជ្ជនាតបថា ព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតាព្រះអង្គគង់ឯឋានតុសិតក៏ពិតមែនហើយ តែថាកាលព្រះអរហំសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះអភិធម្មនោះ ព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតាក៏ព្រះអង្គទ្រង់យាងចុះមកកាន់ឋានតាវត្តឹសពិភព គង់ស្តាប់ព្រះអភិធម្មចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ក្នុងកណ្តាលជំនុំនៃទេវតាទាំងមួយម៉ឺនលោកធាតុដោយពិត ។

៧- ធម្មវាទី ពោលថា សាធុ ប្រពៃហើយអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះ ចុះសម្តេចព្រះអនាវរណញ្ញាណជាម្ចាស់ ព្រះអង្គប្រកបដោយកតញ្ញូតាធម៌មានព្រះហឫទ័យជ្រាបច្បាស់ថា ព្រះពុទ្ធមាតារបស់ព្រះអង្គមានឧបការគុណច្រើនដ៏ក្រៃលែង រករាប់ពុំបានស្មានពុំត្រូវកំណត់ពុំអស់ ធំទូលាយពន់ពេកណាស់ជាអនន្តគុណ ដូចម្តេចក៏ព្រះអង្គពុំបានយាងទៅកាន់ឋានតុសិតពិភព សម្តែងព្រះអភិធម្មតបស្នងសងគុណ

សម្តេចព្រះអនន្តគុណជាពុទ្ធមាតាឯឋានតុសិតតែម្តងទៅ ដូចម្តេចទើបព្រះអង្គយាងទៅកាន់ឋានតាវត្តិង្សពិភព គង់លើផែនបណ្ឌុកម្ពលសិលា-សនៈក្រោមដើមបារិច្ឆត្តកព្រឹក្សជាឋានខាងក្រោមវិញ ឲ្យព្រះពុទ្ធមាតានឿយព្រួយលំបាកព្រះអង្គយាងចុះមកអំពីស្ថានតុសិត រំលងទាំងស្ថានយាមាមួយទៀតផង ទើបបានមកដល់ស្ថានតាវត្តិង្សពិភព តើព្រះអង្គទ្រង់ឈ្វេងយល់ដោយហេតុមានប៉ុន្មានប្រការគឺហេតុអ្វីខ្លះ?

អត្ថវាទី ឆ្លើយតបថា សម្តេចព្រះបរមគ្រូជាម្ចាស់ ព្រះអង្គទ្រង់ឈ្វេងយល់ដោយហេតុ ៤ ប្រការគឺ

ហេតុទី ១ ព្រះអង្គទ្រង់ពិចារណាគុណព្រះមាតាព្រះអង្គ និងគុណព្រះត្រៃបិដក គឺទ្រង់យកគុណព្រះវិនយបិដកពីរម៉ឺនមួយពាន់ព្រះធម្មក្ខន្ធមកថ្លឹងប្រៀបផ្ទឹមនឹងគុណព្រះមាតាព្រះអង្គ ឃើញថាពុំស្មើនឹងគុណព្រះមា-តាព្រះអង្គឡើយ ទើបព្រះអង្គទ្រង់យកគុណព្រះសុត្តន្តបិដកពីរម៉ឺនមួយពាន់ព្រះធម្មក្ខន្ធ មកថ្លឹងប្រៀបផ្ទឹមនឹងគុណព្រះមាតាព្រះអង្គទៀត ក៏ឃើញថាពុំស្មើនឹងគុណព្រះមាតាទៀត ហើយព្រះអង្គទ្រង់យកគុណព្រះអភិធម្មបិដកបួនម៉ឺនពីរពាន់ព្រះធម្មក្ខន្ធ មកថ្លឹងប្រៀបផ្ទឹមនឹងគុណព្រះមាតា ឃើញថាមានគុណធំទូលាយស្មើៗគ្នា ទើបព្រះអង្គទ្រង់យាង

ទៅគង់លើផែនថ្មបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្ស នាឋាន តាវត្តិង្សទេវនគរ នៅទីពាក់កណ្ដាល ឲ្យព្រះពុទ្ធមាតាយាងចុះមកកាន់ទីពាក់កណ្ដាល សម្ដែងសេចក្ដីឲ្យឃើញច្បាស់លាស់ថាគុណវិសេសព្រះអភិធម្មបិដក និងគុណព្រះមាតារបស់ព្រះអង្គស្មើៗ គ្នាដោយពិត ។

ហេតុទី ២ ព្រះអង្គទ្រង់រំពឹងពិចារណាឃើញថាឋានតុសិតគ្មានទីអាសនៈដ៏សមគួរ ក្រៅអំពីទីប្រាសាទវិមានរបស់ទេវបុត្រ ទេវកញ្ញា ដែលជាចន្លោះទំនេរធំទូលាយ ល្មមដល់ទីប្រជុំទេវតាទាំងមួយម៉ឺនលោកធាតុ នឹងចូលមកអង្គុយប្រជុំស្ដាប់ព្រះអភិធម្ម ព្រមទាំងគ្មានទីដ៏សមគួរដល់ពុទ្ធាសនៈ ល្មមព្រះសម្មាសម្ពុទ្ធគង់ចាំវស្សានិងសម្ដែងបរមត្ថព្រះអភិ-ធម្មនោះបានឡើយ ។

ហេតុទី ៣ ព្រះអង្គទ្រង់ពិចារណាឃើញថា ឋានតាវត្តិង្សពិភពប្រកបដោយសួនច្បារមានដើមឈើតូច-ធំ មានពណ៌ល្អផ្សេងៗ ជាទីតម្រេកយ៉ាងវិសេស មានទាំងដើមបារិច្ឆត្តកព្រឹក្សមានសណ្ឋានដូចឆត្ររួត ដុះឡើងក្នុងកណ្ដាលទេវនគរ សំណុំដើមមូលជុំវិញ ១៥ យោជន៍ ប្រវែងពីគល់ទៅដល់ប្រគាបមែកខាងលើ ៥០ យោជន៍ បែកមែកចេញទៅជាប្រាំលូតទៅកាន់ទិសទាំងប្រាំ គឺទិសខាងលើ ទិសខាងកើត ខាងលិច

ខាងត្បូង និងខាងជើង ហាសិបយោជន៍ៗ ដូចគ្នា កម្ពស់ពីគល់ទៅដល់ចុងខាងលើ ១០០ យោជន៍ បែកមែកចេញទៅកាន់ទិសទាំងបួន ម្ខាងៗហាសិបយោជន៍ ត្រូវជា ១០០ យោជន៍ បើវាប់បរិមណ្ឌលសាខាមូលដោយជុំវិញប្រមាណ ៣០០ យោជន៍គត់, រំយោលផ្កាសំយុងចុះមកដ៏រុងរឿងបញ្ចេញពន្លឺរស្មីផ្សាយទៅកាន់ទិសទាំងបួន ៥០០ យោជន៍ ដោយជុំវិញ ផ្កាមានក្លិនក្រអូបផ្សាយទៅបណ្តោយខ្យល់ ១០០ យោជន៍, ឯខាងក្រោមដើមមានសិលាសនៈ ផែនថ្មដ៏ទន់ដូចសំពត់កម្ពល មានពណ៌ក្រហមលឿងដូចផ្កាជយព្រឹក្ស បណ្តោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍, មានការទ្រុឌចុះនិងប៉ោងឡើងជាប្រក្រតីក្នុងពេលដែលអង្គុយចុះនិងក្រោកឡើងជាធម្មតា សមគួរដល់ពុទ្ធាសនៈល្មមដល់ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គគង់ចាំវស្សា សម្តែងបរមត្ថព្រះអភិធម្មដោយសុខក្សេមក្សាន្ត ព្រមទាំងមានទីកន្លែងដទៃដ៏ធំទូលាយល្មមទេវតាទាំងមួយម៉ឺនលោកធាតុ ចូលមកអង្គុយប្រជុំស្តាប់ធម្មទេសនា បរមត្ថព្រះអភិធម្មដោយស្រួល ទើបបានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងទាំងឡាយ ព្រះអង្គទ្រង់យាងទៅគង់ចាំវស្សាលើថ្មបណ្ឌុ-

កម្ពលសិលាសនៈនោះឯង ។

ហេតុទី ៤ ព្រះអង្គទ្រង់ពិចារណាជ្រាបច្បាស់ថា បើតថាគតទៅគង់ចាំវស្សាឯឋានតុសិត នឹងកាត់សេចក្តីសង្ស័យនៃទេវតាទាំងមួយម៉ឺនលោកធាតុពុំបាន ព្រះពុទ្ធមាតាតថាគតស្តាប់ព្រះអភិធម្មកថាទៀតក៏មានផលានិសង្សតិចពុំពេញបរិបូរឡើយ បើតថាគតទៅគង់លើផែនថ្មបណ្តុកម្ពលសិលាសនៈក្នុងឋានតាវត្តិង្សពិភព ទេវតាទាំងមួយម៉ឺនលោកធាតុ នឹងចូលមកប្រជុំស្តាប់ព្រះធម្មទេសនាក្នុងទីនោះ នឹងកើតមានសេចក្តីសង្ស័យក្នុងចិត្តផ្សេងៗគ្នា ទេវតាពួកខ្លះចូលចិត្តថាព្រះតថាគតដែលព្រះអង្គទ្រង់យាងមកនេះ ដើម្បីនឹងសម្តែងព្រះធម៌ទេសនាប្រារព្ធចំពោះយើងទាំងឡាយដោយពិត, ទេវតាពួកខ្លះទៀតចូលចិត្តថាព្រះតថាគតដែលព្រះអង្គទ្រង់យាងមកនេះ ព្រះអង្គពុំបានប្រារព្ធចំពោះយើងទាំងឡាយទេ, មុខជាព្រះអង្គទ្រង់ប្រារព្ធចំពោះបុគ្គលណាមួយដទៃដោយពិត, ទេវតាទាំងឡាយគិតខុសៗគ្នាដូច្នេះហើយ ក៏កើតសេចក្តីសង្ស័យគ្រប់ៗគ្នាពុំដាច់ស្រេច, កាលបើទេវតាទាំងមួយម៉ឺនលោកធាតុមានសេចក្តីសង្ស័យដូច្នេះហើយ, តថាគតក៏នឹងប្រារព្ធសួររកព្រះពុទ្ធមាតារបស់តថាគតចំពោះសម្តេចសក្កទេវរាជថា បពិត្រមហារាជ ព្រះមាតា

តថាគតគង់នៅឋានណា? សម្តេចព្រះសក្កទេវរាជនឹងក្រាបទូលតថាគតថា ព្រះពុទ្ធមាតារបស់ព្រះអង្គគង់នៅឋានតុសិត តថាគតនឹងបង្គាប់សម្តេចសក្កទេវរាជថា បើដូច្នោះ ចូរមហារាជទៅអញ្ជើញព្រះពុទ្ធមាតាតថាគតចុះមកក្នុងឋាននេះ, សម្តេចអម្រិន្ទ្រាធិរាជនឹងទៅអញ្ជើញពុទ្ធមាតារបស់តថាគតឲ្យយាងចុះមកកាន់ឋានតាវត្តិង្សពិភពនេះដោយពិត, កាលបើទេវតាទាំងមួយម៉ឺនលោកធាតុ បានស្តាប់ពាក្យតថាគតពោលដូច្នោះហើយ ក៏អាចនឹងកាត់សេចក្តីសង្ស័យរបស់ខ្លួនៗ ដាច់ស្រេចមួយរំពេចឥតមានសង្ស័យឡើយ ចូលចិត្តជាក់ច្បាស់ថា ឱហ្ន៎! ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ប្រារព្ធចំពោះព្រះមាតារបស់ព្រះអង្គទេតើ! ឯព្រះពុទ្ធមាតារបស់តថាគតដែលមានប្រាថ្នានឹងស្តាប់ព្រះអភិធម្មទេសនា ហើយយាងចុះមកដោយផ្លូវឆ្ងាយមានសេចក្តីនឿយព្រួយលំបាកនោះសោត នឹងបានសោយនូវផលានិសង្សដ៏ច្រើនក្រៃលែង រាប់តាមជំហាន ក្នុងមួយជំហានបានបុណ្យមួយអនន្តៗ រាល់ៗ ជំហានដោយពិត ។ ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងទាំងឡាយ ព្រះអង្គពិចារណាជ្រាបហេតុ ៤ ប្រការនេះហើយ បានជាព្រះអង្គទ្រង់យាងទៅគង់ចាំវស្សាក្នុងឋានតាវត្តិង្សពិភពនោះឯង ។

៨- ធម្មវាទី ពោលថា សាធុៗ អើ!អត្ថវាទី ប្រពៃណាស់ហើយ

លោកជាធម្មកថិកឆ្លៀវឆ្លាសវាងវៃពិតមែន បេះវិសជ្ជនាជីកគាស់សេចក្តីដ៏កំបាំងជ្រាលជ្រៅឲ្យអណ្តែតសេចក្តីរាក់ឡើងស្តាប់បានដោយងាយ តែត្រង់ហេតុទី ៤ សេចក្តីនៅទីបំផុតខាងចុង លោកវិសជ្ជនាថា ព្រះពុទ្ធមាតាដែលទ្រង់យាងចុះមកដោយផ្លូវឆ្ងាយ នឿយព្រួយលំបាកនោះនឹងបានសោយនូវផលានិសង្សដ៏ច្រើនក្រៃលែង រាប់តាមជំហានក្នុងមួយជំហានបានបុណ្យមួយអនន្តៗ រាល់ៗជំហាននោះ យើងមិនទាន់ចូលចិត្តស្តាប់បាននៅឡើយ ព្រោះព្រះសិរិមហាមាយាទេវបុត្រជាទេវតាមានមហិទ្ធានុភាពច្រើន អាចហោះហើរទៅតាមអាកាសបាន នឹងរាប់តាមជំហានដូចម្តេចកើត? បើជាជាតិមនុស្សទៅវ៉ាអាចឈានជើងដើរទៅតាមផែនដីល្មមរាប់អានិសង្សតាមវារៈនៃជំហានដែលឈានដើរទៅ ថាបានបុណ្យមួយអនន្តទៅបាន ចុះបើព្រះសិរិមហាមាយាទេវបុត្រហោះទៅតាមអាកាសទេ នឹងរាប់អានិសង្សថាបានបុណ្យមួយអនន្ត ពីរអនន្តដោយជំហានដូចម្តេចបាន?

អត្ថវាទី វិសជ្ជនាតបថា ឱ! ធម្មវាទីរាប់បានដូចគ្នាទេ ទោះបីមនុស្សសត្វដើរទៅតាមផែនដីក៏គង់រាប់ជំហានបានដែរ មនុស្សដែលហែលទឹកក៏គង់រាប់ជំហានបានដែរ, សត្វហើរទៅលើអាកាសក៏គង់រាប់ជំហានបានដែរ, ទេវតាទាំងឡាយដែលមានឫទ្ធិទិព្វហោះទៅតាមអាកាស ក៏គង់រាប់ជំហាន

បានដូចគ្នាដែរ, ឯមនុស្សដើររាប់តាមវារៈជំហានដែលឈានដើរ គឺឈានទៅមួយវារៈហៅថាមួយជំហាន ពីរវារៈហៅថាពីរជំហាន មនុស្សហែលទឹករាប់តាមវារៈជើងដែលទធាក់ហែលឲ្យលឿនទៅខាងមុខ គឺជើងទធាក់មួយវារៈ ហៅថាមួយជំហាន ពីរវារៈ ហៅថាពីរជំហាន, សត្វហើរទៅលើអាកាសរាប់តាមវារៈទទះស្លាប គឺទទះស្លាបហើរមួយវារៈ ហៅថាមួយជំហាន, ពីរវារៈ ហៅថាពីរជំហាន, ពួកទេវតាទាំងឡាយដែលហោះទៅតាមអាកាស ក៏រាប់តាមវារៈជើងដែលផ្លាស់ប្តូរ គឺវារៈកន្ត្រាញជើងធ្វើក្បាលជង្គង់ខាងស្តាំឲ្យងឡើង សណ្តូកជើងឆ្វេងត្រង់ទៅ ហៅថាមួយជំហាន វារៈកន្ត្រាញជើងធ្វើក្បាលជង្គង់ខាងឆ្វេងឲ្យងឡើង សណ្តូកជើងខាងស្តាំត្រង់ទៅ ហៅថាមួយជំហាន, ឯព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតាដែលរាប់ថាបានបុណ្យច្រើនក្រៃលែង មួយជំហានបានបុណ្យមួយអនន្តៗ ដូច្នេះគឺរាប់តាមវារៈ នៃជើងដែលផ្លាស់ប្តូរហោះដូច្នោះឯង ។

៩- ធម្មវាទី បានស្តាប់ហើយពោលថា អើ!អត្ថវាទី លោកវិសជ្ជនាមកប៉ុណ្ណោះនេះ យើងស្តាប់បានចូលចិត្តហើយរឿងនេះ, តែយើងមានសង្ស័យតទៅទៀត, ចុះព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតា, បើបានស្តាប់ព្រះអភិធម្មបានផលានិសង្សដ៏ច្រើនក្រៃលែង រាប់តាមវារៈជំហាន

ដែលផ្លាស់ប្តូរជើងហោះ មួយវារៈ ហៅថាមួយជំហាន បានបុណ្យមួយអនន្ត, ពីរវារៈ ហៅថាពីរជំហាន បានបុណ្យពីរអនន្ត, ហើយហោះចុះតាំងពីឋានតុសិតរំលងឋានយាមាមួយទៀត ទើបបានមកដល់ឋានតាវត្តិង្សពិភព ឃើញថាឆ្ងាយពន់ពេកណាស់ បើរាប់តាមវារៈជំហានច្រើនជាងសែនកោដិជំហាន បានបុណ្យច្រើនជាងសែនកោដិអនន្ត ជាអនេករាប់ពុំអស់យ៉ាងនេះហើយ កាលណាឡើយនឹងរួចផុតចាកសង្សារទុក្ខបានមុខជានឹងសោយជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ និងមរណទុក្ខជាដើម និងស្លាប់កើតៗ សោយសុខវេទនាប្រឡំដោយទុក្ខវេទនា ដេកត្រាំនៅក្នុងសង្សារភព ឥតមានទីបំផុតជាតិទុក្ខជាដើមឡើយ ឯជាតិកំណើតក៏កាន់តែច្រើនឡើងៗ ដោយបុណ្យជាអនន្តំៗ បានកម្លាំងនាំឲ្យមានជាតិកំណើតកាន់តែឆ្ងាយវែងទៅៗ រកទីបំផុតជាតិគ្មាន អាក់ខានបានសម្រេចព្រះនិព្វានទៅ ឬដូចម្តេច?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី មិនមែនដូច្នោះទេ ព្រោះព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ដែលទ្រង់សម្តែងសរសើរផលានិសង្សបុណ្យស្តាប់ព្រះធម៌ទេសនាថាជាបុណ្យដ៏ឧត្តមខ្ពង់ខ្ពស់នោះ ទោះបីបុគ្គលណាមួយមានប្រាថ្នានឹងស្តាប់ព្រះធម៌ទេសនា ហើយឈានជើងដើរទៅ

កាន់ទីព្រះវិហារ ដែលជាទីប្រជុំគ្នាស្ដាប់ព្រះធម៌ទេសនា បុគ្គលទាំងនោះនឹងបានបុណ្យច្រើន រាប់តាមវារៈនៃជំហាន ដែលឈានដើរទៅ មួយជំហាន បានបុណ្យមួយអនន្តៗនោះ នឹងបែរជាបានគុណឡើងថាបុណ្យនោះនាំឲ្យមានជាតិកំណើតវិលស្លាប់វិលកើត សោយសុខវេទនាប្រឡំទៅដោយកងទុក្ខទាំងពួង មានជាតិទុក្ខជាដើម ដេកត្រាំនៅក្នុងសង្សារ-ភព ឲ្យមានជាតិកំណើតកាន់តែច្រើនឡើងៗ វែងទៅៗ រកទីបំផុតជាតិគ្មានដូច្នោះក៏ទេ, ឯព្រះសម្មាសម្ពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ ដែលទ្រង់សម្ដែងធម៌ទេសនាសរសើរថា បុគ្គលមានប្រាថ្នាចង់ស្ដាប់ធម៌ទេសនាសូម្បីតែឈានជើងដើរទៅមួយជំហាន បានបុណ្យមួយអនន្ត, ពីរជំហានបានបុណ្យពីរអនន្ត, មិនមែនឲ្យគុណឡើងចម្រើនជាតិឲ្យកាន់តែមានច្រើនឡើងវែងទៅៗ រកទីបំផុតជាតិគ្មានដូច្នោះទេ គឺព្រះអង្គឲ្យគុណថយជាតិឲ្យខ្លីចុះមកតិចទេតើ! សេចក្ដីអធិប្បាយថា បើបុគ្គលបានឈានជើងដើរទៅប្រុងនឹងស្ដាប់ធម៌ទេសនា ឈានជើងទៅមួយជំហានបានបុណ្យមួយអនន្តនោះគឺ ថយជាតិកំណើតខ្លីតិចចុះមក មួយអនន្តជាតិដែរ ឈានជើងទៅពីរជំហាន បានបុណ្យពីរអនន្ត ជាតិកំណើតក៏កាន់តែខ្លីថយចុះតិចមកពីរអនន្តជាតិដែរ ដូនកាលបានសម្រេចមគ្គផលក្នុងបច្ចុប្បន្នជាតិនេះទៅ

ក៏គង់មានខ្លះ បើទុកជាពុំបានសម្រេចមគ្គផលក្នុងបច្ចុប្បន្នជាតិនេះ ក៏គង់បានជាវាសនាធម៌យ៉ាងឧត្តមតទៅខាងមុខទៀត បើបានជួបប្រទះនឹងពុទ្ធុប្បាទ កាលដែលព្រះសម្មាសម្ពុទ្ធបានត្រាស់ច្បាស់ឡើងក្នុងលោកជាខាងក្រោយនឹងបានស្តាប់ព្រះធម៌ទេសនា ក្នុងទីចំពោះព្រះភ័ក្ត្រព្រះសម្មាសម្ពុទ្ធអង្គនោះ ហើយអាចបានត្រាស់ដឹងនូវមគ្គផលមួយរំពេចពុំបានយឺតយូរឡើយ ។

ឯព្រះសិរិមហាមាយាទេវបុត្រ ជាពុទ្ធមាតាដែលយាងចុះមកស្តាប់ព្រះអភិធម្មនោះ សម្តែងថាបានបុណ្យច្រើនអនន្តនោះគឺគុណាថយជាតិឲ្យខ្ពិតិចចុះមក ដូចសេចក្តីអធិប្បាយមកខាងលើនេះដែរ ។

១០- ធម្មវាទី បានស្តាប់វិសជ្ជនានេះហើយយល់ព្រមទើបសួរតទៅទៀតថា ព្រះសម្មាសម្ពុទ្ធ កាលដែលព្រះអង្គគង់លើផែនថ្មបណ្ឌុកម្ពលសិលាសនៈក្រោមដើមបារិច្ឆត្តកព្រឹក្ស សម្តែងបរមត្ថព្រះអភិធម្មប្រារព្ធចំពោះសម្តេចព្រះសិរិមហាមាយាទេវបុត្រជាពុទ្ធមាតា ក្នុងកណ្តាលជំនុំនៃទេវតាទាំងមួយម៉ឺនលោកធាតុនោះអស់រយៈកាលចំនួនប៉ុន្មានខែ ប៉ុន្មានថ្ងៃ ទើបចប់? ដែលព្រះអង្គទ្រង់សម្តែងព្រះអភិធម្មនោះទៀត មានពេលព្រះអង្គឈប់សម្រាកខ្លះដែរឬដូចម្តេច?

អត្ថវាទី វិសជ្ជនាតបថា កាលដែលអង្គព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងបរមត្ថព្រះអភិធម្មនោះ កំណត់បីខែ បើគិតជាថ្ងៃវិញបាន ៩០ [១] ថ្ងៃគត់, ដែលព្រះអង្គទ្រង់សម្តែងនោះសោត ក៏គ្មានកាលវេលាឈប់សម្រាកទេ គឺព្រះអង្គទ្រង់សម្តែងតអនុសន្ធិអភិធម្មកថា ហូរហែតាមរបៀបបរមត្ថព្រះអភិធម្មជាប់គ្នាមិនដាច់ ជានិរន្តរកាល ដរាបដល់ចប់ដោយពិត ។

១១- ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា អើ! អត្ថវាទី បើដូច្នោះ ក្នុងរវាងវស្សន្តរដូវបីខែ ៩០ ថ្ងៃនោះ ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គពុំបានយកអរុណ សោយឈើស្ទន់ លុបព្រះភ័ក្ត្រ ពុំបានយាងទៅបិណ្ឌបាត ធ្វើកត្តកិច្ច ពុំបានផ្ទុំសម្រាកព្រះអង្គ កិច្ចទាំងនេះគ្មានសោះទេឬដូចម្តេច?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី មិនមែនដូច្នោះទេ ឯព្រះសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់សម្តែងព្រះអភិធម្មនោះ ក៏ព្រះអង្គទ្រង់សម្តែងជានិរន្តរកាល អស់កាលជាប់មិនដាច់ ពេលអរុណរះក៏ព្រះអង្គចុះមកកាន់ជម្ពូទ្វីប យកអរុណ សោយឈើស្ទន់ លុបព្រះភ័ក្ត្រ ពេលបិណ្ឌបាត ក៏ព្រះអង្គយាងទៅបិណ្ឌបាត ពេលសោយចង្ហាន់ ក៏ព្រះអង្គ

---

១- ក្នុងបាលីថា ៩០ ថ្ងៃ ប៉ុន្តែបើតាមទំនៀមរនោចខែស្រាពណ៍ជាបក្ខខាតឃើញបានតែ ៨៩ ថ្ងៃទេ។

សោយចង្ហាន់ ពេលផ្ទុំ ក៏ព្រះអង្គទ្រង់ផ្ទុំដោយពិត ។

១២- ធម្មវាទី ស្តាប់ហើយសួរបញ្ជាក់តទៅទៀតថា អើ!អត្ថវាទី ប្រស្នាដែលលោកដោះស្រាយមកនេះ យើងស្តាប់មិនទាន់បាននៅឡើយទេ ព្រោះសេចក្តីខាងដើមនិងខាងចុងឃ្លាងចេញពីគ្នា ឯខាងដើមលោកវិសជ្ជនាថា ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះអភិធម្មជានិរន្តរកាល អស់កាលគ្មានចន្លោះរហូតដល់ចប់, ដល់ខាងចុងលោកវិសជ្ជនាថា ព្រះសម្មាសម្ពុទ្ធដល់ពេលអរុណរះ ព្រះអង្គទ្រង់យាងចុះមកកាន់ជម្ពូទ្វីប យកអរុណ សោយឈើស្ទន់ លុបព្រះភ័ក្ត្រ យាងទៅបិណ្ឌបាត សោយចង្ហាន់ ហើយផ្ទុំសម្រាកព្រះអង្គផង ឃើញថាចាក់ស្រេះ ព័ន្ធសេចក្តីគ្នាស្តាប់ពុំបាន ប្រសិនបើព្រះសម្មាសម្ពុទ្ធតែមួយព្រះអង្គ ទ្រង់សម្តែងព្រះអភិធម្មឥតមានសម្រាកសោះ ហើយមានព្រះពុទ្ធអង្គឯណាទៀត ចុះមកយកអរុណ សោយឈើស្ទន់ លុបព្រះភ័ក្ត្រ បិណ្ឌបាត សោយចង្ហាន់ ហើយផ្ទុំសម្រាកព្រះអង្គផង ឬមានព្រះពុទ្ធច្រើនព្រះអង្គដាក់វេនផ្លាស់ប្តូរគ្នាទៅ ឬដូចម្តេច?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះសម្មាសម្ពុទ្ធមិនមានច្រើនព្រះអង្គទេ គឺមានតែមួយព្រះអង្គពិត តែថាព្រះអង្គជាបុគ្គលឯក

ប្លែកអស្ចារ្យណាស់ ប្រសើរជាងសត្តនិករទាំងឡាយមានមនុស្សនិងទេវតាជាដើម នឹងរកបុគ្គលឯណាមួយដទៃមកប្រៀបផ្ទឹមនឹងព្រះអង្គពុំបានឡើយ ព្រះអង្គជាព្រះពុទ្ធតែមួយព្រះអង្គទេ តែបើព្រះអង្គប្រាថ្នាចង់ធ្វើឲ្យទៅជាព្រះពុទ្ធច្រើនព្រះអង្គក៏បាន ព្រោះព្រះអង្គប្រកបដោយឫទ្ធិទាំង ១០ មានមនោមយិទ្ធិជាដើម សម្រេចតាមព្រះហឫទ័យព្រះអង្គ បើព្រះអង្គមានប្រាថ្នាយ៉ាងណា ក៏អាចធ្វើបានតាមប្រាថ្នាយ៉ាងនោះ ពុំបានទើសទាល់ឡើយ កាលដែលព្រះអង្គទ្រង់សម្តែងព្រះអភិធម្មប្រារព្ធចំពោះព្រះពុទ្ធមាតា គង់ក្នុងកណ្តាលជុំនុំនៃទេវតាទាំងមួយម៉ឺនលោកធាតុនោះ ព្រះអង្គទ្រង់ពិចារណារមិលមើលពេល កាលបើបានជ្រាបច្បាស់ថា ពេលនេះអរុណជិតរះហើយ ហើយព្រះអង្គនិម្មិតជាពុទ្ធនិម្មិតឲ្យសម្តែងព្រះអភិធម្មជំនួសព្រះអង្គតទៅ ឯព្រះសម្មាសម្ពុទ្ធក៏ទ្រង់យាងចុះមកកាន់ជម្ពូទ្វីប យកអរុណ សោយឈើស្ទន់ លុបព្រះភ័ក្ត្រ ត្រាច់ទៅបិណ្ឌបាតធ្វើកត្តកិច្ច, ស្រេចហើយយាងឡើងទៅកាន់ឋានតាវត្តិង្សពិភពវិញ ទ្រង់សម្តែងព្រះអភិធម្ម តអំពីពុទ្ធនិម្មិតសម្តែងនោះទៅទៀត ព្រះអង្គទ្រង់ធ្វើយ៉ាងនេះតែរាល់ៗថ្ងៃ គ្រប់ ៩០ ថ្ងៃគត់ ទេវតាទាំងឡាយក៏ពុំបានដឹងទេ, លុះដល់ពេលគួរព្រះអង្គផ្ចុំហើយ ទ្រង់និម្មិតជាពុទ្ធនិម្មិត ឲ្យ

សម្ដែងព្រះអភិធម្មជំនួសព្រះអង្គ ហើយព្រះអង្គទ្រង់ផ្ទំទៅ ដល់ពេលព្រះអង្គតើនឡើង ទើបទ្រង់សម្ដែងព្រះអភិធម្មតពីពុទ្ធនិម្មិតសម្ដែងនោះទៅទៀត ព្រះអង្គទ្រង់ធ្វើយ៉ាងនេះតែរាល់ៗថ្ងៃ ជាធម្មតាពុំដែលដាច់ឡើយ មិនតែប៉ុណ្ណោះ កំពុទ្ធកិច្ចទាំង ៥ ក្នុងរវាងត្រៃមាស ៩០ ថ្ងៃនេះព្រះអង្គពុំលះបង់ឡើយ ទ្រង់បំពេញបានគ្រប់សព្វទាំងអស់ដោយពិត ។

១៣- ធម្មវាទី បានស្ដាប់ហើយ ពោលថាសាធុៗ ប្រពៃណាស់ហើយ ប្រស្នាដែលលោកដោះស្រាយមកនេះ យើងស្ដាប់បានចូលចិត្តហើយ តែនៅមានសេចក្ដីសង្ស័យតទៅទៀត ចុះព្រះទសពលញ្ញាណជាម្ចាស់ តើព្រះអង្គទ្រង់យាងចុះមកកាន់ជម្ពូទ្វីប យកអរុណ សោយឈើស្ទន់លុបព្រះភ័ក្ត្រ ក្នុងទឹកនៃ្ទងប្រទេសណា? ត្រាច់ទៅបិណ្ឌបាតក្នុងស្រុកភូមិប្រទេសណា? ត្រឡប់មកគង់ធ្វើភត្តកិច្ច សោយចង្ហាន់ក្នុងទឹកនៃ្ទងប្រទេសណា?

អត្ថវាទី វិសជ្ជនាតបថា ព្រះសយម្ភូញាណជាម្ចាស់ ដែលព្រះអង្គទ្រង់យាងចុះមកកាន់ជម្ពូទ្វីបនោះ ទ្រង់គង់ទៀបមាត់ស្រះអនោតត្តក្នុងប្រទេសហិមពាន្ត ទ្រង់យកអរុណរះច្បាស់ពេញរស្មីហើយ ទ្រង់សោយឈើស្ទន់ទិព្វដែលទេវតាថ្វាយព្រះអង្គ និងលុបលាងព្រះភ័ក្ត្រ

ដោយទឹកស្រះអនោតត្តដ៏ត្រជាក់រងថ្លាល្អវិសេស ស្រេចហើយព្រះអង្គ ត្រាច់ទៅបិណ្ឌបាតឯឧត្តរកុរុទ្វីប ដោយពុទ្ធានុភាពតែមួយរំពេចបានដល់ ទៅឧត្តរកុរុទ្វីប ហើយទ្រង់យាងទៅបិណ្ឌបាត តាមលំដាប់ប្រកអ្នកស្រុក ឧត្តរកុរុទ្វីបនោះ បានចង្ហាន់ល្មមមួយចម្អែតហើយ ក៏ព្រះអង្គយាងត្រឡប់ មកកាន់ប្រទេសហិមពាន្តវិញ គង់លើបុប្ផាសនៈក្រោមដើមឧលោក-ព្រឹក្ស មានសណ្ឋានដូចមណ្ឌបដ៏ធំទូលាយសាខាល្អ ក្នុងទីជិតស្រះ អនោតត្តនោះ ហើយទ្រង់ធ្វើកត្តកិច្ច សោយចង្ហាន់ សម្រេចកិច្ច ហើយ ទើបទ្រង់យាងទៅកាន់ឋានតាវត្តិង្សពិភពវិញ, ដែលព្រះសម្មាសម្ពុទ្ធទ្រង់ ធ្វើយ៉ាងនេះ គឺទ្រង់ធ្វើរាល់ៗ ថ្ងៃអស់ត្រៃមាសបីខែដោយពិត ។

១៤- ធម្មវាទី ទទួលថាសាធុអត្ថវាទី ប្រពៃហើយប្រស្នានេះ តែ នៅមានសេចក្តីទាក់ទងគ្នាគួរឲ្យមានសេចក្តីសង្ស័យតទៅទៀត អើអត្ថ-វាទី ក្នុងវិកាលភោជនសិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតឲ្យភិក្ខុ ទទួលចង្ហាន់ឆាន់បាន តាំងពីពេលអរុណរះភ្លឺច្បាស់ដរាបដល់ថ្ងៃជិតត្រង់ ទើបឆាន់បានរួចអាបត្តិ តែដល់ថ្ងៃរសៀលជ្រេពីត្រង់សូម្បីតែមួយចម្រៀក សក់ ហើយភិក្ខុទទួលចង្ហាន់ទាយកផ្ទាល់នឹងដៃខ្លួនឯង ត្រូវអាបត្តិទុក្កដ ឆាន់ត្រូវអាបត្តិបាចិត្តិយរាល់ៗ ម៉ាត់ ចុះព្រះសម្មាសម្ពុទ្ធព្រះអង្គយកអរុណ

រះក្នុងជម្ពូទ្វីប ថ្ងៃត្រង់ក្នុងបុព្វវិទេហទ្វីប យប់ឯឧត្តរកុរុទ្វីប ហើយព្រះអង្គយាងទៅបិណ្ឌបាតឯឧត្តរកុរុទ្វីប ទទួលបិណ្ឌបាតក្នុងវេលាយប់ដូច្នេះមិនទាស់ខុសនឹងវិកាលភោជនសិក្ខាបទនោះទេឬដូចម្តេច? មួយវិញទៀតព្រះអង្គយកអរុណក្នុងជម្ពូទ្វីបហើយ ដូចម្តេចក៏ព្រះអង្គមិនយាងទៅបិណ្ឌបាតក្នុងជម្ពូទ្វីបដែលអរុណរះត្រូវគ្នានោះ? ក៏ព្រះអង្គត្រឡប់ជាទៅបិណ្ឌបាតឯឧត្តរកុរុទ្វីបក្នុងវេលាយប់វិញ តើព្រះអង្គទ្រង់ឈ្វេងយល់ប្រយោជន៍ដូចម្តេចខ្លះ?

អត្ថវាទី វិសជ្ជនាថា បពិត្រធម្មវាទី ព្រះសម្មាសម្ពុទ្ធព្រះអង្គបានត្រាស់ដឹងអភិសម្ពោធិញ្ញាណក្នុងជម្ពូទ្វីបពិត វិកាលភោជនសិក្ខាបទក៏ព្រះអង្គបញ្ញត្តក្នុងជម្ពូទ្វីបដែរ ព្រះអង្គពុំបានបញ្ញត្តហាមក្នុងឧត្តរកុរុទ្វីបនោះទេ បើព្រះអង្គបានយកអរុណរះក្នុងជម្ពូទ្វីបហើយ ទើបទ្រង់យាងទៅបិណ្ឌបាតទទួលចង្ហាន់ឯឧត្តរកុរុទ្វីបនោះ បានឈ្មោះថាព្រះអង្គទទួលចង្ហាន់បិណ្ឌបាតក្នុងវេលាព្រឹកដោយពិត មិនបានទាស់ខុសអ្វីក្នុងវិកាល-ភោជនសិក្ខាបទនោះទេ មួយវិញទៀត ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គប្រកបដោយមេត្តាគុណ មានដួងព្រះហឫទ័យស្រឡាញ់រាប់អានស្វែងរកប្រយោជន៍រំលែកចែកឲ្យសត្វលោកទាំងអស់ស្មើៗ គ្នា ពុំរើសមុខ

ព្រះអង្គប្រកបដោយករុណាគុណ មានដួងព្រះហ្ឫទ័យទន់ត្រជាក់អាណិតអាសូរផ្សាយទៅកាន់សព្វសត្វដែលជាប់នៅក្នុងចំណង់ទាំង ៧ ប្រការ នឹងដេកនៅក្នុងគំនរភ្លើងទាំង ១១ ប្រការ ឆេះរោលរាលជាប់ជានិច្ច អាស្រ័យហេតុនេះហើយបានជាអង្គព្រះសព្វញ្ញូសម្ពុទ្ធជាម្ចាស់ ទ្រង់យាងទៅបិណ្ឌបាតប្រោសមនុស្សដែលនៅក្នុងឧត្តរកុរុទ្វីបនោះ ដើម្បីឲ្យបានបុណ្យច្រើនជាវាសនាធមិតទៅខាងមុខទៀត នឹងបានសោយសុខរួចផុតចាកសង្សារទុក្ខ ក៏កាលដែលព្រះអង្គទ្រង់យាងទៅបិណ្ឌបាតឯឧត្តរកុរុទ្វីបនោះ ព្រះអង្គទ្រង់បញ្ចេញឆព្វណ្ណរង្សីរស្មីទាំង ៦ ពណ៌ ផ្សាយទៅក្នុងឧត្តរ-កុរុទ្វីបទាំងមូលដ៏ភ្លឺស្វាងរុងរឿងត្រជាក់សប្បាយវិសេស ជាងពន្លឺព្រះអា-ទិត្យព្រះចន្ទ្រដោយពិត មនុស្សទាំងឡាយដែលបានជ្រះថ្លាយកចង្ហាន់មកដាក់បាត្រថ្វាយព្រះអង្គ ក៏បានសោយចំណែកបុណ្យតាមទេយ្យទានរបស់ខ្លួនៗនោះទៅ មនុស្សទាំងឡាយដែលនៅឆ្ងាយនឹងយកចង្ហាន់មកដាក់បាត្រព្រះអង្គមិនបានទេ ក៏គង់កើតសេចក្ដីជ្រះថ្លាឱនកាយវាចាចិត្តនមស្ការថ្វាយបង្គំចំពោះព្រះអង្គ និងបានសោយចំណែកបុណ្យតាមកិច្ចដែលនមស្ការនោះឯង ឯមនុស្សទាំងឡាយនោះនឹងបានបុណ្យច្រើនជាអសង្ខេយ្យ កើតជាវាសនាធមិតទៅខាងមុខទៀត នឹងបាន

សោយសុខដរាបដល់ព្រះនិព្វាន ពុំបានឃ្លៀងឃ្លាតឡើយ ឯព្រះសម្មា-សម្ពុទ្ធជាម្ចាស់នៃយើងទាំងឡាយ បានជាព្រះអង្គទ្រង់យាងទៅបិណ្ឌបាត ឯឧត្តរកុរុទ្វីបនោះ ព្រោះព្រះអង្គទ្រង់ឈ្វេងយល់ប្រយោជន៍ ដូចបាន អធិប្បាយមកខាងលើនេះ ដែលព្រះអង្គទ្រង់យាងទៅបិណ្ឌបាតឯឧត្តរ-កុរុទ្វីបនោះទៀត ក៏ព្រះអង្គយាងទៅរាល់ៗថ្ងៃអស់ត្រៃមាសបីខែពុំដែល ដាច់ឡើយ ។

១៥- ធម្មវាទី ទទួលថាសាធុអត្ថវាទី ប្រស្នានេះប្រពៃណាស់ ហើយ យើងនឹងសួរប្រស្នាដទៃតទៅទៀត ចុះព្រះសម្មាសម្ពុទ្ធទ្រង់ សម្តែងបរមត្ថព្រះអភិធម្មនោះ ចែកជាបករណៈគឺគម្ពីរមានប៉ុន្មានគម្ពីរ? គឺគម្ពីរឈ្មោះអ្វីខ្លះ? ក្នុងគម្ពីរនីមួយៗ មានធម្មក្ខន្ធប៉ុន្មាន? មានភាណវារៈ ប៉ុន្មាន? មានគណ្ឋៈប៉ុន្មាន? មានអក្ខរៈប៉ុន្មាន? អស់រយៈកាលប៉ុន្មាន? ទេវតាបានសម្រេចមគ្គផលប៉ុន្មានកោដិ? បូករួមគម្ពីរទាំងអស់ត្រូវជាធម្មក្ខន្ធ ប៉ុន្មាន? ភាណវារៈប៉ុន្មាន? គណ្ឋៈប៉ុន្មាន? អក្ខរៈប៉ុន្មាន? អស់រយៈកាល ប៉ុន្មាន? ទេវតាបានសម្រេចមគ្គផលប៉ុន្មានកោដិ?

អត្ថវាទី វិសជ្ជនាថា បពិត្រធម្មវាទី កាលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែង បរមត្ថព្រះអភិធម្មនោះ ចែកជាគម្ពីរមាន ៧ គឺ ធម្មសង្គណី ១ វិភង្គ ១

ធាតុកថា ១ បុគ្គលប្បញ្ញត្តិ ១ កថាវត្ថុ ១ យមកៈ ១ មហាបដ្ឋាន ១ ។

គម្ពីរធម្មសង្គណីព្រះអង្គទ្រង់សម្ដែង ១៣០០ធម្មក្ខន្ធ, ២២ ភាណវារៈ ៥៥០០ គណ្ឋៈ, ១ សែន ៧ ម៉ឺន ៦ ពាន់អក្ខរៈ, ទ្រង់សម្ដែង ១២ ថ្ងៃទើបចប់, ទេវតាបានសម្រេច ៧ កោដិ ។

គម្ពីរវិភង្គ ព្រះអង្គទ្រង់សម្ដែង ៦៥០០ ធម្មក្ខន្ធ, ៣៤ ភាណវារៈ, ៨៥០០ គណ្ឋៈ, ២ សែន ៧ ម៉ឺន ២ ពាន់អក្ខរៈ, ទ្រង់សម្ដែង ១២ ថ្ងៃទើបចប់ ទេវតាបានសម្រេច ៧ កោដិ ។

គម្ពីរធាតុកថា ព្រះអង្គទ្រង់សម្ដែង ៧០០០ ធម្មក្ខន្ធ, ១១ ភាណវារៈ, ២៧៥០ គណ្ឋៈ, ៨ ម៉ឺន ៨ ពាន់អក្ខរៈ, ទ្រង់សម្ដែង ៦ ថ្ងៃទើបចប់, ទេវតាបានសម្រេច ៦ កោដិ ។

គម្ពីរបុគ្គលប្បញ្ញត្តិ ព្រះអង្គទ្រង់សម្ដែង ៥៦០០ ធម្មក្ខន្ធ, ១១ ភាណវារៈ, ២៧៥០ គណ្ឋៈ, ៨ ម៉ឺន ៨ ពាន់ អក្ខរៈ, ទ្រង់សម្ដែង ៧ ថ្ងៃទើបចប់, ទេវតាបានសម្រេច ៦ កោដិ ។

គម្ពីរកថាវត្ថុ ព្រះអង្គទ្រង់សម្ដែង ៧១០០ ធម្មក្ខន្ធ, ៣៤ ភាណវារៈ, ៨៥០០ គណ្ឋៈ, ២ សែន ៧ ម៉ឺន ២ ពាន់អក្ខរៈ, ទ្រង់សម្ដែង ១២ ថ្ងៃទើបចប់, ទេវតាបានសម្រេច ៧ កោដិ ។

គម្ពីរយមកៈ ព្រះអង្គទ្រង់សម្តែង ៥១០០ ធម្មក្ខន្ធ, ១២០ ភាណ-វារៈ, ៣០០០០ គណ្ឋៈ, ៩ សែន ៦ ម៉ឺនអក្ខរៈ, ទ្រង់សម្តែង ១៨ ថ្ងៃទើបចប់, ទេវតាបានសម្រេច ៧ កោដិ ។

គម្ពីរមហាបដ្ឋាន ព្រះអង្គទ្រង់សម្តែង ៩៤០០ ធម្មក្ខន្ធ, ១៨២ ភា-ណាវារៈ, ៤៥៥០០ គណ្ឋៈ, ១ លាន ៩ សែន ៥ ម៉ឺន ៦ ពាន់អក្ខរៈ, ទ្រង់សម្តែង ២៣ ថ្ងៃទើបចប់, ទេវតាបានសម្រេច ៤០ កោដិ ។ បូករួមទាំងអស់ ៤ ម៉ឺន ២ ពាន់ ធម្មក្ខន្ធ, ៤១៤ ភាណវារៈ, ១ សែន ៣ ពាន់ ៥០០ គណ្ឋៈ, ៣ លាន ៨ សែន ១ ម៉ឺន ២ ពាន់អក្ខរៈ, ៩០ ថ្ងៃទើបចប់ ទេវតាបានសម្រេច ៨០ កោដិគត់ ។

ឯព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់សម្តែងបរមត្ថព្រះអភិធម្មនោះ ហើយទ្រង់កំណត់ធម្មក្ខន្ធ ភាណវារៈ គណ្ឋៈ អក្ខរៈដូច្នេះ ដើម្បីរក្សាធម្មរសនិងអត្ថរសឲ្យឋិតថេរចីរកាលយូរអង្វែងតទៅតាមសភាពពិត ការពារមិនឲ្យមានលទ្ធិ ធម្មរស អត្ថរសដទៃ ដែលពុំពិតកើតដោយគំនិតរបស់ខ្លួនចូលមកបូមបន្ថំផងបានដោយពិត ។

១៦- ធម្មវាទី ទទួលថា សាធុៗអត្ថវាទី ប្រស្នានេះប្រពៃណាស់ហើយ តែយើងនៅមានសេចក្តីសង្ស័យតទៅទៀត ត្រង់សេចក្តីដែល

*អត្ថវាទីអធិប្បាយថា ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងបរមត្ថព្រះអភិធម្មនោះកំណត់ ៩០ ថ្ងៃទើបចប់ ទេវតាបានសម្រេចមគ្គផល ៨០ កោដិ ចុះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងព្រះអភិធម្មតបស្នងសងគុណប្រារព្ធចំពោះព្រះពុទ្ធមាតារបស់ព្រះអង្គទេ លុះចប់ព្រះអភិធម្មកថាហើយទេវតាបានសម្រេចមគ្គផលដល់ ៨០ កោដិ ត្រង់ព្រះពុទ្ធមាតាមិនឮសម្តែងប្រាប់ថាបានសម្រេចមគ្គផលអ្វីសោះ ឬបានសម្រេចដែរ តែរាប់បញ្ចូលក្នុងពួកទេវតាទាំង ៨០ កោដិនោះ ឬព្រះពុទ្ធមាតាមានព្រះហឫទ័យពុំបានយាងចុះកាន់ធម៌ទេសនា ដោយមានព្រះហឫទ័យផ្សាយទៅកាន់អារម្មណ៍ផ្សេងៗ អាក់ខានសម្រេចមគ្គផលទៅ ឬដូចម្តេចខ្លះ?*

អត្ថវាទី *វិសជ្ជនាថាបពិត្រធម្មវាទីសម្តេចព្រះសិរិមហាមាយាទេវបុត្រព្រះពុទ្ធមាតាបានសម្រេចមគ្គផលពិត តែពុំបានរាប់បញ្ចូលក្នុងពួកទេវតាទាំង ៨០ កោដិនោះទេ គឺបានសម្រេចជាខាងក្រោយបន្ទាប់ទេវតាទាំង ៨០ កោដិនោះឯង ព្រោះព្រះសិរិមហាមាយាទេវបុត្រជាព្រះពុទ្ធមាតា កាលចុះមកគង់ស្តាប់ព្រះអភិធម្មចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគនោះ បានទតឃើញព្រះពុទ្ធបុត្រព្រះអង្គប្រកបដោយមហាបុរិសលក្ខណៈ ៣២ និងអនុព្យញ្ជនៈ ៨០ ជាមហាបុរសយ៉ាងឯកល្អប្លែក ប្រសើរជាងមនុស្សទេវតា*

ទាំងអស់ ក៏កើតសេចក្ដីស្នេហាស្រឡាញ់ពេញព្រះហឫទ័យនឹងព្រះពុទ្ធបុត្រនោះពន់ពេកណាស់ មានសេចក្ដីសោមនស្សត្រេកអររីករាយសរសើរខ្លួនឯងថា អញបានកើតមកជាស្ត្រីប្រសើរវិសេសជាងស្ត្រីទាំងអស់ក្នុងលោក អញមានផ្ទៃបានទ្រទ្រង់នូវបុត្រដ៏បរិសុទ្ធបានប្រសូតមកហើយ ក៏បានត្រាស់ដឹងជាអង្គព្រះអរហំសម្មាសម្ពុទ្ធប្រាកដក្នុងលោក ដោយសេចក្ដីស្នេហ៍នេះហើយ បានជាព្រះពុទ្ធមាតាពុំបានសម្រេចមគ្គផលជាមួយនឹងទេវតាទាំង ៨០ កោដិ លុះវេលាដែលចប់ព្រះអភិធម្មនោះ ទើបអង្គសម្ដេចព្រះមុនិន្ទ្រជិនស្រីជាម្ចាស់ ទ្រង់បានជ្រាបហេតុនេះហើយ ក៏ទ្រង់សាសម្ដែងក្នុងគម្ពីរវិភង្គ ចំណែកចែកនូវព្រះចតុរារិយសច្ចទាំងបួនដោយសេចក្ដីពិស្ដារមួយពេលទៀត ដល់ចប់ព្រះចតុរារិយសច្ចទាំង ៤ ស្រេចហើយ ទើបសម្ដេចព្រះពុទ្ធមាតាបានសម្រេចសោតាបត្តិផល ដ៏វិសេសប្លែកពីទេវតាទាំងឡាយនោះ ព្រោះទេវតាពួកខ្លះបានសម្រេចជាសត្តក្ខត្តុំសោតាកំណត់ ៧ ជាតិទៀត ទើបបានសម្រេចដល់ព្រះនិព្វាន, ទេវតាពួកខ្លះបានសម្រេចជាកោលំកោលសោតា កំណត់ ៦ ជាតិទៀត ទើបបានសម្រេចដល់ព្រះនិព្វាន, ទេវតាពួកខ្លះបានសម្រេចជាឯកពីជិសោតាកំណត់ ១ ជាតិទៀតទើបបានសម្រេចដល់ព្រះនិព្វាន, ឯព្រះសិរិមហាមាយាទេវបុត្រ

ជាព្រះពុទ្ធមាតាបានសម្រេចសោតាប្ញកឈ្មោះថា លោកានាមិស្សសោតា ជាសោតាវិសេសពុំបានត្រឡប់មកកាន់កាមលោកនេះវិញទេ តែច្យុតអំពីឋានតុសិតទៅ នឹងឡើងទៅកើតក្នុងឋានខាងលើៗ ហើយបានសម្រេចព្រះអរហត្តផលចូលកាន់ព្រះនិព្វានទៅតែម្តង ឯព្រះសម្មាសម្ពុទ្ធព្រះអង្គមានព្រះហឫទ័យប្រកបដោយកតញ្ញូកតវេទិតាធម៌ ទ្រង់លើកយកបរមត្ថព្រះអភិធម្មទាំងបួនម៉ឺនពីរពាន់ព្រះធម្មក្ខន្ធ មកសម្តែងតបស្នងសងគុណសម្តេចព្រះអនន្តគុណជាព្រះពុទ្ធមាតា ដរាបដល់ព្រះពុទ្ធមាតាបានទទួលសោយអត្ថរសនៃបរមត្ថព្រះអភិធម្មស្ថិតនៅក្នុងសោតាបត្តិផល បានឈ្មោះថាព្រះអង្គបានសងគុណសម្តេចព្រះអនន្តគុណ ជាព្រះពុទ្ធមាតារបស់ព្រះអង្គរួចជាជ្រះស្រឡះដោយពិត ហើយព្រះអង្គទ្រង់យាងចុះមកកាន់ឋានមនុស្សលោកវិញ ក្នុងថ្ងៃមហាបវារណានោះឯង ។

១៧- ធម្មវាទី បានស្តាប់ប្រស្នានេះហើយក៏មានសេចក្តីពេញចិត្តក្រៃលែង ទើបសួរប្រស្នាជទៃតទៅទៀតថា ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងបរមត្ថព្រះអភិធម្ម ក្នុងវស្សាជាគម្រប់ ៧ នៅស្ថានសួគ៌តាវត្តិង្សពិភពក្នុងទីប្រជុំនៃទេវតាទាំងឡាយនោះ, តើមានមនុស្សទាំងឡាយក្នុងជម្ពូទ្វីប បានឡើងទៅប្រជុំស្តាប់នៅទីនោះដែរឬដូចម្តេច?

អដ្ឋវាទី វិសជ្ជនាថា កាលព្រះបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់សម្តែងបរមត្ថព្រះអភិធម្មក្នុងឋានតាវត្តិង្សពិភពនោះ នឹងមានមនុស្សទាំងឡាយក្នុងជម្ពូទ្វីបឡើងទៅប្រជុំស្តាប់ក្នុងឋានសួគ៌នោះផងក៏ទេ គឺមានតែពួកទេវតាទាំងមួយម៉ឺនលោកធាតុទៅប្រជុំស្តាប់ព្រះអភិធម្ម ក្នុងឋានតាវត្តិង្សពិភពនោះឯងដោយពិត ។

១៨- ធម្មវាទី សួរថា បើព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះអភិធម្មក្នុងឋានសួគ៌នោះ, មានតែពួកទេវតាចូលទៅប្រជុំស្តាប់ព្រះអភិធម្មក្នុងទីនោះ មិនមានមនុស្សណាមួយឡើងទៅប្រជុំស្តាប់ព្រះអភិធម្មផងទេ ដូចម្តេចក៏មនុស្សទាំងឡាយ បានចេះចាំព្រះអភិធម្ម នាំមកបង្ហាត់បង្ហាញគ្នាបានចេះចាំជាប់តៗ មកដល់សព្វថ្ងៃនេះ ឬមួយព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងព្រះអភិធម្មក្នុងឋានសួគ៌ចប់ស្រេច ហើយព្រះអង្គទ្រង់យាងចុះមកកាន់ឋានមនុស្សលោកសម្តែង ព្រះអភិធម្មក្នុងកាលជាខាងក្រោយទៀត ឬក៏ទ្រង់សម្តែងព្រះអភិធម្មក្នុងឋានមនុស្សលោករួចពីកាលមុនមកហើយឬ ដូចម្តេច?

អដ្ឋវាទី វិសជ្ជនាថា ព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សម្តែងព្រះអភិធម្មក្នុងឋានសួគ៌ចប់មុន ហើយទើបត្រឡប់ចុះមកសម្តែងព្រះអភិធម្ម

ឯឋានមនុស្សក្នុងកាលជាខាងក្រោយទៀតក៏ទេ ឬថាព្រះអង្គទ្រង់សម្ដែងព្រះអភិធម្មក្នុងឋានមនុស្សពីកាលមុនរួចមកហើយក៏ទេ ពិតជាព្រះសម្មា-សម្ពុទ្ធទ្រង់សម្ដែងព្រះអភិធម្ម ក្នុងវស្សានរដូវជាមួយគ្នាមិនមុនមិនក្រោយ គឺទ្រង់សម្ដែងព្រះអភិធម្មក្នុងឋានសួគ៌ផង ក្នុងឋានមនុស្សផង ក្នុងរដូវតែមួយ កាលតែមួយស្មើគ្នា ក្នុងសម័យដែលព្រះអង្គបានត្រាស់ដឹងព្រះអនុត្តរសម្មោធិញ្ញាណ ប្រាកដឡើងក្នុងលោកហើយ គឺក្នុងវស្សាជាគម្រប់ ៧ នោះឯង ឯមនុស្សដ៏ខ្ពង់ខ្ពស់ដែលបានស្ដាប់ព្រះអភិធម្មក្នុងទីចំពោះព្រះភ័ក្ត្រព្រះដ៏មានព្រះភាគចប់ហើយ នាំមកបង្ហាត់បង្ហាញសិស្សានុសិស្សបានរៀនចេះចាំស្ទាត់ហើយ បង្ហាត់បង្ហាញគ្នាតៗ មក ដល់កាលសព្វថ្ងៃនេះដោយពិត ។

១៩- ធម្មវាទី សួរថា អើ! អត្តវាទី បើព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងព្រះអភិធម្ម ក្នុងវស្សានរដូវជាមួយគ្នាមិនមុនមិនក្រោយ ឯឋានសួគ៌ផង ឋានមនុស្សផង ក្នុងសម័យដែលព្រះអង្គបានត្រាស់ដឹងព្រះអនុត្តរសម្មោធិញ្ញាណប្រាកដឡើងក្នុងលោកនាវស្សាជាគម្រប់ ៧ នោះ តើព្រះអង្គទ្រង់រំលែកចែកពេលសម្ដែងព្រះអភិធម្មនោះដូចម្ដេច? ប្រារព្ធចំពោះបុគ្គលណា? ទ្រង់ឃើញយល់ហេតុដូចម្ដេចខ្លះ?

អត្ថវាទី វិសជ្ជនាថា ក្នុងសម័យដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងបរមត្ថព្រះអភិធម្មប្រារព្ធចំពោះព្រះសិរិមហាមាយាទេវបុត្រ ជាព្រះពុទ្ធមាតានោះ ព្រះអង្គទ្រង់ពិចារណារមិលមើលពេល បើបានជ្រាបច្បាស់ថាអរុណជិតរះហើយ ក៏ព្រះអង្គទ្រង់និម្មិតជាពុទ្ធនិម្មិត ឲ្យសម្តែងព្រះអភិធម្មជំនួសព្រះអង្គ ហើយទ្រង់យាងចុះមកកាន់ជម្ពូទ្វីប យកអរុណ សោយឈើស្ទន់ លុបព្រះភ័ក្ត្រ ទៀបមាត់ស្រះអនោតត្ត រួចស្រេចហើយទើបព្រះអង្គទ្រង់យាងទៅបិណ្ឌបាតក្នុងឧត្តរកុរុទ្វីប លុះបានចង្ហាន់ល្មមហើយក៏ទ្រង់ត្រឡប់មកគង់លើបុប្ផាសនៈ នាប្រទេសហិមពាន្ត វេលានោះព្រះសារីបុត្តត្ថេរដ៏មានអាយុ បានចូលទៅធ្វើវត្តប្បដិបត្តិបម្រើព្រះអង្គដោយគោរពក្នុងវេលាសោយចង្ហាន់ ឯព្រះសម្មាសម្ពុទ្ធលុះទ្រង់ធ្វើភត្តកិច្ចសោយចង្ហាន់ស្រេចហើយ ក៏ព្រះអង្គទ្រង់សម្តែងបរមត្ថព្រះអភិធម្មប្រារព្ធចំពោះព្រះសារីបុត្តត្ថេរថា ម្នាលសារីបុត្រ វេលាថ្ងៃនិងយប់ម្សិលមិញ ព្រះតថាគតបានសម្តែងបរមត្ថព្រះអភិធម្មចំនួនប៉ុណ្ណោះ ពុទ្ធនិម្មិតសម្តែងជំនួសតថាគតចំនួនប៉ុណ្ណោះ ត្រូវអ្នករៀនយកចុះ បើអ្នកបានរៀនយកហើយដល់ត្រឡប់ទៅវិញ ចូរអ្នកបង្ហាត់បង្ហាញភិក្ខុទាំង ៥០០ រូប ដែលជាសទ្ធិវិហារិករបស់អ្នកជានិរន្តរកាលទៅ ។ ព្រះសម្មាសម្ពុទ្ធទ្រង់

សម្តែងបរមត្ថ ព្រះអភិធម្មប្រាប់ព្រះសារីបុត្តត្ថេរសព្វគ្រប់ហើយ ក៏ព្រះអង្គទ្រង់យាងទៅកាន់ឋានតាវត្តិង្សពិភពវិញ ហើយព្រះអង្គទ្រង់សម្តែងព្រះអភិធម្មតអំពីពុទ្ធនិម្មិតទៅទៀត, ចំណែកខាងព្រះមហាសារីបុត្ត-ត្ថេរ ក៏ត្រឡប់ទៅកាន់វិហារឯនគរសង្កស្សវិញ ហើយសម្តែងព្រះអភិធម្មបង្រៀនភិក្ខុទាំង ៥០០ រូប ឲ្យរៀនព្រះអភិធម្មតែរាល់ៗ ថ្ងៃទៅលុះដល់ព្រះអរហំសម្មាសម្ពុទ្ធទ្រង់សម្តែងបរមត្ថព្រះអភិធម្មឯឋានតាវត្តិង្ស-ពិភពចប់ហើយ ភិក្ខុទាំង ៥០០ រូប ក៏បានរៀនព្រះអភិធម្មចប់ដែរ ហើយបានទ្រទ្រង់នូវព្រះអភិធម្មទាំងប្រាំពីរគម្ពីរ ព្រមទាំងបាលីនិងអដ្ឋកថាមុនជាងភិក្ខុទាំងឡាយ ហើយបានបង្ហាត់បង្ហាញដល់សិស្សានុ-សិស្សជាប់តៗ គ្នាមកដល់កាលសព្វថ្ងៃនេះ ។ ឯព្រះសម្មាសម្ពុទ្ធទ្រង់ឈ្វេងយល់ឧបនិស្ស័យភិក្ខុទាំង ៥០០ រូបនេះហើយ បានជាព្រះអង្គទ្រង់ខ្វល់ខ្វាយសម្តែងព្រះអភិធម្មប្រាប់ដល់ព្រះសារីបុត្តត្ថេរ ឲ្យរៀនយកទៅបង្ហាត់បង្ហាញដល់ភិក្ខុទាំង ៥០០ រូប នោះឯង ។

២០- ធម្មវាទី ពោលថា សាធុៗអត្ថវាទី ប្រស្នានេះប្រពៃណាស់ហើយ តែយើងនៅមានសង្ស័យតទៅទៀត ត្រង់ពាក្យខាងចុងដែលលោកវិសជ្ជនាថា ព្រះសម្មាសម្ពុទ្ធទ្រង់ឈ្វេងយល់ឧបនិស្ស័យភិក្ខុទាំង

៥០០ រូបនោះ បានជាព្រះអង្គទ្រង់ខ្វល់ខ្វាយសម្ដែងព្រះអភិធម្មប្រាប់ព្រះសារីបុត្តត្ថេរ ឲ្យរៀនយកនាំទៅបង្ហាត់បង្ហាញភិក្ខុទាំង ៥០០ រូបនោះ ចុះកាលបុព្វជាតិមុន ភិក្ខុទាំងឡាយនោះបានបំពេញឧបនិស្ស័យពីកាលណាមក? កើតជាជាតិអ្វី បានធ្វើបុណ្យអ្វី ដែលជាបុណ្យអស្ចារ្យជាហេតុមានកម្លាំង គួរឲ្យបានទ្រទ្រង់នូវបរមត្ថព្រះអភិធម្មចប់មុនជាងបុគ្គលទាំងអស់ក្នុងព្រះពុទ្ធសាសនានេះ ?

អដ្ឋវាទី វិសជ្ជនាថា ក្នុងកាលសាសនាព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបព្រះអង្គបានត្រាស់ប្រាកដឡើងក្នុងលោកនេះ ឯភិក្ខុទាំង ៥០០ រូបនោះបានកើតជាសត្វប្រចៀវតូចៗ ហើយបាននៅអាស្រ័យក្នុងញកភ្នំមួយមានព្រះថេរៈពីរព្រះអង្គលោកបានទៅចង្ក្រមស្វាធ្យាយ ព្រះអភិធម្មទៀបញកភ្នំនោះ ឯសត្វប្រចៀវទាំងនោះក៏បានផ្ទង់ស្ដាប់កាន់យកនិមិត្តក្នុងសំ-ឡេងមកជាអារម្មណ៍សម្ងំស្ដាប់ព្រះអភិធម្មដោយគោរព តែថាសត្វប្រ-ចៀវទាំងអស់នោះ នឹងបានដឹងអត្ថរសថាធម៌ប៉ុណ្ណេះ ឈ្មោះ ខន្ធ អាយ-តនៈ ធាតុ ជាដើមក៏ទេដែរ គ្រាន់តែកាន់យកនូវនិមិត្តសំឡេងដែលលោកស្វាធ្យាយចម្រើនព្រះអភិធម្មមកជាអារម្មណ៍ជាទីត្រេកអរប៉ុណ្ណោះ សត្វប្រចៀវទាំងនោះ ក៏គង់បានធម្មស្សវនានិសង្សយ៉ាងឧត្តមខ្ពង់ខ្ពស់ លុះ

ច្យុតអំពីជាតិជាសត្វប្រចៀវនោះទៅ កំបានផ្លាស់កំណើតពីសត្វតិរច្ឆាន បានទៅកើតជាកំណើតទេវតាក្នុងឋានតាវត្តិង្សទេវលោក បានសោយនូវសម្បត្តិទិព្វទាំង ១០ ប្រការជាសុខក្សេមក្សាន្ត អស់កាលជាអន្លើងមួយពុទ្ធន្តរ គឺចន្លោះព្រះពុទ្ធមួយព្រះអង្គដោយពិត លុះដល់ច្យុតចុះមកអំពីឋានតាវត្តិង្សព្រិភពនោះកំបានមកកើតក្នុងត្រកូលទាំង ៥០០ ដ៏ស្តុកស្តម្ភទៀបក្រុងសាវត្ថីមានសេចក្តីជ្រះថ្លាកើតឡើងក្នុងយមកប្បាដិហារិយ៍ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នៃយើងទាំងឡាយនេះ ហើយកំបានលះបង់ទ្រព្យសម្បត្តិកូនប្រពន្ធ ចូលមកសូមផ្នួសបួសក្នុងសំណាក់ព្រះសារីបុត្តត្ថេរ ជាព្រះឧបជ្ឈាយ៍លុះអង្គសម្តេចព្រះបរមគ្រូជាម្ចាស់ ទ្រង់ត្រាស់សម្តែងព្រះអភិធម្មនៅឋានតាវត្តិង្សព្រិភព ចប់ស្រេចហើយ ភិក្ខុទាំង ៥០០ រូបនោះកំបានរៀនយកនូវព្រះអភិធម្មទាំងប្រាំពីរគម្ពីរ អំពីសំណាក់ព្រះសារីបុត្តត្ថេរជាព្រះឧបជ្ឈាយ៍ចប់ដែរ ហើយបានទ្រទ្រង់នូវបរមត្ថព្រះអភិធម្មទាំងប្រាំពីរគម្ពីរចប់មុនជាងបុគ្គលទាំងអស់ ក្នុងព្រះពុទ្ធសាសនានេះ ដោយផលានិសង្សដែលបានគោរពស្តាប់ព្រះអភិធម្មកាន់យកនូវនិមិត្តសំឡេង នៃព្រះថេរៈទាំងពីរអង្គដែលលោកកំពុងស្វាធ្យាយនោះ យកមកជាអារម្មណ៍ជាទីត្រេកអរប៉ុណ្ណោះឯង ។

សប្បុរសទាំងឡាយ បើបានជ្រាបច្បាស់នូវផលានិសង្សស្ដាប់ធម៌ព្រះអភិធម្មជាអស្ចារ្យយ៉ាងនេះហើយ គួរតែខំព្យាយាមស្ដាប់បរមត្ថព្រះអភិធម្មឲ្យញឹកញយរឿយៗ ហើយខំរំពឹងគិតពិចារណាមើល ជ្រើសរើសយកសេចក្ដីតាមសភាពពិត មិនត្រូវប្រកាន់មាំយកលទ្ធិគ្រូផ្សេងៗ ដែលមិនសមគួរតាមបាលីនិងអដ្ឋកថា ដីកា និស្ស័យ យោជនា ព្រះអភិធម្មនោះឡើយ ដែលជាហេតុនាំឲ្យខាតប្រយោជន៍ គួរបានផលា-និសង្សដ៏ខ្ពង់ខ្ពស់ ត្រឡប់ទៅជាបានផលានិសង្សទន់តិចថោកទាបទៅវិញ ព្រោះតែពុំបានគិតពិចារណាដោយសេចក្ដីម៉ដ្ឋចត់ប៉ុណ្ណោះឯង ។

បប់អភិធម្មត្ថាធិប្បាយនិទានកថាដោយសង្ខេប ។

## អភិធម្មត្ថាធិប្បាយបរមត្ថកថា

២១- ធម្មវាទី បានស្ដាប់ហើយពោលថា ម្នាលអត្ថវាទី យើងបានបុច្ឆាវិសជ្ជនាគ្នាអំពីអភិធម្មត្ថាធិប្បាយមកនេះ ក៏ឃើញថាល្មមសមគួរហើយ យើងនឹងបញ្ចប់សេចក្ដីដោយសង្ខេបតែប៉ុណ្ណេះចុះ តអំពីនេះទៅ យើងនឹងបុច្ឆា វិសជ្ជនាគ្នាអំពីអភិធម្មត្ថាធិប្បាយបរមត្ថកថាតទៅទៀត អើ! អត្ថវាទី សម្ដេចព្រះមុនីនាថជាម្ចាស់ទ្រង់ត្រាស់សម្ដែងរួបរួមកងធម៌ ជាសុខុមភាពដ៏ល្អិតជ្រាលជ្រៅហ្មត់ចត់ កំណត់ឲ្យឈ្មោះថាគម្ពីរធម្មសង្គណី

នោះតើព្រះអង្គទ្រង់កំណត់អក្ខរៈប៉ុន្មានហៅថាមួយបាទ? ប៉ុន្មានបាទហៅថាមួយគណ្ឋៈ? ប៉ុន្មានគណ្ឋៈហៅថាមួយភាណវារៈ? ម្យ៉ាងទៀត ព្រះអង្គទ្រង់សម្តែងគម្ពីរធម្មសង្គណីកំណត់បរិច្ឆេទ, បទមាតិកា, បទភាជនីយ, ធម្មក្ខន្ធនោះ តើត្រូវកំណត់រាប់ឲ្យបានដឹងច្បាស់លាស់ដូចម្តេចខ្លះ? សូមលោកវិសជ្ជនាឲ្យសព្វគ្រប់ យើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី ពោលថា បពិត្រធម្មវាទី កាលអង្គព្រះភគវន្តមុនីជាម្ចាស់ទ្រង់ត្រាស់សម្តែងគម្ពីរធម្មសង្គណី រូបរួមធម៌ ដ៏ល្អិតម៉ដ្ឋជ្រាលជ្រៅនោះ ទ្រង់កំណត់ ៨ អក្ខរៈ ហៅថាមួយបាទ, ៤បាទហៅថាមួយគណ្ឋៈ, ២៥០ គណ្ឋៈ ហៅថាមួយភាណវារៈ(៨ពាន់អក្ខរៈ) ហើយព្រះអង្គទ្រង់សម្តែងកំណត់ជាបរិច្ឆេទ ១៥ មានកុសលបរិច្ឆេទជាដើម មានវិជ្ជាភាគបរិច្ឆេទជាទីបំផុតខាងចុង ជាមាតិកាមាន ៣ គឺ ១- **តិកមាតិកា** ២២ មានកុសលត្តិកមាតិកាជាដើម មាននិទស្សនត្តិកមាតិកាជាទីបំផុតខាងចុង ។ ២- **ទុកមាតិកា** ១០០ មានហេតុទុកមាតិកាជាដើម មានបិដ្ឋិទុកមាតិកាជាទីបំផុតខាងចុង ។ ៣- **សុត្តន្តិកមាតិកា** ៤២ មានវិជ្ជាភាគទុកមាតិកាជាដើម មានខយេញាណទុកមាតិកាជាទីបំផុតខាងចុង ។ ឯតិកមាតិកាទាំង ២២ នោះត្រូវឲ្យកំណត់រាប់ធម្មក្ខន្ធតាមរបៀបបទមាតិកា ដូចយ៉ាង

អកុសលត្តិកមាតិកាខាងដើមមានបីបទមាតិកា គឺ កុសលា ធម្មា ធម៌ទាំង-ឡាយជាកុសល បានឈ្មោះថាបទមាតិកា ១ រាប់ថាធម្មក្ខន្ធ ១ អកុសលា ធម្មា ធម៌ទាំងឡាយជាអកុសល បានឈ្មោះថាបទមាតិកា ១ រាប់ថាធម្មក្ខន្ធ ១ អព្យាកតា ធម្មា ធម៌ទាំងឡាយជាអព្យាក្រឹត បានឈ្មោះថាបទមាតិកា ១ រាប់ថាធម្មក្ខន្ធ ១ ។ ក៏ក្នុងតិកមាតិកាមួយៗ មានបទ បទមាតិកាបីៗ មានធម្មក្ខន្ធបីៗដែរ ២២ តិកមាតិកាត្រូវជា ៦៦ ធម្មក្ខន្ធគត់ ហើយត្រូវរាប់តាមវារៈនៃចិត្តនិងចេតសិកធម៌ តាមបទ បទភាជនីយ ដែលសម្តែងញែកចែកចេញអំពីបទ បទមាតិកា ដូចយ៉ាងបទថា កុសលា ធម្មា ចិត្តនិងចេតសិកទាំងឡាយជាកុសលជាដើម ត្រូវរាប់តាមវារៈនៃចិត្តនិងចេតសិកមួយៗ ថាជាធម្មក្ខន្ធមួយៗ ជាលំដាប់ទៅ វារៈនៃចិត្តនិងចេតសិកមានចំនួនប៉ុន្មាន ធម្មក្ខន្ធក៏មានចំនួនប៉ុណ្ណោះដែរ ឯទុកមាតិកាទាំង ១០០ នោះក្តី សុត្តន្តិកទុកមាតិកាទាំង ៤២ នោះក្តី ត្រូវរាប់តាមទុក-មាតិកា ក៏ក្នុងទុកមាតិកាមួយៗ មានធម្មក្ខន្ធពីរៗ ដូចបទថា ហេតូ ធម្មា ធម៌ទាំងឡាយជាហេតុ ន ហេតូ ធម្មា ធម៌ទាំងឡាយមិនមែនជាហេតុជាដើម សឹងមានធម្មក្ខន្ធពីរៗ ដូចគ្នាទាំងអស់ ។

កុលបុត្រអ្នកសិក្សាបរមត្ថព្រះអភិធម្មក្នុងគម្ពីរធម្មសង្គណី ត្រូវកំណត់

អក្ខរៈ គណ្ឋៈ ភាណវារៈ មាតិកា ជាដើម ដូចបានអធិប្បាយដោយសង្ខេបមកនេះ ទើបអាចនឹងកាន់យកអត្ថរសចំពោះបរមត្ថព្រះអភិធម្មតាមសភាពពិតទៅបានដោយងាយ ។

២២- ធម្មវាទី បានស្តាប់ហើយពោលថាសាធុៗ ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះត្រឹមត្រូវពិតហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ម្នាលអត្ថវាទី ក៏ក្នុងកុសលត្តិកមាតិកា ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ជាបទមាតិកា សេចក្តីថា កុសលធម៌ទាំងឡាយ អកុសលធម៌ទាំងឡាយ អព្យាកតធម៌ទាំងឡាយ លុះដល់ព្រះអង្គទ្រង់សម្តែងជាបទបទភាជនីយ ចំណែកចែកបរមត្ថធម៌ដោយសេចក្តីពិស្តារ ពន្យល់ដល់វេនេយ្យសត្វទាំងឡាយ ព្រះអង្គទ្រង់ត្រឡប់យកអកុសលធម៌ទាំងឡាយមកសម្តែងជាមុន ឲ្យខុសអំពីបទមាតិកានោះទៅ មិនយកកុសលធម៌ទាំងឡាយមកសម្តែងជាមុនវិញឲ្យត្រូវត្រង់តាមបទមាតិកានោះ តើព្រះអង្គទ្រង់ឈ្វេងយល់ហេតុផលដូចម្តេចខ្លះ?

អត្ថវាទី វិសជ្ជនាថា បពិត្រធម្មវាទី ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គជាបុគ្គលឆ្លៀវឆ្លាសវាងវៃក្នុងវិធីសម្តែងធម៌ទេសនា នឹងរកបុគ្គលណា

មួយដទៃមកប្រៀបផ្ទឹមនឹងព្រះអង្គពុំបានឡើយ ព្រោះព្រះអង្គជាអង្គសព្វញ្ញូទ្រង់ត្រាស់ដឹងសព្វឥតមានចន្លោះ កាលដែលព្រះអង្គទ្រង់សម្តែងធម៌ទេសនានោះ ទ្រង់ពិចារណាមើលឧបនិស្ស័យសត្វលោកទាំងពួងដោយសព្វគ្រប់ជាមុន បើព្រះអង្គបានពិចារណាឃើញសត្វទាំងឡាយពួកខ្លះដែលមានឧបនិស្ស័យក្រាស់មាំមួន មានឥន្ទ្រិយចាស់ទុំពេញបរិបូរ ស្គាល់ខុសត្រូវ គុណទោស ល្អអាក្រក់ បុណ្យបាប មានមុខឈមទៅកាន់ផ្លូវត្រង់គឺព្រះអដ្ឋង្គិកមគ្គដែលប្រកបដោយអង្គទាំង ៨ មានសម្មាទិដ្ឋិ យល់ឃើញត្រូវជាដើមហើយ ក៏ព្រះអង្គលើកយកកុសលធម៌ទាំងឡាយមកសម្តែងប្រាប់ពន្យល់ដល់សត្វទាំងឡាយពួកនោះ ឲ្យបានសម្រេចមគ្គផលត្រង់តាមបទមាតិកានោះទៅក៏មានខ្លះដែរ តែថាសត្វទាំងឡាយដែលមានឧបនិស្ស័យក្រាស់មាំមួន មានឥន្ទ្រិយចាស់ទុំពេញបរិបូរនោះតិចពន់ពេកណាស់ ឯសត្វទាំងឡាយដែលក្រាស់ទៅដោយកងកិលេសទាំងឡាយមានរាគៈ ទោសៈ ជាដើម ដេកផ្កាប់នៅក្នុងសង្សារ-ចក្រ លុះទៅតាមអំណាចនៃតណ្ហាដឹកនាំជ្រមុជចុះក្នុងសង្សារវដ្ត ប្រាសចាកសទ្ធា សតិ បញ្ញា មិនជឿកម្មផល មិនមានសតិភ្ញាក់រឭកនឹករកកុសលផលបុណ្យសោះ អាប់ឥតបញ្ញាវង្វេងកាន់ច្រឡំ សម្គាល់ខុស

ជាត្រូវ គុណជាទោស បុណ្យជាបាប ល្អជាអាក្រក់ជាដើម ហើយប្រព្រឹត្តធ្វើនូវអំពើបាបទាំងនោះតាមទំនើងចិត្តខ្លួន ឥតមានកោតញញើតឡើយ វីសត្វទាំងឡាយដែលប្រព្រឹត្តបែបនេះ មានច្រើនជាអនេកត្រារាប់ពុំអស់ឡើយ ។ ហេតុហ្នឹងហើយបានជាព្រះសម្មាសម្ពុទ្ធទ្រង់ឆ្លៀវឆ្លាសវាងវៃក្នុងវិធីសម្តែងធម៌ទេសនា ព្រះអង្គទ្រង់លើកយកអកុសលធម៌ទាំងឡាយមកសម្តែងប្រាប់ពន្យល់ដល់វេនេយ្យសត្វទាំងឡាយ ដែលប្រព្រឹត្តធ្វើនូវអំពើបាបដ៏លាមកនោះ ដោយគំនិតគិតខុសប្រាសចាកសទ្ធា សតិ បញ្ញា ជាមិច្ឆាទិដ្ឋិ យល់ឃើញខុស កាន់ផ្លូវឆ្វេងប្រកបដោយសេចក្តីអន្តរាយផ្សេងៗ មានសោយទុក្ខក្នុងនរកជាដើម រកទីបំផុតជាតិគ្មាន ឲ្យវេនេយ្យសត្វទាំងនោះបានភ្ញាក់ដឹងខ្លួន តក់ស្លុតភិតភ័យនឹងអំពើដែលខ្លួនធ្វើខុសនោះ ឲ្យងាកបែរមុខឈមមកកាន់សម្មាទិដ្ឋិ យល់ឃើញត្រូវជាផ្លូវត្រង់វិញ ដោយមេត្តាករុណាគុណរបស់ព្រះអង្គពិតៗ មានសេចក្តីឧបមាដូចបណ្ឌិតជាតិបុរស ប្រកបដោយប្រាជ្ញាឆ្លៀវឆ្លាសវាងវៃក្នុងវិធីបង្ហាញផ្លូវ ដែលប្រកបដោយសេចក្តីមេត្តាករុណាដល់មនុស្សអ្នកដំណើរដើរវង្វេងផ្លូវ មិនដឹងទិស ប្រាកដត្រង់ណាសោះ បណ្ឌិតបុរសនោះក៏អធិប្បាយ ពន្យល់ចង្អុល ប្រាប់ផ្លូវដែលវៀចវាងឆ្ងាយប្រកបដោយ

សេចក្តីអន្តរាយផ្សេងៗ ដែលជាហេតុនាំដំណើរឲ្យយឺតយូរលំបាកកំណត់មិនបាន ឲ្យងាកបែរមុខឈមមករកផ្លូវត្រង់ ដែលជាហេតុនាំដំណើរឲ្យបានដើរដល់ឆាប់រហ័ស មានឧបមាយ៉ាងណាមិញ ព្រះបរមគ្រូជាម្ចាស់ ទ្រង់លើកយកអកុសលធម៌ទាំងឡាយដែលជាផ្លូវវៀចវង្វេងឆ្ងាយ មកសម្តែងអធិប្បាយប្រាប់ពន្យល់ដល់វេនេយ្យសត្វទាំងឡាយឲ្យបានដឹងច្បាស់ក្នុងខ្លួន តក់ស្លុតភិតភ័យនឹងផ្លូវវៀចវង្វេងឆ្ងាយប្រកបដោយសេចក្តីអន្តរាយផ្សេងៗ នោះ ឲ្យងាកបែរមុខឈមមកកាន់ផ្លូវជិតប្រកបដោយអង្គទាំង ៨ មានសម្មាទិដ្ឋិយល់ឃើញត្រូវជាដើម ប្រតិបត្តិត្រូវតាមគន្លងផ្លូវត្រង់ជារបស់ព្រះអរិយបុគ្គលវិញ មានឧបមេយ្យដូចបណ្ឌិតបុរសមានប្រាជ្ញាឈ្លាសវាងវៃ អ្នកបង្ហាញផ្លូវដូច្នោះឯង។

២៣- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្ថវាទី ប្រស្នានេះ ពិរោះពិតណាស់ហើយ តែថាយើងនឹងសួរលោកតទៅទៀត ចុះពាក្យថាធម៌ៗ នោះមានប៉ុន្មាន? ធម្មសព្ទនោះតើសេចក្តីអធិប្បាយដូចម្តេច?

អត្ថវាទី វិសជ្ជនាថា បពិត្រធម្មវាទី ឯពាក្យថាធម៌ៗ នោះតាមន័យព្រះអភិធម្មសម្តែងថាមាន ១០ គឺ សោតាបត្តិមគ្គ ១ សោតាបត្តិផល ១

សកិទាគាមិមគ្គ ១ សកិទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ ១ អរហត្តផល ១ ព្រះនិព្វាន ១ ថែមព្រះបរិយត្តិ ១ ទៀត ជាគម្រប់ ១០ បានឈ្មោះថាធម៌ដោយពិត ម្យ៉ាងទៀត ធម្មសព្ទនេះ តាមន័យអដ្ឋកថាព្រមទាំងដីកាព្រះអភិធម្មប្រែថា ទ្រទ្រង់ ថា ស្ទួយឡើង ។ អធិប្បាយថា សភាវវិបាកឯណា ទ្រទ្រង់ទុកនូវសត្វទាំងឡាយឯណា ដែលទ្រទ្រង់ខ្លួនទុក សត្វទាំងឡាយនោះ មិនឲ្យធ្លាក់លិចចុះទៅក្នុងអបាយទាំងឡាយ ៤ ផង ក្នុងវដ្តទុក្ខទាំងឡាយផង សភាវវិបាកនោះបានឈ្មោះជាធម៌ពិត គឺថាបុគ្គលឯណាបានទ្រទ្រង់ធម៌ល្អ រក្សាធម៌ឲ្យល្អហើយ វិបាកធម៌ដែលល្អនោះឯងរមែងទ្រទ្រង់រក្សាបុគ្គលនោះឲ្យល្អវិញ មិនឲ្យធ្លាក់ចុះទៅក្នុងអបាយភូមិទាំង ៤ នោះឡើយ បុគ្គលឯណាបានទ្រ-ទ្រង់នូវធម៌ដ៏ខ្ពង់ខ្ពស់វិសេសបំផុតក្នុងសន្តានខ្លួនល្អហើយ ធម៌ដែលខ្ពង់ខ្ពស់នោះនឹងទ្រទ្រង់រក្សាបុគ្គលនោះឲ្យស្ថិតនៅក្នុងឋាន ដ៏ខ្ពង់ខ្ពស់វិសេសបំផុត គឺព្រះនិព្វានជាសុខក្សេមក្សាន្តវិញ ពុំបានឲ្យធ្លាក់ចុះទៅក្នុងវដ្តទុក្ខទាំងឡាយនោះទៀតឡើយ ។ ឯសប្បុរសអ្នកសិក្សាព្រះអភិធម្ម ត្រូវរំពឹងមើលតាមសេចក្តីអធិប្បាយជាយ៉ាងសង្ខេបនេះចុះ គង់នឹងបានជ្រាបច្បាស់នូវអត្ថរសព្រះអភិធម្មដោយពិត ។

២៤- ធម្មវាទី បានស្ដាប់ហើយពោលថា អើអត្ថវាទី លោកវិសជ្ជនាពាក្យពីរម៉ាត់ គឺរាប់ចំនួនធម៌ ១០ និងសេចក្ដីអធិប្បាយធម្មស័ព្ទមកនេះ យើងស្ដាប់បានចូលចិត្តខ្លះហើយ តែយើងមានសេចក្ដីសង្ស័យខ្លះតទៅទៀត ត្រង់ពាក្យថាកុសលធម៌ អំពើដែលសត្វទាំងឡាយធ្វើល្អប្រពៃកើតបុណ្យជាកុសលវិបាកនោះ បានឈ្មោះថាធម៌ទ្រទ្រង់នូវសត្វទាំងឡាយ មិនឲ្យធ្លាក់លិចចុះក្នុងអបាយភូមិផង ក្នុងវដ្តទុក្ខផង នោះយើងឥតមានសេចក្ដីសង្ស័យសោះឡើយ យើងសង្ស័យតែត្រង់ពាក្យថា អកុសលធម៌ គឺអំពើដែលសត្វទាំងឡាយប្រព្រឹត្តធ្វើអាក្រក់លាមកនោះ បានឈ្មោះថាធម៌ ទ្រទ្រង់នូវសត្វទាំងឡាយមិនឲ្យធ្លាក់លិចចុះក្នុងអបាយភូមិនិងក្នុងវដ្តទុក្ខដែរ ពាក្យនេះយើងគិតពុំយល់ ស្ដាប់ពុំបាន ស្មានពុំត្រូវ ព្រោះពាក្យនេះដំល្អិតជ្រាលជ្រៅពេក ចូរលោកវិសជ្ជនាដោយស្រាយអធិប្បាយឲ្យមានសេចក្ដីរាក់ងាយឡើង យើងនឹងស្ដាប់ឲ្យចូលចិត្តបានដោយងាយផងមើល ។

អត្ថវាទី វិសជ្ជនាថា បពិត្រធម្មវាទី ត្រង់ពាក្យថាកុសលធម៌និងអកុសលធម៌នោះគួរសង្ស័យពិតមែន ព្រោះព្រះសម្មាសម្ពុទ្ធព្រះអង្គសម្ដែងថា កុសលា ធម្មា អកុសលា ធម្មា ឃើញសេចក្ដីថា កុសលកម្ម

ទាំងឡាយក៏បានឈ្មោះថាធម៌ដែរ អកុសលកម្មទាំងឡាយក៏បានឈ្មោះថាធម៌ដែរ តែអត្ថរសរបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់មិនមែនដូច្នោះទេ តាមសេចក្តីពិតថា សម្តេចព្រះលោកនាថជាម្ចាស់ ព្រះអង្គជាមគ្គនាយក ទ្រង់ដឹកនាំបង្ហាញផ្លូវសត្វលោក ជាមគ្គវិទូ ព្រះអង្គទ្រង់ជ្រាបច្បាស់នូវផ្លូវល្អនិងផ្លូវអាក្រក់ពិតប្រាកដណាស់ ហើយព្រះអង្គទ្រង់សម្តែងធម៌ទូន្មានប្រៀនប្រដៅដល់សត្វលោកទាំងឡាយ ឲ្យបានដឹងច្បាស់នូវអំពើអាក្រក់ទាំងឡាយមានប្រព្រឹត្តធ្វើនូវកាយទុច្ចរិតជាដើម ដែលជាផ្លូវអាក្រក់វៀចវាងឆ្ងាយ ប្រកបដោយសេចក្តីអន្តរាយផ្សេងៗ មានសោយទុក្ខវេទនាក្នុងនរកជាដើម ដើម្បីឲ្យសត្វលោកទាំងឡាយលះបង់ចោលពីសន្តានខ្លួនឲ្យស្រឡះចេញ បើបានលះបង់ហើយទើបបានឈ្មោះថាសត្វលោកទាំង-ឡាយនោះជាបុគ្គលមានធម៌ពិត ជាគ្រឿងទ្រទ្រង់ខ្លួនមិនឲ្យលង់លិចចុះទៅក្នុងអបាយភូមិទាំងឡាយនោះឡើយ បើសត្វលោកទាំងឡាយឯណាមិនបានដឹងក្តី បានដឹងហើយក្តី ហើយពុំបានលះបង់ នៅតែប្រព្រឹត្តនូវអំពើអាក្រក់លាមកនោះដដែល សត្វលោកទាំងឡាយនោះបានឈ្មោះថាជាបុគ្គលឥតធម៌ គ្មានវត្ថុអ្វីជាគ្រឿងទ្រទ្រង់ខ្លួនទុក មុខជានឹងលង់លិចចុះទៅក្នុងអបាយភូមិទាំង ៤ នោះពុំខានឡើយ ឯព្រះសម្មាសម្ពុទ្ធព្រះអង្គ

ជាសាស្តាចារ្យ តែងហ្វឹកហ្វឺនប្រៀនប្រដៅពួកវេនេយ្យសត្វដែលព្រះអង្គគួរនឹងហ្វឹកហ្វឺនប្រៀនប្រដៅបាន ឲ្យខំប្រឹងប្រែងសិក្សារៀនសូត្រឲ្យបានចេះដឹងស្គាល់ច្បាស់នូវអំពើអកុសល ដែលជាអំពើឲ្យផលប្រកបដោយសេចក្តីអន្តរាយផ្សេងៗ មានអបាយទុក្ខជាដើម ជាបហានលក្ខណៈ មានកិរិយាឲ្យវេនេយ្យសត្វលះបង់ចេញជាលក្ខណៈ បើសត្វលោកបានលះបង់តាមពាក្យប្រដៅរបស់ព្រះអង្គហើយ ទើបបានឈ្មោះថាធម៌ដោយពិត បើសត្វលោកពុំបានលះបង់ទេ នឹងត្រឡប់បានឈ្មោះថាអធម៌គឺមិនមែនជាធម៌ទៅវិញដោយពិត ទោះបីអំពើជាកុសលដែលជាអំពើឲ្យផលល្អមានឲ្យបាននូវមនុស្សសម្បត្តិជាដើម បើបុគ្គលទាំងឡាយបានស្តាប់ពុទ្ធឱវាទហើយសិក្សារៀនសូត្របានចេះដឹងច្បាស់លាស់ហើយ ខំប្រឹងព្យាយាមធ្វើបុណ្យឲ្យកើតមានចម្រើនច្រើនឡើងក្នុងសន្តានខ្លួន ទើបបានឈ្មោះថាជាធម៌ពិតមែន បើពុំខំព្យាយាមធ្វើបុណ្យឲ្យកើតមានចម្រើនច្រើនឡើងក្នុងសន្តានខ្លួនសោះទេ ក៏បានឈ្មោះថាអធម៌គឺជាបុគ្គលឥតធម៌វិញដដែលដោយពិត ព្រោះអត្ថសេក្កុងកុសលត្តិកមាតិកានេះ ត្រង់បទថា កុសលា ធម្មា កុសលធម៌ទាំងឡាយ គឺព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ចំពោះយកភាវនាលក្ខណៈ ឬភាវេតព្វលក្ខណៈ កិរិយាដែលចម្រើន ឬត្រូវចម្រើន

បុណ្យឲ្យកើតមានច្រើនឡើងក្នុងសន្តានខ្លួនជាលក្ខណៈ ទើបព្រះសម្មា-សម្ពុទ្ធព្រះអង្គឲ្យឈ្មោះថាធម៌ជាគ្រឿងទ្រទ្រង់សត្វដោយពិត បើមិនចម្រើនឬថា មិនត្រូវចម្រើនបុណ្យឲ្យកើតមានច្រើនឡើងក្នុងសន្តានខ្លួនជាលក្ខណៈសោះទេ ក៏ពុំបានឈ្មោះថាធម៌ជាគ្រឿងទ្រទ្រង់សត្វឡើយ ត្រង់បទថា អកុសលា ធម្មា អកុសលធម៌ទាំងឡាយ គឺព្រះអង្គចំពោះយកបហាន-លក្ខណៈ ឬបហាតព្វលក្ខណៈ កិរិយាដែលលះបង់ឬថាត្រូវតែលះបង់នូវអំពើបាបមិនឲ្យកើតមានឡើងក្នុងសន្តានខ្លួនជាលក្ខណៈ ទើបព្រះអង្គឲ្យឈ្មោះថា ធម៌ជាគ្រឿងទ្រទ្រង់សត្វដូចគ្នា បើមិនបានលះបង់ឬថាមិនត្រូវលះបង់នូវអំពើបាបនោះជាលក្ខណៈសោះទេ ក៏ពុំបានឈ្មោះថាធម៌ឡើយ ត្រឡប់បានឈ្មោះថា អធម៌គឺមិនមែនជាធម៌ឬជាបុគ្គលឥតធម៌ទៅវិញដោយពិត ត្រង់បទថា អព្យាកតា ធម្មា អព្យាកតធម៌ទាំងឡាយគឺព្រះអង្គចំពោះយកធម្មជាតដែលស្ទាក់ស្ទើរជាកណ្តាល មិនមែនជាកុសល មិនមែនជាអកុសល បណ្តោយទៅតាមតែកម្លាំងកុសលនិងអកុសល បើកុសលមានកម្លាំងខ្លាំងជាង ក៏ប្រព្រឹត្តតាមកុសលទៅ បើអកុសលមានកម្លាំងខ្លាំងជាង ក៏ប្រព្រឹត្តទៅតាមអកុសលទៅ ទើបព្រះសម្មាសម្ពុទ្ធព្រះអង្គឲ្យឈ្មោះថា អព្យាកតធម៌ដោយពិត បពិត្រធម្មវាទី ខ្ញុំអត្តវាទី

បានវិសជ្ជនាតាមសភាពពិតមកដោយសង្ខេបតែប៉ុណ្ណោះឯង ។

២៥- ធម្មវាទី បានស្តាប់ហើយពោលថា សាធុៗ ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះពីរោះណាស់ហើយ ឃើញថាត្រឹមត្រូវតាមធម្មរសនិងអត្ថរសនៃបរមត្ថព្រះអភិធម្មពិតមែនហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ម្នាលអត្ថវាទី ចុះធម្មជាតអ្វីឬវត្ថុអ្វីដែលជាដើមហេតុជាមេបណ្តាលឲ្យកើតឡើងនូវកុសលកម្ម អកុសលកម្ម និងអព្យាកតកម្មក្នុងសន្តានសត្វលោកទាំងឡាយនេះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី កុសលកម្មក្តី អកុសលកម្មក្តី អព្យាកតកម្មក្តី ដែលនឹងកើតឡើងក្នុងសន្តានសត្តនិកាយទាំងឡាយក្នុងលោកសន្និវាសនេះ មិនមែនកើតឡើងមកអំពីធម្មជាតអ្វីឬវត្ថុអ្វីដទៃឡើយ គឺកើតមកតែអំពីចិត្តុប្បាទ គឺធម្មសមូហៈ សង្ខារធម៌ប្រជុំព្រមគ្នាកើតឡើងជាមួយនឹងចិត្តជាប្រធាន ដែលប្រកបដោយលក្ខណៈ ៤ យ៉ាងគឺ សភាវៈប្រជុំព្រមគ្នានឹងចិត្តកើតឡើងជាមួយគ្នា រលត់ទៅជាមួយគ្នា ទទួលអារម្មណ៍ជាមួយគ្នា អាស្រ័យវត្ថុរូបជាមួយគ្នា វៀរលែងចាកគ្នា កើតឡើងពុំបានឡើយ ចិត្តុប្បាទរបស់សត្វទាំងឡាយហ្នឹងហើយ ដែលជាសភាវៈបណ្តាលឲ្យកើត

ឡើងនូវកុសលកម្មផង អកុសលកម្មផង អព្យាកតកម្មផង ក្នុងសន្តាននៃសត្តនិកាយទាំងឡាយក្នុងលោកសន្និវាសនេះដោយចំណែកមួយមែនពិត ។

២៦- ធម្មវាទី ពោលថា ម្នាលអត្តវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះត្រឹមត្រូវពិតហើយ តែយើងនៅមានសង្ស័យតទៅទៀត ត្រង់ពាក្យដែលលោកពោលថា ចិត្តុប្បាទគឺធម្មសមូហៈ សង្ខារធម៌ប្រជុំព្រមគ្នាកើតឡើងជាមួយនឹងចិត្តជាប្រធាន ប្រកបដោយលក្ខណៈ ៤ យ៉ាងនោះ តើលក្ខណៈអ្វីខ្លះ? លក្ខណៈមួយៗ មានសេចក្តីអធិប្បាយដូចម្តេច? ចូរលោកវិសជ្ជនាមកឲ្យសព្វគ្រប់យើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ចិត្តុប្បាទដែលប្រកបដោយលក្ខណៈ ៤ យ៉ាងនោះគឺឧប្បាទលក្ខណៈ ១ និរុជ្ឈនលក្ខណៈ ១ អាលម្ពណលក្ខណៈ ១ វត្ថុលក្ខណៈ ១ ។ ឯឧប្បាទលក្ខណៈនោះ គឺសង្ខារធម៌ប្រជុំព្រមជាមួយនឹងចិត្តដែលជាប្រធាន កើតឡើងព្រមគ្នាជាលក្ខណៈ ១ រលត់ទៅព្រមគ្នាជាលក្ខណៈ ១ ទទួលអារម្មណ៍ព្រមគ្នាជាលក្ខណៈ ១ អាស្រ័យនូវវត្ថុរូបជាលក្ខណៈ ១, សេចក្តីអធិប្បាយក្នុងបរមត្ថព្រះអភិធម្មថា សង្ខារធម៌នោះ គឺចេតសិកទាំង ៥២ ប្រជុំព្រមនឹងចិត្តជាអធិបតី ទទួលនូវអារម្មណ៍ ដែលចូលមកតាមវត្ថុរូប ប៉ះខ្ទប់នឹងបសាទរូបហើយ កាន់យកជា

ចំណីអាហារកើតឡើងព្រមគ្នា ដែលនឹងរលត់ទៅវិញក៏រលត់ទៅព្រមគ្នា មិនមុនមិនក្រោយស្មើៗគ្នា តាមលំដាប់វីថិចិត្តនិងភូមិរបស់ខ្លួនផ្សេងៗ ។

ម៉្យាងទៀត ក្នុងយោជនានិងដីកាព្រះអភិធម្មលោកសម្ដែងពន្យល់ថា សន្ធារផង អារម្មណ៍ផង វត្ថុផង ប្រជុំផ្សំចូលគ្នា ទើបបានឈ្មោះថាចេត-សិក ជាគ្រឿងប្រកបក្នុងចិត្ត ឬថាជាពន្ទីរស្មើរបស់ចិត្ត បានឈ្មោះពីរ គឺចិត្ត ១ ចេតសិក ១ តែថាចេតសិកនឹងកើតឡើងតាមទំនើងខ្លួនឯងពុំបាន លុះតែចិត្តកើតឡើងមុន ចេតសិកក៏កើតឡើងព្រមជាមួយនឹងចិត្តទើបបាន មានសេចក្ដីឧបមាដូចព្រះរាជា និងពួកសេវកាមាត្យទាំងឡាយ ឯពួក សេវកាមាត្យទាំងឡាយ នឹងប្រជុំគ្នាចាត់ចែងការរាជការទាំងពួងចេញទៅ ត្រួតត្រាស្រុកប្រទេសផ្សេងៗ តាមទំនើងខ្លួនឯងពុំបានឡើយ លុះតែមាន ព្រះរាជបញ្ញត្តិត្រាស់បង្គាប់មកជាមុន ទើបសេវកាមាត្យទាំងឡាយចាត់ ចែងការរាជការគ្រប់ជំពូក រៀបចំដំណើរតាមហែរហាមអមស្ដេចចេញអំពី ព្រះបរមរាជវាំងទៅ ត្រួតត្រាស្រុកប្រទេសផ្សេងៗ តាមកំណត់ស្រុក ប្រទេសជាអារម្មណ៍ ដឹកនាំដំណើរព្រះរាជាចេញទៅ លុះដល់ព្រះរាជា ស្ដេចទ្រង់ត្រួតត្រាស្រុកប្រទេសសម្រេចកិច្ចគ្រប់សព្វហើយ ទើបស្ដេច ទ្រង់យាងត្រឡប់មកព្រមទាំងពួកសេវកាមាត្យទាំងឡាយ តាមចោម

រោមដង្កែត្រឡប់មកកាន់ព្រះនគរគង់លើបល្ល័ង្ក ក្នុងព្រះបរមរាជវាំងវិញ មានសេចក្ដីឧបមាយ៉ាងណា ឯភវង្គចិត្តកើតឡើង ចេតសិកធម៌ទាំងឡាយ ក៏កើតឡើងព្រមជាមួយនឹងចិត្តដែរ ចេញទៅតាមខ្សែភវង្គដែលជាផ្លូវ របស់វីថិចិត្ត ទទួលត្រួតត្រាពិចារណានូវអារម្មណ៍ជាខាងក្រៅ ដែលចូល មកតាមទ្វារទាំងឡាយមានចក្ខុទ្វារជាដើម ដើម្បីសម្រេចកិច្ចផ្សេងៗ មាន បដិសន្ធិកិច្ចជាដើម ស្រេចហើយទទួលយកចំណែកផលបានគ្រប់គ្រាន់ តាមចំណែកធំនិងតូច សមគួរតាមអារម្មណ៍ធំនិងតូចជាលំដាប់ រលត់ហើយទម្លាក់ចោលនូវអារម្មណ៍ ភវង្គចិត្តព្រមទាំងចេតសិកទាំង ឡាយ ក៏ត្រឡប់ចូលមកកាន់កាយនគរ ស្ថិតនៅលើហទយៈបេះដូង ដូចជាបល្ល័ង្កក្នុងប្រជុំនៃបសាទទាំងឡាយមានចក្ខុបសាទជាដើម មាន សេចក្ដីឧបមេយ្យដូចព្រះរាជានិងសេវកាមាត្យទាំងឡាយដូច្នោះឯង ។

២៧- ធម្មវាទី ទទួលថាសាធុៗ ពិរោះណាស់ហើយអត្ថវាទីប្រស្នានេះ តែយើងនឹងសួរលោកតទៅទៀត ចុះចិត្តសព្ទនេះ ប្រែបានដូចម្ដេចខ្លះ? សេចក្ដីអធិប្បាយថាដូចម្ដេច? ម្យ៉ាងទៀត ចិត្តនិងចេតសិកតែមួយ ហើយមានឈ្មោះពីរ សេចក្ដីផ្សេងគ្នាយ៉ាងណា? ឧបមាដូចវត្ថុអ្វី?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ចិត្តសព្ទនេះប្រែថា ធម្មជាត

សម្រាប់គិត សម្រាប់ដឹងនូវអារម្មណ៍ក៏បាន ថាធម្មជាតសម្រាប់ធ្វើជ្រើសរើសនូវអារម្មណ៍ដ៏វិចិត្ររចនាផ្សេងៗ ដោយខ្លួនឯងក៏បាន សេចក្តីអធិប្បាយថា ចិត្តនេះ ជាធម្មជាតមិនចេះរើសអារម្មណ៍ ក៏ក្នុងអារម្មណ៍ទាំង ៦ នោះតាមតែអារម្មណ៍ណាក៏ដោយ ចិត្តតែងត្រូវការគិត ត្រូវការដឹងទាំងអស់ បើរូបារម្មណ៍មកកាន់រន្ធង់ភ្នែកហើយ ចិត្តក៏កើតឡើងភ្លាម ទទួលគិត ទទួលដឹងថា នេះរូប បើសទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍ ចូលមកកាន់រន្ធង់ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត វីថិចិត្តក៏កើតឡើងភ្លាម ទទួលគិត ទទួលដឹងថា នេះសំឡេង នេះក្លិន នេះរស នេះសម្ផស្ស នេះធម៌ ដោយពិត ឥតមានអាក់ខានឡើយ ត្រង់ចិត្តស័ព្ទប្រែថា ធម្មជាតសម្រាប់ធ្វើកិច្ចជ្រើសរើសអារម្មណ៍ដ៏វិចិត្ររច-នាផ្សេងៗ ដោយខ្លួនឯងនោះ មានសេចក្តីឧបមាដូចនាយជាងគំនូរដែលធ្លៀវធ្លាសវាងវៃ អាចធ្វើកិច្ចជ្រើសរើសនូវអារម្មណ៍ផ្សំគ្រឿងប្រដាប់ផ្សេងៗ មានក្រដាស សំពត់ ខ្មៅដៃ ថ្នាំគំនូរជាដើម ហើយតាំងគូរក្បូរក្បាច់រចនាដ៏វិចិត្រផ្សេងៗ ជារូបតូច រូបធំ រូបល្អ រូបអាក្រក់ តាមត្រូវការខ្លួនឯងដោយពិត ឥតមានទើសទាល់ឡើយ មានសេចក្តីឧបមាយ៉ាងណា ចំណែកចិត្តដែលមានក្នុងសន្តានសព្វសត្វទាំងអស់ ជាធម្មជាតអាចធ្វើកិច្ចជ្រើសរើស

នូវអារម្មណ៍ទាំងឡាយ មានរូបារម្មណ៍ជាដើម ហើយធ្វើវិចិត្ររចនាផ្សេងៗ នូវអារម្មណ៍ទាំងនោះ ឲ្យទៅជាអនិដ្ឋារម្មណ៍ជាអារម្មណ៍មិនគប្បី គឺអ្នកប្រាជ្ញទាំងឡាយមិនត្រូវការប្រាថ្នាត្រេកអរឡើយ ហើយខ្ពន្ត្រូវការប្រាថ្នាត្រេកអរនឹងអនិដ្ឋារម្មណ៍នោះ ឲ្យកើតជាអកុសលផលបាបតូចធំ តិចច្រើនទៅក៏បាន ឲ្យទៅជាឥដ្ឋារម្មណ៍ជាអារម្មណ៍គួរគប្បី គឺអ្នកប្រាជ្ញទាំងឡាយតែងប្រាថ្នា ត្រូវការ ត្រេកអរប្រព្រឹត្តធ្វើឲ្យកើតជាកុសលផលបុណ្យតូចធំ តិចច្រើនទៅក៏បាន មានឧបមេយ្យដូចនាយជាងគំនូរនោះឯង ។ ត្រង់ដួងចិត្តនិងចេតសិកតែមួយហើយមានឈ្មោះពីរនោះ មានសេចក្តីឧបមាដូចតួភ្លើងគោម បើប្រឆេះតូចឆេះឡើង អណ្តាតភ្លើងក៏តូចដែរ ពន្លឺរស្មីរបស់ភ្លើងផ្សាយចេញទៅកាន់ទិសក៏តូចឬជិតដែរ បើប្រឆេះធំឆេះឡើង អណ្តាតភ្លើងក៏ធំ ពន្លឺរស្មីរបស់ភ្លើងផ្សាយចេញទៅកាន់ទិសក៏ធំឆ្ងាយដែរ មានសេចក្តីឧបមាយ៉ាងណា ឯដួងចិត្តនិងចេតសិកតែងទទួលយកនូវអារម្មណ៍ជាមួយគ្នា បើអារម្មណ៍តូចតិចចូលមកដួងចិត្តកើតឡើង ចេតសិកជាពន្លឺរស្មីរបស់ដួងចិត្ត ក៏ផ្សាយចេញទៅកាន់អារម្មណ៍តូចតិចដែរ បើអារម្មណ៍ធំច្រើនចូលមក ដួងចិត្តកើតឡើង ចេតសិកជាពន្លឺរស្មីរបស់ដួងចិត្ត ក៏ផ្សាយចេញទៅកាន់អារម្មណ៍ធំឆ្ងាយ

ច្រើនដែរ មានឧបមេយ្យដូចតួអណ្តាតភ្លើងនិងពន្លឺរស្មីរបស់ភ្លើង គឺថា អារម្មណ៍ដូចប្រឆេះប្រេងគោម ដួងចិត្តដូចតួអណ្តាតភ្លើង ចេតសិកទាំងឡាយដូចពន្លឺរស្មីរបស់ភ្លើងយ៉ាងនោះឯង ។

២៨- ធម្មវាទី ពោលថាសាធុ ម្នាលអត្តវាទី ប្រស្នានេះប្រពៃហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ម្នាលអត្តវាទី ចុះចិត្តនោះបើនឹងហ៊ឹកហ៊ឺនប្រៀនប្រដៅឲ្យចម្រើនទៅតាមថ្នាក់ តាមជាន់ទាបខ្ពស់ជាលំដាប់ៗ ទៅបានប៉ុន្មានជាន់? ដូចម្តេចខ្លះ? ប្រព្រឹត្តទៅក្នុងភូមិប៉ុន្មាន? ឈ្មោះអ្វីខ្លះ? ចិត្តមានឈ្មោះផ្សេងៗគ្នា មានប៉ុន្មាន? គឺចិត្តឈ្មោះអ្វីខ្លះ?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ប្រស្នានេះខ្ញុំនឹងអធិប្បាយជាសរុបពាក្យសួរទាំង ៣ ប្រស្នាតែម្តង តាមន័យបរមត្ថព្រះអភិធម្មដែលព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងពន្យល់ដល់វេនេយ្យសត្វទាំងឡាយថា ចិត្តដែលកើតមានក្នុងសន្តានសព្វសត្វទាំងអស់ក្នុងលោកសន្និវាសនេះ ដែលហ៊ឹកហ៊ឺនប្រៀនប្រដៅឲ្យចម្រើនទៅតាមលំដាប់ថ្នាក់លំដាប់ជាន់ទាបខ្ពស់នោះមានថ្នាក់ ៤ មានភូមិ ៤ មានឈ្មោះ ៤ ដូចគ្នាសេចក្តីអធិប្បាយពន្យល់ថា ចិត្តទី ១ របស់សត្វទាំងឡាយឯណាដែលប្រព្រឹត្តទៅលុះក្នុងអំណាចនៃកាមតណ្ហា ដឹកនាំឲ្យត្រេកត្រអាលនឹង

កាមគុណទាំង ៥ ព្រោះមានរូប សំឡេង ក្លិន រស សម្ផស្សជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះមានឈ្មោះថាហីនចិត្ត ជាចិត្តយ៉ាងថោកថយ ប្រព្រឹត្តទៅក្នុងកាមភូមិ គឺទីកន្លែងដែលកើតអាស្រ័យនៅក្នុងកាមភព មានឈ្មោះថាកាមាវចរចិត្ត ។ ចិត្តទី ២ របស់សត្វទាំងឡាយឯណា ដែលប្រព្រឹត្តទៅលុះក្នុងអំណាចនៃរូបតណ្ហា ដែលបានលះបង់កាមគុណទាំង ៥ ហើយត្រេកត្រអាលតែនឹងរូបរបស់ខ្លួន ព្រោះមានរូបតណ្ហាជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះ មានឈ្មោះថាឧក្កដ្ឋចិត្ត ជាចិត្តជាន់ខ្ពស់ ល្មមប្រព្រឹត្តទៅក្នុងរូបភូមិ គឺទីកន្លែងកើតអាស្រ័យនៅក្នុងរូបភព បានឈ្មោះថារូបាវចរចិត្ត ។ ចិត្តទី ៣ របស់សត្វទាំងឡាយឯណាដែលប្រព្រឹត្តទៅលុះក្នុងអំណាចនៃអរូបតណ្ហា ត្រេកត្រអាលតែនឹងនាមធម៌ ព្រោះមានអរូបធម៌ជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះបានឈ្មោះថាឧក្កដ្ឋតរចិត្ត ជាចិត្តយ៉ាងជាន់ខ្ពស់បំផុត ប្រព្រឹត្តទៅក្នុងអរូបភូមិ គឺទីកន្លែងកើតអាស្រ័យនៅក្នុងអរូបភព បានឈ្មោះថា អរូបាវចរចិត្ត ។ ចិត្តទី ៤ របស់សត្វទាំងឡាយឯណា ដែលប្រព្រឹត្តទៅក្នុងទីដ៏ឧត្តមធ្ងន់ផុតចាកលោកជាស្រឡះ ព្រោះមានព្រះនិព្វានជាអារម្មណ៍ ចិត្តរបស់សត្វទាំងឡាយនោះបានឈ្មោះថា ឧក្កដ្ឋតរតមចិត្ត ជាចិត្តយ៉ាងប្រសើរ

វិសេសខ្ពង់ខ្ពស់បំផុត ប្រព្រឹត្តទៅក្នុងលោកុត្តរភូមិ គឺទីកន្លែងសោយសុខដ៏ឧត្តមក្សេមក្សាន្ត ក្នុងទីបំផុតលោកទាំង ៣ គឺកាមលោក ១ រូបលោក ១ អរូបលោក ១ ជាកិច្ចរួចផុតចាកតណ្ហា បានឈ្មោះថា លោកុត្តរចិត្ត រួបរួមចិត្តទាំងអស់ត្រូវជាថ្នាក់ ៤ ភូមិ ៤ ចិត្ត ៤ ដោយពិត ។

២៩- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្តវាទី ប្រស្នានេះយើងស្តាប់ចូលចិត្តហើយ តែយើងនឹងសួរលោកតទៅទៀត ចុះត្រង់ពាក្យដែលលោកវិសជ្ជនាមកថាភូមិមាន ៤ គឺកាមភូមិ ១ រូបភូមិ ១ អរូបភូមិ ១ លោកុត្តរកភូមិ ១ ជាបទមាតិកានោះយើងស្តាប់បានហើយ តែបទភាជនីយយើងស្តាប់ពុំទាន់បាននៅឡើយ ដូច្នេះសូមឲ្យលោកសម្តែងជាបទភាជនីយតទៅទៀត តើកាមភូមិមានប៉ុន្មាន? រូបភូមិមានប៉ុន្មាន? អរូបភូមិមានប៉ុន្មាន? លោកុត្តរភូមិមានប៉ុន្មាន? ចូរលោកវិសជ្ជនាមកឲ្យសព្វគ្រប់យើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្តវាទី វិសជ្ជនាថា បពិត្រធម្មវាទី តាមបទភាជនីយលោកសម្តែងចំណែកចែកភូមិដោយពិស្តារថា ទី **១ កាមាវចរភូមិមាន** ១១ ជាន់ គឺអបាយភូមិ ៤ ជាន់ នរក ១ ប្រេត ១ អសុរកាយ ១ តិរច្ឆាន ១ កាមសុគតិ ៧ ជាន់ ឋានមនុស្ស ១ ឋានសួគ៌ ៦ ជាន់ គឺចាតុម្មហារាជិ-

កា ១ តាវត្តឹសា ១ យាមា ១ តុសិតា ១ និម្មានរតី ១ បរនិម្មិតវសវត្តី ១ ត្រូវជាកាមភូមិ ១១ ជាន់ បើនឹងហៅថាកាមភព ១១ ជាន់ ទៅវិញក៏បានៗ **ទី ២ រូបភូមិមាន** ១៦ ជាន់ មានព្រហ្មបារិសជ្ជាជាដើម មានអកនិដ្ឋ-ព្រហ្មជាទីបំផុត ត្រូវជារូបភូមិ ១៦ ជាន់ បើនឹងហៅថារូបភព ១៦ ជាន់ ទៅវិញក៏បានៗ ទី **៣ អរូបភូមិមាន** ៤ ជាន់ គឺអាកាសានញ្ចាយតនៈ ១ វិញ្ញាណញ្ចាយតនៈ ១ អាកិញ្ចញ្ញាយតនៈ ១ នេវសញ្ញានាសញ្ញាយតនៈ ១ ត្រូវជាអរូបភូមិ ៤ ជាន់ បើនឹងហៅថាអរូបភព ៤ ជាន់ទៅវិញក៏បានៗ **ទី ៤ លោកុត្តរភូមិ**នោះ សេចក្ដីអធិប្បាយថា ព្រះអរិយបុគ្គលទាំងឡាយ ៤ ពួក គឺសោតាបត្តិមគ្គពួក ១ សោតាបត្តិផលពួក ១ សកិទាគាមិមគ្គពួក ១ សកិទាគាមិផលពួក ១ គឺព្រះអរិយទាំងឡាយ ៤ ពួកនេះ អាចត្រាច់ទៅក្នុងភូមិទាំង ២១ ជាន់ គឺកាមសុគតិភូមិ ៧ ជាន់ រូបភូមិ ១០ ជាន់ អរូបភូមិ ៤ ជាន់ ត្រូវជា ២១ ជាន់ វៀរលែងតែភូមិទាំង ១០ ជាន់ចេញ គឺសុទ្ធាវាស-សភូមិ ៥ ជាន់ អបាយភូមិ ៤ ជាន់ អសញ្ញីភូមិ ១ ជាន់ លោកពុំបានកើតឡើយ, ចំណែកខាងព្រះអនាគាមិបុគ្គលទាំងឡាយ លោកអាចត្រាច់ទៅកើតក្នុងសុទ្ធាវាសភូមិ ៥ ជាន់ គឺអវិហា ១ អតប្បា ១ សុទស្សា ១ សុទស្សី ១ អកនិដ្ឋ ១ តែប៉ុណ្ណោះ ព្រោះលោកមានកាមរាគបានលះបង់

ជាស្រឡះហើយ ម៉្យាងទៀត ព្រះអរិយទាំងឡាយដែលជាសេខបុគ្គល លោកអាចកើតបានក្នុងភូមិទាំង ២៦ ជាន់ វៀរលែងតែអបាយភូមិ ៤ និង អសញ្ញីភូមិ ១ ចេញ បើលោកបានចម្រើនសម្រេចព្រះអរហត្តផលហើយ ដល់កំណត់អស់អាយុសង្ខារ លោកនឹងរំលត់ខន្ធ ចូលកាន់សិវស្ថាន ជាស្ថានដ៏ទៀងសោយបរមសុខក្សេមក្សាន្ត គឺអមតមហានិញ្វានទៀងដោយ ពិត ខ្ញុំអត្ថវាទី វិសជ្ជនាមកអំពីភូមិទាំង ៤ ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៣០- ធម្មវាទី បានស្ដាប់ហើយពោលថា សាធុៗ ប្រស្នានេះប្រ-ពៃណាស់ហើយ តែយើងនឹងសួរលោកតទៅទៀត ម្នាលអត្ថវាទី ចុះចិត្ត ទាំង ៤ យ៉ាងនោះ គឺចិត្តទី ១ កាមាវចរចិត្ត ជាចិត្តលុះទៅក្នុងអំណាចនៃ កាមតណ្ហាដឹកនាំឲ្យត្រាច់ទៅដោយច្រើន សោយសុខខ្លះ ទុក្ខខ្លះក្នុងកាម-ភពនោះ តើមានចិត្តចំនួនប៉ុន្មាន? ចិត្តទី ២ រូបាវចរចិត្ត ជាចិត្តលុះទៅក្នុង អំណាចនៃរូបតណ្ហាដឹកនាំឲ្យត្រាច់ទៅដោយច្រើន សោយសុខក្នុងរូប-ភពនោះ តើមានចិត្តចំនួនប៉ុន្មាន? ចិត្តទី ៣ អរូបាវចរចិត្ត ជាចិត្តលុះទៅ ក្នុងអំណាចនៃអរូបតណ្ហាដឹកនាំឲ្យត្រាច់ទៅដោយច្រើន សោយសុខក្នុង អរូបភពនោះ តើមានចិត្តចំនួនប៉ុន្មាន? ចិត្តទី ៤ លោកុត្តរចិត្ត ជាចិត្ត ធ្វងផុតចាកលោកទាំង ៣ នោះ តើមានចិត្តចំនួនប៉ុន្មាន? បូករួមចិត្តទាំង ៤

ដោយសង្ខេប តើមានចិត្តប៉ុន្មាន? បើដោយពិស្តារតើមានចិត្តចំនួនប៉ុន្មាន? ចូរលោកវិសជ្ជនារៀបរាប់ចំនួនចិត្តឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថាបពិត្រធម្មវាទី កាមាវចរចិត្តទី ១ នោះមានចិត្តចំនួន ៥៤ ដួង, រូបាវចរចិត្តទី ២ នោះ មានចិត្តចំនួន ១៥ ដួង, អរូបាវចរចិត្តទី ៣ នោះ មានចិត្តចំនួន ១២ ដួង, លោកុត្តរចិត្តទី ៤ នោះ មានចិត្តចំនួន ៨ ដួង ដោយសង្ខេប, បើដោយពិស្តារមានចិត្តចំនួន ៤០ ដួងគត់ បូករួមចិត្តទាំង ៤ យ៉ាងនោះដោយសង្ខេបមានចិត្តចំនួន ៨៩ ដួង, បើសម្តែងដោយពិស្តារមានចិត្តចំនួន ១២១ ដួងគត់ ខ្ញុំអត្ថវាទី បានវិសជ្ជនារៀបរាប់ចំនួនទាំង ៤ យ៉ាងមកតែត្រឹមប៉ុណ្ណោះឯង ។

៣១- ធម្មវាទី សួរទៀតថា ប្រស្នាដែលលោកវិសជ្ជនារៀបរាប់ចំនួនចិត្តមកនេះត្រឹមត្រូវពិតហើយ ចុះកាមាវចរចិត្ត ៥៤ ដួង, ខាងដើមនោះ ចែកជាអកុសលចិត្តប៉ុន្មាន? ជាអហេតុកចិត្តប៉ុន្មាន? ជាសហេតុកកាមាវចរចិត្តប៉ុន្មាន? ចូរលោកវិសជ្ជនារៀបរាប់មកមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី កាមាវចរចិត្តទី ១ ខាងដើមនោះ ចែកជាអកុសលចិត្ត ១២ ជាអហេតុកចិត្ត ១៨ ជាសហេតុកចិត្ត ២៤

ត្រូវជាកាមាវចរចិត្ត ៥៤ ដោយពិត ។

៣២- ធម្មវាទី បានស្តាប់ហើយសួរបញ្ជាក់ទៀតថា ម្នាលអត្ថវាទី ចុះពាក្យថា អកុសលចិត្តៗ នោះ តើសេចក្តីអធិប្បាយដូចម្តេច? ពាក្យថា អហេតុកចិត្តៗ នោះ សេចក្តីអធិប្បាយដូចម្តេច? ពាក្យថា សហេតុកកាមាវចរចិត្តៗ នោះ សេចក្តីអធិប្បាយដូចម្តេច?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអកុសលចិត្តនោះ សេចក្តីអធិប្បាយក្នុងបរមត្ថព្រះអភិធម្ម លោកសម្តែងពន្យល់ថាចិត្តរបស់បុគ្គលទាំងឡាយឯណា កើតឡើងឥតពន្លឺរស្មីសោះអាប់ឥតបញ្ញាមិនចៀវឆ្លាសវាងវៃពិចារណាកាន់ប្រឡំក្នុងអារម្មណ៍ទាំងឡាយ ដែលជាគុណមានផលប្រយោជន៍ក្នុងលោកនេះនិងលោកខាងមុខ ពិចារណាយល់ឃើញខុសថា ឥតគុណ ឥតផលប្រយោជន៍ទៅវិញ មិនខំព្យាយាមប្រឹងប្រែងធ្វើឲ្យកើតផលឡើងក្នុងសន្តានខ្លួន អារម្មណ៍ទាំងឡាយដែលជាទោសឥតផលប្រយោជន៍សោះក្នុងលោកនេះនិងលោកខាងមុខ ពិចារណាយល់ឃើញខុសថា មានគុណមានផលប្រយោជន៍ទៅវិញ ហើយខំព្យាយាមប្រឹងប្រែងប្រព្រឹត្តធ្វើអំពើខុសនោះពុំដាច់មានកម្មារម្មណ៍ អារម្មណ៍គឺអំពើបៀតបៀនសម្លាប់សត្វលួចទ្រព្យគេ ប្រព្រឹត្តក្បត់ក្នុងប្រពន្ធកូនចៅគេ

ជាដើម ដែលជាអំពើឥតប្រយោជន៍ប្រកបដោយទោសផ្សេងៗ ក្នុងលោកនេះនិងលោកខាងមុខ ដោយចំណែកមួយ ព្រោះគ្មានសទ្ធា សតិ បញ្ញា ជាគ្រឿងដាស់តឿនខ្លួន ជាបុគ្គលវង្វេងកាន់ច្រឡំក្នុងអារម្មណ៍ ខំព្យាយាមធ្វើទៅតាមអំណាចនៃកាមតណ្ហាដឹកនាំជំរុលទៅក្នុងកាមគុណទាំង ៥ ឥតមានស្រាកស្រាន្តសោះ ចិត្តរបស់បុគ្គលទាំងឡាយនោះឯងបានឈ្មោះថាអកុសលចិត្តដោយពិត ។ ឯពាក្យថាអហេតុកចិត្តនោះ សេចក្តីអធិប្បាយក្នុងគម្ពីរអដ្ឋសាលិនីអដ្ឋកថាអភិធម្មសង្គណី លោកពន្យល់ថាចិត្តឯណាឥតហេតុ មិនអាចនឹងញុំាងគុណវិសេសមានឈានសមាបត្តិជាដើមឲ្យកើតឡើងបានឡើយ គ្រាន់តែនឹកស្រាវជ្រាវរាវរកអារម្មណ៍ ឃើញអារម្មណ៍ ទទួលចាប់យកអារម្មណ៍ ពិចារណាកំណត់អារម្មណ៍បានត្រឹមវីថិចិត្តទី ៤ ហើយរលត់បាត់ទៅវិញ ធ្លាក់ចុះមកកាន់ឧបេក្ខាវេទនាវិញដដែល ពុំច្បាស់លាស់ថាជាកុសលឬជាអកុសលពេញទីនោះឡើយ ព្រោះកុសលនិងអកុសលដែលនឹងកើតឡើងច្បាស់លាស់ តែក្នុងវេជ្ជពូនវីថិចិត្តទី ៥ ប៉ុណ្ណោះ ចិត្តនោះឯងបានឈ្មោះថាអហេតុកចិត្តដោយពិត ។ ឯសហេតុកកាមាវចរចិត្តនោះ លោកសំដៅយកចិត្តដែលរុងរឿងឆ្លៀវឆ្លាសវាងវៃ ស្គាល់ខុសត្រូវ គុណទោស បុណ្យបាប ប្រកបដោយ

ហេតុ មានអលោភចិត្ត គឺចិត្តមិនលោភហួសប្រមាណជាដើម អាចលះបង់សេចក្តីកំណាញ់ កាត់អាល័យបរិច្ចាគទ្រព្យឲ្យទានដល់បុគ្គលដទៃបាន កើតជាកុសល ជាវិបាក ជាកិរិយា និងបានអន្ទោលទៅមកសោយសុខក្នុងកាមសុគតិភូមិទាំង ៧ ជាន់ដោយច្រើន ចិត្តនោះឯងបានឈ្មោះថាសហេតុកកាមាវចរចិត្តដោយពិត ។ ខ្ញុំអត្តវាទីអធិប្បាយឈ្មោះចិត្តទាំង ៣ យ៉ាងមកដោយសង្ខេបតែប៉ុណ្ណេះឯង ។

៣៣- ធម្មវាទី បានស្តាប់ហើយ ពោលថា អើអត្តវាទី លោកវិសជ្ជនាមកនេះ យើងស្តាប់បានហើយ តែយើងនឹងសួរតទៅទៀតចុះចិត្តដែលប្រកបដោយហេតុៗ នោះមានចំនួនប៉ុន្មាន ? គឺហេតុអ្វីខ្លះ ? ចូរលោករាប់ចំនួនហេតុព្រមទាំងសេចក្តីអធិប្បាយ ឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ចិត្តដែលប្រកបដោយហេតុនោះ មាន ៦ គឺ លោភៈ ១ ទោសៈ ១ មោហៈ ១ ទាំង ៣ នេះជាអកុសលហេតុ ព្រោះចិត្តដែលសម្បយោគប្រកបព្រមដោយលោភៈចង់បាន កំណាញ់ស្វិតស្វាញ ចំពាក់ជាប់នៅក្នុងទ្រព្យសម្បត្តិទាំងពួងក្តី ទោសៈ ក្រោធខឹង កាចសាហាវឬប្រទូស្តសត្វនិងសង្ខារទាំងពួងក្តី

មោហៈ វង្វេងភាន់ច្រឡំក្នុងអារម្មណ៍ សម្គាល់ខុស ឥដ្ឋារម្មណ៍ថាជាអនិដ្ឋារម្មណ៍ក្ដី ជាហេតុបណ្ដាលឲ្យកើតឡើងជាអកុសលផលបាបដោយពិត ។ អលោភៈ ១ អទោសៈ ១ អមោហៈ ១ ទាំង ៣ នេះ ជាកុសលហេតុ ព្រោះចិត្តដែលសម្បយោគប្រកបព្រមដោយអលោភៈ មិនកំណាញ់ស្វិតស្វាញ ចំពាក់ជាប់នៅក្នុងទ្រព្យសម្បត្តិទាំងពួងក្ដី អទោសៈ មិនក្រោធខឹង កាចសាហាវ មិនប្រទូស្តសត្វនិងសង្ខារទាំងពួងក្ដី អមោហៈ មិនវង្វេងភាន់ច្រឡំក្នុងអារម្មណ៍ សម្គាល់ត្រូវ ឥដ្ឋារម្មណ៍ ថាជាឥដ្ឋារម្មណ៍ អនិដ្ឋារម្មណ៍ ថាជាអនិដ្ឋារម្មណ៍តាមសភាពពិតក្ដី ជាហេតុបណ្ដាលឲ្យកើតឡើងជាកុសលផលបុណ្យដោយពិត ។ ខ្ញុំអត្តវាទី បានវិសជ្ជនាហេតុ ៦ យ៉ាងព្រមទាំងសេចក្ដីអធិប្បាយមកដោយសង្ខេបតែប៉ុណ្ណោះឯង ។

៣៤- ធម្មវាទី ពោលថា ម្នាលអត្តវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះ មានសេចក្ដីចំពាក់ទាក់ទាមគ្នាគួរឲ្យសង្ស័យតទៅទៀត ដូចត្រង់កុសលចិត្តទាំង ២១ សម្បយោគប្រកបព្រមដោយហេតុឲ្យឈ្មោះថា សហេតុកកាមាវចរចិត្ត ត្រង់អកុសលចិត្តទាំង ១២ សម្បយោគប្រកបព្រមដោយហេតុដែរ ដូចម្ដេចក៏ពុំឲ្យឈ្មោះថា សហេតុកកាមាវចរចិត្តផង? បើពុំឲ្យឈ្មោះថាសហេតុកកាមាវចរចិត្តទេ តើព្រះសម្មាសម្ពុទ្ធ

ជាម្ចាស់ទ្រង់កំណត់ឲ្យឈ្មោះផ្សេងគ្នាដូចម្ដេចខ្លះ? សេចក្ដីអធិប្បាយយ៉ាងណា? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មក យើងនឹងបានស្ដាប់ចូលចិត្តជឿផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯកុសលចិត្តទាំង ២១ នោះសម្បយោគប្រកបព្រមដោយ អលោភៈ អទោសៈ អមោហៈ គឺសេចក្ដីមិនលោភហួសប្រមាណផង មិនក្រោធខឹងប្រទូស្តសត្វនិងសង្ខារផង មិនវង្វេងភាន់ច្រឡំក្នុងអារម្មណ៍ផង មានបញ្ញាឆ្លៀវឆ្លាសវាងវៃស្គាល់ខុសត្រូវ គុណទោសជាដើម ដូចមានសេចក្ដីអធិប្បាយតទៅនេះ ។ ទី ១ កុសលចិត្តរបស់បុគ្គលដែលជាសម្មាទិដ្ឋិ ពិចារណាយល់ឃើញត្រូវដឹងច្បាស់ស្គាល់ច្បាស់នូវទោសនៃលោភៈ សេចក្ដីលោភហួសប្រមាណប្រព្រឹត្តកំណាញ់លាក់បាំងទ្រព្យរបស់ខ្លួនទុក ពុំបានបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទាន ថាជាសភាវៈ ដឹកនាំសត្វទាំងឡាយទៅកាន់អបាយភូមិ ៤ ដោយពិត ហើយខំព្យាយាមលះបង់សេចក្ដីលោភ បន្ថយកម្លាំងសេចក្ដីលោភឲ្យថយចុះតិចទៅ ខំព្យាយាមចម្រើនអលោភៈ សេចក្ដីមិនលោភមិនប្រព្រឹត្តកំណាញ់ បរិច្ចាគទ្រព្យរបស់ខ្លួនធ្វើបុណ្យឲ្យទាន ញុំាងបុណ្យឲ្យកើតមានច្រើនឡើងក្នុងសន្តានខ្លួន ។ ទី ២ ដឹងច្បាស់ស្គាល់

ច្បាស់នូវទោសនៃទោសៈ សេចក្ដីក្រោធខឹង ប្រទូស្ដសត្វនិងសង្ខារទាំង-ឡាយថាជាសភាវៈដឹកនាំសត្វទាំងឡាយទៅកាន់អបាយភូមិ ៤ ដោយពិត ហើយខំព្យាយាមលះបង់ទោសៈ បន្ថយកម្លាំងទោសៈ ឲ្យថយចុះតិចទៅ ខំព្យាយាមចម្រើនអទោសៈ សេចក្ដីមិនក្រោធខឹងប្រទូស្ដសត្វនិងសង្ខារ តាំងចិត្តសុចរិតប្រព្រឹត្តរក្សាសីល ៥ សីលឧបោសថដែលប្រកបព្រម ដោយអង្គទាំង ៨ ញ៉ាំងបុញ្ញរាសីឲ្យកើតមានច្រើនឡើងក្នុងសន្ដានខ្លួន ។ ទី ៣ ដឹងច្បាស់ស្គាល់ច្បាស់នូវទោសនៃមោហៈ សេចក្ដីវង្វេងកាន់ច្រឡំ ឥដ្ឋារម្មណ៍ ដែលជាអារម្មណ៍ គួរគប្បីប្រាថ្នាត្រេកអរពិត ថាជាអនិដ្ឋា-រម្មណ៍ គឺជាអារម្មណ៍មិនគួរគប្បីប្រាថ្នាត្រេកអរទៅវិញ គឺថាកាន់យក អារម្មណ៍ដែលគួរគប្បីត្រេកអរប្រព្រឹត្តធ្វើ ថាជាអារម្មណ៍មិនគួរគប្បីត្រេក-អរប្រព្រឹត្តធ្វើទៅវិញ ដឹងច្បាស់ថាការដែលកាន់ច្រឡំអារម្មណ៍ យ៉ាងនេះ ជាសភាវៈដឹកនាំសត្វទាំងឡាយទៅកាន់អបាយភូមិ ៤ ដោយពិត ហើយ ខំព្យាយាមលះបង់មោហៈបន្ថយកម្លាំងមោហៈ ឲ្យថយចុះតិចទៅ ខំព្យា-យាមប្រឹងប្រែងរៀនសូត្រចម្រើនអមោហៈ សេចក្ដីមិនវង្វេងកាន់ច្រឡំអា-រម្មណ៍ ឲ្យបានចេះដឹងពិតតាំងចិត្តចម្រើនភាវនាកុសលផលបុណ្យឲ្យកើត មានច្រើនឡើងក្នុងសន្ដានខ្លួន ។ កំចិត្តដែលសម្បយោគប្រកបព្រមដោយ

កុសលហេតុទាំង ៣ យ៉ាងដូចបានអធិប្បាយមកនេះ ជាចិត្តមានកម្លាំងឲ្យផលប្រកបដោយហេតុ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឲ្យឈ្មោះថា សហេតុកកាមាវចរចិត្តដោយពិត ។ ឯអកុសលចិត្តទាំង ១២ នោះសម្ប្រ-យោគប្រកបព្រមដោយ លោភៈ ទោសៈ មោហៈ គឺសេចក្តីលោភហួសប្រមាណផង ក្រោធខឹងប្រទូស្តច្រើនផង វង្វេងភាន់ច្រឡំអារម្មណ៍ផង មិនមានបញ្ញាឆ្លៀវឆ្លាសវាងវៃ មិនស្គាល់ខុសត្រូវ គុណទោសជាដើម ជាមិច្ឆាទិដ្ឋិ ពិចារណាយល់ឃើញខុសថា អលោភៈ សេចក្តីដែលមិនលោភចង់បានលាក់ទ្រព្យទុក មិនកំណាញ់ ហើយបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទាននេះជាការឥតប្រយោជន៍ យល់ឃើញខុសថា អទោសៈ សេចក្តីដែលមិនក្រោធខឹងមិនប្រទូស្តសត្វនិងសង្ខារ ហើយខំតាំងចិត្តរក្សាសីលនេះជាការឥតប្រយោជន៍ យល់ឃើញខុសថា អមោហៈ សេចក្តីដែលមិនវង្វេងភាន់ច្រឡំប្រកាន់មាំថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឬទាន សីល ភាវនាជាដើម ដែលថាជាឥដ្ឋារម្មណ៍ ជាអារម្មណ៍ គឺបុគ្គលគប្បីប្រាថ្នាត្រេកអរស្រឡាញ់គាប់ចិត្តប្រព្រឹត្តធ្វើ ហើយថាបានបុណ្យបានប្រ-យោជន៍នោះពុំពិតទេ ជាពាក្យគេបញ្ឆោតដល់មនុស្សល្ងង់ខ្លៅទាំងឡាយឲ្យយកប្រយោជន៍ទៅឲ្យគេប៉ុណ្ណោះទេ ចិត្តគំនិតរបស់បុគ្គលដែលយល់

ឃើញខុស គំនិតច្រើនដូចអធិប្បាយដោយសង្ខេបមកខាងលើនេះបាន ឈ្មោះថា ចិត្តប្រកបព្រមដោយលោភៈ ទោសៈ មោហៈ គ្របសង្កត់បំបាត់ គំនិតល្អ ហើយញុំាងគំនិតអាក្រក់លាមកឲ្យកើតឡើង ប្រព្រឹត្តធ្វើនូវអំពើ ទុច្ចរិតមានសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តក្បត់ក្នុងប្រពន្ធកូនគេជាដើម ពេញទីឥតកោតញញើតឡើយ ។ ក៏អកុសលចិត្តទាំង១២នេះ អកុសលចិត្ត ១០ គឺលោភចិត្ត ៨ ទោសចិត្ត ២ ជាទុហេតុកៈ ប្រកបដោយ ហេតុពីរ គឺលោភៈ ១ ទោសៈ ១, មោហចិត្ត ២ ជាឯកហេតុកៈ ប្រកបដោយ ហេតុ ១ គឺ មោហៈ ទោះបីប្រកបដោយហេតុយ៉ាងនេះក៏ដោយ គង់ព្រះ សម្មាសម្ពុទ្ធព្រះអង្គពុំបានឲ្យឈ្មោះថា សហេតុកកាមាវចរចិត្តឡើយ ព្រះ អង្គទ្រង់ឲ្យឈ្មោះថា អសោភណចិត្ត ជាចិត្តមិនរុងរឿងល្អសោះឡើយ ព្រោះអកុសលចិត្តទាំងនោះមានកម្លាំងខ្សោយ ឲ្យផលមិនប្រកបដោយ ហេតុជាអហេតុកវិបាកចិត្តពិត ។ ឯកុសលចិត្តទាំងឡាយដែលប្រកបដោយ ត្រៃហេតុក្តី ទុហេតុក្តី ព្រះអង្គឲ្យឈ្មោះថាសហេតុកកាមាវចរចិត្តផង ឲ្យឈ្មោះថាសោភណចិត្ត ជាចិត្តដ៏រុងរឿងល្អផង ព្រោះកុសលចិត្ត ទាំងឡាយមានកម្លាំងខ្លាំង អាចឲ្យផលប្រកបដោយហេតុជាសហេតុកវិបាកចិត្តដោយពិត ។ បពិត្រធម្មវាទី ខ្ញុំព្រះករុណាបានអធិប្បាយអំពី

កាមាវចរចិត្ត ដែលបានចំណែកចែកជាកុសលចិត្តផង អកុសលចិត្តផង ប្រកបដោយហេតុនិងមិនប្រកបដោយហេតុផង ដែលមានឈ្មោះនិងសេចក្ដីអធិប្បាយផ្សេងៗ គ្នាដោយសង្ខេបមកតែប៉ុណ្ណោះសូមជ្រាប ។

៣៥- ធម្មវាទី ពោលថា សាធុៗ ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃហើយ តែយើងនឹងសួរលោកតទៅទៀត ។ ចុះអង្គសម្ដេចព្រះសយម្ភុញាណជាម្ចាស់ ទ្រង់ត្រាស់សម្ដែងអំពីចិត្តដែលជាធម្មជាត ដ៏ល្អិត ឥតរូប អាចត្រាច់ទៅធាប់រហ័សកាន់អារម្មណ៍ផ្សេងៗ មិនមានទើសទាក់ ហើយព្រះអង្គទ្រង់ជ្រាបច្បាស់នូវវារៈចិត្តរបស់សត្វទាំង-ឡាយ តើព្រះអង្គទ្រង់កំណត់វារៈចិត្ត ឲ្យឈ្មោះថា អសោភណចិត្ត មានចំនួនប៉ុន្មាន? កំណត់វារៈចិត្តឲ្យឈ្មោះថាសោភណចិត្តដោយសង្ខេប មានចំនួនប៉ុន្មាន? ដោយពិស្ដារមានចំនួនប៉ុន្មាន? គឺពួកចិត្តអ្វីខ្លះ?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះសម្មាសម្ពុទ្ធព្រះអង្គទ្រង់ពិចារណាជ្រាបច្បាស់នូវវារៈចិត្តនៃសត្វទាំងឡាយ ហើយព្រះអង្គទ្រង់កំណត់វារៈចិត្តទាំង ៣០ គត់ ដែលជាចិត្តអាប់ឥតពន្លឺរស្មី ឥតមានសេចក្ដីរុងរឿង បញ្ញាចេតសិកប្រកបកើតរលត់ព្រមជាមួយផងពុំបាន គឺអកុសលចិត្ត ១២ អហេតុកចិត្ត ១៨ ជាចិត្តមិនប្រកបដោយហេតុ ព្រះ

អង្គឲ្យឈ្មោះថាអសោភណចិត្តមានចំនួន ៣០ គត់ ជាចិត្តឥតពន្លឺរស្មីមិនមានសេចក្តីរុងរឿងល្អឡើយ ហើយព្រះអង្គទ្រង់កំណត់វារៈចិត្តដែលរុងរឿងល្អយ៉ាងសង្ខេបមានចំនួន ៥៩ គឺកាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៧ គឺរូបាវចរចិត្ត ១៥ អរូបាវចរចិត្ត ១២ និងលោកុត្តរចិត្ត ៨ ត្រូវជា ៥៩ គត់ ។ បើដោយពិស្តារព្រះអង្គទ្រង់យកលោកុត្តរចិត្តទាំង ៨ ចែកជាប្រាំ ៗ តាមប្រភេទនៃឈានទាំង ៥ គឺមគ្គចិត្ត ២០ ផលចិត្ត ២០ ត្រូវជា ៤០ គត់ ផ្សំគ្នាទាំងអស់បានចំនួន ៩១ ហើយព្រះអង្គឲ្យឈ្មោះថា សោភណចិត្ត មានចំនួន ៩១ គត់ ជាចិត្តប្រកបដោយហេតុ មានពន្លឺរស្មីរុងរឿងល្អដោយពិត ។ បពិត្រធម្មវាទី ខ្ញុំព្រះករុណាបានវិសជ្ជនារៀបរាប់អំពីអសោភណចិត្តនិងសោភណចិត្តដោយសេចក្តីសង្ខេបមកតែប៉ុណ្ណោះឯង ។

៣៦- ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា ចុះអសោភណចិត្តទាំង ៣០ នោះ បើវៀរលែងអសោភណចិត្ត ១២ ដែលប្រកបដោយហេតុនោះចេញ ហើយយកតែអសោភណចិត្ត ១៨ ដែលមិនប្រកបដោយហេតុនោះ មកចែកជាអកុសលវិបាកអហេតុកចិត្តមានប៉ុន្មាន? ជាកុសលវិបាកអហេតុកចិត្តមានប៉ុន្មាន? ជាអហេតុកកិរិយាចិត្តមានប៉ុន្មាន?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអសោភណចិត្តទាំង

១៨ ដែលមិនប្រកបដោយហេតុនោះ ចែកជាអកុសលវិបាកអហេតុកចិត្ត ៧ ជាកុសលវិបាកអហេតុកចិត្ត ៨ ជាអហេតុកកិរិយាចិត្ត ៣ រួមទាំងអស់ត្រូវជាអសោភណចិត្ត ១៨ គត់ ។ បពិត្រព្រះធម្មវាទី ខ្ញុំព្រះករុណាបានវិសជ្ជនារាប់ចំនួនអសោភណចិត្ត ដែលចែកទៅតាមពួកតាមក្រុមផ្សេងៗ គ្នាដោយសង្ខេបតែប៉ុណ្ណេះឯង ។

៣៧- ធម្មវាទី បានស្តាប់ហើយសួរសេចក្តីអធិប្បាយតទៅទៀតថា ម្នាលអត្តវាទី ចុះអកុសលវិបាកអហេតុកចិត្តទាំង ៧ នោះគឺចិត្តអ្វីខ្លះ? អធិប្បាយដូចម្តេច? សូមលោកសម្តែងសេចក្តីអធិប្បាយឲ្យពិស្តារសព្វគ្រប់មក យើងនឹងស្តាប់ចូលចិត្តបានដោយងាយផងមើល ។

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះអរហំសម្មាសម្ពុទ្ធព្រះអង្គទ្រង់សម្តែងអំពីអកុសលវិបាកអហេតុកចិត្តទាំង ៧ នោះជាសុខុមភាព ជំល្អិតជ្រាលជ្រៅពន់ពេកណាស់ ដូចមានសេចក្តីអធិប្បាយតទៅនេះ, ទី ១- ឧបេក្ខាសហគតចក្ខុវិញ្ញាណ សេចក្តីអធិប្បាយថា អនិដ្ឋារម្មណ៍ជាអារម្មណ៍មិនជាទីប្រាថ្នាគឺរូបដែលអ្នកប្រាជ្ញទាំងឡាយ លោកមិនប្រាថ្នាមិនស្រឡាញ់គាប់ចិត្ត លោកតែងលះបង់វៀរលែង គេចវេះចេញជាធម្មតា ទោះឧបាទិន្នករូប គឺរូបដែលមានវិញ្ញាណ មានរូបមនុស្សប្រុស

ស្ត្រីនិងរូបសត្វតូចធំជាដើមក្តី និងអនុបាទិន្នករូបដែលមិនមានវិញ្ញាណមាន សំពត់អាវមាសប្រាក់គ្រឿងប្រើប្រាស់ទាំងពួងជាដើមក្តី រូបារម្មណ៍ទាំង នោះចូលមកកាន់រង្វង់ភ្នែកក្នុងចក្ខុទ្វារប៉ះទង្គិចនឹងចក្ខុប្បសាទ ចក្ខុវិញ្ញាណ ដែលអាស្រ័យនៅក្នុងភ្នែក កើតឡើងអំពីចំហាយនៃអហេតុកកិរិយាមនោ-ធាតុដាស់តឿន កើតឡើងមួយខណៈចិត្តធំ ជា ៣ ខណៈចិត្តតូចគឺ ឧប្បាទ វីថិចិត្តកើតឡើងតាមភវង្គទ្វារឬឋាមនោទ្វារវិញក៏បាន ឋិតិប៉ះពាល់នូវរូបា-រម្មណ៍ដែលស្ថិតនឹងនៅក្នុងរង្វង់ចក្ខុទ្វារយ៉ាងរហ័ស, ភង្គៈកើតឡើងហើយ បែករលត់ចេញអំពីរូបារម្មណ៍នោះធ្លាក់ចុះមកកាន់ទ្វារភវង្គវិញ ៣ ខណៈ ចិត្តតូចនេះហៅថា ១ ខណៈចិត្តធំ ទើបបានឈ្មោះថា ឧបេក្ខាសហគត-ចក្ខុវិញ្ញាណ វីថិចិត្តអាចញ៉ាំងទស្សនកិច្ច គឺកិច្ចដែលឃើញដឹងថា រូបា-រម្មណ៍ឲ្យសម្រេចបាន កើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវ រសនៃរូបារម្មណ៍ និងនៅក្នុងអនិដ្ឋារម្មណ៍ ជាកណ្តាលមិនកគ្រើក កាល បើចក្ខុវិញ្ញាណកើតឡើងហើយ រលត់ទៅវិញយ៉ាងនេះហើយ សម្ប-ដិច្ឆន្នចិត្តក៏កើតឡើងបន្ទាប់អំពីចក្ខុវិញ្ញាណនោះ អំពីចំហាយនៃអហេតុ-កវិបាកមនោធាតុដាស់តឿន ហើយទទួលចាប់យកនូវរូបារម្មណ៍នោះ បានមួយខណៈចិត្តធំ ៣ ខណៈចិត្តតូចដូចគ្នា ទើបបានឈ្មោះថា

ឧបេក្ខាសហគតសម្បដិច្ឆន្នចិត្ត វីថិចិត្ត អាចញុំាំងសម្បដិច្ឆន្នកិច្ច គឺកិច្ចដែលទទួលចាប់ព្រមនូវរូបារម្មណ៍ឲ្យសម្រេចបាន កើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃរូបារម្មណ៍ និងនៅក្នុងអនិដ្ឋារម្មណ៍ជាកណ្តាលមិនកក្រើក កាលបើសម្បដិច្ឆន្នចិត្តកើតឡើងហើយ រលត់ទៅវិញយ៉ាងនេះហើយ សន្តីរណចិត្តក៏កើតឡើងជាបន្ទាប់អំពីសម្បដិច្ឆន្នចិត្តនោះ អំពីចំហាយនៃអហេតុកវិបាកមនោវិញ្ញាណធាតុ ដាស់តឿនហើយពិចារណាកំណត់នូវរូបារម្មណ៍នោះបានមួយខណៈចិត្តធំ ៣ ខណៈចិត្តតូចទៀតដូចគ្នា ទើបបានឈ្មោះថា ឧបេក្ខាសហគតសន្តីរណចិត្ត វីថិចិត្ត អាចញុំាំងសន្តីរណកិច្ច គឺកិច្ចដែលពិចារណាកំណត់នូវរូបារម្មណ៍ឲ្យសម្រេចបាន កើតរលត់ព្រមជាមួយឧបេក្ខាវេទនាសោយរសនៃរូបារម្មណ៍ នឹងនៅក្នុងអនិដ្ឋារម្មណ៍ជាកណ្តាលមិនកក្រើក កាលបើសន្តីរណចិត្តកើតឡើងហើយ រលត់ទៅវិញយ៉ាងនេះហើយ វោដ្ឋព្វនចិត្តក៏កើតឡើង វីថិចិត្តទី ៥ នេះ កើតឡើងជាបន្ទាប់អំពីសន្តីរណចិត្តនោះតវ៉ៃត្រវង្គមកអំពីចំហាយនៃកិរិយាមនោវិញ្ញាណធាតុដាស់តឿន ហើយកំណត់នូវរូបារម្មណ៍នោះដដែល បើវីថិចិត្តនេះកំណត់អារម្មណ៍ទុកក្នុងចិត្តខុស ជាអនិដ្ឋារម្មណ៍មិនត្រូវតាមឧបាយនៃប្រាជ្ញាទេ ក៏កើតឡើង

ជាអកុសលផលបាបពេញទី បើវិថិចិត្តនេះកំណត់អារម្មណ៍ទុកក្នុងចិត្ត ជាឥដ្ឋារម្មណ៍ត្រូវតាមឧបាយនៃប្រាជ្ញាប្រាកដ កំកើតឡើងជាកុសលផលបុណ្យពេញទី កំវិថិចិត្តដែលកំណត់នូវអារម្មណ៍យ៉ាងនេះ ទើបបានឈ្មោះថា វោដ្ឋព្វនចិត្ត វិថិចិត្ត អាចញ៉ាំងវោដ្ឋព្វនកិច្ច គឺកិច្ចដែលត្រូវធ្វើកំណត់អារម្មណ៍ ទុកក្នុងចិត្តឲ្យសម្រេចបាន បើកំណត់ខុសមិនត្រូវតាមឧបាយនៃបញ្ញាជាអនិដ្ឋារម្មណ៍ ហើយរលត់ចុះមកកាន់មនោទ្វារវិញ បណ្តាអកុសលចិត្តទាំង ១២ នោះ អកុសលចិត្តណាមួយកើតឡើងជាអកុសលជវនទទួលសោយនូវរសនៃអនិដ្ឋារម្មណ៍ ដែលវោដ្ឋព្វនចិត្តកំណត់ទុកហើយនោះ រីអកុសលជវននេះ ដែលនឹងសោយនូវរសនៃអារម្មណ៍នោះសោត កំសោយតែតាមកម្លាំងនៃអារម្មណ៍ជាលំដាប់ បើអារម្មណ៍មានកម្លាំងខ្លាំងពេក អកុសលជវនសោយរសនៃអារម្មណ៍អស់វារៈ ៧ ដងយ៉ាងច្រើន បាបកំធ្ងន់ខ្លាំង បើអារម្មណ៍មានកម្លាំងល្មមទេ អកុសលជវនសោយរសនៃអារម្មណ៍អស់វារៈ ៥ ឬ ៦ ដង បាបកំធ្ងន់ល្មមដែរ បើអារម្មណ៍មានកម្លាំងខ្សោយតិចចុះមកជាលំដាប់ អកុសលជវនសោយរសនៃអារម្មណ៍អស់វារៈ ៤ ៣ ២ ១ ដង បាបកំតិចចុះមកជាលំដាប់ៗ ដែរ ទើបបានឈ្មោះថា កាមាវចរអកុសលជវនចិត្ត វិថិចិត្ត

អាចញ៉ាំងជវនកិច្ច គឺកិច្ចដែលសោយនូវរសនៃរូបារម្មណ៍ ឲ្យសម្រេចបាន ហើយរលត់ព្រមជាមួយឧបេក្ខាវេទនា សោយរសនៃរូបារម្មណ៍និងនៅក្នុងអនិដ្ឋារម្មណ៍ ជាកណ្តាលមិនកក្រើក ។ កាលបើអកុសលជវនកើតឡើងហើយរលត់ទៅវិញ យ៉ាងនេះហើយ អហេតុកសន្តីរណចិត្តកើតឡើងពិចារណាកំណត់យកនូវរសនៃរូបារម្មណ៍ ដែលអកុសលជវនសោយនោះ មកជាអារម្មណ៍ជាប់នៅក្នុងសន្តានខ្លួន បានឈ្មោះថា តទាលម្ពណអហេតុកអកុសលវិបាកចិត្ត តែម្យ៉ាងពិត ព្រោះសម្តេចព្រះសក្យមុនីជាម្ចាស់ ទ្រង់ត្រាស់សម្តែងថា អកុសលធម៌ទាំងឡាយគឺអកុសលចិត្ត ១២ ក្តី អកុសលចេតសិកទាំង ១៤ ក្តី ជាសភាវៈមានកម្លាំងខ្សោយ មានអានុភាពតិចពន់ពេកណាស់ ពុំអាចធ្វើនូវលោកុត្តរធម៌ឲ្យជាអារម្មណ៍បានឡើយ ទោះបីប្រកបដោយទុហេតុឯកហេតុក៏ដោយ គង់ពុំអាចឲ្យផលជាសហេតុកកាមាវចរវិបាកចិត្តបានឡើយ នឹងឲ្យផលជាអហេតុកអកុសលវិបាកចិត្ត គឺឧបេក្ខាសហគតសន្តីរណចិត្ត ជាតួតទាលម្ពណអកុសលវិបាក ជាពូជបដិសន្ធិប្រព្រឹត្តទៅក្នុងអបាយភូមិ ៤ តែប៉ុណ្ណោះ ។

អធិប្បាយអំពីអហេតុកអកុសលវិបាកចិត្ត : ទី១ គឺចក្ខុវិញ្ញាណកើតឡើង

ហើយរលត់ទៅ សម្បដិច្ឆន្នចិត្តកើតឡើងក្នុងលំដាប់នៃចក្ខុវិញ្ញាណនោះ ហើយរលត់ទៅ ទើបសន្តីរណចិត្តកើតឡើងបន្ទាប់គ្នាហើយរលត់ទៅវិញ ហៅថាគណនូបគ្គចិត្ត ជាចិត្តកើតឡើងរលត់ទៅ តាមពួក តាមក្រុមរបស់ ខ្លួន តែងកើតជាអហេតុកវិបាកចិត្ត៣ៗ ដូច្នេះឯង ។ ឯអហេតុកវិបាកចិត្ត ទី២ ៣ ៤ ៥ ក៏កើតឡើងនិងរលត់ទៅវិញ ប្រកបដោយអហេតុកវិបាក-ចិត្ត ៣ៗ ដូចគ្នាទាំងអស់ ។ ម៉្យាងទៀតអកុសលវិបាកអហេតុកចិត្ត ដែលជា ចិត្តមិនប្រកបដោយហេតុជាផលរបស់អកុសលចិត្តនេះ បើរាប់តាមឈ្មោះ នោះមាន ៧ រាប់តាមពួក តាមក្រុមរបស់វីថិចិត្តមាន ១៥ គត់ តែថា ត្រង់ អហេតុកវិបាកចិត្តទី២ ៣ ៤ ៥ មានសេចក្តីប្លែកគ្នាខ្លះដែរ ព្រោះសោត-វិញ្ញាណទី២ វិញ្ញាណដែលអាស្រ័យនៅក្នុងសោតទ្វារ សម្រាប់ស្តាប់នូវ សំឡេងផ្សេងៗ ដែលជាអនិដ្ឋារម្មណ៍មានសំឡេងភ្លេងមហោស្រពនិង សំឡេងចម្រៀងជាដើម ឃានវិញ្ញាណទី៣ វិញ្ញាណដែលអាស្រ័យនៅ ក្នុងឃានទ្វារសម្រាប់ថើបហិតស្រង់ដឹងនូវក្លិនផ្សេងៗ ដែលជាអនិដ្ឋារម្មណ៍ មានក្លិនផ្កានិងទឹកអប់គ្រឿងក្រអូបជាដើម ជិវ្ហាវិញ្ញាណទី៤ វិញ្ញាណ ដែលអាស្រ័យនៅក្នុងជិវ្ហាទ្វារ សម្រាប់ជញ្ជាប់ដឹងនូវឱជារសផ្សេងៗ ដែល ជាអនិដ្ឋារម្មណ៍ មានបរិភោគសាច់ផឹកសុរាជាដើម អហេតុកវិបាកទាំង

៣ នេះប្រកបដោយឧបេក្ខាវេទនាដូចគ្នា ។ ទុក្ខសហគតកាយវិញ្ញាណទី៥ វិញ្ញាណដែលអាស្រ័យនៅក្នុងកាយទ្វារសម្រាប់ដឹងនូវសម្ផស្សផ្សេងៗ ដែលជាអនិដ្ឋារម្មណ៍ គឺសម្ផស្សរបស់សត្វទាំងឡាយ មានចៃ សង្កើច ខ្ទួយ ក្អែបជាដើម និងសម្ផស្សរបស់មនុស្សទាំងឡាយ មានមនុស្សកាចព្រហើនជាដើម ចូលមកខាំទិចនិងវាយវែធទាត់ជាក់រាងកាយខ្លួនជាដើម កាយវិញ្ញាណកើតឡើងដឹងច្បាស់នូវសម្ផស្សទាំងនោះហើយ កើតព្រមជាមួយទុក្ខវេទនា សោយនូវរសនៃផោដ្ឋព្វារម្មណ៍ ជាទុក្ខលំបាកប្រព្រឹត្តទៅក្នុងកាយទ្វារ ហើយរលត់ទៅវិញ ឧបេក្ខាសហគតសម្បដិច្ឆន្នចិត្ត វីថិចិត្តកើតឡើងទទួលចាប់យកនូវផោដ្ឋព្វារម្មណ៍នោះ កើតព្រមជាមួយឧបេក្ខា-វេទនា ហើយរលត់ទៅវិញ ។ សប្បុរសទាំងឡាយអ្នកសិក្សាបរមត្ថព្រះអភិធម្មគប្បីកំណត់ដឹងតាមសេចក្តីអធិប្បាយក្នុងចក្ខុវិញ្ញាណ ខាងដើមនេះចុះ គង់ដឹងច្បាស់នូវសេចក្តីអធិប្បាយដោយពិត ខ្ញុំព្រះករុណាបានអធិប្បាយអំពីអកុសលវិបាកអហេតុកចិត្តទាំង ៧ ដោយសង្ខេបតែប៉ុណ្ណេះ។

៣៨- ធម្មវាទី ទទួលថា សាធុៗ ម្នាលអត្ថវាទី ប្រស្នានេះប្រពៃហើយ ចុះកុសលវិបាកអហេតុកចិត្តទាំង ៨ នោះ សេចក្តីអធិប្បាយថាដូចម្តេចខ្លះ ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មក យើងនឹងបានស្តាប់

ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី កុសលវិបាកអហេតុកចិត្ត ទាំង ៨ នោះមានសេចក្ដីលោកសម្ដែងថាវីថិចិត្តដែលកើតឡើងនិងរលត់ទៅតាមខណៈចិត្តធំ និងខណៈចិត្តតូចជាលំដាប់និងលំដាប់គ្នា ដូចអកុសលវិ-បាកអហេតុកចិត្តទាំង ៧ នោះដែរ ប្លែកផ្សេងគ្នាខ្លះតែអារម្មណ៍និងវេទនាប៉ុណ្ណោះ ដូចមានសេចក្ដីអធិប្បាយតទៅខាងក្រោយនេះ ។ ទី ១ ឧបេ-ក្ខាសហគតចក្ខុវិញ្ញាណ សេចក្ដីថា រូបទាំងឡាយដែលជាឥដ្ឋារម្មណ៍ចូលមកកាន់វង្វង់ចក្ខុទ្វារ ប៉ះខ្ទប់នឹងចក្ខុប្បសាទ ឧបេក្ខាសហគតចក្ខុវិញ្ញាណក៏កើតឡើងញ៉ាំងទស្សនកិច្ច គឺកិច្ចដែលឃើញដឹងថារូបារម្មណ៍ឲ្យសម្រេច ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃរូបារម្មណ៍នឹងនៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ជាកណ្ដាលមិនកក្រើក ឧបេក្ខាសហគតសម្ប-ដិច្ឆន្នចិត្ត ក៏កើតឡើងជាលំដាប់គ្នា ហើយញ៉ាំងសម្បដិច្ឆន្នកិច្ច គឺកិច្ចដែលទទួលចាប់យកនូវរូបារម្មណ៍នោះឲ្យសម្រេច ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃរូបារម្មណ៍ និងនៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ជាកណ្ដាលមិនកក្រើក ឧបេក្ខាសហគតសន្តីរណចិត្ត ក៏កើតឡើងជាលំដាប់គ្នាទៀត ហើយញ៉ាំងសន្តីរណកិច្ច គឺកិច្ចដែលរិះគិតកំណត់នូវ

រូបារម្មណ៍នោះឲ្យសម្រេច ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃរូបារម្មណ៍និងនៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ ជាកណ្តាលមិនកក្រើក ។ ឯកុសលវិបាកអហេតុកចិត្តទី២ ៣ ៤ ក៏មានសេចក្តីអធិប្បាយជាលំដាប់គ្នាដូច្នេះដែរ ។ ត្រង់កុសលវិបាកអហេតុកចិត្តទី៥ នោះមានសេចក្តីអធិប្បាយថា បើផោដ្ឋព្វារម្មណ៍ទាំងឡាយដែលជាឥដ្ឋារម្មណ៍មានសម្ផស្សរបស់មនុស្សជាដើម និងគ្រឿងប្រើប្រាស់ផ្សេងៗ មានសំពត់ អាវ ពូក កន្ទេល ខ្នើយជាដើម ចូលមកប៉ះខ្ទប់នឹងកាយប្បសាទ សុខសហគតកាយវិញ្ញាណ ក៏កើតឡើងញុំាងផុស្សនកិច្ច គឺកិច្ចដែលប៉ះខ្ទប់នូវផោដ្ឋព្វារម្មណ៍ ឲ្យសម្រេចហើយកើតរលត់ព្រមជាមួយសុខវេទនា សោយនូវរសនៃផោដ្ឋព្វារម្មណ៍ ជាសុខសប្បាយប្រព្រឹត្តទៅក្នុងកាយទ្វារ ឧបេក្ខាសហគតសម្បដិច្ឆន្នចិត្តក៏កើតឡើងញុំាងសម្បដិច្ឆន្នកិច្ច គឺកិច្ចដែលទទួលចាប់ព្រមនូវផោដ្ឋព្វារម្មណ៍ឲ្យសម្រេច ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃផោដ្ឋព្វារម្មណ៍នឹងនៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ជាកណ្តាលមិនកក្រើក សោមនស្សសហគតសន្តីរណចិត្តក៏កើតឡើងញុំាងសន្តីរណកិច្ច គឺកិច្ចដែលរិះគិតកំណត់នូវផោដ្ឋព្វារម្មណ៍ឲ្យសម្រេចហើយកើតរលត់ព្រមជាមួយសោមនស្សវេទនា សោយនូវរសនៃ

ផោដ្ឋព្វារម្មណ៍ប្រកបដោយចិត្តរីករាយស្រស់ស្រាយល្អក្នុងមនោទ្វារ ។ ក៏កុសលជវនដែលសោយនូវរសនៃអារម្មណ៍ជាកុសល ហើយធ្លាក់ចុះមកឲ្យផលជាកុសលវិបាកអហេតុកចិត្តទាំង ៨ ដូច្នេះ ព្រោះតែអារម្មណ៍ខ្សោយកម្លាំងតិចពេកណាស់ វិថិចិត្តកើតឡើងចាប់តោងនូវអារម្មណ៍ពុំជាប់ មានខណៈចិត្តតិចពេកជាអាយុនៃរូបធម៌ទាំងឡាយគឺជាអារម្មណ៍ មានខណៈចិត្តកើតឡើង ៩ ខណៈ ១០ ខណៈ ១១ ខណៈ ប្រព្រឹត្តកន្លងទៅ ហើយមានតែខណៈចិត្ត ៨ ៧ ៦ ជាអាយុនៃរូបធម៌ទាំងឡាយ សូន្យវិថិចិត្ត ៣ គឺ តទាលម្ពណៈ ១ ជវនៈ ១ វោដ្ឋព្វនៈ ១ ហើយពុំបានកើតតទៅទៀត ធ្លាក់ចុះមកកាន់ទ្វារភវង្គវិញ កុសលចិត្តបែបនេះ ទោះបីប្រកបដោយហេតុក៏ដោយ រមែងតែឲ្យផលជាកុសលវិបាកអហេតុកចិត្តតាមធម្មតាដោយពិត ខ្ញុំព្រះករុណាវិសជ្ជនាមកអំពីកុសលវិបាកអហេតុ-កចិត្តទាំង ៨ ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៣៩- ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា ម្នាលអត្ថវាទី ចុះអហេតុកកិរិយាចិត្តទាំង ៣ នោះ មានសេចក្តីអធិប្បាយដូចម្តេចខ្លះ? មានសេចក្តីផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យពិស្តារសព្វគ្រប់មក យើងនឹងបានស្តាប់ចូលចិត្តអស់សេចក្តីសង្ស័យផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអហេតុកកិរិយាចិត្ត ទាំង ៣ នោះ សេចក្តីអធិប្បាយថា អហេតុកមនោធាតុ ផ្សាយចំហាយ គឺសង្ខារឲ្យចម្រើនឡើង ញុំាងវីថិចិត្តឲ្យកើតឡើងពិចារណាជ្រាវរាវរកអារម្មណ៍ក្នុងបញ្ចទ្វារនិងមនោទ្វារ ឬថាធ្វើអាការប្រែកមានញញឹមស្រស់ស្រាយជាដើម បានឈ្មោះថា អហេតុកកិរិយាចិត្តដោយពិត ដូចមានសេចក្តីអធិប្បាយពិស្តារតទៅនេះ៖

**ទី ១- បញ្ចទ្វារាវជ្ជនចិត្ត** ចែកចេញទៅជា ៥ គឺ ១- ឧបេក្ខាសហគតចក្ខុទ្វារាវជ្ជនចិត្ត វីថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុដាស់តឿនភវង្គ អាចញុំាងអាវជ្ជនកិច្ច គឺកិច្ចដែលជ្រាវរាវរកនូវរូបារម្មណ៍ ដែលចូលមកកាន់រង្វង់ចក្ខុទ្វារ ប៉ះខ្ទប់នឹងចក្ខុប្បសាទឲ្យសម្រេចបាន ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃរូបារម្មណ៍នឹងនៅជាកណ្តាលមិនកក្រើក ។ ២- ឧបេក្ខាសហគតសោតទ្វារាវជ្ជនចិត្ត វីថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុ ដាស់តឿនភវង្គ អាចញុំាងអាវជ្ជនកិច្ច គឺកិច្ចដែលពិចារណាជ្រាវរាវរកនូវសទ្ទារម្មណ៍ ដែលចូលមកកាន់រង្វង់សោតទ្វារប៉ះខ្ទប់នឹងសោតប្បសាទឲ្យសម្រេចបាន ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃសទ្ទារម្មណ៍ នឹងនៅជាកណ្តាល

មិនកក្រើក ។ ៣- ឧបេក្ខាសហគតឃានទ្វារាវជ្ជនចិត្ត វិថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុដាស់តឿនភវង្គ អាចញ៉ាំងអាវជ្ជនកិច្ច គឺកិច្ចដែលពិចារណាជ្រាវរាវរកនូវគន្ធារម្មណ៍ ដែលចូលមកកាន់វង្វង់ឃានទ្វារប៉ះខ្ទប់នឹងឃានប្បសាទឲ្យសម្រេចបាន ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនាសោយនូវរសនៃគន្ធារម្មណ៍និងនៅជាកណ្ដាលមិនកក្រើក ។ ៤- ឧបេក្ខាសហគតជិវ្ហាទ្វារាវជ្ជនចិត្ត វិថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុ ដាស់តឿនភវង្គអាចញ៉ាំងអាវជ្ជនកិច្ច គឺកិច្ចដែលពិចារណាជ្រាវរាវរកនូវរសារម្មណ៍ ដែលចូលមកកាន់វង្វង់ជិវ្ហាទ្វារប៉ះខ្ទប់នឹងជិវ្ហាបសាទឲ្យសម្រេចបាន ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃរសារម្មណ៍និងនៅជាកណ្ដាលមិនកក្រើក ។ ៥- ឧបេក្ខាសហគតកាយទ្វារាវជ្ជនចិត្ត វិថិចិត្តដែលកើតឡើងអំពីកិរិយាមនោធាតុដាស់តឿនភវង្គអាចញ៉ាំងអាវជ្ជនកិច្ច គឺកិច្ចដែលពិចារណាជ្រាវរាវរកនូវផោដ្ឋព្វារម្មណ៍ដែលចូលមកកាន់វង្វង់កាយទ្វារប៉ះនឹងកាយប្បសាទ ឲ្យសម្រេចបាន ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃផោដ្ឋព្វារម្មណ៍ជាកណ្ដាលមិនកក្រើក ក៏បញ្ចទ្វារាវជ្ជនចិត្តទាំង ៥ នេះ គ្រាន់តែពិចារណាជ្រាវរាវរកនូវអារម្មណ៍តែប៉ុណ្ណោះឯង ។

**ទី ២- មនោទ្វារាវជ្ជនចិត្ត**នោះបែកចេញទៅជាពីរគឺ ១- បញ្ចទ្វារឧបេក្ខាសហគតមនោទ្វារាវជ្ជនចិត្ត វីថិចិត្តដែលកើតឡើងអំពីកិរិយាមនោវិញ្ញាណធាតុដាស់តឿនភវង្គ អាចញ៉ាំងវោដ្ឋព្វនកិច្ច គឺកិច្ចដែលធ្វើកំណត់ទុកក្នុងចិត្តនូវអារម្មណ៍ទាំង ៥ មានរូបារម្មណ៍ជាដើម ដែលចូលមកកាន់វង្វង់នៃមនោទ្វារឲ្យសម្រេចបាន គឺថា បើវីថិចិត្តធ្វើកំណត់ទុកក្នុងចិត្តនូវអារម្មណ៍ខុសជាអនិដ្ឋារម្មណ៍ មិនត្រូវល្អតាមទំនងនៃបញ្ញាទេនឹងកើតទៅជាអកុសលផលបាបពិត បើធ្វើកំណត់ទុកក្នុងចិត្តនូវអារម្មណ៍ ត្រូវល្អជាឥដ្ឋារម្មណ៍ ត្រូវតាមទំនងនៃប្រាជ្ញាពិតប្រាកដ នឹងកើតទៅជាកុសលផលបុណ្យដោយពិត ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃអារម្មណ៍និងនៅជាកណ្តាលនៃទ្វារទាំង ៥ មានចក្ខុទ្វារជាដើម ។ ២- មនោទ្វារ ឧបេក្ខាសហគតមនោទ្វារាវជ្ជនចិត្ត វីថិចិត្តដែលកើតឡើងអំពីកិរិយាមនោវិញ្ញាណធាតុដាស់តឿនភវង្គ អាចញ៉ាំងអាវជ្ជនកិច្ចគឺកិច្ចដែលពិចារណាជ្រើសរើសរាវរកនូវធម្មារម្មណ៍ ក្នុងមនោទ្វារឲ្យសម្រេចបាន ហើយកើតរលត់ព្រមជាមួយឧបេក្ខាវេទនា សោយនូវរសនៃធម្មារម្មណ៍នឹងនៅជាកណ្តាលតែក្នុងមនោទ្វារដោយពិត, ក៏មនោទ្វារាវជ្ជនចិត្តទាំងពីរនេះគ្រាន់តែពិចារណាជ្រាវរាវរកនូវអារម្មណ៍ ក្នុង

បញ្ចទ្វារនិងមនោទ្វារតែប៉ុណ្ណោះឯង ។

**ទី ៣- សោមនស្សសហគតហសិតុប្បាទចិត្ត**នោះ សេចក្តីអធិប្បាយក្នុងដីកាមានបាលីថា ហសិតសទ្ទោ បេត្ថ សិតវាចកោ ក៏ហសិតសព្ទក្នុងទីនេះប្រែថា ត្រេកអររីករាយ ញញឹម ស្រស់ប្រិមប្រិយ បានដល់ព្រះខីណាស្រពទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ ពុំបានដល់បុថុជ្ជននិងសេខបុគ្គលទាំងឡាយឡើយ ព្រោះព្រះខីណាស្រពទាំងឡាយលោកមានអារម្មណ៍ពុំបានគ្រោតគ្រាតប្រកបដោយនេក្ខម្មគុណ លោកមានគុណវិសេសចេញចាកកាមគុណទាំង ៥ ជាជ្រះស្រឡះហើយៗ លោកបានឃើញនូវចំណែកនៃផែនដីដែលរាបទាបល្អជាទីត្រេកអរ ដ៏សមគួរល្មមតម្កល់នូវព្យាយាមចម្រើនព្រះកម្មដ្ឋានជាដើមហើយ លោកគិតថា ឱហ្ន៎! ប្រទេសនេះស្អាត់ល្អគួរដល់ព្រះកម្មដ្ឋានពិត សោមនស្សសហគតហសិតុប្បាទចិត្ត រឺចិត្តដែលត្រេកអររីករាយញញឹមស្រស់ប្រិមប្រិយ កើតឡើងប្រកបដោយសោមនស្សវេទនា សោយនូវរសនៃអារម្មណ៍ជាសុខ ប្រព្រឹត្តទៅក្នុងសន្តាននៃព្រះខីណាស្រពដោយពិត ម្យ៉ាងទៀតព្រះខីណាស្រពទាំងឡាយដែលលោកនឹងត្រេកអររីករាយនោះសោត ក៏លោកតែងត្រេកអររីករាយដោយកិរិយាចិត្តទាំង ៥ គឺសហេតុកកាមាវចរកិរិយាចិត្ត ដែលប្រកបដោយ

សោមនស្សវេទនា ៤ អហេតុកកិរិយាចិត្តនេះ១ ត្រូវជាកិរិយាចិត្ត ៥ កើតមាន ដល់ព្រះខីណាស្រពទាំងឡាយតែមួយចំណែកយ៉ាងប្រសើរដោយពិត ឯហសិតសំពួកនុ៎ះទីជទៃអំពីនេះ ប្រែថា អស់សំណើច សើចក្អាកក្អាយ បានដល់បុថុជ្ជនបុគ្គលនិងសេខបុគ្គលទាំងឡាយនោះមាន ៦ យ៉ាងគឺ សិតំ ត្រេកអរញញឹមស្រស់ស្រាយ ១ ហសិតំ អស់សំណើចខើចបបូរមាត់ សម្តែងឲ្យមានធ្មេញចេញក្រៅ ១ វិហសិតំ អស់សំណើចសើចរលាក់រលែកឲ្យមានសំឡេងពិរោះ ១ ឧបហសិតំ អស់សំណើចសើចអង្រួនញ័រទាំងក្បាល ១ អបហសិតំ អស់សំណើចសើចហូរទាំងទឹកភ្នែក ១ អបវិហសិតំ អស់សំណើចសើចញ័រអស់ទាំងខ្លួន ១ អស់សំណើចទាំង ៦ យ៉ាងនេះបានដល់បុថុជ្ជនបុគ្គលនិងសេខបុគ្គលទាំងឡាយ ដោយពិត តែថាបុថុជ្ជនទាំងឡាយអស់សំណើចដោយចិត្តទាំងឡាយ ៨ គឺអកុសល-ចិត្តដែលប្រកបដោយសោមនស្សវេទនា ៤ កុសលចិត្តដែលប្រកបដោយសោមនស្សវេទនា ៤ ត្រូវជា ៨ គត់ ។ ជំនុំចិត្តទាំងឡាយ ៨ នេះ ចិត្តណាមួយកើតឡើងដល់បុថុជ្ជនទាំងឡាយៗ សឹងត្រេកអរសើចរួសរាយ ដោយចិត្តនោះជា ហីនៈ យ៉ាងថោកទាប ព្រោះបុគ្គលបុថុជ្ជនទាំងឡាយ មានកាមតណ្ហាជាអារម្មណ៍ ។ ចំណែកខាងសេខបុគ្គលទាំងឡាយ

វិញលោកតែងត្រេកអរសើចរួសរាយប្រកបដោយចិត្តទាំងឡាយ ៦ គឺ អកុសលចិត្តជាទិដ្ឋិគតវិប្បយុត្ត ប្រាសចេញផុតពីមិច្ឆាទិដ្ឋិ ប្រកបដោយសោមនស្សវេទនា ២ មហាកុសលចិត្តប្រកបដោយសោមនស្សវេទនា ៤ ត្រូវជា ៦ ។ ជំនុំចិត្តទាំង ៦ នេះ ចិត្តណាមួយកើតឡើងដល់សេខបុគ្គលទាំងឡាយៗ សឹងត្រេកអរសើចរួសរាយដោយចិត្តនោះ ជាមជ្ឈិមយ៉ាងកណ្តាលមិនបានខ្ពាំងពេក ព្រោះសេខបុគ្គលទាំងឡាយលោកមានព្រះនិព្វានជាអារម្មណ៍ដោយពិត ។ ឯព្រះសម្មាសម្ពុទ្ធទាំងឡាយ ព្រះអង្គត្រេកអររីករាយស្រស់ស្រាយប្រិមប្រិយ ប្រកបដោយសហេតុកកាមាវចរកិរិយាចិត្ត ៤ ដែលប្រកបដោយសោមនស្សវេទនា ។ ជំនុំមហាកិរិយាចិត្តទាំង ៤ នេះ មហាកិរិយាចិត្តណាមួយ កើតឡើងដល់ព្រះសម្មាសម្ពុទ្ធទាំងឡាយៗ សឹងត្រេកអរស្រស់ស្រាយប្រិមប្រិយដោយមហាកិរិយាចិត្តនោះយ៉ាងប្រសើរវិសេសខ្ពង់ខ្ពស់បំផុត ព្រោះព្រះសព្វញ្ញុសម្ពុទ្ធទាំងឡាយ ព្រះអង្គមានគុណសម្បត្តិគឺសព្វញ្ញុតញ្ញាណ ជាអារម្មណ៍ដោយចំណែកមួយពិត ។ វិសជ្ជនាមកអំពីអហេតុកកិរិយាចិត្តទាំង ៣ ជាសេចក្តីសង្ខេបតែប៉ុណ្ណោះ ។

៤០- ធម្មវាទី បានស្តាប់ហើយពោលថា សាធុៗ ម្នាលអត្តវាទី

ប្រស្នានេះប្រពៃណាស់ហើយ តែយើងនៅមានសេចក្តីសង្ស័យតទៅទៀត ព្រោះលោកវិសជ្ជនាអំពីអារម្មណ៍ទាំងឡាយនោះ ត្រង់អារម្មណ៍ទាំង ៥ គឺ រូប សំឡេង ក្លិន រស សម្ផស្សនោះ យើងស្តាប់បានហើយឥតមានសង្ស័យទេ យើងសង្ស័យតែអារម្មណ៍ដែលមានឈ្មោះផ្សេងគ្នាទាំង ៤ គឺឥដ្ឋារម្មណ៍ ១ អនិដ្ឋារម្មណ៍ ១ ឥដ្ឋមជ្ឈត្តារម្មណ៍ ១ អនិដ្ឋមជ្ឈត្តារម្មណ៍ ១ ក៏អារម្មណ៍ទាំង ៤ នេះលោកបានអធិប្បាយមកខ្លះហើយតែពុំទាន់បានសព្វគ្រប់ យើងនឹងជឿស៊ប់សួនឲ្យច្បាស់លាស់ផងពុំទាន់បាន ដូច្នេះចូរលោកវិសជ្ជនានូវអារម្មណ៍ទាំង ៤ យ៉ាងនេះឲ្យបានសេចក្តីពិស្តារសព្វគ្រប់មកម្តងទៀត យើងនឹងស្តាប់ឲ្យបានជឿស៊ប់សួនអស់សេចក្តីសង្ស័យផងមើល ។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអារម្មណ៍ទាំង ៤ នោះខ្ញុំព្រះករុណាបានពិនិត្យសង្កេតយកសេចក្តីក្នុងដីកានិងអនុដីកា ព្រមទាំងយោជនាព្រះអភិធម្មនោះឃើញ សេចក្តីដូចតទៅនេះ អារម្មណ៍ទី ១ មានបាលីថា តត្ថ កុសលវិបាកភូតា រូបាទយោ ឥដ្ឋា សេចក្តីថា បណ្តាអារម្មណ៍ទាំងឡាយនោះ អារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមដែលកើតមកជាកុសលវិបាកដោយពិត បានឈ្មោះថា ឥដ្ឋារម្មណ៍ជាអារម្មណ៍គឺអ្នកប្រាជ្ញទាំងឡាយ មានសព្វញ្ញូពោធិសត្វ និង បច្ចេក-

ពោធិសត្វជាដើម លោកតែងត្រេកអរប្រាថ្នាស្រឡាញ់គាប់ចិត្ត ចំពោះតែត្រង់តាំងចិត្តជាម្ចាស់ ឬជាជានាយចៅហ្វាយត្រួតត្រាលើកាមតណ្ហា ពុំបានលុះទៅក្នុងអំណាចនៃកាមតណ្ហាដឹកនាំឡើយ ព្រោះអ្នកប្រាជ្ញទាំងឡាយនោះលោកជាសម្មាទិដ្ឋិប្រកបដោយវិចារណបញ្ញា តែងពិចា-រណាជ្រើសរើសកំណត់ដឹងច្បាស់ប្រាកដនូវអារម្មណ៍ទាំង ៥ គឺរូប សំឡេង ក្លិន រស សម្ផស្សនោះថា ជាគ្រឿងល្បួងលួងលោមបញ្ឆោតរបស់មារទាំង ៥ មានកិលេសមារជាដើមទេ តែបុគ្គលណាមួយត្រេកអរប្រាថ្នាស្រឡាញ់គាប់ចិត្តនឹងកាមារម្មណ៍ទាំង ៥ នេះ ខ្លាំងហួសប្រមាណពេកមិនប្រព្រឹត្តធម៌សន្តោសត្រេកអរស្មើៗ ដ៏សមគួរតាមលាភហើយ មុខជាកាមារម្មណ៍ទាំង ៥ នេះ នឹងសម្លាប់បុគ្គលនោះវិញ បើទុកជាពុំបានដល់ស្លាប់ខ្លួនទេ ក៏គង់បានសេចក្តីទុក្ខលំបាកអាក្រក់ក្នុងបច្ចុប្បន្ននេះមានពាក្យគរហានិន្ទាជាដើម ក្នុងលោកខាងមុខនឹងធ្លាក់ទៅសោយទុក្ខ-វេទនាក្នុងអបាយភូមិទាំង ៤ ជាពុំខាន អ្នកប្រាជ្ញទាំងឡាយ លោកបានពិចារណាដឹងច្បាស់ប្រាកដយ៉ាងនេះហើយ លោកតាំងចិត្តមិនប្រាថ្នាត្រេកអរស្រឡាញ់គាប់ចិត្ត នឹងរូប សំឡេង ក្លិន រស សម្ផស្ស ទាំង ៥ នេះ ខ្លាំងហួសប្រមាណឡើយ លោកតែងប្រតិបត្តិតាមពុទ្ធឱវាទ

ប្រព្រឹត្តធម៌សន្តោស ត្រេកអរស្រឡាញ់គាប់ចិត្តនឹងកាមារម្មណ៍ទាំង ៥ មានរូបារម្មណ៍ជាដើមនេះស្មើៗ សមគួរតាមលាភពិត ប្រកបដោយសោមនស្សវេទនា សោយនូវរសនៃកាមារម្មណ៍ជាសុខសប្បាយក្នុងចិត្ត តែង ប្រព្រឹត្តធ្វើការជាកុសលមានលះបង់សេចក្តីលោភមិនកំណាញ់ បរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានជាដើម ហើយអ្នកប្រាជ្ញទាំងឡាយនោះ តែងត្រាច់អន្ទោលទៅមកសោយសុខក្សេមក្សាន្តក្នុងសុគតិភពទាំង ៧ ជាន់ ដោយច្រើន បានឈ្មោះថាឥដ្ឋារម្មណ៍ ជាអារម្មណ៍នាំឲ្យកើតជាកុសលវិបាកចិត្តដោយពិត ។ អារម្មណ៍ទី ២ មានបាលីថា អកុសលវិបាកភូតារូបាទយោ អនិដ្ឋា សេចក្តីថា អារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើមដែលកើតមកជាអកុសលវិបាកចិត្តពិតៗ បានឈ្មោះថា អនិដ្ឋារម្មណ៍ជាអារម្មណ៍ គឺអ្នកប្រាជ្ញទាំងឡាយ មានសព្វញ្ញូពោធិសត្វនិងបច្ចេកពោធិសត្វជាដើម លោកមិនប្រាថ្នាត្រេកអរស្រឡាញ់គាប់ចិត្ត លោកតែងវៀរលែងចេញជាស្រឡះ មិនឲ្យជំពាក់ជាប់នៅក្នុងសន្តានចិត្តរបស់លោកឡើយ ចំណែកឯបុគ្គលពាលទាំងឡាយ ជាមិច្ឆាទិដ្ឋិ យល់ឃើញខុស តែងមានចិត្តកើតឡើងយកអនិដ្ឋារម្មណ៍នោះ មកជាឥដ្ឋារម្មណ៍ជាទីប្រាថ្នាត្រេកអរ ស្រឡាញ់ គាប់ចិត្ត នឹងរូប សំឡេង ក្លិន រស

សម្ផស្សនោះទៅវិញ លុះទៅក្នុងអំណាចនៃកាមតណ្ហាដឹកនាំ ជាខ្ញុំបម្រើតណ្ហា គឺថា បានរូបមួយហើយប្រាថ្នាចង់បានរូបពីរបីបួន តទៅទៀតជាដើម មិនប្រតិបត្តិតាមពុទ្ធឱវាទ គឺថាមិនប្រព្រឹត្តធម៌សន្តោសត្រេកអរស្មើៗ ឲ្យសមគួរតាមលាភឡើយ ជាបុគ្គលមានទិដ្ឋិវិបល្លាសប្រែប្រួលគំនិតគិតខុសវង្វេងភាន់ច្រឡំអារម្មណ៍ សម្គាល់ថាបុគ្គលអ្នកធ្វើបុណ្យឲ្យទានរក្សាសីលភាវនាជាដើមនេះជាការឥតប្រយោជន៍ ជាបុគ្គលប្រកបដោយ លោភៈ ទោសៈ មោហៈ ពេញទី ប្រព្រឹត្តកំណាញ់មិនបរិច្ចាគទ្រព្យឲ្យទាន និងប្រទូស្តសត្វនិងសង្ខារមិនរក្សាសីល វង្វេងភាន់ច្រឡំអារម្មណ៍មិនចម្រើនមេត្តាភាវនាឡើយ ហើយប្រកបដោយសោមនស្ស-វេទនា សោយនូវរសនៃកាមារម្មណ៍ជាសុខសប្បាយក្នុងចិត្ត មានគំនិតស៊ុងទៅតាមបង្គាប់តណ្ហាដឹកនាំឲ្យប្រាថ្នា ត្រេកត្រអាលស្រឡាញ់គាប់ចិត្តតែនឹង រូប សំឡេង ក្លិន រស សម្ផស្ស ដែលជាគ្រឿងទាស់នឹងពុទ្ធឱវាទដោយពិត ។ បុគ្គលពាលទាំងឡាយនោះរមែងត្រាច់អន្ទោលទៅមកសោយទុក្ខវេទនាក្នុងអបាយភូមិទាំង ៤ ដោយច្រើន បានឈ្មោះថាអនិដ្ឋារម្មណ៍ជាអារម្មណ៍នាំឲ្យកើតជាអកុសលវិបាកចិត្តដោយពិត ។ ទី ៣ ឥដ្ឋ-មជ្ឈត្តារម្មណ៍មានសេចក្តីអធិប្បាយដូចគ្នានឹងឥដ្ឋារម្មណ៍នោះដែរ ប៉ុន្តែ

គ្នាតែវេទនា គឺជាឥដ្ឋារម្មណ៍ជាសោមនស្សវេទនា ឯឥដ្ឋមជ្ឈត្តារម្មណ៍នេះ ជាឧបេក្ខាវេទនា សោយនូវរសនៃអារម្មណ៍ប្រព្រឹត្តទៅជាកណ្តាលនិង នៅក្នុងឥដ្ឋារម្មណ៍មិនកក្រើក គឺថាមិនប្រែប្រួលត្រឡប់ទៅជា សុខ ទុក្ខ សោមនស្ស ទោមនស្សឡើយ បានឈ្មោះថា ឥដ្ឋមជ្ឈត្តារម្មណ៍ ជាអារម្មណ៍នាំឲ្យកើតជាកុសលវិបាកចិត្តដោយពិត ។ ទី៤- អនិដ្ឋមជ្ឈ-ត្តារម្មណ៍ សេចក្តីអធិប្បាយ ដូចគ្នានឹងអនិដ្ឋារម្មណ៍នោះដែរ ប្លែកផ្សេង គ្នាតែវេទនា គឺថា អនិដ្ឋារម្មណ៍ជាសោមនស្សវេទនា ឯអនិដ្ឋមជ្ឈត្តារម្មណ៍ ជាឧបេក្ខាវេទនា សោយនូវរសនៃអារម្មណ៍ ប្រព្រឹត្តទៅជាកណ្តាលនិង នៅក្នុងអនិដ្ឋារម្មណ៍មិនកក្រើក គឺថាមិនប្រែប្រួលត្រឡប់ទៅជា សុខ-ទុក្ខ សោមនស្ស-ទោមនស្សឡើយ បានឈ្មោះថាអនិដ្ឋមជ្ឈត្តារម្មណ៍ ជា អារម្មណ៍ នាំឲ្យកើតជាអកុសលវិបាកចិត្តដោយពិត ។ ខ្ញុំអត្តវាទី បានអធិប្បាយអំពីអារម្មណ៍មានឈ្មោះផ្សេងគ្នាទាំង ៤ ដោយសង្ខេបមក តែប៉ុណ្ណេះ ។

៤១- ធម្មវាទី បានស្តាប់ហើយ ពោលថា ម្នាលអត្តវាទី អារម្មណ៍ ដែលមានឈ្មោះផ្សេងគ្នាទាំង ៤ ដែលលោកវិសជ្ជនាមកនេះ យើង ស្តាប់បានហើយ តែយើងនៅមានសង្ស័យនឹងអារម្មណ៍ទាំង ៦ ក្នុងកាមា-

វចរចិត្តតទៅទៀត គឺរូបារម្មណ៍ ១ សទ្ទារម្មណ៍ ១ គន្ធារម្មណ៍ ១ រសារម្មណ៍ ១ ផោដ្ឋព្វារម្មណ៍ ១ ធម្មារម្មណ៍ ១ ត្រូវជា ៦ គឺរូប សំឡេង ក្លិន រស សម្ផស្ស ធម៌ ដូចម្តេច ក៏ឲ្យឈ្មោះថាអារម្មណ៍ ៗ សព្ទនេះ តើអធិប្បាយថាដូចម្តេច? ម្យ៉ាងទៀត ធម្មស័ព្ទ ក្នុងកុសល-ត្តិកមាតិកាយើងបានសួរឲ្យលោកវិសជ្ជនាមករួចហើយ ចុះធម្មសព្ទ ក្នុងធម្មារម្មណ៍ កាមាវចរចិត្តនេះ មានសេចក្តីអធិប្បាយដូចធម្មសព្ទ ក្នុងកុសលត្តិកមាតិកានោះដែរ ឬផ្សេងគ្នាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាឲ្យពិស្តារសព្វគ្រប់មក យើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ក្នុងបាលីអដ្ឋកថា ដីកា អនុដីកា ព្រមទាំងយោជនាព្រះអភិធម្ម លោកសម្តែងសេចក្តីពន្យល់ថា រូប សំឡេង ក្លិន រស សម្ផស្ស ធម៌នេះ លោកកំណត់ឲ្យឈ្មោះជាពីរគឺ អាលម្ពណៈ ១ អារម្មណៈ ១ ។ ទី ១ អាលម្ពណៈ នោះមានបាលីបទវិគ្រោះថា ចិត្តចេតសិកេហិ អាលម្ពិយតីតិ > អាលម្ពណំ សេចក្តីថា វត្ថុទាំង ៦ មានរូបវត្ថុជាដើមឯណា ដែលចិត្តនិងចេតសិកទាំងឡាយចាប់តោងជាប់ជាកម្លាំង ហេតុនោះវត្ថុទាំង ៦ នោះបានឈ្មោះថា អា-លម្ពណៈ ជាធម្មជាតសម្រាប់ចិត្តនិងចេតសិក ចាប់តោងជាប់ជាកម្លាំង

ទើបកើតឡើងបាន មានសេចក្តីឧបមាដូចបុរសខ្វិន មានកម្លាំងថយពន់ពេកធម្មតាឯបុរសខ្វិនមានកម្លាំងថយ យ៉ាងនេះហើយដែលនឹងក្រោកឈរឡើងឋិតនៅនឹងបាននោះ លុះតែបានអាស្រ័យនឹងខ្សែផ្តៅឬខ្សែព្រ័ត្រដែលបុគ្គលបានចងសំយុងចុះមកឲ្យ ទើបយកដៃចាប់តោងនូវខ្សែផ្តៅឬខ្សែព្រ័ត្រនោះ ហើយខំប្រឹងព្យាយាមចាប់ស្រាវតាមខ្សែនោះក្រោកឈរឡើងទើបឋិតនៅនឹងបាន បើខ្សែនោះមានកម្លាំងជាប់មាំមួន បុរសដែលចាប់តោងខ្សែក៏ឈរឋិតនៅនឹងបានយូរដែរ បើខ្សែនោះមិនជាប់មាំមួន ពុកផុយដាច់ទៅហើយ បុរសដែលចាប់តោងខ្សែឈរនោះ ក៏នឹងដួលធ្លាក់ចុះមកអន្តយក្នុងទីកន្លែងរបស់ខ្លួនវិញដដែល មានសេចក្តីឧបមាយ៉ាងណា ឯអារម្មណ៍ទាំង ៦ ដូចខ្សែដែលបុគ្គលចងសំយុងចុះខ្ទប់នឹងបសាទទាំង ៦ មានចក្ខុប្បសាទជាដើម ចិត្តនិងចេតសិកដូចបុរសខ្វិនមានកម្លាំងថយខំប្រឹងចាប់តោងនូវខ្សែគឺអារម្មណ៍ទាំង ៦ អារម្មណ៍ណាមួយចាប់ស្រាវតាមខ្សែគឺអារម្មណ៍នោះ ខំក្រោកឈរឡើងឋិតនៅនឹងបានតាមកម្លាំងនៃអារម្មណ៍ជាលំដាប់ដោយពិត បើអារម្មណ៍ធំមានកម្លាំងខ្លាំង ចិត្តនិងចេតសិកក៏ចាប់តោងយកជាអារម្មណ៍ឋិតនៅនឹងបានយូរ បើអារម្មណ៍តូចមានកម្លាំងខ្សោយ ចិត្តនិងចេតសិកចាប់តោងយកជាអារម្មណ៍ឋិត

នៅនឹងយូរពុំបាន នឹងដាច់ចេញពីអារម្មណ៍ធ្លាក់ចុះមកកាន់ទ្វារភវង្គវិញ ដដែល មានសេចក្តីឧបមេយ្យដូចបុរសខ្វិននោះឯង ទើបអាលម្ពណវត្ថុទាំង ៦ បានឈ្មោះថាធម្មជាតសម្រាប់ចិត្តនិងចេតសិកចាប់តោងកើតឡើងៗ

ទី២ អារម្មណៈនោះ មានបាលីបទវិគ្រោះថា ចិត្តចេតសិកានិ អាគន្ត្វា ឯត្ថ រមន្តីតិ > អារម្មណំ សេចក្តីថា ចិត្តនិងចេតសិកទាំងឡាយ មកហើយត្រេកអរក្នុងរូបវត្ថុជាដើមនេះ ហេតុនោះ រូបវត្ថុជាដើមនោះបានឈ្មោះថាអារម្មណ៍ ជាគ្រឿងមកត្រេកអរនៃចិត្តនិងចេតសិក គឺថា រូបចូលទៅកាន់រង្វង់ចក្ខុទ្វារប៉ះខ្ទប់នឹងចក្ខុប្បសាទញ័រកក្រើកដល់ភវង្គហើយ វីថិចិត្តនិងចេតសិកទាំងឡាយកើតឡើងមកតាមចក្ខុទ្វារ ទទួលត្រេកអរនឹងរូបនោះឯង ទោះបីសំឡេងក្តី ក្លិនក្តី រសក្តី សម្ផស្សក្តី ធម៌ក្តី ចូលទៅកាន់រង្វង់សោតទ្វារ ឃានទ្វារ ជិវ្ហាទ្វារ កាយទ្វារ មនោទ្វារ ប៉ះខ្ទប់នឹងបសាទនោះៗ ញ័រកម្រើកដល់ភវង្គហើយ វីថិចិត្តនិងចេតសិកទាំងឡាយក៏កើតឡើងមកតាមទ្វារនោះៗ ទទួលត្រេកអរនឹងសំឡេង ក្លិន រស សម្ផស្ស ធម៌នោះៗឯង ទើបបានឈ្មោះថាអារម្មណ៍ រូបវត្ថុជាដើមជាគ្រឿងមកត្រេកអរនៃចិត្តនិងចេតសិកដោយពិត ។ ឯធម្មសព្ទក្នុងធម្មារម្មណ៍ជាកាមាវចរចិត្តនេះ សេចក្តីអធិប្បាយមិនបានដូចធម្មសព្ទ

ក្នុងកុសលត្តិកមាតិកានោះទេ ព្រោះធម្មសព្ទក្នុងកុសលត្តិកមាតិកានោះ លោកចំពោះយកសភាវវិបាក ជាធម៌ទ្រទ្រង់សត្វទាំងឡាយមិនឲ្យធ្លាក់ចុះទៅក្នុងអបាយភូមិ ៤ និងក្នុងវដ្តទុក្ខដោយពិត ក៏ធម្មសព្ទក្នុងធម្មារម្មណ៍នោះ លោកចំពោះយកព្រះបរិយត្តិធម៌ ដែលបុគ្គលបានទ្រទ្រង់ចាំទុកក្នុងសន្តានខ្លួនដោយសមគួរតាមសភាពពិត ដូចមានបទវិគ្រោះថា ធារិយតិ យថាសភាវតោតិ > ធម្មោ សេចក្ដីថា (សភាវៈឯណា) ដែលអ្នកប្រាជ្ញបានទ្រទ្រង់ចំណាំចាំទុកដោយសមគួរតាមសភាពពិត (សភាវៈនោះឯង) បានឈ្មោះថា ធម្មោ គឺសភាវៈដែលអ្នកប្រាជ្ញបានទ្រទ្រង់ចំណាំចាំទុកក្នុងចិត្តដោយសមគួរតាមសភាពពិត ធម្មោ ឯវ អារម្មណំ > ធម្មារម្មណំ ធម៌មែនពិត ជាទីមកត្រេកអរនៃចិត្តនិងចេតសិកបានឈ្មោះថា ធម្មារម្មណ៍ សេចក្ដីអធិប្បាយថា សប្បុរសទាំងឡាយដែលមានសេចក្ដីប្រាថ្នាចង់ឲ្យស្ងប់រម្ងាប់បាបធម៌ ហើយខំប្រឹងព្យាយាមស្ដាប់ធម្មរស រៀនទន្ទេញធម្មរសទ្រទ្រង់ចំណាំចាំទុកធម្មរសក្នុងចិត្ត ហើយខំរៀនប្រែត្រិះរិះគិតជញ្ជឹងរំពឹងកំណត់យកសេចក្ដីអត្ថរស ចំពោះតាមធម្មរសដែលខ្លួនបានទ្រទ្រង់ទុកមកហើយ បើបានចាំធម្មរសគឺរសបាលី រៀនកំណត់ដឹងច្បាស់អត្ថរសគឺរសសេចក្ដីពិតប្រាកដហើយ ខំព្យាយាមប្រតិបត្តិតាមឲ្យសមគួរដល់ធម្ម-

រសនិងអត្ថរសនោះឯង បានឈ្មោះថាធម្មារម្មណ៍ កាមាវចរកុសលចិត្ត ចាប់យកធម៌ជាអារម្មណ៍ ត្រូវទំនងជាឥដ្ឋារម្មណ៍តាមឧបាយនៃប្រាជ្ញា នឹងកើតជាកាមាវចរកុសលវិបាកដោយពិត បើមិនបានប្រតិបត្តិតាមឲ្យសមគួរដល់ធម្មរសនិងអត្ថរសនោះទេ គង់បានឈ្មោះថាធម្មារម្មណ៍ដែរ តែថាបានខាងកាមាវចរអកុសលចិត្តចាប់យកធម៌ជាអនិដ្ឋារម្មណ៍ មិនបានត្រូវតាមឧបាយនៃប្រាជ្ញា នឹងកើតជាអកុសលវិបាកអហេតុកចិត្តពិត ។ ម្យ៉ាងវិញទៀត ក្នុងគម្ពីរអដ្ឋសាលិនី អដ្ឋកថាអភិធម្មសង្គណី លោកសម្តែងចំពោះយកបរមត្ថទានទាំង ៣ យ៉ាង គឺជីវិតទាន ១ បានទាន ១ រសទាន ១ ដែលសម្តេចព្រះអនន្តញាណជាម្ចាស់ ព្រះអង្គទ្រង់អនុញ្ញាតឲ្យភិក្ខុសង្ឃទទួលត្រេកអរឆាន់បានផង ព្រះអង្គទ្រង់អនុគ្រោះដល់ទាយកទាយិកាទាំងឡាយ ដែលមានសទ្ធាបានបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានបានផលានិសង្សច្រើនដ៏ខ្ពង់ខ្ពស់ផង ដូចមានសេចក្តីអធិប្បាយតទៅនេះ ។

ទី ១- គឺឲ្យទានភត្តទាំង ១៨ ដែលជាគ្រឿងចិញ្ចឹមជីវិតដល់ភិក្ខុ សាមណេរទាំងឡាយ ដែលបានបួសក្នុងព្រះពុទ្ធសាសនានេះបានឈ្មោះថាជីវិតទាន ឯភត្តទាំង ១៨ នោះគឺ ១- សង្ឃភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះព្រះភិក្ខុសង្ឃ

ដែលនិមន្តមកអំពីទិសទាំង ៤ ទទួលចង្ហាន់បិណ្ឌបាតឥតកំណត់ ។ ២- ឧទ្ទេសភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុ ឬភិក្ខុនីដែលគណសង្ឃទាំងពីរពួកបានចាត់ឲ្យមកទទួលចង្ហាន់បិណ្ឌបាតសមគួរតាមពាក្យទាយកគេនិមន្ត ។ ៣- និមន្តនភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចូលមកកាន់រោងឆាន់ក្នុងអារាម ហើយកាន់យកបាត្រលោកឥតចំពោះរូប យកទៅចាត់ដាក់ចង្ហាន់បិណ្ឌបាតប្រគេនសង្ឃ ចំណែកខាងភិក្ខុសង្ឃបានដឹងហើយក៏ចេញទៅទទួលចង្ហាន់បិណ្ឌបាត សម្គាល់តាមបាត្ររបស់ខ្លួន ។ ៤- សលាកភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយបានធ្វើស្លាកដាក់ឈ្មោះខ្លួន ព្រមទាំងទីលំនៅ ហើយចូលមកកាន់វត្តវាយគោរាំងប្រជុំលោកចាប់ស្លាក[១] លុះព្រឹកឡើងលោកក៏និមន្តទៅទទួលចង្ហាន់បិណ្ឌបាតតាមស្លាករបស់ខ្លួន ។ ៥- បក្ខិកភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះព្រះ

---

១- ក្នុងព្រះវិនយធរសិក្ខាបទថាទាយកទាយិកា យកស្លាកទៅឲ្យលោកចាប់ពេលព្រឹកបានហើយនាំលោកទៅទទួលភត្តឯផ្ទះក៏បាន។ បើមានភត្តបម្រុងមកស្រេចឲ្យលោកចាប់ស្លាកហើយប្រគេនភត្តក្នុងវត្តក៏បាន បានឈ្មោះថាសង្ឃុគតាទក្ខិណាទានដូចគ្នា ។

សង្ឃក្នុងសុក្កបក្ខឬកាឡបក្ខ គឺកន្លះខែខាងខ្នើតឬខាងរនោចមួយបក្ខៗ[១] តាមសទ្ធា ។ ៦- ឧបោសថិកភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានសមាទានឧបោសថរួចហើយចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុសង្ឃតែក្នុងថ្ងៃឧបោសថក្នុងមួយខែៗ អស់វារៈ ២ ដង ៤ ដង ៨ ដង តាមថ្ងៃឧបោសថដ៏សមគួរតាមសទ្ធា ។ ៧- បាដិបទិកភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះព្រះភិក្ខុសង្ឃក្នុងថ្ងៃ ១ កើតឬថ្ងៃ ១ រោច ជាភត្តដែលព្រះពុទ្ធទ្រង់សរសើរថាជាភត្តដ៏ឧត្តមមានផលានិសង្សច្រើន ។ ៨- គិលានភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះព្រះភិក្ខុសង្ឃដែលមានជំងឺអាពាធតែម្យ៉ាង ។ ៩- គិលានុបដ្ឋាកភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុឬសាមណេរ ដែលបម្រើជំងឺភិក្ខុអ្នកអាពាធតែម្យ៉ាង ។ ១០- គមិកភត្ត ភត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាត ចំពោះព្រះភិក្ខុសង្ឃដែលមានកិច្ចរៀបចំដំណើរនឹងចេញទៅកាន់ទីឆ្ងាយ ។ ១១- អាគន្តុកភត្ត ភត្តាហារដែល

---

១- គឺថ្ងៃ បញ្ចមី អដ្ឋមី ចាតុទ្ទសី បណ្ណរសីឧបោសថ ខ្នើត ៤ ថ្ងៃ រនោច ៤ ថ្ងៃៗ

ទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះព្រះភិក្ខុសង្ឃជាអាគន្តុកៈ ដែលទើបនឹងនិមន្តមកដល់ថ្មីៗ ។ ១២- ធុវភត្ត កត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌ-បាត មួយសម្រាប់ឬពីរសម្រាប់ ចំពោះព្រះភិក្ខុសង្ឃក្នុងវត្តមួយៗ រាល់ៗ ថ្ងៃពុំបានដាច់ ។ ១៣- កុដិភត្ត កត្តាហារដែលទាយកទាយិកាទាំង-ឡាយ បានបវារណាហើយចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុសង្ឃឬសាមណេរ ដែលបានមកនៅក្នុងកុដិ ដែលខ្លួនបានកសាងទុកក្នុងព្រះពុទ្ធសាសនា ។ ១៤- វារកភត្ត កត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងដាក់វេនផ្លាស់ប្តូរគ្នា ម្តងត្រូវផ្ទះអ្នកឯណេះ ម្តងត្រូវផ្ទះអ្នកឯណោះ ចំពោះភិក្ខុសង្ឃ សាមណេរដែលនៅក្នុងវត្តមួយៗ ។ ១៥- វិហារភត្ត កត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុសង្ឃសាមណេរដែលនៅក្នុងវត្តមួយ ៗ បានឆាន់គ្រប់គ្រាន់បរិបូរទាំងអស់ ។ ១៦- ចតុក្កភត្ត កត្តាហារដែលទាយកទាយិកាទាំងឡាយ បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុសង្ឃ បួនៗ អង្គ ដែលខ្លួនបានសូមមកអំពីគណសង្ឃៗ បានចាត់មកឲ្យទទួលចង្ហាន់បិណ្ឌបាតនៅផ្ទះខ្លួនរាល់ៗ ថ្ងៃពុំបានដាច់ ។ ១៧- អដ្ឋ-

កកត្ត      កត្តាហារដែលទាយកទាយិកាទាំងឡាយ      បានចាត់ចែងចង្ហាន់បិណ្ឌបាតចំពោះភិក្ខុសង្ឃប្រាំបីៗ  រូបដែលខ្លួនបានសូមមកអំពីគណសង្ឃៗ បានចាត់មកឲ្យទទួលចង្ហាន់បិណ្ឌបាតនៅផ្ទះខ្លួនរាល់ៗ ថ្ងៃ ពុំបានដាច់ ។

១៨-   គុឡុកត្ត[១]   កត្តាហារដែលទាយកទាយិកាទាំងឡាយ   បានចាត់ចែងកត្តលាយដោយស្ករអំពៅមានបាយដំណើប បបរស្ករ នំលតជាដើម ចំពោះភិក្ខុសង្ឃ សាមណេរដែលនៅក្នុងវត្តមួយៗ តាមសទ្ធា ។ ឯទាយកទាយិកាទាំងឡាយ      បាននឹករឭកដល់ព្រះធម៌គឺព្រះសុគតោវាទនិងពុទ្ធានុញ្ញាតនេះជាអារម្មណ៍    កាមាវចរកុសលចិត្តក៏កើតឡើង    ជំនុំកត្តទាំង   ១៨   នោះ   ក្នុងកត្តណាមួយ   ហើយមានសេចក្តីជ្រះថ្លាបានបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានកត្តនោះៗ    ចំពោះព្រះភិក្ខុសង្ឃបានឈ្មោះជាជីវិតទានដោយពិត ។

ទី ២- បានទាន ឲ្យទានទឹកបានទាំង ៨ មានទឹកស្វាយទុំជា-ដើម ចំពោះភិក្ខុសង្ឃ សាមណេរ បានឈ្មោះថាបានទាន ។

ទី ៣- រសទាន ឲ្យរសទឹកភេសជ្ជៈ ទាំង ៥ យ៉ាងមានទឹកសប្បិ

---

១- គុឡុភត្ត ក្នុងវិនយធរសិក្ខាបទបា គុឡុសព្ទនេះ ប្រែថាអង្គញ់បានដល់ភត្តដែលទាយកទាយិកាបានចាត់ចែងរួចហើយចូលទៅក្នុងវត្ត     ធ្វើស្លាកមិនទាន់ហើយយកអង្គញ់មកចែកឲ្យភិក្ខុសង្ឃចាប់ហើយប្រគេនភត្តតាមអង្គញ់នោះ បានឈ្មោះថាសង្ឃគតាទក្ខិណាទានដូចគ្នា ។

និងនវនីតជាដើម ចំពោះភិក្ខុសង្ឃ សាមណេរ បានឈ្មោះថារស-ទាន ។ ក៏បានទាននិងរសទានទាំងពីរយ៉ាងនេះ លោករាប់បញ្ចូលក្នុងភេសជ្ជទានដោយពិត ។ បុគ្គលដែលបានទឹករព្រកដល់ពុទ្ធឱវាទទាំង-ឡាយនេះជាអារម្មណ៍ ហើយមានសេចក្តីពេញចិត្តនឹងទានណា កាមាវចរកុសលចិត្តក៏កើតឡើង បរិច្ចាគទ្រព្យធ្វើទាននោះឯង បានឈ្មោះថាធម្មារម្មណទាន ឲ្យទានបរមត្ថមានធម៌ជាអារម្មណ៍ដោយពិត ។ ខ្ញុំអត្តវាទី បានវិសជ្ជនាមកអំពីអារម្មណ៍ទាំង ៦ ដោយសង្ខេបតែប៉ុណ្ណេះ ។

៤២- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្តវាទី យើងបានបុច្ឆាវិសជ្ជនាគ្នាអំពីអសោភណចិត្តទាំង ៣០ គឺអកុសលចិត្ត ១២ ដោយសង្ខេប អហេតុកចិត្ត ១៨ ដោយពិស្តារព្រមទាំងអារម្មណ៍ ៥-៤-៦ ជាសេចក្តីពិស្តារខ្លះ សង្ខេបខ្លះ ល្មមស្តាប់បានហើយ ឥឡូវនេះយើងនឹងសួរលោកអំពីសោភណចិត្ត ៥៩ ដែលជាចិត្តប្រកបដោយហេតុមានពន្លឺរស្មីរុងរឿងល្អតទៅទៀត ។ ចុះសោភណចិត្តទាំង ៥៩ នោះបើចែកជាកុសលតាមពួកមានចំនួនប៉ុន្មាន? ចែកជាវិបាកចិត្តតាមពួកមានចំនួនប៉ុន្មាន? ចែកជាកិរិយាចិត្តតាមពួកមានចំនួនប៉ុន្មាន? ចូរលោកវិសជ្ជនា

បែកចំនួនចិត្តនេះតាមពួកឲ្យសព្វគ្រប់មកមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯសោភណចិត្តទាំង ៥៩ នោះព្រះបរមគ្រូជាម្ចាស់ព្រះអង្គទ្រង់ត្រាស់សម្ដែងបែកជា កុសលចិត្ត ២១ គឺកាមាវចរកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ លោកុត្តរកុសលចិត្ត ៤ ត្រូវជា ២១ បែកជាវិបាកចិត្ត ២១ គឺកាមាវចរ-វិបាកចិត្ត ៨ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ លោកុត្តរវិបាកចិត្ត ៤ ត្រូវជា ២១ បែកជាកិរិយាចិត្ត ១៧ គឺកាមាវចរកិរិយាចិត្ត ៨ រូបាវចរកិរិយាចិត្ត ៥ អរូបាវចរកិរិយាចិត្ត ៤ ត្រូវជា ១៧ ព្រោះលោកុត្តរកិរិយាចិត្តពុំមានឡើយ បូករួមចិត្តទាំងអស់ត្រូវជាសោភណ-ចិត្ត ៥៩ គត់ ។ ខ្ញុំអត្ថវាទី បានវិសជ្ជនាមកអំពីសោភណចិត្តបែកទៅតាមពួកចិត្ត ជាកុសលចិត្ត ជាវិបាកចិត្ត ជាកិរិយាចិត្ត ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៤៣- ធម្មវាទី បានស្ដាប់ហើយពោលថា អើ! អត្ថវាទី លោកបានវិសជ្ជនាចំណែកសោភណចិត្តទាំង ៥៩ តាមពួកចិត្ត ក៏ត្រឹមត្រូវពិតមែនហើយ តែយើងនឹងសួរលោកតទៅទៀត ។ ត្រង់ចិត្ត-សព្វនេះ យើងបានសួរឲ្យលោកវិសជ្ជនាមករួចហើយ យើងឥតមាន

សង្ស័យទេ យើងសង្ស័យតែត្រង់ចិត្តតែមួយហើយឲ្យឈ្មោះផ្សេងគ្នាជាបីយ៉ាង ជាកុសល ជាវិបាក ជាកិរិយានេះ តើមានសេចក្ដីផ្សេងគ្នាយ៉ាងណាខ្លះ? អធិប្បាយជាដូចម្ដេចខ្លះ? មានសេចក្ដីឧបមាដូចវត្ថុអ្វីខ្លះ? គួរលោកវិសជ្ជនាឲ្យពិស្ដារសព្វគ្រប់មកយើងនឹងបានស្ដាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ត្រង់ចិត្តតែមួយឲ្យឈ្មោះផ្សេងគ្នាជា ៣ យ៉ាងនោះដូច្នេះ ត្រង់ឈ្មោះជាកុសលនោះ សេចក្ដីអធិប្បាយពិស្ដារថាចិត្តព្រមទាំងសោភណចេតសិកប្រជុំគ្នា កើតឡើងព្រមជាមួយគ្នាមានអារម្មណ៍តែ ១ មានវត្ថុតែ ១ ដ៏ភ្លឺស្វាងរុងរឿងល្អ មានបញ្ញាឆ្លៀវឆ្លាសវាងវៃអាចប្រួតកាត់នូវអំពើបាបធម៌ ដ៏អាក្រក់លាមកដែលបណ្ឌិតគប្បីខ្ពើមគឺអំពើបាបធម៌ដែលបុគ្គលធ្វើប្រកបដោយលោភៈ សេចក្ដីលោភចង់បានហួសប្រមាណ ទោសៈ សេចក្ដីក្រោធខឹងប្រទូស្តសត្វនិងសង្ខារ មោហៈ សេចក្ដីវង្វេងភាន់ច្រឡំអារម្មណ៍ លះបង់ចោលចេញជាស្រឡះ ហើយខំព្យាយាមចម្រើន អលោភៈ អទោសៈ អមោហៈ ឲ្យកើតមានច្រើនឡើងក្នុងសន្ដាននៃខ្លួន អាចបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទាន សមាទានរក្សាសីល ៥ សីលឧបោសថ ប្រកបព្រមដោយ

អដ្ឋ ៨ និងចម្រើនសមថកម្មដ្ឋានជាដើមបានឈ្មោះថាកុសលចិត្ត ។ ត្រង់ថាវិបាកនោះ សេចក្តីថា វីថិចិត្តដែលចាប់តោងយកនូវផលនៃអំពើជាឥដ្ឋារម្មណ៍ដែលកុសលជវនបានសោយសម្រេចហើយ ជាប់មកក្នុងសន្តាននៃខ្លួនបានឈ្មោះថាវិបាកចិត្ត ឬថាតទាលម្ពណៈក៏បាន ។ ត្រង់ថាកិរិយានោះ សេចក្តីថា វីថិចិត្តដែលធ្វើផលគឺកិត្តិគុណសព្ទឲ្យល្បីផ្សាយចេញទៅកាន់ទិសផ្សេងៗ បានឈ្មោះថាកិរិយាចិត្ត ដូចមានសេចក្តីឧបមាក្នុងអដ្ឋកថា លោកសម្តែងពន្យល់ថា ធម្មតាផ្កាឈើទាំងឡាយដែលកើតមានឡើងក្នុងលោកនេះមិនដូចគ្នាទេ ព្រោះផ្កាឈើដែលគ្រាន់តែមានពណ៌និងសណ្ឋានល្អផ្សេងៗ ឥតក្លិនក្រអូបច្រើនជាអនេក ឈើដែលមានផ្កាមានពណ៌និងសណ្ឋានល្អផ្សេងៗ ហើយមានក្លិនក្រអូបផងតិចពន់ពេកណាស់ មានសេចក្តីឧបមាយ៉ាងណា ឯកុសលចិត្តដូចរូបផ្កា វិបាកចិត្តដូចពណ៌និងសណ្ឋានល្អផ្សេងៗ របស់ផ្កា កិរិយាចិត្តដូចខ្យល់សម្រាប់ធ្វើក្លិនឲ្យក្រអូបរបស់ផ្កាឲ្យផ្សាយចេញទៅកាន់ទិសទាំងពួង គឺថាបុគ្គលទាំងឡាយឯណាដែលមានកុសលចិត្តតិច វិបាកចិត្តដែលជាផលកើតមកអំពីកុសលក៏តិចដែរ ដូចផ្កាឈើទាំងឡាយដែលឥតក្លិនមានតែពណ៌និងសណ្ឋានល្អផ្សេងៗ ពុំមានក្លិនក្រអូបផ្សាយទៅកាន់ទិសទាំងពួង

ឡើយ បុគ្គលទាំងឡាយនោះមានច្រើនជាអនេក កើតឡើងក្នុងលោកនេះមានតែរូបមានតែពណ៌និងសណ្ឋានល្អផ្សេងៗ ឥតកិរិយាចិត្តពុំមានវីថិចិត្ត ដែលនឹងធ្វើក្លិនគឺកិត្តិគុណសព្ទឲ្យល្បីផ្សាយទៅកាន់ទិសផ្សេងៗឡើយ ចំណែកខាងបុគ្គលឯណាដែលមានកុសលចិត្តកើតឡើងច្រើនវិបាកចិត្តដែលជាផលកើតមកអំពីកុសលក៏ច្រើនដែរ ដូចផ្កាឈើដែលមានពណ៌និងសណ្ឋានល្អផ្សេងៗ មានក្លិនក្រអូប មានផ្កាចម្ប៉ា និងផ្កាម្លិះរួតជាដើម បុគ្គលនោះមានតិចពន់ពេកណាស់ កើតឡើងក្នុងលោកនេះ មានរូបនិងពណ៌សណ្ឋានល្អផ្សេងៗ មានទាំងកិរិយាចិត្ត អាចធ្វើក្លិនក្រអូបគឺកិត្តិគុណសព្ទ ឲ្យល្បីផ្សាយទៅកាន់ទិសផ្សេងៗ ដ៏ប្រសើរ តែជាមិនមានច្រើនទេ ព្រោះមហាកិរិយាចិត្តនេះមិនមានដល់បុថុជ្ជននិងសេខបុគ្គលទាំងឡាយឡើយ មានតែដល់ព្រះខីណាស្រពទាំងឡាយតែប៉ុណ្ណោះ ឯកុសលចិត្តដូចរូបផ្កា វិបាកចិត្តដូចក្លិនក្រអូបនៅក្នុងផ្កា កិរិយាចិត្តដូចក្លិនក្រអូបផ្សាយចេញអំពីតួផ្កា មានសេចក្ដីឧបមេយ្យដូចផ្កាឈើទាំងឡាយនោះឯង ។

ម្យ៉ាងទៀត លោកសម្ដែងពន្យល់ក្នុងអដ្ឋកថា ថាបុគ្គលអ្នកធ្វើស្រែតែងព្យាយាមប្រុងប្រៀបរកគោក្របីនង្គ័លរនាស់បម្រុងទុក ដល់មានទឹក

ភ្លៀងធ្លាក់ចុះមកក្នុងរដូវដើមឆ្នាំ ហើយក្សួររាស់សាបព្រោះដកស្ទូងចាត់ចែងទាំរក្សាស្រែដរាបដល់ស្រូវទុំ ហើយច្រូតកាត់បែនបោកកើបធាររស្រូវដាក់ជង្រុកហើយ ទុកដាក់គ្រឿងប្រដាប់មានទន្តីលរនាស់ជាដើមជាស្រេច ក៏ស្រូវដែលនៅក្នុងជង្រុកនោះ លុះដល់ពេលម្ចាស់ស្រូវគេត្រូវការ ហើយបានចាត់ចែងធ្វើស្រូវទាំងនោះទៅតាមប្រាថ្នា មានចម្អិនធ្វើអាហារបរិភោគជាដើមមានសេចក្តីឧបមាយ៉ាងណា បុគ្គលដែលមានកុសលចិត្តកើតឡើងក្នុងសន្តានខ្លួន មានសេចក្តីជ្រះថ្លាហើយចាត់ចែងធ្វើការជាកុសលផ្សេងៗ ប្រកបដោយកុសលចេតនាមួយលើក ៗ នោះដរាបដល់ហើយស្រេច បានឈ្មោះថាកុសលចិត្ត បុណ្យដែលជាផលកើតមកអំពីកុសលចិត្តនោះ ៗ ជាប់ឋិតនៅក្នុងជង្រុកគឺដួងហ្ឫទ័យបានឈ្មោះថាវិបាកចិត្តឬថាតទាលម្ពណៈក៏បាន កិរិយាធ្វើគុណសម្បត្តិទាំងពួងមានបញ្ញាសម្បត្តិជាដើម ឲ្យផ្សាយចេញអំពីវិបាកចិត្តនោះ ៗ ល្បីទៅកាន់ទិសផ្សេងៗ ច្បាស់លាស់ដោយរហ័ស បានឈ្មោះថាកិរិយាចិត្ត មានសេចក្តីឧបមេយ្យដូចបុគ្គលអ្នកចាត់ចែងធ្វើស្រែនោះឯង ។ ខ្ញុំអត្ថវាទី បានវិសជ្ជនាអំពីកុសលចិត្ត វិបាកចិត្ត កិរិយាចិត្ត ដោយសង្ខេបមកតែប៉ុណ្ណោះឯង ។

៤៤- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះត្រឹមត្រូវហើយ តែយើងនឹងសួរតទៅទៀត ។ ចុះកាមាវចរកុសលចិត្តទាំង ៨ នោះ ផ្សេងគ្នាដោយវេទនាមានប៉ុន្មាន? គឺវេទនាអ្វីខ្លះ? ដោយញាណមានប៉ុន្មាន? គឺញាណអ្វីខ្លះ? ដោយសង្ខារិកមានប៉ុន្មាន? គឺសង្ខារិកអ្វីខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯកាមាវចរកុសលចិត្តទាំង ៨ នោះ ផ្សេងគ្នាដោយវេទនាមានពីរគឺសោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ផ្សេងគ្នាដោយញាណមាន ៤ គឺសោមនស្ស-ញាណសម្បយុត្ត-អសង្ខារិក ១ សោមនស្ស-ញាណសម្បយុត្ត-សសង្ខារិក ១ ឧបេក្ខា-ញាណសម្បយុត្ត-អសង្ខារិក ១ ឧបេក្ខា-ញាណសម្បយុត្ត-សសង្ខារិក ១ ផ្សេងគ្នាដោយសង្ខារិកមាន ៨ គឺ កុសលចិត្តទី ១ និងទី ៣ ដែលប្រកបដោយសោមនស្សវេទនា ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណ-វិប្បយុត្ត ១ កុសលចិត្តទី ៥ និងទី ៧ ដែលប្រកបដោយឧបេក្ខាវេទនា ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណវិប្បយុត្ត ១ ត្រូវជាអសង្ខារិក ៤, កុសលចិត្តទី ២ និង ទី ៤ ដែលប្រកបដោយសោមនស្សវេទនា

ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណវិប្បយុត្ត ១ កុសលចិត្តទី ៦ និងទី ៨ ដែលប្រកបដោយឧបេក្ខាវេទនា ចំណែកខាងញាណសម្បយុត្ត ១ ខាងញាណវិប្បយុត្ត ១ ត្រូវជាសសង្ខារិក ៤ រួមទាំងអស់ត្រូវជាសង្ខារិក ៨ ដោយពិត ។

៤៥- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះយើងស្តាប់បានហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ។ ចុះកាមាវចរកុសលចិត្តទាំង ៨ នោះ ដែលផ្សេងគ្នាដោយសោមនស្សវេទនានិងឧបេក្ខាវេទនា តើមានសេចក្តីអធិប្បាយផ្សេងគ្នាយ៉ាងណាខ្លះ? ដោយញាណសម្បយុត្តនិងញាណវិប្បយុត្ត តើមានសេចក្តីអធិប្បាយផ្សេងគ្នាយ៉ាងណាខ្លះ? ដោយអសង្ខារិកនិងសសង្ខារិក តើមានសេចក្តីអធិប្បាយផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យពិស្តារសព្វគ្រប់មក យើងនឹងស្តាប់ចូលចិត្តបានដោយងាយផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី បណ្តាកាមាវចរកុសលចិត្តទាំង ៨ នោះ បឋមកុសលចិត្តទី ១ មានសេចក្តីអធិប្បាយថា: បុគ្គលឯណាបានអាស្រ័យនូវទេយ្យធម្មសម្បត្តិ គឺបរិបូណ៌ដោយទេយ្យវត្ថុ មានសំពត់សម្រាប់ធ្វើចីវរជាដើមក្តី កត្តាហារទាំងពួងដ៏ឧត្តមក្តី សេនាសនៈ

វត្ថុសម្រាប់ដេកអង្គុយមានកន្ទេលខ្នើយជាដើមក្តី គ្រឿងភេសជ្ជៈទាំងពួង ដ៏ឧត្តមក្តី បដិគ្គាហកសម្បត្តិ គឺបរិបូណ៌ដោយបុគ្គលអ្នកទទួលដែលប្រកប ដោយវត្តប្បដិបត្តិដ៏សមរម្យល្អ គួរដល់សមណសារូបក្តី បដិគ្គាហក បុគ្គលដែលធ្លាប់ស្រឡាញ់រាប់អានជាញាតិឬជាមិត្រសំឡាញ់ក្តី ឬនូវ សម្បត្តិដទៃដែលជាហេតុ ឲ្យកើតសេចក្តីសោមនស្សមានចិត្តត្រេកអររីក រាយប្រកបដោយសោមនស្សវេទនា សោយនូវរសនៃឥដ្ឋារម្មណ៍ជាសុខ សប្បាយប្រព្រឹត្តទៅក្នុងចិត្ត ។ បានបំពេញនូវសម្មាទិដ្ឋិគឺការដឹងច្បាស់ ឃើញត្រូវឲ្យពេញបរិបូណ៌តាមអង្គព្រះអដ្ឋង្គិកមគ្គជាបឋម ប្រព្រឹត្តទៅ ដោយន័យមានន័យថាទានដែលអញបានឲ្យហើយនេះ ជាទានមាន ផលានិសង្សច្រើន អាចនាំមកនូវប្រយោជន៍និងសេចក្តីសុខសេចក្តីចម្រើន ជាអសង្ខេយ្យជាដើម ជាញាណសម្បយុត្តប្រកបព្រមដោយញាណ គឺបញ្ញាដឹងច្បាស់នូវហេតុទាំង ៤ យ៉ាង តាមសភាពពិត គឺ

១- កម្ម : ដឹងច្បាស់ថា បុគ្គលធ្វើអំពើអាក្រក់លាមកនឹងបានសេចក្តីអាក្រក់ លាមកវិញ បុគ្គលធ្វើអំពើល្អដ៏ប្រសើរនឹងបានសេចក្តីល្អដ៏ប្រសើរមកវិញ។

២- ឧបបត្តិ : ដឹងច្បាស់ថាបុគ្គលដែលចូលទៅជិតកើតក្នុងព្រហ្មលោកដោយ មិនមានសេចក្តីព្យាបាទ មានមេត្តាព្រហ្មវិហារជាដើម ។

៣- ឥន្ទ្រិយបរិបាក : មានបញ្ញាជាធំចាស់ដោយជុំវិញ ព្រោះមានចិត្ត មិនរបើងរើងរូសប្រកាន់ទិដ្ឋិមានះឡើយ ខំព្យាយាមដើរសាកសួរនូវអត្ថ-រសនិងធម្មរស ចំពោះអ្នកប្រាជ្ញដែលមានបញ្ញាចាស់មានចិត្តធ្ងន់ក្នុងព្រះពុទ្ធសាសនា ញុំាងបញ្ញារបស់ខ្លួនឲ្យសម្រេច គេចវៀះចៀសចេញ មិនសេពគប់នូវបុគ្គលពាលអាប់ឥតបញ្ញាឡើយ ហើយស្វែងរកសេព-គប់នូវបុគ្គលជាបណ្ឌិតមានបញ្ញាដ៏ល្អិតជ្រាលជ្រៅ ខំពិចារណាសាកសួរ ប្រព្រឹត្តសន្សំនូវញាណ គឺបញ្ញារបស់ខ្លួនឲ្យបានជ្រាលជ្រៅទៅក្នុង អត្ថរសនិងធម្មរសដោយពិត ។ ៤- កិលេសទូរិភាវៈ : ដឹងច្បាស់ ថាភាវៈដែលឆ្ងាយចាកកិលេសនោះ ត្រូវគេសង្កត់សង្កិនកម្ចាត់បង់នូវ កងកិលេសទាំងពួងដោយឈានសមាបត្តិជាដើមទើបបាន ។ បុគ្គល ដែលដឹងច្បាស់នូវហេតុទាំង ៤ យ៉ាងនេះ ទើបបានឈ្មោះថាញាណ-សម្បយុត្តប្រកបព្រមដោយញាណ ។ លុះបានដឹងច្បាស់យ៉ាងនេះហើយ មានចិត្តពុំបានលិចចុះក្នុងសេចក្ដីខ្ជិលច្រអូសទម្រន់ចុះឡើយ មិនមាន បុគ្គលទាំងឡាយដទៃ មកជួយជ្រោមជ្រែងរំពុកដាស់តឿនឲ្យមាន ឧស្សាហ៍ក្លៀវក្លាឡើយ គឺថាមានចិត្តសប្បាយជ្រះថ្លាចំពោះបុគ្គលអ្នក ទទួលក្ដី អាហារបិណ្ឌបាតក្ដី ទីសេនាសនៈក្ដី វត្ថុក្ដី ដែលជាទីពេញ

ចិត្ត កំកើតឧស្សាហ៍ព្យាយាមក្លៀវក្លាឡើងដោយខ្លួនឯង ហើយបាន ធ្វើបំពេញនូវបុញ្ញកិរិយាវត្ថុទាំង ១០ យ៉ាង មានបរិច្ចាគទ្រព្យឲ្យទានជាដើម បានឈ្មោះថាអសង្ខារិក កុសលចិត្តប្រកបដោយសេចក្ដីសប្បាយ កើតឧស្សាហ៍ព្យាយាមយ៉ាងក្លៀវក្លាធ្វើការជាកុសលផ្សេងៗ ដោយខ្លួនឯង ក្នុងកាលឯណា បឋមកុសលចិត្តប្រកបដោយសោមនស្សវេទនាញាណសម្បយុត្តអសង្ខារិកកំកើតឡើងប្រាកដដល់បុគ្គលនោះ ក្នុងកាលនោះឯង ។

ទុតិយកុសលចិត្តទី ២ មានសេចក្ដីអធិប្បាយដូចបឋមកុសលចិត្តនោះដែរ ប្លែកគ្នាតែត្រង់សង្ខារិក ព្រោះទុតិយកុសលចិត្តនេះជាសសង្ខារិក សេចក្ដីអធិប្បាយថា បុគ្គលឯណាមានកុសលចិត្តប្រកបដោយសោម-នស្សវេទនាញាណសម្បយុត្តដែរ តែថាជាបុគ្គលមានចិត្តធុញទ្រាន់លិចចុះក្នុងសេចក្ដីខ្ជិលច្រអូសទម្រន់ចុះ មិនធ្វើបំពេញនូវបុញ្ញកិរិយា-វត្ថុទាំង ១០ យ៉ាង មានបរិច្ចាគទ្រព្យឲ្យទានជាដើម ព្រោះមិនសប្បាយពេញចិត្តចំពោះរដូវកាលក្ដី បុគ្គលអ្នកទទួលក្ដី អាហារបិណ្ឌបាតក្ដី ទីសេនាសនៈក្ដី នាំឲ្យមានចិត្តធុញទ្រាន់ធ្វើបុណ្យឲ្យទានមិនកើតឡើយ លុះមានបុគ្គលទាំងឡាយដទៃទោះបីជាញាតិសាច់សាលោហិតក្ដី ជាមិត្ត

សំឡាញ់នឹងគ្នាក្តី ចូលមកជួយនិយាយរំពុកដាស់តឿន ទើបមានឧស្សាហ៍ សេចក្តីព្យាយាមក្លៀវក្លាកើតឡើង បានចាត់ចែងធ្វើបំពេញនូវបុញ្ញកិរិយាវត្ថុទាំង ១០ យ៉ាង មានបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានជាដើម បានឈ្មោះថា សសង្ខារិក កុសលចិត្តប្រកបដោយសេចក្តីធុញទ្រាន់ខ្ជិលច្រអូសមិនសប្បាយពេញចិត្តនឹងធ្វើបុណ្យឲ្យទានឡើយ លុះមានបុគ្គលដទៃមកជួយនិយាយរំពុកដាស់តឿន ទើបមានឧស្សាហ៍ សេចក្តីព្យាយាមក្លៀវក្លាសប្បាយពេញចិត្ត បានចាត់ចែងធ្វើការកុសលផ្សេងៗតាមកម្លាំងសទ្ធាក្នុងកាលឯណា ទុតិយកុសលចិត្តដែលប្រកបដោយសោមនស្សវេទនា-ញាណសម្បយុត្ត-សសង្ខារិក ក៏កើតឡើងប្រាកដដល់បុគ្គលនោះក្នុងកាលនោះឯង ។

តតិយកុសលចិត្តទី ៣ មានសេចក្តីអធិប្បាយថា: ពាលទារកក្មេងទាំងឡាយដែលពុំទាន់រៀនសូត្រចេះដឹងចំណេះវិជ្ជាមាំមួន នៅក្មេងសេចក្តីខ្ចីគំនិតមានកិរិយាប្រព្រឹត្តសន្សំនូវវត្តប្រតិបត្តិកើតឡើង ដោយសារបានឃើញនូវសេចក្តីគោរពប្រតិបត្តិនៃជនទាំងឡាយជាញាតិ មានមាតាបិតាជាដើម ដែលខំព្យាយាមធ្វើបំពេញនូវបុញ្ញកិរិយាវត្ថុទាំង ១០ ក្នុងព្រះពុទ្ធសាសនា, ពាលទារកទាំងឡាយនោះ លុះបាន

ឃើញភិក្ខុ-សាមណេរទាំងឡាយហើយ មានសេចក្តីសោមនស្សត្រេក-អររីករាយកើតឡើង តែថាជាញាណវិប្បយុត្តប្រាសចេញផុតចាកញាណគឺមិនមានបញ្ញាពិចារណាដឹងច្បាស់នូវហេតុទាំង ៤ យ៉ាងនោះទេ ហើយមានចិត្តពុំបានលិចចុះ ក្នុងសេចក្តីខ្ជិលច្រអូសធុញទ្រាន់ឡើយ មិនមានបុគ្គលទាំងឡាយដទៃ មកជួយនិយាយរំឭកដាស់តឿនឲ្យមានឧស្សាហ៍ព្យាយាមក្លៀវក្លាឡើយ គឺមានចិត្តសប្បាយជ្រះថ្លានឹងភិក្ខុសាមណេរដែលខ្លួនបានឃើញនោះ ក៏កើតឧស្សាហ៍ព្យាយាមក្លៀវក្លាឡើងដោយខ្លួនឯង មានទេយ្យវត្ថុអ្វីបន្តិចបន្តួចក្នុងដៃខ្លួន ក៏លះបង់នូវទេយ្យវត្ថុនោះប្រគេនដល់ភិក្ខុ សាមណេរទាំងឡាយនោះដោយរហ័សឬថាធ្វើបំពេញនូវបុញ្ញកិរិយាវត្ថុឯណាមួយក្តី ក្នុងកាលឯណា តតិយ-កុសលចិត្តប្រកបដោយសោមនស្សវេទនាញាណវិប្បយុត្តអសង្ខារិក ក៏កើតឡើងប្រាកដដល់ទារកទាំងឡាយនោះក្នុងកាលនោះឯង ។

ចតុត្ថកុសលចិត្តទី ៤ មានសេចក្តីអធិប្បាយដូចតតិយកុសលចិត្តទី ៣ នោះដែរ ប្លែកគ្នាតែត្រង់សង្ខារិក គឺចតុត្ថកុសលចិត្តជាសសង្ខារិក សេចក្តីអធិប្បាយថា ទារកទាំងឡាយមានចិត្តលិចចុះក្នុងសេចក្តីខ្ជិលច្រអូសធុញទ្រាន់មិនសប្បាយពេញចិត្តនឹងធ្វើបុណ្យសោះ លុះមាន

បុគ្គលទាំងឡាយដទៃមានមាតាបិតាជាដើម បានជួយនិយាយល្បួងលួង លោមរំពុកដាស់តឿនថា កូន! អ្នកចូរកាន់យកវត្ថុនេះទៅប្រគេនលោក អ្នកត្រូវថ្វាយបង្គំលោកជាដើម ទើបទារកទាំងឡាយនោះមានឧស្សាហ៍ សេចក្តីព្យាយាមក្លៀវក្លាកើតឡើង បានប្រគេនទេយ្យវត្ថុដល់លោក បានថ្វាយបង្គំលោក បានចាត់ចែងធ្វើការកុសលផ្សេងៗ តាមកម្លាំង សទ្ធាក្នុងកាលឯណា ចតុត្ថកុសលចិត្តដែលប្រកបដោយសោមនស្ស-វេទនាញាណវិប្បយុត្តសសង្ខារិក ក៏កើតឡើងប្រាកដដល់ពាលទារក ទាំងឡាយនោះក្នុងកាលនោះឯង ។ ក៏ក្នុងមហាដីកា លោកសម្តែងកាត់ សេចក្តីថា កុសលចិត្តទី ៣-៤ នោះលោកយកពាលទារកទាំងឡាយ មកជាទីតាំង ហាក់ដូចជាកុសលចិត្តទី ៣-៤ នោះកើតឡើងបាន តែត្រឹមពាលទារកក្មេងតូចៗ ប៉ុណ្ណោះ តែមិនមែនតែដូច្នោះទេ ទោះបី បុរស ឬស្ត្រីក្មេងចាស់ក្តី ក៏គង់មានកុសលចិត្តទី ៣-៤ នោះកើតឡើង ដូចគ្នាដែរ មានសេចក្តីអធិប្បាយដូចពាលទារកទាំងឡាយនោះឯង ។

ឯកុសលចិត្តទី ៥-៦-៧-៨ មានសេចក្តីអធិប្បាយដូចកុសលចិត្តទី-១-២-៣-៤ នោះដែរ ផ្សេងគ្នាតែវេទនា ព្រោះកុសលចិត្តទី ៥ ៦-៧-៨ នេះ ប្រកបដោយឧបេក្ខាវេទនាសោយនូវរសនៃឥដ្ឋារម្មណ៍

ប្រព្រឹត្តទៅជាកណ្តាល នឹងនៅក្នុងការបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទាន ក្នុងកិច្ចរក្សាសីល ក្នុងកិច្ចចម្រើនភាវនា មិនករើកប្រែប្រួលត្រឡប់បែរទៅជាសុខ - ទុក្ខ - សោមនស្ស - ទោមនស្សវេទនាឡើយ ដូចមានសេចក្តីពិស្តារក្នុងអដ្ឋកថា មហាដីកា អនុដីកា ព្រមទាំងយោជនា លោកអធិប្បាយពន្យល់សព្វគ្រប់ថា: ឧបេក្ខាវេទនានេះ ជាចេតសិកធម៌ឯកដ៏ប្រសើរឥតគូនឹងរកចេតសិកធម៌ឯណាមួយមកផ្ទឹមជាគូផងពុំបាន ក្នុងវេទនាខន្ធលោកសម្តែងចែកទៅជា ៣ គឺសុខវេទនាជាគូនឹងទុក្ខវេទនា អទុក្ខមសុខវេទនា សោយនូវរសនៃអារម្មណ៍មិនជាទុក្ខមិនជាសុខយ៉ាងកណ្តាល បានឈ្មោះថាឧបេក្ខាវេទនា ជាចេតសិកធម៌ឯក ឥតគូដែលលោកចែកទៅជា ៥ គឺទោមនស្សវេទនាជាគូនឹងសោមនស្សវេទនា ទុក្ខវេទនាជាគូនឹងសុខវេទនា ឧបេក្ខាវេទនាជាចេតសិកធម៌ឯកដ៏ប្រសើរឥតគូ បើសម្តែងអំពីជ្រៅនិងរាក់វិញទៀតនោះ លោកពោលថា កុសល-ចិត្តដែលប្រកបដោយសោមនស្សវេទនាជាចេតសិកធម៌រាក់ៗ ទេ ព្រោះលាយទៅដោយកាមតណ្ហាអាស្រ័យនឹងសម្បត្តិទើបកើតឡើងបាន បើគ្មានសម្បត្តិទេក៏កើតឡើងពុំបានដែរ ត្រេកអររីករាយចំពោះទេយ្យវត្ថុ-សម្បត្តិជាដើម គឺមានវត្ថុទេយ្យទានបរិបូណ៌ទើបកើតសេចក្តីសោមនស្ស

មានចិត្តត្រេកអររីករាយបរិច្ចាគទ្រព្យឲ្យទានបាន បើវត្ថុទេយ្យទានមិនបានគ្រប់គ្រាន់បរិបូណ៌ទេ សេចក្តីសោមនស្សក៏កើតឡើងពុំបានបរិច្ចាគទ្រព្យឲ្យទានក៏ពុំកើតដែរជាដើម ឯកុសលចិត្ត ដែលប្រកបដោយឧបេក្ខាវេទនាជាចេតសិកធម៌ដ៏ប្រសើរ កើតឡើងពុំបានអាស្រ័យនូវសម្បត្តិទាំងពួង មានទេយ្យវត្ថុជាដើមនោះឡើយ ជាចេត-សិកធម៌ប្រាសចេញស្រឡះចាកសម្បត្តិទាំងពួង ដែលជាហេតុនាំឲ្យកើតសោមនស្សវេទនាដោយពិត ព្រោះមានសទ្ធាចេតសិកជឿកម្មនិងផលរបស់កម្មមិនករេក្រើក មានសតិចេតសិកភ្ញាក់រឭកនឹករេរកឧបាយបំពេញការកុសលពុំភ្លេច មានបញ្ញាចេតសិកពិចារណាដឹងច្បាស់ថា ការបរិច្ចាគទ្រព្យឲ្យទានក្តី កិច្ចរក្សាសីលក្តី កិច្ចភាវនាក្តី ជាកិច្ចយ៉ាងឧត្តម អាចញុំាងខ្លួនឲ្យឆ្លងផុតចាកសង្សារទុក្ខបានដោយពិត ឧបេក្ខាវេទនាក៏កើតឡើងក្នុងសន្តាននៃខ្លួនជាសភាវៈមានជម្រៅ ពុំបានករេក្រើកប្រែប្រួលទៅជាទុក្ខ សុខ ទោមនស្ស សោមនស្សវេទនាឡើយ សោយនូវរសនៃឥដ្ឋារម្មណ៍កណ្តាល នឹងនៅក្នុងការបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានក្នុងកិច្ចរក្សាសីល ក្នុងកិច្ចភាវនាព្រះកម្មដ្ឋានមិនបានលះបង់ឡើយ ក៏កុសលចិត្តទី ៥-៦-៧-៨ នេះផ្ទុយគ្នាអំពីកុសលចិត្តទី ១-២-៣-៤

តែត្រឹមឧបេក្ខាវេទនាដូចបានអធិប្បាយមកហើយនេះ ។ វិសជ្ជនាមកអំពីកាមាវចរកុសលចិត្តទាំង ៨ ដែលផ្សេងគ្នា ដោយវេទនាមាន ២ ដោយញាណមាន ៤ ដោយសង្ខារិកមាន ៨ ជាសេចក្តីសង្ខេបតែប៉ុណ្ណោះ ។

៤៦- ធម្មវាទី បានស្តាប់ហើយពោលថាសាធុៗ ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃណាស់ហើយ តែយើងនឹងសួរលោកតទៅទៀត ។ ចុះបុគ្គលដែលបានធ្វើបុណ្យឲ្យទាន រក្សាសីល ៥ សីលឧបោសថ ចម្រើនភាវនាសមថកម្មដ្ឋាន ដោយកុសលចិត្តជាញាណសម្បយុត្តក្តី ញាណវិប្បយុត្តក្តី អសង្ខារិកក្តី សសង្ខារិកក្តី ប្រកបដោយសោមនស្សវេទនាក្តី ឧបេក្ខាវេទនាក្តី តើបានផលានិសង្សមានកម្លាំងខ្លាំង កម្លាំងខ្សោយ បានបុណ្យច្រើន បុណ្យតិចផ្សេងគ្នាដូចម្តេច? ឬមានផលានិសង្សដូចៗ គ្នាទេ ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មក យើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី បុគ្គលធ្វើបុណ្យឲ្យទានរក្សាសីល ៥ សីលឧបោសថ ចម្រើនភាវនាសមថកម្មដ្ឋានដោយកាមាវចរកុសលចិត្តទាំង ៨ នោះបានផលានិសង្សមិនដូចគ្នាទេ ដូចមានបាលីសម្រាប់កាត់សេចក្តីក្នុងអនុដីកាព្រះអភិធម្មថា ពលវាពលវិភាវតោតិ ញាណ-

វិប្បយុត្តតោ ញាណសម្បយុត្តំ ពលវំ សសង្ខារិកតោ អសង្ខារិកំ ពលវំ សោមនស្សសហគតតោ ឧបេក្ខាសហគតំ ពលវំ *សេចក្តីថា បុគ្គលបានធ្វើបុណ្យឲ្យទាន រក្សាសីល ចម្រើនភាវនា ដោយកុសលចិត្តជាញាណសម្បយុត្តបានបុណ្យច្រើនមានកម្លាំងខ្លាំងជាងបុគ្គលដែលបានធ្វើបុណ្យឲ្យទានរក្សាសីល ចម្រើនភាវ-នាដោយកុសលចិត្តមានកម្លាំងខ្សោយជាញាណវិប្បយុត្ត បុគ្គលដែលបានធ្វើបុណ្យឲ្យទាន រក្សាសីលចម្រើនភាវនាដោយកុសលចិត្តជាអសង្ខារិកបានបុណ្យច្រើន មានកម្លាំងខ្លាំងជាងបុគ្គលដែលបានធ្វើបុណ្យ ឲ្យទានរក្សាសីល ចម្រើនភាវនា ដោយកុសលចិត្តមានកម្លាំងខ្សោយជាសសង្ខារិកបុគ្គលដែលបានធ្វើបុណ្យឲ្យទាន រក្សាសីល ចម្រើនភាវនា ដោយកុសល-ចិត្តប្រកបដោយឧបេក្ខាវេទនា បានបុណ្យច្រើនមានកម្លាំងខ្លាំងជាងបុគ្គលដែលបានធ្វើបុណ្យឲ្យទាន រក្សាសីល ចម្រើនភាវនាដោយកុសលចិត្តមានកម្លាំងខ្សោយប្រកបដោយសោមនស្សវេទនា។ វិសជ្ជនាមកអំពីកាមាវចរកុ-សលចិត្តទាំង ៨ ដែលមានផលានិសង្សផ្សេងគ្នាបានបុណ្យច្រើនមានកម្លាំងខ្លាំង បានបុណ្យតិចមានកម្លាំងខ្សោយ ជាសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។*

៤៧- ធម្មវាទី *បានស្តាប់ហើយពោលថា ម្នាលអត្តវាទី ប្រស្នា*

ដែលលោកវិសជ្ជនាមកនេះប្រពៃណាស់ហើយ តែយើងនៅមានសង្ស័យតទៅទៀត ត្រង់កាមាវចរកុសលចិត្តជាញាណសម្បយុត្តក្តី ញាណវិប្បយុត្តក្តី ជាអសង្ខារិកក្តី សសង្ខារិកក្តី នោះយើងមិនសង្ស័យឡើយ យើងសង្ស័យតែត្រង់ពាក្យថា កាមាវចរកុសលចិត្តដែលប្រកបដោយសោមនស្សវេទនា ថាជាកុសលចិត្តមានកម្លាំងខ្សោយ ដែលប្រកបដោយឧបេក្ខាវេទនា ថាជាកុសលចិត្តមានកម្លាំងខ្លាំង បើដូច្នេះបុគ្គលដែលបានឲ្យទានដោយកុសលចិត្តប្រកបដោយសោមនស្សវេទនានោះ បានតែត្រឹមបាដិបុគ្គលិកទានមិនកើតជាសង្ឃគតាទក្ខិណាទានទេ បុគ្គលដែលបានឲ្យទានដោយកុសលចិត្តប្រកបដោយឧបេក្ខាវេទនា ទើបបានកើតជាសង្ឃគតាទក្ខិណាទាន ឬដូចម្តេច? ចូរលោកវិសជ្ជនាឲ្យពិស្តារសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី សេចក្តីនេះជាសុខុមភាពដ៏ល្អិតជ្រាលជ្រៅពន់ពេកណាស់ អ្នកសិក្សាបរមត្ថព្រះអភិធម្ម គោងយកគម្ពីរបញ្ញា ប្រាជ្ញដ៏ល្អិតជ្រាលជ្រៅ មកពិចារណារំពឹងដញ្ញឹងមើលរឿយៗ ដោយសេចក្តីម៉ត់ចត់ ទើបអាចយកអត្ថរសចំពោះបរមត្ថព្រះអភិធម្មបាន ត្រូវត្រង់តាមពុទ្ធភាសិតសម្តែងថា កុសលចិត្តដែលប្រកប

ដោយសោមនស្សវេទនាជាចេតសិកធម៌រាក់ថ្នាក់ទី ២ មានគូ ជាចិត្តមានកម្លាំងខ្សោយ កុសលចិត្តដែលប្រកបដោយឧបេក្ខាវេទនាជាចេតសិកធម៌ថ្នាក់ទី ១ មានជម្រៅយ៉ាងឯកឥតគូ ជាចិត្តមានកម្លាំងខ្លាំង ព្រោះកុសល-ចិត្តដែលប្រកបដោយសោមនស្សវេទនានេះ ជាគូនឹងទោមនស្សវេទនាកើតឡើងអាស្រ័យនឹងទេយ្យវត្ថុសម្បត្តិគឺបរិបូណ៌ ដោយវត្ថុទេយ្យទានជាដើមក្តី បដិគ្គាហកសម្បត្តិគឺបរិបូណ៌ដោយបុគ្គលអ្នកទទួលមួយរូបៗជាទីស្រឡាញ់ពេញចិត្តជាដើមក្តី ទើបកើតសេចក្តីសោមនស្សបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានបាន បើមិនមានទេយ្យវត្ថុសម្បត្តិក្តី មិនមានបដិគ្គាហកសម្បត្តិក្តី នឹងបែរទៅជាកើតសេចក្តីទោមនស្សពុំបានបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានឡើយ ក៏កិច្ចដែលបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានបែបនេះ បានឈ្មោះថាបាដិបុគ្គលិកទាន គឺថាឲ្យទានចំពោះបុគ្គលផ្សេងៗតាមពេញចិត្ត តែក៏គង់បានផលានិសង្សតិចច្រើនជាអសង្ខេយ្យតាមលំ-ដាប់បុគ្គលដែលឥតគុណធម៌និងមានគុណធម៌តិចច្រើនទាំង ១៤ ពួកឬ ២១ ពួកដោយសេចក្តីពិស្តារនោះ ម្យ៉ាងទៀត កុសលចិត្តដែលប្រកបដោយសោមនស្សវេទនានេះ មិនបាននឹងទៀងទាត់ទេតែងរាយមាយប្រែប្រួលទៅផ្សេងៗ បើទុកជាមានប្រាថ្នានឹងធ្វើសង្ឃគតាទក្ខិណាទានក៏ធ្វើកម្រនឹង

កើតដែរ ព្រោះទាយកអ្នកមានប្រាថ្នានឹងធ្វើសង្ឃគតាទក្ខិណាទាន ធ្វើចិត្ត គោរពក្នុងព្រះសង្ឃបានដោយកម្រពន់ពេកណាស់ បើបានទៅសូមព្រះ ថេរៈមួយអង្គឲ្យគណសង្ឃចាត់មកឲ្យតាមពុទ្ធឱវាទ លុះដល់ភិក្ខុអ្នកកាន់ បញ្ជីបានចាត់សាមណេរឲ្យមកទទួលភត្តតាមបញ្ជីសង្ឃហើយ ទាយកទា-យិកាអ្នកឲ្យទានបានឃើញសាមណេរ និមន្តមកដល់ហើយ គិតថាអញ បានសាមណេរហើយ ក៏កើតចិត្តរាយមាយប្រកបដោយទោមនស្សតូច ចិត្តឲ្យទានដល់សាមណេរនោះ ក៏ពុំកើតជាសង្ឃគតាទក្ខិណាទានឡើយ ត្រឡប់ទៅជាបានឈ្មោះថាបាដិបុគ្គលិកទានទៅវិញ បើភិក្ខុអ្នកកាន់បញ្ជី បានចាត់ព្រះថេរៈមកឲ្យទទួលភត្ត ទាយកទាយិកាអ្នកឲ្យទានបានឃើញ ព្រះថេរៈនិមន្តមកដល់ ក៏កើតសេចក្តីសោមនស្សមានចិត្តត្រេកអរស្រស់ ស្រាយគិតថាអញបានព្រះថេរៈហើយ ក៏ឲ្យទានដល់ព្រះថេរៈនោះទៅ ពុំបានកើតជាសង្ឃគតាទក្ខិណាទានឡើយ ត្រឡប់ទៅជាបានឈ្មោះថា បាដិបុគ្គលិកទានទៅវិញដោយពិត ។ ឯកុសលចិត្តដែលប្រកបដោយ ឧបេក្ខាវេទនានេះជាចេតសិកធម៌សោយរសនៃឥដ្ឋារម្មណ៍ ស្មើនឹងនៅ ជាកណ្តាលក្នុងការបរិច្ចាគទ្រព្យឲ្យទាន មិនបានអាស្រ័យនូវទេយ្យវត្ថុ-សម្បត្តិនិងបដិគ្គាហកសម្បត្តិជាដើម ដូចសោមនស្សវេទនានោះឡើយ

ជាគ្រឿងប្រកបកើតព្រមជាមួយនឹងចិត្ត ឋិតនៅក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ មានអារម្មណ៍ប្រព្រឹត្តទៅជាកណ្តាល ជាទីប្រាថ្នាត្រេកអរកំណត់ត្រូវតាមឧបាយនៃបញ្ញា ជាទីតាំងមាំមិនកគ្រើកក្នុងកិច្ចបរិច្ចាគទ្រព្យឲ្យទានចំពោះស្មូមអ្នកសូមទានមិនរើសមុខ គឺថាមានទេយ្យទានច្រើន ឲ្យទានច្រើន មានទេយ្យទានតិច ឲ្យទានតិច ស្មើៗ គ្នាមិនប្រកាន់បុគ្គលឡើយ ម្យ៉ាងទៀតបើទាយកឯណាមានប្រាថ្នានឹងធ្វើសង្ឃគតាទក្ខិណាទាន ដែលជាទានមានផលានិសង្សច្រើនខ្ពង់ខ្ពស់បំផុត ហើយបានទៅសូមភិក្ខុមួយអង្គឲ្យគណសង្ឃចាត់មកឲ្យ លុះដល់ទាយកនោះបានឃើញនូវបុគ្គលឯណានីមួយ ទោះបីជាសាមណេរក្តី ភិក្ខុខ្ចីវស្សាក្តី ភិក្ខុចាស់វស្សាក្តី ភិក្ខុពាលក្តី ភិក្ខុជាបណ្ឌិតក្តី ដែលគណសង្ឃចាត់មកឲ្យហើយ ក៏ឥតមានសេចក្តីសង្ស័យចំពោះបុគ្គលនោះសោះ ធ្វើចិត្តគោរពចំពោះព្រះសង្ឃតែម្យ៉ាងប៉ុណ្ណោះ ហើយបានឲ្យទានចំពោះសង្ឃដោយគោរព បានឈ្មោះថាសង្ឃគតាទក្ខិណាទានដោយពិត ។ ពិនិត្យមើលតាមពុទ្ធឱវាទនេះឃើញថាបុគ្គលអ្នកឲ្យទានដោយកុសលចិត្ត ប្រកបដោយសោមនស្សវេទនាច្រើនបានតែជាបាដិបុគ្គលិកទាន បើប្រកបដោយឧបេក្ខាវេទនាទើបកើតជាសង្ឃគតាទក្ខិណាទានពិត ៗ ។ វិសជ្ជនាមកអំពីកុសលចិត្ត ដែលប្រកបដោយសោម-

នស្សវេទនានិងឧបេក្ខាវេទនាជាសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៤៨- ធម្មវាទី បានស្ដាប់ហើយពោលថា អើ! អត្ថវាទី ប្រស្នា ដែលលោកវិសជ្ជនាមកនេះយើងស្ដាប់បានហើយ តែយើងនឹងសួរត ទៅទៀត ។ ចុះសម្ដេចព្រះអនន្តញាណជាម្ចាស់ទ្រង់ត្រាស់សម្ដែងថា បុគ្គលជាសប្បុរសទាំងឡាយ ដែលបានធ្វើបុណ្យឲ្យទានចំពោះបុគ្គល ឬ ចំពោះសង្ឃដោយកាមាវចរកុសលចិត្តទាំង ៨ នោះ ថាបានបុណ្យតិច- បានបុណ្យច្រើន បានបុណ្យជាអសង្ខេយ្យ តើព្រះអង្គទ្រង់រំពឹងជញ្ជឹងយក ធម្មជាតអ្វីមកជាទីតាំង ទ្រង់គុណខែឡើងថាបានបុណ្យតិចចំនួនប៉ុន្មាន? ថាបានបុណ្យច្រើនចំនួនប៉ុន្មាន? ថាបានបុណ្យជាអសង្ខេយ្យរាប់ពុំបាន ស្មានមិនត្រូវនោះ ទ្រង់គុណដូចម្ដេច? ចូរលោកវិសជ្ជនាឲ្យពិស្ដារសព្វ គ្រប់មកយើងនឹងបានស្ដាប់ឲ្យចូលចិត្តដោយងាយផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី តាមន័យពុទ្ធភាសិតដែល អង្គព្រះអរហំសម្មាសម្ពុទ្ធ ទ្រង់សម្ដែងពន្យល់ដល់វេនេយ្យសត្វទាំងឡាយ ក្នុងបរមត្ថព្រះអភិធម្មដោយសេចក្ដីសព្វគ្រប់ថា សប្បុរសទាំងឡាយ ដែលបានឲ្យទានចំពោះបុគ្គល ទាំង ១៤ ពួកជាបាដិបុគ្គលិកទានដោយ សោមនស្សវេទនា នឹងបានបុណ្យតិច បានបុណ្យច្រើន តាមលំដាប់នៃ

បុគ្គលផ្សេងៗ ដូចអធិប្បាយតទៅនេះ បើទាយកទាយិកាទាំងឡាយបានឲ្យទានចំពោះបុគ្គល ៤ ពួកជាន់ទាបខាងដើមបានបុណ្យតិច ព្រោះព្រះអង្គទ្រង់កំណត់រាប់ផលានិសង្សគុណខែឡើង ដោយកំណត់រាប់ជាតិបានមិនឲ្យលើសខ្វះឡើយ គឺថាទី ១ បុគ្គលឲ្យទានចំពោះសត្វតិរច្ឆានមានសត្វឆ្កែជាដើម បានផលានិសង្សមួយរយគុណ ដោយគុណប្រាំ គឺបានសោយផលកើតជាមនុស្សមានអាយុវែងមួយរយជាតិ មានពណ៌សម្បុរល្អមួយរយជាតិ បានសេចក្តីសុខចិត្តឥតក្តៅក្រហាយសុខកាយឥតរោគមួយ-រយជាតិ មានកម្លាំងខ្លាំងមួយរយជាតិ មានប្រាជ្ញាអង់អាចមានសំដីដ៏វិចិត្រមួយរយជាតិ ត្រូវជាប្រាំរយជាតិគត់ ។ ទី ២ ឲ្យទានចំពោះបុគ្គលទ្រុស្តសីលបានផលានិសង្ស មួយពាន់គុណ ដោយគុណប្រាំដូចគ្នា ត្រូវជាប្រាំ-ពាន់ជាតិគត់ ។ ទី ៣ ឲ្យទានចំពោះបុគ្គលជាកណ្តាលនឹងថាជាបុគ្គលទ្រុស្តសីលក៏ទេ ថាជាបុគ្គលបានរក្សាសីលក៏ទេដែរ គ្រាន់តែជាបុគ្គលរកស៊ីចិញ្ចឹមជីវិតតាមសម្មាអាជីវៈប៉ុណ្ណោះ បានផលានិសង្ស មួយសែនគុណ ដោយគុណប្រាំដូចគ្នា ត្រូវជាប្រាំសែនជាតិគត់ ។ ទី ៤ ឲ្យទានចំពោះតាបសឫសីដែលជាអ្នកស្វែងរកគុណដ៏ប្រសើរ មានសីលគុណជាដើម បានលះបង់កាមគុណទាំងប្រាំជាស្រឡះ ចូលទៅនៅក្នុង

ព្រៃយកផ្នួសបួសជាតាបសបុសីចម្រើនព្រះកម្មដ្ឋាន បានផលានិសង្សមួយសែនកោដិគុណ ដោយគុណប្រាំដូចគ្នាដែរ ត្រូវជាប្រាំសែនកោដិជាតិគត់ ។ បើទាយកទាយិកាទាំងឡាយបានឲ្យទានចំពោះបុគ្គលទាំង ១០ ពួកជាន់ខ្ពស់ខាងលើគឺបុគ្គលដែលបានរក្សាសរណគមន៍ ៣ សីល ៥ សីលឧបោសថជាដើម ខំព្យាយាមប្រតិបត្តិដើម្បីសម្រេចសោតាបត្តិមគ្គ ១ សោតាបត្តិផល ១ សកិទាគាមិមគ្គ ១ សកិទាគាមិផល ១ អនាគាមិមគ្គ ១ អនាគាមិផល ១ អរហត្តមគ្គ១ អរហត្តផល ១ ព្រះបច្ចេកពុទ្ធ ១ ព្រះសម្មាសម្ពុទ្ធ ១ ត្រូវជាបុគ្គល ១០ ពួកជាន់ខ្ពស់ខាងលើ សេចក្តីអធិប្បាយថា បើទាយកទាយិកាទាំងឡាយ បានឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិដើម្បីសម្រេចសោតាបត្តិមគ្គមួយដង បានផលានិសង្សច្រើនជាងឲ្យទានដល់តាបសបុសី ១ រយដង បានឲ្យទានចំពោះបុគ្គលដែលបានឋិតនៅក្នុងសោតាបត្តិផល ១ ដង បានផលានិសង្សច្រើនជាងឲ្យទានដល់បុគ្គលដែលប្រតិបត្តិដើម្បីសម្រេចសោតាបត្តិមគ្គ ១ រយដង បានឲ្យទានចំពោះបុគ្គលដែលបានឋិតនៅក្នុងសកិទាគាមិមគ្គ ១ ដង បានផលានិសង្សច្រើនជាងឲ្យទានដល់បុគ្គលដែលបានឋិតនៅក្នុងសោតាបត្តិផល ១ រយដង បានឲ្យទានចំពោះបុគ្គលដែលបានឋិតនៅក្នុងសកិទាគាមិផល ១

ជង បានផលានិសង្សច្រើនជាងឲ្យទានដល់បុគ្គលដែលឋិតនៅក្នុងសកិទា-គាមិមគ្គ ១ រយដង បានឲ្យទានចំពោះបុគ្គលដែលបានឋិតនៅក្នុងអនាគាមិ-មគ្គ១ជង បានផលានិសង្សច្រើនជាងឲ្យទានដល់បុគ្គលដែលឋិតនៅក្នុងសកិ-ទាគាមិផល ១ រយដង បានឲ្យទានចំពោះបុគ្គលដែលបានឋិតនៅក្នុងអ-នាគាមិផល ១ ជង បានផលានិសង្សច្រើនជាងឲ្យទានដល់បុគ្គលឋិតនៅក្នុង អនាគាមិមគ្គ ១ រយដង បានឲ្យទានចំពោះបុគ្គលដែលឋិតនៅក្នុង អរហត្តមគ្គ ១ ជង បានផលានិសង្សច្រើនជាងឲ្យទានដល់បុគ្គលឋិតនៅក្នុង អនាគាមិផល ១ រយដង បានឲ្យទានចំពោះបុគ្គលដែលឋិតនៅក្នុង អរហត្តផល ១ ជង បានផលានិសង្សច្រើនជាងឲ្យទានដល់បុគ្គលឋិតនៅ ក្នុងអរហត្តមគ្គ ១ រយដង បានឲ្យទានចំពោះព្រះបច្ចេកពុទ្ធ ១ ជង បាន ផលានិសង្សច្រើនជាងឲ្យទានដល់ព្រះអរហត្តផល ១ រយដង បានឲ្យទាន ចំពោះព្រះសម្មាសម្ពុទ្ធ ១ ជង បានផលានិសង្សច្រើនជាងឲ្យទានដល់ព្រះ បច្ចេកពុទ្ធ ១ រយដង ទានដែលឲ្យចំពោះបុគ្គលទាំង ១០ ពួកនោះបាន ឈ្មោះថាបាដិបុគ្គលិកទាន ឲ្យទានចំពោះបុគ្គលផ្សេងៗ ជាទានមានផលា-និសង្សតិចឬច្រើន តាមលំដាប់នៃបដិគ្គាហកៈអ្នកទទួលទាន ដែលឥតគុណ-វិសេសក្នុងខ្លួន និងមានគុណវិសេសក្នុងខ្លួនជាន់ទាប ជាន់កណ្តាល ជាន់ខ្ពស់ ដូចបានអធិប្បាយមកខាងលើនេះស្រេចហើយ តែត្រង់ពាក្យ

ថាបានផលានិសង្សច្រើននេះ ព្រះពុទ្ធញាណកំណត់ជាតិកំណើតពុំបាន ដោយព្រះអង្គទ្រង់រំពឹងឃើញយល់ច្បាស់ថា ទាយកទាយិកាទាំងឡាយ ដែលបានឲ្យទានចំពោះបុគ្គលទាំង ១០ នេះ ចំពោះបុគ្គលណាមួយនឹង បានសោយផលានិសង្សច្រើនជាសុខក្សេមក្សាន្ត ហូរជូនមកពុំបានដាច់ ជាអនេកជាតិរាប់ជាតិកំណើតពុំអស់ឡើយ ហើយព្រះអង្គទ្រង់សរសើរ ថាបានបុណ្យជាអសង្ខេយ្យ ព្រោះមានផលានិសង្សហូរជូនមកពុំចេះ អស់ដរាបដល់បានសម្រេចព្រះនិព្វានជាឯកន្តសុខក្នុងកាលណា ទើប អស់ផលានិសង្សក្នុងកាលនោះឯង ។ បើទាយកទាយិកាទាំងឡាយបាន ឲ្យទានចំពោះព្រះសង្ឃទាំង ៧ ពួកមានពុទ្ធប្បមុខឧភតោសង្ឃជាដើមក្ដី បានឲ្យវិហារទានមានរោងឧបោសថជាដើម ចំពោះព្រះសង្ឃដែល មកអំពីទិសទាំងបួនក្ដី នឹងបានសោយផលានិសង្សច្រើនជាអសង្ខេយ្យ ដ៏ឧត្ដមខ្ពង់ខ្ពស់វិសេសជាងបាដិបុគ្គលិកទាន ១ រយគុណដោយពិត ។ ទើបទាយកទាយិកាទាំងឡាយបានឲ្យទាន ចំពោះភិក្ខុមួយរូបៗ បាន ឈ្មោះថាបុគ្គលិកទាន បានឲ្យទានចំពោះភិក្ខុ ២ រូប ៣ រូបបានឈ្មោះថា គណិកទាន បានឲ្យទានចំពោះភិក្ខុ ៤ រូបជាដើមឡើងទៅ បានឈ្មោះថា សង្ឃគតាទក្ខិណាទាន ឬថាបានឲ្យទានដល់ភិក្ខុ ១ រូបក្ដី ២ រូបក្ដី ៣ រូប

ក្តី ដែលខ្លួនបានចូលទៅសូមសង្ឃឲ្យគណៈចាត់ឲ្យមក ក៏គង់បាន ឈ្មោះថាសង្ឃគតាទក្ខិណាទានដែរ ។ ម៉្យាងទៀត នយកោវិទោ អ្នកប្រាជ្ញ ដែលឆ្លៀវឆ្លាសវាងវៃក្នុងន័យបរមត្ថព្រះអភិធម្ម ត្រូវយកកាមាវចរកុសល-ចិត្តទាំង ៨ មកគុណដោយបុញ្ញកិរិយាវត្ថុ ១០ ផ្សេងៗ គ្នា គឺយកកុសល-ចិត្តមួយៗ គុណឡើងជាលំដាប់ៗ ដោយបុញ្ញកិរិយាវត្ថុ ១០ ត្រូវជាកាមាវចរ បុណ្យ ៨០ គត់ ហើយយកកាមាវចរបុណ្យទាំង ៨០ មកគុណដោយ អារម្មណ៍ទាំង ៦ ផ្សេងៗ គ្នា ក្នុងអារម្មណ៍មួយៗ ៨០ ៗ ត្រូវជា ៤៨០ គត់ យកបុណ្យដែលកើតអំពីកុសលចិត្ត ៤៨០ ជាញាណវិប្បយុត្តមក គុណនឹងអធិបតី ៤ ត្រូវជា ៩៦០ គត់ យកបុណ្យដែលកើតអំពីកុសលចិត្ត ៤៨០ ជាញាណសម្បយុត្តគុណនឹងអធិបតី ៤ ត្រូវជា ៩៦០ គត់ បូករួមអធិបតី ៤ ទាំងពីរផ្នែកត្រូវជាបុណ្យ ១៩២០ គត់ យកបុណ្យ ១៩២០ មកគុណជា ៣ ដោយកាយកម្ម វចីកម្ម មនោកម្ម ត្រូវជា ៥៧៦០ គត់ យកបុណ្យ ៥៧៦០ មកគុណជា ៣ ដោយហីនៈ មជ្ឈិមៈ បណីតៈ ត្រូវជាបុណ្យ ១៧២៨០ គត់ សម្រេចព្រមក្នុងកាលដែលទាយក ទាយិកាទាំងឡាយ បានធ្វើបុណ្យឲ្យទានមួយលើកៗ ដោយពិត បើ កំណត់រាប់ផលានិសង្សដោយសុខុមភាពដ៏ល្អិត ជ្រាលជ្រៅដោយប្រភេទ

ផ្សេងៗ មានកាលៈទេសៈជាដើម បានបុណ្យសុទ្ធតែជាអសង្ខេយ្យតូច អសង្ខេយ្យធំជាលំដាប់ៗ ទៅមែនពិត ។ វិសជ្ជនាអំពីសប្បុរសទាំងឡាយ ដែលធ្វើបុណ្យឲ្យទានក្នុងកាលមួយលើកៗ អាចញ៉ាំងកាមាវចរកុសលចិត្តទាំង ៨ ឲ្យកើតឡើងក្នុងសន្តានខ្លួន បានបុណ្យតិច បុណ្យច្រើន បុណ្យជាអសង្ខេយ្យដោយសង្ខេបតែប៉ុណ្ណោះឯង ។

៤៩- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះត្រូវហើយ តែយើងនៅសង្ស័យពាក្យពីរម៉ាត់ទៀតដែលលោកវិសជ្ជនាមកថា បុគ្គលអ្នកធ្វើបុណ្យឲ្យទាន បានបុណ្យជាអសង្ខេយ្យតូច ជាអសង្ខេយ្យធំ ដូចជាអសង្ខេយ្យនោះ មានច្រើនយ៉ាងផ្សេងៗគ្នា តើពាក្យថាបានបុណ្យជាអសង្ខេយ្យៗនោះចែកទៅទៀតមានប៉ុន្មាន? មានសេចក្តីឧបមាដូចម្តេច? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ត្រង់ពាក្យថាបុគ្គលអ្នកធ្វើបុណ្យឲ្យទានហើយបានបុណ្យជាអសង្ខេយ្យៗ នោះ ចែកទៅជា ៣ យ៉ាងគឺជាអសង្ខេយ្យតូច ១ អសង្ខេយ្យកណ្តាល ១ អសង្ខេយ្យធំ ១ បើទាយកទាយិកាបានឲ្យទានដល់បដិគ្គាហកៈ អ្នកទទួលមានគុណធម៌

ក្នុងខ្លួនជាន់ទាប បានបុណ្យជាអសង្ខេយ្យតូច បានឲ្យទានដល់បដិគ្គាហ-ក: អ្នកទទួលមានគុណធម៌ក្នុងខ្លួនជាន់កណ្ដាល បានបុណ្យជាអសង្ខេយ្យកណ្ដាល បានឲ្យទានដល់បដិគ្គាហក: អ្នកទទួលមានគុណធម៌ក្នុងខ្លួនជាន់ខ្ពស់ បានបុណ្យជាអសង្ខេយ្យធំខ្ពង់ខ្ពស់ដែរ មានសេចក្ដីឧបមាដូចបុរសអ្នកចេះចំណានខាងវិជ្ជាវាល់វត្ថុផ្សេងៗ បានវាល់ទឹកស្ទឹងដែលមានខ្សែទឹកហូរមកជាប់មិនដាច់ ដោយរង្វាល់មានថាំងជាដើម ដងទឹកអំពីស្ទឹងចាក់ទៅក្នុងទីដទៃកំណត់រាប់ថា ១ ថាំង ២ ថាំងដរាបដល់ ១ សែនកោដិថាំង ឃើញថាមិនចេះរលស់ស្រកទឹកពីស្ទឹងតូចនោះសោះហើយលាន់វាចាថា ទឹកស្ទឹងនេះវាល់រាប់ពុំអស់ទេ ច្រើនណាស់ ជាអសង្ខេយ្យ បុរសនោះបានទៅវាល់ទឹកទន្លេធំជាកណ្ដាលទៀត ក៏ឃើញថាវាល់រាប់ពុំអស់ជាអសង្ខេយ្យដូចគ្នា បានទៅវាល់រាប់ទឹកសមុទ្រធំទៀត ក៏ឃើញថាវាល់រាប់ពុំអស់ច្រើនណាស់ជាអសង្ខេយ្យដូចគ្នាដែរ មានសេចក្ដីឧបមាយ៉ាងណា បុគ្គលដែលមានបសាទសទ្ធា ជឿកម្ម ជឿផលដ៏ជ្រះថ្លាស្អាត បានឲ្យទានចំពោះបុគ្គលដែលមានគុណធម៌ក្នុងខ្លួនជាន់ទាប ក៏គង់បានបុណ្យរាប់ពុំបានស្មានពុំត្រូវ ដោយអានិសង្សហូរជូនមកជាប់ពុំដាច់ជាអសង្ខេយ្យតូច ដូចបុរសអ្នកវាល់រាប់ទឹកស្ទឹងតូចនោះដែរ បុគ្គល

ដែលបានឲ្យទានចំពោះបុគ្គល ដែលមានគុណធម៌ក្នុងខ្លួនជាន់កណ្តាល ក៏គង់បានបុណ្យរាប់ពុំបាន ស្មានពុំត្រូវ ដោយអានិសង្សហូរជូនមកជាប់ពុំដាច់ជាអសង្ខេយ្យកណ្តាល ដូចបុរសអ្នកវាល់រាប់ទឹកទន្លេធំជាកណ្តាលនោះដែរ បុគ្គលដែលបានឲ្យទានចំពោះបុគ្គលដែលមានគុណធម៌ក្នុងខ្លួនជាន់ខ្ពស់ ក៏គង់បានបុណ្យរាប់ពុំបានស្មានពុំត្រូវ ដោយអានិសង្សហូរជូនមកជាប់ពុំដាច់ជាអសង្ខេយ្យធំខ្ពង់ខ្ពស់ តាមលំដាប់នៃបដិគ្គាហកៈ លោកអ្នកទទួលទាន ដូចជាបុរសអ្នកវាល់រាប់ទឹកសមុទ្រធំនោះដែរ ឯលោកអ្នកប្រាជ្ញទាំងឡាយមានព្រះអរហំសម្មាសម្ពុទ្ធជាដើម លោកតែងកំណត់រាប់ផលានិសង្សនៃទាយកទាយិកាទាំងឡាយ ដែលមានសទ្ធាជឿកម្ម ជឿផលមាំមួន បានបរិច្ចាគទ្រព្យឲ្យទានចំពោះបុគ្គលផ្សេងៗ និងចំពោះព្រះសង្ឃ ថាបានបុណ្យជាអសង្ខេយ្យតូច ជាអសង្ខេយ្យកណ្តាល ជាអសង្ខេយ្យធំខ្ពង់ខ្ពស់ មានសេចក្តីឧបមេយ្យដូចបុរសអ្នកវាល់រាប់ទឹកស្ទឹង ទឹកទន្លេ និងទឹកសមុទ្រនោះឯង ។

៩០- ធម្មវាទី បានស្តាប់ហើយពោលថា សាធុៗ ម្នាលអត្តវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃណាស់ហើយ យើងបានបុច្ឆាវិសជ្ជនាគ្នាអំពីកាមាវចរសោភណចិត្តទាំង ២៤ មកនេះ ក៏ល្មមសមគួរ

ស្តាប់បានហើយ នឹងបញ្ចប់សេចក្តីប៉ុណ្ណោះសិនចុះ ។ តអំពីនេះ យើងនឹងសួរអំពីរូបាវចរសោភណចិត្តទាំង ១៥ តទៅទៀត តែត្រង់រូបាវចរ-វិបាកចិត្តនិងរូបាវចរកិរិយាចិត្តនោះយើងមិនបានសួរទេ ព្រោះពាក្យថាវិបាកចិត្តនិងកិរិយាចិត្តនោះ យើងបានសួរឲ្យលោកវិសជ្ជនាមកក្នុងកាមា-វចរវិបាកចិត្ត-កិរិយាចិត្តសព្វគ្រប់ហើយ ឃើញថាសេចក្តីដូចគ្នាទេ យើងសួរតែត្រង់រូបាវចរកុសលចិត្តទាំងប្រាំតែប៉ុណ្ណោះ ។ ចុះរូបាវចរ-កុសលចិត្តនោះបានខាងបុគ្គលពួកណា? ប្រព្រឹត្តធ្វើដូចម្តេច? ក្នុងរូបាវចរ-កុសលចិត្តមួយៗ មានសេចក្តីអធិប្បាយថាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯរូបាវចរកុសលចិត្តទាំងប្រាំនោះបានខាងព្រះយោគាវចរកុលបុត្ត ដែលបានពិចារណាឃើញនូវទោសនៃនីវរណធម៌ទាំងប្រាំថាជាសត្រូវ អាចបិទបាំងរាំងផ្លូវមិនឲ្យសត្វទាំង-ឡាយ ត្រាច់ទៅសោយសុខរបស់មនុស្ស សុខរបស់ទេវតា សុខក្នុងព្រះនិព្វានបានឡើយ ហើយបើកផ្លូវឲ្យសត្វទាំងឡាយត្រាច់ទៅសោយទុក្ខលំបាកក្នុងនរក ប្រេត អសុរកាយ តិរច្ឆាន គឺ ១- កាមច្ឆន្ទ សេចក្តីប្រាថ្នាត្រេកត្រអាលក្នុងកាមគុណ ទាំងប្រាំមានរូបជាដើម លុះទៅតាម

អំណាចតណ្ហាដឹកនាំ, ២- ព្យាបាទ សេចក្តីក្រោធខឹងគំនុំគុំកួនធ្វើប្រយោជន៍របស់បុគ្គលដទៃឲ្យវិនាស ឬថា ធ្វើបុគ្គលដទៃឲ្យអន្តរាយជីវិតប្រកបដោយអាឃាតវត្ថុទាំង៩, ៣- ថីនមិទ្ធ សេចក្តីខ្ជិលច្រអូសមិនមានឧស្សាហ៍ព្យាយាមខ្វល់ខ្វាយនិងងងុយងោកច្រើន ៤- ឧទ្ធច្ចកុក្កុច្ច មានចិត្តរាយមាយហុយឡើងដូចផេះត្រូវខ្យល់ ឬដូចផ្សែងភ្លើង និងសេចក្តីក្តៅក្រហាយស្តាយក្រោយដោយគិតថា អំពើលាមកអាក្រក់អញធ្វើជ្រុលហើយ អំពើល្អអញពុំបានធ្វើឡើយ, ៥- វិចិកិច្ឆា សេចក្តីសង្ស័យប្រកបដោយវត្ថុទាំង ៨ មានសង្ស័យក្នុងគុណព្រះពុទ្ធជាដើម ត្រូវជានីវរណធម៌ទាំងប្រាំ ជាសត្រូវដល់កុសលធម៌ទាំងពួងមានឈានជាដើម ព្រះយោគីកុលបុត្ត អ្នកមានព្យាយាមមាំបានពិចារណាឃើញទោសនោះហើយក៏ខំព្យាយាមលះបង់នីវរណធម៌ទាំងប្រាំ ខំប្រឹងប្រែងព្យាយាមចម្រើនភាវនា នូវបណ្តាសមថកម្មដ្ឋានទាំង ៤០ នោះ សមថកម្មដ្ឋានឯណាមួយ ឬនូវវិបស្សនាកម្មដ្ឋានក្តីដែលជាធម៌សម្រាប់រម្ងាប់នីវរណធម៌ទាំងប្រាំបាន ហើយញុំាងបឋមជ្ឈានកុសលចិត្តឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួន គឺកុសលចិត្តព្រមទាំងចេតសិកកើតរលត់ជាមួយគ្នាដោយបឋមជ្ឈាន ទី ១ ប្រកបដោយអង្គ ៥ គឺ ១- វិតក្កោ សេចក្តីត្រិះរិះ

លើកចិត្តដាក់ទៅក្នុងអារម្មណ៍នៃព្រះកម្មដ្ឋានឯណានីមួយ ។ ២- វិចារៈ ញុំាងចិត្តឲ្យត្រាច់ទៅក្នុងអារម្មណ៍នៃព្រះកម្មដ្ឋាន មានកិរិយាពិចារណា ដុសខាត់នូវអារម្មណ៍ជាលក្ខណៈ ។ ៣- បីតិ ធម្មជាតិញុំាងកាយនិងចិត្ត ឲ្យឆ្អែតចម្រើនឡើង មានការប្រកបដោយសេចក្ដីត្រេកអរពេញចិត្ត និង កាន់យកនូវអារម្មណ៍ដ៏ស្រាលរហ័សជាលក្ខណៈ មាន ៥ គឺ ខុទ្ទកាបីតិ សេចក្ដីអំណរពេញចិត្តធ្វើឲ្យព្រឺក្បាល ព្រឺខ្លួនប្រកបដោយរស្មីមានពណ៌ ខៀវកើតឡើងប្រាកដត្រង់ទ្រូងកែ្នកឬត្រង់ហទយវត្ថុ ១, ខណិកាបីតិ សេចក្ដីអំណរពេញចិត្តធ្វើឲ្យព្រឺៗ ព្រួចៗ ហើយបាត់ទៅប្រកបដោយ រស្មីមានពណ៌សផ្ទេកៗ ដូចរលកទឹកកើតឡើងប្រាកដត្រង់ទ្រូងកែ្នកឬ ត្រង់ហទយវត្ថុ ១, ឱក្កន្តិកាបីតិ សេចក្ដីអំណរពេញចិត្តធ្វើឲ្យស្ទុង កាយ-ចិត្ត ប្រកបដោយរស្មីមានពណ៌ប្រាលដូចភ្លឺភ្លើងកើតឡើងប្រាកដ ត្រង់ទ្រូងកែ្នកឬត្រង់ហទយវត្ថុ ១, ឧព្វេង្គាបីតិ សេចក្ដីអំណរពេញចិត្ត ធ្វើឲ្យហាក់អណ្ដែតខ្លួន បើចម្រើនខ្លាំងអាចបណ្ដែតទាំងខ្លួនឡើងទៅ ប្រកបដោយរស្មីមានពណ៌លឿង កើតឡើងប្រាកដត្រង់ទ្រូងកែ្នកឬត្រង់ ហទយវត្ថុ ១, ផរណាបីតិ សេចក្ដីអំណរពេញចិត្ត ធ្វើឲ្យធំទូលាយចិត្ត ហាក់ដូចរីកខ្លួនធំឡើងប្រកបដោយរស្មីមានពណ៌សដូចសំឡី កើតឡើង

ប្រាកដត្រង់វង្វេនក្អែកឬត្រង់ហទយវត្ថុ ១ ។ ៤- សុខំ ប្រព្រឹត្តទៅដោយស្រួលក្នុងសម្បយុត្តធម៌មានសោយនូវរសនៃអារម្មណ៍ ជាទីត្រេកអរពេញចិត្តជាលក្ខណៈ ដូចជាព្រះរាជាមានព្រះរាជហ្ឫទ័យជ្រះថ្លាសោយនូវភោជនមានឱជារសដ៏ឆ្ងាញ់ ។ ៥- ឯកគ្គតា ភាវៈនៃចិត្តដ៏ប្រសើរ មានអារម្មណ៍តែមួយតម្កល់មាំមិនបានរវើរវាយ ដោយអារម្មណ៍ផ្សេងៗ បានឈ្មោះថា បឋមជ្ឈានកុសលចិត្ត ។

ទី ២- ទុតិយជ្ឈានកុសលចិត្ត មានសេចក្ដីអធិប្បាយដូចបឋមជ្ឈានកុសលចិត្តទី ១ នោះដែរ ប្លែកផ្សេងគ្នាតែអង្គ ព្រោះទុតិយជ្ឈានកុសលចិត្តនេះប្រកបដោយអង្គ ៤ គឺ ១- វិចារៈ ២- បីតិ ៣- សុខៈ ៤- ឯកគ្គតា ត្រូវជាអង្គ ៤ បានឈ្មោះថា ទុតិយជ្ឈានកុសលចិត្ត ។

ទី ៣- តតិយជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ៣ គឺ ១- បីតិ ២- សុខៈ ៣- ឯកគ្គតា ត្រូវជាអង្គ ៣ បានឈ្មោះថា តតិយជ្ឈានកុសលចិត្ត ។

ទី ៤- ចតុត្ថជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ២ គឺ ១- សុខៈ ២- ឯកគ្គតា ជាអង្គ ២ បានឈ្មោះថា ចតុត្ថជ្ឈានកុសលចិត្ត ។

ទី ៥- បញ្ចមជ្ឈានកុសលចិត្ត ប្រកបដោយអង្គ ២ គឺ ១- ឧបេក្ខា

ធម្មជាតិសម្ងឹងមើលមាំ គឺជាធម្មជាតិប្រព្រឹត្តរម្ងាប់នូវនីវរណធម៌ទាំងប្រាំបាន យ៉ាងចុះជាខាងក្នុងៗ សេចក្ដីស្រួលកាយស្រួលចិត្តគឺបណ្ឌិតពោលថាសេចក្ដីសុខយ៉ាងសំខាន់ដោយពិត, ២- ឯកគ្គតា ភាវៈនៃចិត្តដ៏ប្រសើរមានអារម្មណ៍តែមួយ តម្កល់មាំ មិនបានរវើរវាយដោយអារម្មណ៍ផ្សេងៗ ជាអង្គ ២ បានឈ្មោះថាបញ្ចមជ្ឈានកុសលចិត្ត ។

ម្យ៉ាងវិញទៀត ព្រះយោគីកុលបុត្ត ដែលនឹងធ្វើឈានទាំងនេះឲ្យកើតឡើងបានក្នុងសន្តានរបស់ខ្លួននោះ ត្រូវលះបង់នីវរណធម៌ទាំងប្រាំឲ្យស្រឡះហើយខំព្យាយាមឲ្យមាំមួនប្រកបដោយធម៌ ២ យ៉ាងជាដើម គឺភាវនា ខំចម្រើននូវព្រះកម្មដ្ឋានសមគួរតាមចរិតរបស់ខ្លួន ១, សមាធិតម្កល់ចិត្តឲ្យមាំ នឹងនៅក្នុងអារម្មណ៍ នៃព្រះកម្មដ្ឋានដែលខ្លួនបានរៀនមកហើយមិនឲ្យនីវរណធម៌ទាំង ៥ ចូលមកបៀតបៀនបាន ១ ទើបអាចញុំាងឈានទាំងនេះឲ្យកើតឡើងក្នុងសន្តានរបស់ខ្លួនបាន ដោយពិត ។ វិសជ្ជនាមកអំពីរូបាវចរកុសលចិត្តទាំង ៥ ដោយសង្ខេបតែប៉ុណ្ណេះឯង ។

៥១- ធម្មវាទី បានស្ដាប់ហើយពោលថា ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះត្រឹមត្រូវហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ។ ចុះពាក្យថា សមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋាននោះមាន

សេចក្ដីអធិប្បាយដូចម្ដេច? សមថកម្មដ្ឋានទាំង ៤០ នោះគឺកម្មដ្ឋានអ្វីខ្លះ? ចូរលោកវិសជ្ជនាអំពីពាក្យថាសមថកម្មដ្ឋាន វិបស្សនាកម្មដ្ឋាននិងរាប់ចំនួនកម្មដ្ឋានទាំង ៤០ ព្រមទាំងពាក្យប្រែអធិប្បាយឲ្យសព្វគ្រប់មកយើងនឹងបានស្ដាប់ចូលចិត្តផងមើល ។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី សេចក្ដីអធិប្បាយថា ចិត្តកាន់យកនូវអារម្មណ៍ទាំងឡាយមានបឋវីកសិណារម្មណ៍ជាដើម មកជាទីតាំងបរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្ត ភាវនាឲ្យរឿយៗ រម្ងាប់នូវនីវរណធម៌បានហើយ ញុំាងឧបចារសមាធិនិងអប្បនាសមាធិឲ្យកើតឡើងប្រាកដ បានឈ្មោះថា សមថកម្មដ្ឋាន ។ ព្រះយោគាវចរកុលបុត្របានចម្រើនភាវនាដោយបញ្ញាពិចារណាឃើញដោយអាការផ្សេងៗ មានអនិច្ចលក្ខណៈ ទុក្ខលក្ខណៈ អនត្តលក្ខណៈ ជាដើមជាអារម្មណ៍ បានឈ្មោះថា វិបស្សនាកម្មដ្ឋាន ដោយពិត ។ ឯចំនួនសមថកម្មដ្ឋានទាំង ៤០ នោះគឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ សញ្ញា ១ វវដ្ឋាន ១ អរូប ៤ ត្រូវជា ៤០ គត់ ។ សេចក្ដីអធិប្បាយថា កសិណទាំង ១០ នោះ ចែកទៅជាភូតកសិណ ៤ គឺ ១- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា បឋវី ៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពី

មណ្ឌលនៃដីជាអារម្មណ៍ ក្នុងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា បឋវីកសិណ ។ ២- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា អាបោៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃទឹកជាអារម្មណ៍ក្នុងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា អាបោកសិណ ។ ៣- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា តេជោៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃភ្លើងជាអារម្មណ៍ក្នុងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា តេជោកសិណ ។ ៤- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា វាយោៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតអំពីមណ្ឌលនៃខ្យល់ជាអារម្មណ៍ក្នុងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា វាយោកសិណ ។ ចែកទៅជាវណ្ណកសិណ ៤ គឺ ៥- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា នីលំៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃផ្កាឬសំពត់ មានពណ៌ខៀវជាអារម្មណ៍ក្នុងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា នីលកសិណ ។ ៦- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា បីតំៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃផ្កាឬសំពត់ មានពណ៌លឿងជាអារម្មណ៍ក្នុង

មនោទ្វារ ដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា បីតកសិណ ។ ៧- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា លោហិតំៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃផ្កាឬសំពត់ មានពណ៌ក្រហមជាអារម្មណ៍ក្នុងមនោទ្វារដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា លោហិតកសិណ ។ ៨- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា ឱទាតំៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃផ្កាឬសំពត់មានពណ៌សជាអារម្មណ៍ក្នុងមនោទ្វារ ដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា ឱទាតកសិណ ។ ៩- បរិកម្មចម្រើនធ្វើកំណត់អាកាសទីវាលទទេទុកក្នុងចិត្តភាវនាថា អាកាសោៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃអាកាស ជាអារម្មណ៍ក្នុងមនោទ្វារ ដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា អាកាសកសិណ ។ ១០- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តដោយអំណាចនៃពន្លឺមានពន្លឺព្រះចន្ទ្រជាដើមភាវនាថា អាលោកោៗ សម្លឹងយកឧគ្គហនិមិត្តដែលកើតមកអំពីមណ្ឌលនៃពន្លឺជាអារម្មណ៍ក្នុងមនោទ្វារ ដោយចក្ខុបញ្ញាជាទីត្រេកអរនៃចិត្ត បានឈ្មោះថា អាលោកកសិណ ។ កសិណទាំង ១០ នេះ សម្រេចដល់ឧបចារសមាធិនិងអប្បនាសមាធិ បានរហូតបញ្ច-

មជ្ឈានដោយពិត ។

អសុភ ១០ នោះគឺ ១- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា ឧទ្ធុមាតកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសព[១] មានសរីរៈស្រស់គួរខ្ពើមហើមប៉ោងឡើងជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថាឧទ្ធុមាតកៈ ។ ២- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា វិនីលកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈស្រស់ហើមខ្លាំង មានពណ៌ខៀវផ្សេងៗ ដោយច្រើនជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា វិនីលកៈ ។ ៣- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា វិបុព្វកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសពមានខ្ទុះហូរចេញផ្សេងៗ ជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា វិបុព្វកៈ ។ ៤- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា វិច្ឆិទ្ទកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈដែលបុគ្គលកាត់ដាច់ពាក់កណ្តាលជាពីរកំណាត់ជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា វិច្ឆិទ្ទកៈ ។ ៥- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា វិក្ខាយិតកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈ

១- ដែលហៅថា “សាកអសុភ” តែក្នុងវិបតានុក្រមថា “សាកសព” ដូច្នេះវិញ ។

ស្រស់ដែលសត្វក្អែក ក្អែក ចចកជាដើម ទំពាស៊ីហើយជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា វិក្ខាយិតកៈ ។ ៦- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា វិក្ខិត្តកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសពមានសរីរៈស្រស់ជារំពាដែលសត្វក្អែ ចចកជាដើម ទំពាស៊ីចោលហើយរាត់រាយជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា វិក្ខិត្តកៈ ។ ៧- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា ហតវិក្ខិត្តកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសពមានសរីរៈស្រស់ ដែលបុគ្គលកាត់ចិញ្ច្រាំដាច់ជាកំណាត់តូច ធំដោយកាំបិត ហើយចោលផ្សេងៗ ជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា ហតវិក្ខិត្តកៈ ។ ៨- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា លោហិតកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសពមានសរីរៈ ស្រស់ ប្រឡាក់ដោយឈាមក្រហមច្រាលដែលបុគ្គលកាត់ដាច់ហើយថ្មីៗ ជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា លោហិតកៈ ។ ៩- បរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តភាវនាថា បុឡុវកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសព មានសរីរៈស្រស់លាយប្រឡំដោយត្រកូលនៃសត្វដង្កូវទាំងឡាយហូរចេញពុំដាច់ ជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា បុឡុវកៈ ។ ១០- បរិកម្មចម្រើនធ្វើ

កំណត់ទុកក្នុងចិត្តភាវនាថា អដ្ឋិកំៗ រំពឹងកាន់យកឧគ្គហនិមិត្តដែលកើតមកអំពីសាកសពមានតែរាងឆ្អឹងទទេជាអារម្មណ៍ជាទីសង្វេគ បានឈ្មោះថា អដ្ឋិកៈ ។ អសុភទាំង ១០ នេះ សម្រេចដល់ឧបចារសមាធិនិងអប្បនាសមាធិ បានត្រឹមតែបឋមជ្ឈានប៉ុណ្ណោះ ។

អនុស្សតិទាំង ១០ នោះ គឺ ១- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវព្រះពុទ្ធគុណទាំង ១០ រំពឹងភាវនាថា សោ ភគវា ឥតិបិ អរហំ សោ ភគវា ឥតិបិ អរហំ, សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ សោ ភគវា ឥតិបិ សម្មាសម្ពុទ្ធោ ។ ល ។ សោ ភគវា ឥតិបិ ពុទ្ធោ សោ ភគវា ឥតិបិ ពុទ្ធោ, សោ ភគវា ឥតិបិ ភគវា សោ ភគវា ឥតិបិ ភគវា ឬថារំពឹងភាវនាឲ្យខ្លីតិចចុះមកថា អរហំ អរហំ សម្មាសម្ពុទ្ធោ សម្មាសម្ពុទ្ធោ ។ ល ។ ពុទ្ធោ ពុទ្ធោ ភគវា ភគវា តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្វិលជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងព្រះពុទ្ធគុណជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បានមានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សេងៗ ផ្សាយចេញទៅតាមកាយទ្វារសម្រេចបានត្រឹមឧបចារសមាធិ បានឈ្មោះថា ពុទ្ធានុស្សតិ ។ ២- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗនូវព្រះធម្មគុណ រំពឹងភាវនាថា

ស្វាក្ខាតោ ភគវតា ធម្មោ ស្វាក្ខាតោ ភគវតា ធម្មោ, សន្ទិដ្ឋិកោ សន្ទិដ្ឋិកោ អកាលិកោ អកាលិកោ, ឯហិបស្សិកោ ឯហិបស្សិកោ, ឱបនយិកោ ឱបនយិកោ, បច្ចត្តំ វេទិតព្វោ វិញ្ញូហិ បច្ចត្តំ វេទិតព្វោ វិញ្ញូហិ, *ឬជារំពឹងភាវនាឲ្យខ្ជីតិចចុះមកថា* ធម្មោ ធម្មោ *តាំងតម្កល់ចិត្តឲ្យមាំ ដោយអំណាចនៃកិរិយាបង្អោន បង្វិរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ ក្នុងព្រះធម្មគុណជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សេងៗ ផ្សាយចេញទៅតាមកាយទ្វារសម្រេចបានត្រឹមឧបចារសមាធិ បានឈ្មោះថា ធម្មានុស្សតិ ។*

*៣- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវព្រះសង្ឃគុណរំពឹងភាវនាថា* សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។ ល ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស *ឬជារំពឹងភាវនាឲ្យខ្ជីតិចចុះមកថា* សង្ឃោ សង្ឃោ *តាំងតម្កល់ចិត្តឲ្យមាំ ដោយអំណាចនៃកិរិយាបង្អោន បង្វិរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងព្រះសង្ឃគុណជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សេងៗ ផ្សាយចេញទៅតាមកាយទ្វារ សម្រេចបានត្រឹមឧបចារសមាធិ បានឈ្មោះថា*

សង្ឃានុស្សតិ ។ ៤- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវសីល-គុណរបស់ខ្លួនដ៏បរិសុទ្ធល្អដោយការៈមានសីលមិនបានដាច់ជាដើម រំពឹងភាវនាថា សីលំៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោនបង្ហូរ ជម្រុលចិត្តទៅឲ្យជ្រកនៅស៊ប់ក្នុងសីលគុណជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផូរផង់ៗ ផ្សាយចេញទៅតាមកាយទ្វារ សម្រេចបានត្រឹមឧបចារ-សមាធិ បានឈ្មោះថា សីលានុស្សតិ ។ ៥- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវចាគគុណ គុណដែលខ្លួនបានបរិច្ចាគបាយទឹកសំពត់យានជំនិះផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដំណេក ទីនៅអាស្រ័យគ្រឿងប្រទីបសម្រាប់អុជ ឲ្យជាទានមិនកួច ដោយការៈនៃខ្លួនមានចិត្តកំណាញ់ជាមន្ទិលប្រាសចេញជាស្រឡះហើយ រំពឹងភាវនាថា ចាគំ[១] ។ តាំងតម្កល់ចិត្តឲ្យមាំ ដោយអំណាចនៃកិរិយាបង្អោន បង្ហូរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងចាគគុណជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផូរផង់ៗ ផ្សាយចេញទៅតាមកាយទ្វារ សម្រេចត្រឹមឧបចារសមាធិ បានឈ្មោះថា

---

១- មានបាលីខ្លះថា ចាគោៗ តែក្នុងដីកាព្រះអភិធម្មថា ចាគំៗ ដូច្នេះ ។

ចាគានុស្សតិ ។ ៦- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវទេវតា-គុណឲ្យជាបន្ទាល់សាក្សីនៃខ្លួន ដឹងច្បាស់ថា ទេវតាទាំងឡាយប្រកបដោយគុណធម៌ទាំងឡាយ ៥ មានសទ្ធាគុណជាដើមយ៉ាងណាមិញ អញក៏ប្រកបដោយគុណធម៌ទាំង ៥ យ៉ាងនោះដែរ ហើយរំពឹងភាវនាថា ទេវតាៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្ហួរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងទេវតាគុណជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផង់ៗ ផ្សាយទៅតាមកាយទ្វារ សម្រេចត្រឹម ឧបចារសមាធិ បានឈ្មោះថា ទេវតានុស្សតិ ។ ៧- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវឧបសមគុណនៃព្រះនិព្វាន ដែលជាគុណជាតកើតឡើងអាចរម្ងាប់នូវកងទុក្ខទាំងអស់បាន រំពឹងភាវនាថា សន្តំៗ រលត់ទុក្ខៗ អច្ចុតំៗ មិនច្យុតៗ សិវំៗ ទៀងៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្ហួរ ជម្រុលចិត្ត ឲ្យទៅជ្រកនៅស៊ប់ក្នុងឧបសមគុណជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផង់ៗ ផ្សាយចេញទៅតាមកាយទ្វារសម្រេចត្រឹមឧបចារសមាធិ បានឈ្មោះថា ឧបសមានុស្សតិ ។ ៨- ធ្វើបរិកម្មចម្រើនតាំង

សតិនឹករឭករឿយៗ នូវមរណៈសេចក្តីស្លាប់មិនទៀងដល់ខ្លួន តែកើតឡើងហើយកាត់ផ្តាច់បង់នូវជីវិតិន្ទ្រិយឲ្យសូន្យទៅ ឥតកំណត់កាលឡើយ រំពឹងភាវនាថា មរណំៗ ស្លាប់ៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្ហូរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងមរណានុស្សរណៈ កិរិយានឹករឭករឿយៗ នូវសេចក្តីស្លាប់ជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើង អំពីចិត្តដ៏ស្អាតផូរ-ផង់ផ្សេងៗ ផ្សាយទៅតាមកាយទ្វារ សម្រេចត្រឹមឧបចារសមាធិ បានឈ្មោះថា មរណានុស្សតិ ។ ៩- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវកាយកោដ្ឋាសនិមិត្ត ចំណែកនៃរាងកាយមានសក់ជាដើម រំពឹងភាវនានូវអាការ ៣២ មានចម្រើនថា កេសាៗ លោមាៗ នខាៗ ទន្តាៗ តចោៗ ជាអនុលោមបដិលោមជាដើម ថាជារបស់ឥតខ្លឹមសារសូន្យសោះ គួរខ្ពើមដោយពិត តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្ហូរជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ ក្នុងកាយកោដ្ឋាសនិមិត្តជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ស្អាតផូរផង់ផ្សេងៗ ផ្សាយទៅតាមកាយទ្វារ សម្រេចដល់ឧបចារសមាធិ និងអប្បនាសមាធិ ត្រឹមបឋមជ្ឈានប៉ុណ្ណោះ បានឈ្មោះថា កាយគតា-

សតិ ។ ១០- ធ្វើបរិកម្មចម្រើនតាំងសតិនឹករឭករឿយៗ នូវអានាបានៈ ខ្យល់ដែលខ្លួនដកដង្ហើមចេញនិងដកដង្ហើមចូល ឲ្យដឹងច្បាស់ថា អញដកដង្ហើមចេញវែង អញដកដង្ហើមចូលក៏វែងជាដើម រំពឹងភាវនាថា អានាបានំៗ អស្សាសបស្សាសាៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោនបង្ហូរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងអស្សាសបស្សាសនិមិត្តជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្ត ដ៏ស្អាតផូរផង់ផ្សេងៗ ផ្សាយចេញទៅតាមកាយទ្វារ សម្រេចដល់ឧបចារ-សមាធិនិងអប្បនាសមាធិរហូតបញ្ចមជ្ឈានដោយពិត បានឈ្មោះថាអានា-បានស្សតិ, ត្រូវជាអនុស្សតិ ១០ ។

ព្រហ្មវិហារ ២ នោះគឺ ១- បរិកម្មចម្រើនឲ្យរឿយៗ ដើម្បីលះបង់នូវព្យាបាទ សេចក្តីក្រោធខឹងគំនុំគំគួនដល់សត្វទាំងឡាយ ដោយមេត្តាចិត្ត ផ្សាយទៅកាន់ទិសទាំងពួងមានសេចក្តីស្រឡាញ់រាប់អានស្មើៗ ប្រមូលមកនូវប្រយោជន៍និងសេចក្តីសុខ ចម្រើនដល់សព្វសត្វទាំងឡាយជាលក្ខណៈ រំពឹងភាវនាថា សព្វេ សត្តា អវេរា ហោន្តុៗ សត្វទាំងឡាយទាំងពួង ចូរកុំឲ្យមានពៀរឡើយៗ សព្វេ សត្តា សុខិតា ហោន្តុៗ សត្វទាំង-ឡាយទាំងពួង ចូរឲ្យបានសេចក្តីសុខក្សេមក្សាន្តៗ តាំងតម្កល់ចិត្តឲ្យ

មាំដោយអំណាចនៃកិរិយាបង្អោន បង្ហួរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងមេត្តាគុណ មានសត្វប្រមាណពុំបានជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ថ្លាស្អាតផូរផង់ផ្សេងៗ ផ្សាយចេញទៅតាមកាយទ្វារ សម្រេចដល់ឧបចារសមាធិនិងអប្បនាសមាធិត្រឹមចតុក្កជ្ឈាន បានឈ្មោះថា មេត្តាព្រហ្មវិហារ ។

២- បរិកម្មចម្រើនឲ្យរឿយៗ ដើម្បីលះបង់នូវវិហឹសកម្ម អំពើបៀតបៀនសម្លាប់សត្វទាំងឡាយ ដោយករុណា សេចក្ដីអាណិតអាសូរចំពោះសត្វទាំងឡាយដែលមានសេចក្ដីទុក្ខលំបាកផ្សេងៗ មានប្រាថ្នានឹងនាំសត្វឲ្យរួចផុតចាកទុក្ខជាលក្ខណៈ រំពឹងភាវនាថា សព្វេ សត្តា ទុក្ខា បមុញ្ចន្តុ សត្វទាំងឡាយទាំងពួងចូរឲ្យរួចផុតចាកទុក្ខៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្ហួរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងករុណាគុណ មានសត្វប្រមាណពុំបានជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ថ្លាស្អាតផូរផង់ផ្សេងៗផ្សាយចេញទៅតាមកាយទ្វារ សម្រេចដល់ឧបចារសមាធិនិងអប្បនាសមាធិត្រឹមចតុក្កជ្ឈាន បានឈ្មោះថា ករុណាព្រហ្មវិហារ ។

៣- បរិកម្មចម្រើនឲ្យរឿយៗ ដើម្បីលះបង់នូវសេចក្ដីឫស្យាប្រណែនឈ្នា-

នីស មិនត្រេកអរចំពោះសេចក្ដីសុខ ចម្រើន និងភោគសម្បត្តិនៃបុគ្គលដទៃ មានកិរិយាត្រេកអររីករាយចំពោះសុខសម្បត្តិ របស់អ្នកដទៃជាលក្ខណៈ រំពឹងភាវនាថា សព្វេ សត្តា លទ្ធសុខសម្បត្តិតោ មា វិគច្ឆន្តុ សត្វទាំងឡាយទាំងពួង ចូរកុំឲ្យប្រាសឃ្លាតចាកសុខសម្បត្តិដែលខ្លួនបានហើយៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្ហូរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងមុទិតាគុណ មានសត្វប្រមាណពុំបានជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន មានពន្លឺរស្មីកើតឡើងអំពីចិត្តដ៏ថ្លាស្អាតផូរផង់ផ្សេងៗ ផ្សាយចេញទៅតាមកាយទ្វារ សម្រេចដល់ឧបចារសមាធិនិងអប្បនាសមាធិត្រឹមចតុក្កជ្ឈាន បានឈ្មោះថា មុទិតាព្រហ្មវិហារ ។ ក៏ព្រហ្មវិហារទាំង ៣ មានមេត្តាជាដើមនេះ ប្រកបដោយសោមនស្សវេទនា ជាចេតសិកធម៌មានកម្លាំងថយ ជាគូសត្រូវនឹងទោមនស្សវេទនា ឲ្យសម្រេចបានតែត្រឹមចតុក្កជ្ឈាន ពុំបានសម្រេចដល់បញ្ចមជ្ឈានឡើយ ព្រោះមេត្តា ករុណា មុទិតាដែលប្រកបដោយសោមនស្សនេះ ជាធម៌សម្រាប់លះបង់នូវអកុសលទាំង ៣ គឺព្យាបាទៈ ១ វិហឹសា ១ អរតិ សេចក្ដីមិនត្រេកអរចំពោះសុខសម្បត្តិអ្នកដទៃ ១ ឲ្យជ្រះស្រឡះបានអាចសម្រេចបានតែត្រឹមចតុក្កជ្ឈានប៉ុណ្ណោះ ។ ៤- បរិកម្មចម្រើនឲ្យ

រឿយៗ ដើម្បីលះបង់នូវចិត្តដែលត្រេកអរក្នុងអកុសលកម្មមានសេចក្ដីព្យា-បាទជាដើម ដោយឧបេក្ខាចិត្តជាកុសលប្រកបដោយបញ្ញាដឹងច្បាស់ថាកម្មជារបស់ខ្លួនពិតៗ មានកិរិយាប្រព្រឹត្តទៅជាកណ្ដាលក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាលក្ខណៈ រំពឹងភាវនាថា សព្វេ សត្តា យថា វា តថា វា កម្មស្សកា ហោន្តុ សត្វទាំងឡាយទាំងពួង មានកម្មល្អ អាក្រក់របស់ខ្លួនជាយ៉ាងណាៗ នឹងកើតមានប្រាកដជាយ៉ាងនោះៗ តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្ហួរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងឧបេក្ខាគុណ មានសត្វនិងសង្ខារប្រមាណពុំបានជាអារម្មណ៍ អាចគ្របសង្កត់នូវអកុសលធម៌ទាំងឡាយមាននីវរណធម៌ជាដើមបាន សម្រេចដល់ឧបចារសមាធិនិងអប្បនាសមាធិ ចំពោះតែបញ្ចមជ្ឈានដែលជាឈានដ៏ឧត្ដមខ្ពង់ខ្ពស់ ព្រោះឧបេក្ខាព្រហ្មវិហារដែលប្រកបដោយឧបេក្ខាវេទនានេះមានកម្លាំងខ្លាំង អាចញ៉ាំងបញ្ចមជ្ឈានឲ្យកើតឡើងបានដោយពិត ។

៣៥- បដិកូលសញ្ញា សេចក្ដីអធិប្បាយថា ព្រះយោគាវចរកុល-បុត្រ បានបរិកម្មចម្រើនធ្វើកំណត់ចំណាំចាំទុកក្នុងចិត្តប្រព្រឹត្តទៅដោយកិច្ចពិចារណានូវអាហារទាំងពួងថាជាវត្ថុ គឺបុគ្គលគប្បីខ្ពើមរអើមក្រៃពេក រំពឹងភាវនាថា កវឡិង្ការាហារោ បដិក្កូលោៗ អាហារដែលបុគ្គលធ្វើ

ឲ្យជាពំនូត គួរខ្ពើមរអើមក្រៃពេកៗ ដោយអំណាចនៃកាលទាំងឡាយ មានគមនកាល កាលជាទីដើរចេញទៅ, បរិយេសនកាល កាលជាទីស្វែងរកអាហារ, បរិភោគកាល កាលជាទីបរិភោគជាដើម តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្អូរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងទីបដិកូលជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បានសម្រេចត្រឹមឧបចារសមាធិ បានឈ្មោះថា បដិកូលសញ្ញា ។

៣៦- ធាតុវវដ្ឋាន ព្រះយោគាវចរកុលបុត្រ បានបរិកម្មចម្រើនធ្វើកំណត់ទុកក្នុងចិត្តនូវធាតុទាំង ៤ មានបឋវីធាតុជាដើម ថាជាសភាវៈទ្រទ្រង់នៅ មិនមែនជាសត្វ មិនមែនមានជីវិត តែងសូន្យទៅជាធម្មតា មានរំពឹងភាវនាថា កេសា ធាតូៗ សក់ទាំងឡាយជាធាតុៗ លោមា ធាតូៗ រោមទាំងឡាយជាធាតុៗ ជាដើម តាំងតម្កល់ចិត្តឲ្យមាំដោយអំណាចនៃកិរិយាបង្អោន បង្អូរ ជម្រុលចិត្តឲ្យទៅជ្រកនៅស៊ប់ក្នុងកិរិយាកំណត់ធាតុទាំង ៤ ជាអារម្មណ៍ អាចគ្របសង្កត់នូវនីវរណធម៌ទាំង ៥ បាន សម្រេចឧបចារសមាធិ បានឈ្មោះថា ធាតុវវដ្ឋាន ។

អរូប ៤ នោះគឺ ទី១- ព្រះយោគាវចរកុលបុត្រ ដែលបានចេះស្ទាត់ក្នុងរូបជ្ឈានទាំង ៥ ហើយបានរំពឹងពិចារណាឃើញនូវទោសនៃ

កូតរូបទាំង ៤ ដែលធំគ្រោតគ្រាតមិនចង់ឲ្យមានឡើយ ចង់មានតែអា-កាសធាតុទ្រទ្រង់នូវវាលទទេដែលល្អិតផូរផង់ បណ្តាកសិណទាំង ១០ នោះដែលរើឡើងហើយ គឺថាលើកលែងចោលនូវកសិណបដិភាគនិមិត្តទាំង ៩ ចេញ ដោយពុំបានធ្វើកំណត់ទុកក្នុងចិត្តឡើយ ហើយប្រារព្ធកាន់យកបដិភាគនិមិត្តមួយ ដែលកើតអំពីអាកាសកសិណ មកបរិកម្មចម្រើនរឿយៗភាវនាថា អនន្តំ អាកាសំៗ អាកាសមានទីបំផុតមិនមានៗ ឬថា អនន្តោ អាកាសោៗ អាកាសមានទីបំផុតមិនមានៗ សម្ងំងបដិភាគនិមិត្តដែលកើតមកអំពីមណ្ឌលនៃអាកាសដ៏ធំទូលាយ មានទីបំផុតមិនមាននោះជាអារម្មណ៍ ក្នុងមនោទ្វារ ដោយចក្ខុបញ្ញាជាទីពេញចិត្តចូលកាន់បញ្ច-មជ្ឈានគឺអាកាសានញ្ចាយតនៈអរូបជ្ឈានទី ១ មានតែអាកាសមានទីបំផុតមិនមានជាអាយតនៈក្នុងអាកាសារម្មណ៍នោះឯង ។ ទី ២- ព្រះយោគាវចរ-កុលបុត្រ បានពិចារណាឃើញនូវទោសនៃអាកាសថាធំទូលាយពន់-ពេកណាស់ នាំឲ្យលំបាកមិនចង់ឲ្យមានឡើយ ចង់ឲ្យមានតែវិញ្ញាណជាអាយតនៈវិញ ហើយតាំងព្យាយាមបរិកម្មចម្រើនភាវនាថា អនន្តំ វិញ្ញាណំ អនន្តំ វិញ្ញាណំ វិញ្ញាណមានទីបំផុតមិនមានៗ តាំងចម្រើនយ៉ាងនេះឲ្យរឿយៗ ញ៉ាំងអរូបវិញ្ញាណជាបឋមដែលមានទីបំផុត

មិនមាន ឲ្យបានសម្រេចចូលកាន់បញ្ចមជ្ឈានគឺវិញ្ញាណញ្ចាយតនៈ អរូបជ្ឈានទី ២ មានតែអរូបវិញ្ញាណជាបឋម មានទីបំផុតមិនមានជាអាយតនៈក្នុងវិញ្ញាណារម្មណ៍នោះឯង ។ ទី៣- ព្រះយោគាវចរកុលបុត្របានពិចារណាឃើញនូវទោសនៃអរូបវិញ្ញាណជាបឋម ផ្សាយទៅដ៏ធំឆ្ងាយទូលាយពន់ពេករកទីបំផុតគ្មាន មិនចង់ឲ្យមានអរូបវិញ្ញាណជាបឋមបន្តិចបន្តួចជាអាយតនៈហើយតាំងព្យាយាមបរិកម្មថា នត្ថិ កិញ្ចិ នត្ថិ កិញ្ចិ អរូបវិញ្ញាណបន្តិចបន្តួចមិនមានឡើយៗ តាំងចម្រើនយ៉ាងនេះឲ្យរឿយៗ ដរាបដល់បានសម្រេចរំលត់អស់អរូបវិញ្ញាណជាបឋមហើយចូលកាន់បញ្ចមជ្ឈាន គឺអាកិញ្ចញ្ញាយតនៈ អរូបជ្ឈានទី ៣ មិនមានអរូបវិញ្ញាណជាបឋមបន្តិចបន្តួចជាអាយតនៈក្នុងបឋមារូបវិញ្ញាណភាវារម្មណ៍ គឺឈានមានភាវៈមិនមាននៃអរូបវិញ្ញាណជាបឋមជាអារម្មណ៍នោះឯង ។ ទី ៤- ព្រះយោគាវចរកុលបុត្របានពិចារណាឃើញនូវទោសនៃអរូបជ្ឈានទី ៣ នេះថា នៅមិនទាន់ល្អិតដ៏ឧត្តមផូរផង់ ព្រោះនៅមានសញ្ញាដ៏គ្រោតគ្រាតមិនចង់ឲ្យមានឡើយហើយតាំងព្យាយាមបរិកម្មភាវនាថា ឯតំ សន្តំ បណីតំ អរូបជ្ឈានទី ៣ នេះដ៏ល្អិតទៅ អរូបជ្ឈានទី ៣ នេះ ដ៏ឧត្តមម៉ត់ចត់ទៅ តាំងចម្រើនយ៉ាងនេះឲ្យរឿយៗ ដរាបបានសម្រេច ចូលកាន់បញ្ចមជ្ឈាន គឺ

នេវសញ្ញានាសញ្ញាយតនៈ អរូបជ្ឈានទី ៤ មិនមានសញ្ញាដ៏គ្រោតគ្រាត សោះ តែជាមិនមែនជាមិនមានសញ្ញាសោះ គឺមានសញ្ញាដ៏ល្អិតផូរផង់ ជាអាយតនៈក្នុងតតិយារូបជ្ឈានារម្មណ៍ គឺឈានមានអរូបជ្ឈានទី ៣ ជាអារម្មណ៍នោះឯង ។ ឯអរូបជ្ឈានទាំង ៤ នេះប្រកបដោយអង្គពីរៗ ដូចគ្នាគឺ ឧបេក្ខា ១ ឯកគ្គតា ១ សេចក្តីអធិប្បាយដូចអរូបជ្ឈានទី ៥ ដែរ រួមព្រះកម្មដ្ឋានទាំងអស់ គឺកសិណ ១០ អសុភ ១០ អនុស្សតិ ១០ ព្រហ្មវិហារ ៤ បដិកូលសញ្ញា ១ ធាតុវវដ្ឋាន ១ អរូបជ្ឈាន ៤ ត្រូវជា សមថកម្មដ្ឋាន ៤០ គត់ ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៥២- ធម្មវាទី បានស្តាប់ហើយពោលថា សាធុៗ ម្នាលអត្ថវាទីប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃណាស់ហើយ តែយើងនឹងសួរលោកតទៅទៀត ។ ចុះព្រះយោគាវចរកុលបុត្រ ដែលមានព្យាយាមនឹងរៀនព្រះកម្មដ្ឋានត្រូវឲ្យរៀនសមគួរតាមចរិតរបស់ខ្លួន តើចរិតនោះមានប៉ុន្មាន? គឺចរិតអ្វីខ្លះ? ក្នុងចរិតមួយៗ មានសេចក្តីអធិប្បាយយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនារាប់ចំនួនចរិត ព្រមទាំងសេចក្តីអធិប្បាយ ឲ្យសព្វគ្រប់មក យើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះយោគាវចរកុលបុត្រដែល

រៀនព្រះកម្មដ្ឋានសមគួរតាមចរិតរបស់ខ្លួននោះ ដោយសង្ខេបចរិតមាន ៦ គឺ រាគចរិត ១ ទោសចរិត ១ មោហចរិត ១ សទ្ធាចរិត ១ ពុទ្ធិចរិត ១ វិតក្កចរិត ១ សេចក្តីអធិប្បាយក្នុងចរិតមួយៗ ដូច្នេះ ទី ១- បុគ្គលដែលមានរាគៈជាចរិតនោះតែងមានមាយាបិទបាំងទោស ដែលមានក្នុងខ្លួនមិនឲ្យប្រាកដដល់អ្នកដទៃ សម្តែងនូវគុណដែលពុំមានក្នុងខ្លួនថាមានក្នុងខ្លួន មានចិត្តប្រកបដោយអស្មិមានះរបឹងរឹងរូស មានប្រាថ្នាតែអំពើដ៏លាមក ជាអ្នកប្រាថ្នាច្រើនពេកហួសប្រមាណ មិនប្រព្រឹត្តធមិសន្តោសត្រេកអរស្មើៗសមគួរតាមលាភ ចូលចិត្តតែប្រដាប់តាក់តែងស្អិតស្អាងរាងកាយជាដើម បានឈ្មោះថា បុគ្គលជារាគចរិត ។ ទី ២- បុគ្គលដែលមានទោសៈជាចរិតនោះ តែងមានចិត្តក្រោធខឹង ច្រើនគំនុំគុំកួនដល់អ្នកដទៃ ចូលទៅជិតចងពៀរទុកចំពោះបុគ្គលដទៃ ពោលលុបគុណអ្នកដទៃ មានចិត្តឫស្យា ឈ្នានីស ប្រណែននូវសេចក្តីសុខ ចម្រើន និងសម្បត្តិអ្នកដទៃមិនឲ្យលើសខ្លួន ប្រព្រឹត្តកំណាញ់ទ្រព្យលាក់លៀមទុកមិនឲ្យដល់បុគ្គលដទៃជាដើម បានឈ្មោះថា បុគ្គលជាទោសចរិត ។ ទី ៣- បុគ្គលដែលមានមោហៈជាចរិតនោះ តែងមានសេចក្តីខ្ជិលច្រអូសច្រើននិងអង្គុយងោកងក់ល្ងោកដេកលក់ច្រើន មានចិត្តរាយមាយផ្សាយហុយ

ឡើងដូចផេះត្រូវខ្យល់ តែងមានចិត្តក្តៅក្រហាយស្តាយក្រោយជានិច្ច មានចិត្តសង្ស័យច្រើនមិនចេះដាច់ស្រេច ប្រកាន់យកមាំតែអំពើដែលមិនមែនជាឧបាយនៃប្រាជ្ញា លះបង់នូវអំពើដែលធ្វើខុសហើយបានដោយកម្រក្រៃពេកជាដើម បានឈ្មោះថា បុគ្គលជាមោហចរិត ។ ទី ៤ បុគ្គលដែលមានសទ្ធាជាចរិត តែបានបរិច្ចាគទានរួចហើយតែងមានចិត្តត្រេកអរមិនបានក្តៅក្រហាយស្តាយក្រោយ មានប្រាថ្នាត្រូវការចង់ឃើញនូវព្រះអរិយបុគ្គលទាំងឡាយ តែងមានសេចក្តីបំណងចង់ស្តាប់នូវព្រះសទ្ធម្ម មានសេចក្តីត្រេកអរជ្រះថ្លាច្រើន មិនបានសម្តែងសេចក្តីអំនួតអួតគុណដែលមិនមានក្នុងខ្លួនឡើយ ជាបុគ្គលមិនមានមាយាបិទបាំងនូវទោសខ្លួនទុក មានសេចក្តីជ្រះថ្លាតែក្នុងទីដែលគួរជ្រះថ្លាជាដើម បានឈ្មោះថាបុគ្គលជាសទ្ធាចរិត ។ ទី ៥- បុគ្គលដែលមានសេចក្តីចេះដឹង(បញ្ញា)ជាចរិត ជាបុគ្គលនិយាយប្រដៅបានដោយងាយ ចូលចិត្តសេពគប់នូវកល្យាណមិត្តដែលមានចិត្តល្អជាកុសល ជាបុគ្គលដឹងប្រមាណក្នុងចិត្តបរិភោគនូវភោជនមិនល្មោភឥតកំណត់ មានសតិភ្ញាក់រឭកដឹងខ្លួនល្អ មានព្យាយាមប្រកបការរឿយៗ ក្នុងកិរិយាភ្ញាក់រឭកពុំភ្លេច មានសេចក្តីសង្វេគក្នុងទីទាំងឡាយដែលគួរសង្វេគ ខំព្យាយាមតម្កល់នូវសេចក្តី

សង្វេគ ដោយឧបាយនៃប្រាជ្ញាជាដើម បានឈ្មោះថា បុគ្គលជាពុទ្ធិ-ចរិត ។ ទី ៦- បុគ្គលដែលមានវិតក្កៈជាចរិត តែងនិយាយពាក្យសំដីច្រើនប្រកបដោយពាក្យសំនួន ចូលចិត្តត្រេកអរតែក្នុងពួកមនុស្សប្រជុំគ្នាច្រើន មិនត្រេកអរក្នុងកិរិយាប្រកបរឿយៗ ក្នុងធម៌ជាកុសល មានកិច្ចពុំបានតម្កល់ខ្ជាប់មាំឡើយ ច្រើនត្រិះរិះគិតរំពឹងជញ្ជឹងនូវកិច្ចក្នុងវេលាយប់ ហើយធ្វះបំភ្លឺនូវកិច្ចនោះឲ្យរុងរឿងក្នុងវេលាថ្ងៃ មានចិត្តគំនិតច្រើនវើរុះស្ទុះទៅក្នុងអារម្មណ៍ខាងនេះម្តង ខាងណោះម្តង ជាដើម បានឈ្មោះថា បុគ្គលជាវិតក្កចរិត ។ វិសជ្ជនាមកអំពីចរិតទាំង ៦ ព្រមទាំងសេចក្តីអធិប្បាយដោយសង្ខេបតែប៉ុណ្ណោះឯង ។

៥៣- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្ថវាទី លោកវិសជ្ជនាមកនេះយើងស្តាប់បានហើយ ចុះព្រះកម្មដ្ឋានទាំង ៤០ នោះ បើចែកអនុលោមតាមបុគ្គលដែលប្រកបដោយចរិតទាំង ៦ នោះ តើព្រះកម្មដ្ឋានណាខ្លះដែលផ្សេងគ្នា? មានចំនួនប៉ុន្មានដែលជាទីសប្បាយដល់បុគ្គលទាំងឡាយដែលប្រកបដោយចរិតទាំង ៦ នោះ? ចូរលោកវិសជ្ជនាឲ្យច្បាស់លាស់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះកម្មដ្ឋាន ១១ គឺអសុភ

១០ កាយគតាសតិ ១ ជាទីសប្បាយនៃបុគ្គលជារាគចរិតដោយពិត ។ ព្រះកម្មដ្ឋាន ៨ គឺព្រហ្មវិហារ ៤ វណ្ណកសិណ ៤ ជាទីសប្បាយនៃបុគ្គលជាទោសចរិត ។ ព្រះកម្មដ្ឋានតែ ១ គឺអានាបានស្សតិ ជាទីសប្បាយនៃបុគ្គលជាមោហចរិតផង វិតក្កចរិតផង ។ ព្រះកម្មដ្ឋាន ៦ គឺអនុស្សតិទាំង ៦ មានពុទ្ធានុស្សតិជាដើម ជាទីសប្បាយនៃបុគ្គលជាសទ្ធាចរិត ។ ព្រះកម្មដ្ឋាន ៤ គឺមរណានុស្សតិ ១ ឧបសមានុស្សតិ ១ បដិកូលសញ្ញា ១ ចតុធាតុវវដ្ឋាន ១ ជាទីសប្បាយនៃបុគ្គលជាពុទ្ធិចរិត ។ ព្រះកម្មដ្ឋានដ៏សេសសល់ទាំង ១០ គឺភូតកសិណ ៤ អាកាសកសិណ ១ អាលោក-កសិណ ១ អរូបជ្ឈាន ៤ ត្រូវជា ១០ ជាទីសប្បាយនៃបុគ្គលប្រកបដោយចរិតទាំង ៦ មានបុគ្គលជារាគចរិតជាដើម, បណ្តាចរិតទាំង ៦ នោះ កសិណដែលធំក្រាស់ទូលាយជាទីសប្បាយនៃបុគ្គលជាមោហចរិត កសិណដែលតូចស្តើងជាទីសប្បាយនៃបុគ្គលជាវិតក្កចរិត ។ វិសជ្ជនាមកអំពីព្រះកម្មដ្ឋានទាំង ៤០ ដែលអនុលោមសមគួរតាមចរិតទាំង ៦ ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៥៤- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី ក្នុងព្រះកម្មដ្ឋានទាំង ៤០ នោះ តើមានភាវនាប៉ុន្មាន? មាននិមិត្តប៉ុន្មាន?

មានសមាធិប៉ុន្មាន? កើតមានផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ក្នុងព្រះកម្មដ្ឋានទាំង ៤០ នោះ មានភាវនា ៣ គឺបរិកម្មភាវនា ១ ឧបចារភាវនា ១ អប្បនាភាវនា ១ ។ មាននិមិត្ត ៣ គឺបរិកម្មនិមិត្ត ១ ឧគ្គហនិមិត្ត ១ បដិភាគនិមិត្ត ១ ។ មានសមាធិ ៣ គឺបរិកម្មសមាធិ ១ ឧបចារសមាធិ ១ អប្បនាសមាធិ ១ ដូចមានសេចក្តីអធិប្បាយតទៅនេះ ក៏រីភាវនាទាំង ៣ នោះគឺ ១- ភាវនាដែលមានកម្លាំងខ្សោយជាចំណែកខាងដើម ដែលព្រះយោគាវចរកុលបុត្រខំព្យាយាមចម្រើនធ្វើកំណត់ជាអារម្មណ៍ នៃព្រះកម្មដ្ឋានមានបឋវីកសិណជាដើម ក្នុងមនោទ្វារហើយពិចារណារឿយៗ សម្លឹងមើលនិមិត្តកើតអំពីមណ្ឌលនៃកសិណ បានឈ្មោះថា បរិកម្មភាវនា ។ ២- ភាវនាដែលមានកម្លាំងខ្លាំងបានឧគ្គហនិមិត្តកើតឡើង ហើយជាកាមាវចរកុសលដែលបានសង្កត់សង្កិនទូវនីវរណធម៌បាន មានគោត្រភូកុសលជវនជាទីបំផុតត្រាច់ទៅក្នុងទីជិតនៃអប្បនា ដូចជាឧបចារនៃស្រុក បានឈ្មោះថា ឧបចារភាវនា ។ ៣- ភាវនាដែលព្រះយោគាវចរកុលបុត្រចម្រើនលះបង់នូវនីវរណធម៌ទាំង ៥ បាន ហើយចូលកាន់មហគ្គតគុណដ៏ប្រសើរគឺ បឋម-

ជ្ឈាន មានវិតក្កជាប្រធានជារូបាវចរកុសលសិប់សួន បានឈ្មោះថា អប្ប-នាភាវនា ។ ឯបរិកម្មភាវនាសម្រេចបានក្នុងព្រះកម្មដ្ឋានទាំងអស់, ឧប-ចារភាវនាសម្រេចបានតែក្នុងព្រះកម្មដ្ឋាន ១០ គឺ អនុស្សតិ ៨ មានពុទ្ធា-នុស្សតិជាដើម បដិកូលសញ្ញា ១ ធាតុវវដ្ឋាន ១ ។ អប្បនាភាវនាសម្រេច បានក្នុងព្រះកម្មដ្ឋានទាំង ៣០ គឺកសិណ ១០ អានាបានស្សតិ ១ ប្រកបក្នុង បញ្ចមជ្ឈាន អសុភ ១០ កាយគតាសតិ ១ ប្រកបក្នុងបឋមជ្ឈាន ព្រហ្ម វិហារ ៣ មានមេត្តាជាដើម ប្រកបក្នុងចតុក្កជ្ឈាន ឧបេក្ខាព្រហ្មវិហារ ១ ប្រកបក្នុងបញ្ចមជ្ឈាន កំកម្មដ្ឋានទាំង ២៦ នេះ ប្រកបក្នុងរូបាវចរជ្ឈាន អរុប្ប ៤ ប្រកបក្នុងអរូបាវចរជ្ឈានទាំង ៤ ដោយពិត ។ និមិត្ត ៣ នោះគឺ ១- ព្រះយោគាវចរកុលបុត្របានកាន់យកនិមិត្តផ្សេងៗ មានកសិណមណ្ឌល ជាដើមជាអារម្មណ៍ខំព្យាយាមចម្រើនបរិកម្មរឿយៗ បានឈ្មោះថាបរិកម្ម-និមិត្ត ។ ២- ព្រះយោគាវចរកុលបុត្របានរៀនយកនិមិត្តដែលកើតមកអំពី បរិកម្មភាវនាកើតឡើងប្រាកដក្នុងមនោទ្វារហើយ ដឹងច្បាស់ដោយចក្ខុ-បញ្ញាដូចជាបានឃើញច្បាស់ដោយភ្នែក បានឈ្មោះថា ឧគ្គហនិមិត្ត ។ ៣- តអំពីឧគ្គហនិមិត្តនោះ ព្រះយោគាវចរកុលបុត្រខំប្រកបចម្រើនរឿយៗ ដោយបរិកម្មសមាធិក្នុងឧគ្គហនិមិត្តនោះ លុះដល់អារម្មណ៍ដែលសម្រេច

ដោយភាវនា ហៅថាបញ្ញត្តិ រួចផុតស្រឡះចាកវត្ថុធម៌ដែលមានចំណែកដូចឧគ្គហនិមិត្តនោះ ដំឆ្អែតស្ងប់ស្ងាត់ថ្លាស្អាតកើតប្រាកដក្នុងចិត្ត ក្នុងកាលណា បានឈ្មោះថា បដិភាគនិមិត្ត កើតឡើងប្រាកដក្នុងកាលនោះឯង ។ ឯនិមិត្តទាំងពីរគឺបរិកម្មនិមិត្ត ១ ឧគ្គហនិមិត្ត ១ នេះសម្រេចបានក្នុងព្រះកម្មដ្ឋានទាំងអស់សមគួរតាមហេតុពិត, ឯបដិភាគនិមិត្តសម្រេចបានតែក្នុងព្រះកម្មដ្ឋាន ២២ គឺកសិណ ១០ អសុភ ១០ កាយគតាសតិ ១ អានាបានស្សតិ ១ ប៉ុណ្ណោះ ។ សមាធិ ៣ នោះគឺ ១- ព្រះយោគាវចរកុលបុត្រដែលមានចិត្តតម្កល់មាំមិនរវើរវាយក្នុងកិច្ចបរិកម្ម បានឈ្មោះថា បរិកម្មសមាធិ ។ ២- ព្រះយោគាវចរកុលបុត្រដែលមានចិត្តតម្កល់មាំមិនរវើរវាយក្នុងកិច្ចឧបចារ បានឈ្មោះថា ឧបចារសមាធិ ។ ៣- ព្រះយោគាវចរកុលបុត្រដែលមានចិត្តតម្កល់មាំមិនរវើរវាយក្នុងកិច្ចអប្បនា បានឈ្មោះថា អប្បនាសមាធិ ។ ម្យ៉ាងទៀត ព្រះយោគាវចរកុលបុត្រទាំងឡាយដែលបានព្យាយាមរៀននូវបណ្តាព្រះកម្មដ្ឋានទាំង ៤០ នោះ ព្រះកម្មដ្ឋានឯណានីមួយ ហើយបានកើតគុណវិសេសត្រឹមឧបចារភាវនាឬឧបចារសមាធិបានឈ្មោះថា កាមាវចរកម្មដ្ឋាន បើបានកើតគុណវិសេសដល់អប្បនាភាវនា ឬអប្បនាសមាធិ បានឈ្មោះថារូបាវចរកម្មដ្ឋាន ឬ

អរូបាវចរកម្មដ្ឋានដោយសមគួរតាមលំដាប់ ។ វិសជ្ជនាមកអំពីភាវនា ៣ និមិត្ត ៣ សមាធិ ៣ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៩៥- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្ថវាទី ប្រស្នានេះប្រពៃហើយ តែយើងនឹងសួរប្រស្នាដទៃតទៅទៀត ចុះព្រះយោគាវចរកុលបុត្រដែលមានប្រាថ្នានឹងរៀនព្រះកម្មដ្ឋានទាំងអស់នេះ ក្នុងគម្ពីរព្រះត្រៃបិដកគឺព្រះវិន័យ ព្រះសូត្រ ព្រះអភិធម្ម ក្នុងកាលមុនជាខាងដើមដែលពុំទាន់ភាវនាព្រះកម្មដ្ឋានណាមួយ តើមានបាឡីបង្គាប់ឲ្យសូត្រអារាធនាខ្វះដែរ ឬគ្មានទេ? ឬមានបាឡីបង្គាប់ឲ្យសូត្រដូចម្តេចខ្វះ? ចូរលោកវិសជ្ជនាឲ្យប្រាកដមកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ខ្ញុំព្រះករុណាបានសង្កេតពិនិត្យមើលបាឡីក្នុងគម្ពីរព្រះត្រៃបិដក ដោយសព្វគ្រប់ពុំឃើញមានបាឡីក្នុងគម្ពីរណាបង្គាប់ឲ្យសូត្រអារាធនាព្រះកម្មដ្ឋាននោះទេ ឃើញមានតែបាឡីក្នុងគម្ពីរព្រះវិសុទ្ធិមគ្គមានបង្គាប់ថា ព្រះយោគាវចរកុលបុត្រដែលនឹងរៀនព្រះកម្មដ្ឋាននោះ ត្រូវសូត្របាឡីសូមសេចក្តីសង្គ្រោះ អំពីសម្នាក់អាចារ្យនិងសូត្រសូមសេចក្តីសង្គ្រោះ អំពីសម្នាក់ព្រះសម្មាសម្ពុទ្ធជាមុនសិន ដើម្បីការពារនូវសេចក្តីអន្តរាយទាំងឡាយ មិនឲ្យកើតមានឡើង

ដល់ខ្លួនក្នុងកាលដែលចម្រើនព្រះកម្មដ្ឋាននោះ ឯបាឡីសម្រាប់សូត្រសូមសេចក្ដីសង្គ្រោះអំពីសម្នាក់អាចារ្យនោះគឺ ត្រូវចូលទៅជិតកាន់សម្នាក់អាចារ្យគោរពថ្វាយបង្គំហើយសូត្របាឡីថា (ឱកាស) ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ (សូមឱកាស) បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណា សូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់ ទុតិយម្បិ ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាសូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់អស់វារៈជាគម្រប់ពីរដងផង, តតិយម្បិ ឥមាហំ ភន្តេ អត្តភាវំ តុម្ហាកំ បរិច្ចជាមិ បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាសូមលះបង់នូវអត្តភាពនេះចំពោះលោកម្ចាស់អស់វារៈជាគម្រប់បីដងផង ។ បើសូត្រសូមសេចក្ដីសង្គ្រោះអំពីសម្នាក់ព្រះសម្មាសម្ពុទ្ធនោះ ត្រូវតាំងនមស្ការនឹករឭកព្រះពុទ្ធគុណ ធម្មគុណ សង្ឃគុណស្រេចហើយ សូត្របាឡីពុទ្ធ-សង្គហៈថា (ឱកាស) ឥមាហំ ភគវា អត្តភាវំ តុម្ហាកំ បរិច្ច-ជាមិ (សូមធ្វើគោរពយ៉ាងខ្ពង់ខ្ពស់) បពិត្រព្រះដ៏មានព្រះភាគខ្ញុំព្រះអង្គសូមលះបង់នូវអត្តភាពនេះថ្វាយចំពោះព្រះអង្គ, ទុតិយម្បិ ឥមាហំ

ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជ្ជាមិ *បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះករុណាសូមលះបង់នូវអត្តភាពនេះ ថ្វាយចំពោះព្រះអង្គអស់វារៈជាគម្រប់ពីរដងផង* តតិយម្បិ ឥមាហំ ភគវា អត្តភាវំ តុម្ហាកំ បរិច្ចជ្ជាមិ *បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះករុណាសូមលះបង់នូវអត្តភាពនេះ ថ្វាយចំពោះព្រះអង្គអស់វារៈជាគម្រប់បីដងផង ។ ស្រេចហើយទើបឲ្យចម្រើនព្រះកម្មដ្ឋានជាខាងក្រោយ នឹងបានសម្រេចដូចសេចក្តីប្រាថ្នាដោយពិត ឯសាធុជនជាយោគាវចរកុលបុត្រដែលនឹងចម្រើនព្រះកម្មដ្ឋាននោះ បើពុំបានសូត្របាឡីសង្គហៈនេះទេ បានឈ្មោះថា ពុំទាន់បាននូវទីពឹងមាំក្នុងព្រះពុទ្ធសាសនាឡើយ បើបានសូត្របាឡីសង្គហៈនេះហើយ ទើបបានឈ្មោះថា បាននូវទីពឹងមាំក្នុងព្រះពុទ្ធសាសនាដោយពិត អាចបានសម្រេចនូវប្រាជ្ញាដ៏ចម្រើនពេញបរិបូណ៌ ព្រះធម៌នឹងកើតឡើងប្រាកដក្នុងមនោទ្វារ កាយទ្វារតាមសភាពពិត ។ មួយវិញទៀត អាចកម្ចាត់បង់នូវសេចក្តីអន្តរាយទាំងពួង មានភេរវារម្មណ៍គឺអារម្មណ៍គួរខ្លាចស្ញប់ស្ញែងជាដើម មិនបានកើតចូលមកកាន់ចក្ខុទ្វារ មនោទ្វារ បើទុកជាកើតមកហើយក៏គង់វិនាសសាបសូន្យបាត់បង់ទៅវិញមួយរំពេច ។ វិសជ្ជនាមកអំពីបាឡីសម្រាប់សូត្រសូមសេចក្តីសង្គ្រោះ ឬថ្វាយខ្លួន ក្នុងកាលមុន*

ពេលដែលបរិកម្មការនោ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៥៦- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្ថវាទី ចុះព្រះ-យោគាវចរកុលបុត្រដែលបានចម្រើនព្រះកម្មដ្ឋានញុំាងឈាន ឲ្យកើតឡើងហើយថា ត្រូវចម្រើនឲ្យស្ទាត់ក្នុងឈានដោយវសីទាំងប្រាំនោះ តើគឺវសីអ្វីខ្លះ? សេចក្តីអធិប្បាយថាដូចម្តេច?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯព្រះយោគាវចរកុលបុត្រដែលបានចម្រើនធ្វើឈានឲ្យកើតឡើងហើយ ត្រូវធ្វើឈានឲ្យស្ទាត់ជំនាញដោយវសីទាំងប្រាំនោះគឺ ១- អាវជ្ជនវសី ចម្រើនឲ្យស្ទាត់ជំនាញមិនបាច់ចាំកាន់យកនូវភវង្គតទៅតមកអំពីភវង្គកើតឡើងអស់វារៈមួយដង ពីរដងក្នុងខាងនាយអំពីជវនទី ៤ ទី ៥ នោះឡើយ ហើយអាចពិចារណាដឹងច្បាស់នូវអង្គនៃឈានក្នុងលំដាប់នៃជវនដែលកើតឡើងក្នុងអារម្មណ៍មួយៗដោយពិត ។ ២- សមាបជ្ជនវសី ចម្រើនឲ្យស្ទាត់ជំនាញមិនបាច់ឲ្យចិត្តស្ទុះទៅកាន់ភវង្គដទៃអំពីភវង្គពីរបីក្នុងលំដាប់នៃចិត្តដែលមានប្រាថ្នាដើម្បីចូលកាន់ឈាន ហើយអាចនឹងចូលកាន់ឈានក្នុងលំដាប់នៃជវនដែលកើតឡើងហើយដោយរហ័ស ។ ៣- អធិដ្ឋានវសី ចម្រើនឲ្យស្ទាត់ជំនាញដ៏អាចដើម្បីផ្តាច់នូវវេលានៃភវង្គហើយតម្កល់នូវឈាន ឲ្យឋិតនៅសម

គួរតាមកាលដែលខ្លួនកំណត់ទុកហើយ ប្រកបក្នុងកិរិយារក្សានូវជវនមិនឲ្យធ្លាក់ចុះមកកាន់ភវង្គវិញ អាចតម្កល់តាំងនៅក្នុងឈានមិនឲ្យជ្រុលហួសអំពីកាលដែលខ្លួនបានកំណត់ទុកនោះឡើយ ។ ៤- វុដ្ឋានវសី ចម្រើនឲ្យស្ទាត់ជំនាញ មិនបានឲ្យប្រព្រឹត្តកន្លងនូវកាលដែលខ្លួនបានកំណត់ទុកដោយសមគួរ ហើយអាចនឹងចេញចាកឈានដែលខ្លួនបានចូលសមគួរតាមកំណត់ គឺថាមិនបានចេញចាកឈានខាងក្នុងចន្លោះនៃកាលដែលខ្លួនកំណត់ អាចចេញអំពីឈានដោយអំណាចនៃកាលដ៏សមគួរតាមកំណត់ពិត ។ ៥- បច្ចវេក្ខណវសី ចម្រើនឲ្យស្ទាត់ជំនាញក្នុងខណៈពិចារណាដោយប្រាជ្ញាដឹងច្បាស់នូវឈានដោយកិច្ចទាំងឡាយ មានពិចារណានូវអង្គនៃឈានទាំងឡាយ ដោយសមគួរតាមប្រាជ្ញាជាដើម នឹងលះបង់នូវអង្គនៃឈានដ៏គ្រោតគ្រាត ហើយចូលកាន់ឈានជាលំដាប់មានទុតិយជ្ឈាននិងតតិយជ្ឈានជាដើម ដែលមានអង្គដ៏ល្អិតផូរផង់ជាសុខសប្បាយយ៉ាងសំខាន់ ។ ព្រះយោគាវចរកុលបុត្រដែលបានឈានហើយត្រូវហាត់ចិត្តឲ្យស្ទាត់ជំនាញដោយវសីទាំងប្រាំនេះ ទើបបានឈ្មោះថាបានឈានពិតប្រាកដមែន ។ វិសជ្ជនាមកអំពីវសីទាំងប្រាំដោយសង្ខេបតែប៉ុណ្ណោះឯង ។

៥៧- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្តវាទី យើងបានបុច្ឆាវិសជ្ជនាគ្នាអំពីសេចក្តីដ៏កំបាំងជ្រាលជ្រៅ ក្នុងកាមាវចរសោ-ភណចិត្តទាំង ២៤ និងរូបាវចរសោភណចិត្តទាំង ១៥ ក៏ល្មមស្តាប់បានហើយ ឯរូបាវចរសោភណចិត្តទាំង ១២ យើងពុំបានសួរគ្នាតទៅទៀតទេ ព្រោះមានសេចក្តីអធិប្បាយដូចគ្នានឹងអរូបជ្ឈានទាំង ៤ នោះដែរ ប្លែកគ្នាតែត្រង់ពាក្យថា អរូបាវចរកុសល-វិបាក-កិរិយា ប៉ុណ្ណោះ ក៏គង់មានសេចក្តីអធិប្បាយដូចកាមាវចរកុសល-វិបាក-កិរិយា និងរូបាវចរ-កុសល-វិបាក-កិរិយា ដែលបានបុច្ឆាវិសជ្ជនាគ្នាមករួចហើយនោះដែរ ចំ-ណែកសប្បុរសអ្នកសិក្សាបរមត្ថព្រះអភិធម្ម គប្បីរំពឹងយកសេចក្តីអធិប្បាយតាមន័យខាងលើនេះចុះ តពីនេះយើងនឹងសួរលោកអំពីលោកុត្តរសោ-ភណចិត្តវិញ ចុះលោកុត្តរសោភណចិត្ត បើសម្តែងដោយធម្មាធិដ្ឋាន យកធមិជាទីតាំងចែកជាលោកុត្តរកុសលចិត្តមានប៉ុន្មាន? ជាលោកុត្តរ-វិបាកចិត្តមានប៉ុន្មាន? បានឈ្មោះថា លោកុត្តរមគ្គចិត្តមានប៉ុន្មាន? បានឈ្មោះថា លោកុត្តរផលចិត្តមានប៉ុន្មាន? សេចក្តីអធិប្បាយផ្សេងគ្នាដូចម្តេចខ្លះ?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី សេចក្តីអធិប្បាយថា

កុសលចិត្តដែលឆ្លៀវឆ្លាសវាងវៃបានពិចារណា ឃើញជាក់ច្បាស់នូវព្រះអរិយសច្ចទាំង ៤ មានទុក្ខសច្ចជាដើម ហើយលះបង់បុថុជ្ជនគោត្រឡើងកាន់ព្រះអរិយគោត្រឆ្លងផុតចាកលោកទាំង ៣ មានកាមលោកជាដើម ហៅថា លោកុត្តរកុសលចិត្តមាន ៤ គឺព្រះអរហំសម្មាសម្ពុទ្ធទ្រង់សម្តែងចែកជា ៤ ចំណែកតាមប្រភេទនៃមគ្គ ៤ ឲ្យឈ្មោះថា សោតាបត្តិ-មគ្គចិត្ត ១ សកិទាគាមិមគ្គចិត្ត ១ អនាគាមិមគ្គចិត្ត ១ អរហត្តមគ្គចិត្ត ១ ឯវិបាករបស់លោកុត្តរកុសលចិត្តនោះ ព្រះអង្គទ្រង់សម្តែងចែកជា ៤ ចំណែក តាមប្រភេទនៃផល ៤ ឲ្យឈ្មោះថា សោតាបត្តិផលចិត្ត ១ សកិទាគាមិផលចិត្ត ១ អនាគាមិផលចិត្ត ១ អរហត្តផលចិត្ត ១ ព្រោះភាវៈនៃលោកុត្តរវិបាកចិត្តនោះជាផលរបស់លោកុត្តរកុសលចិត្តនោះឯង ៗ សេចក្តីអធិប្បាយពិស្តារថា ទី ១- សោតសព្ទ ប្រែថា ស្តាប់ ព្រោះអាស្រ័យនូវព្រះនិព្វានធ្វើឲ្យជាអារម្មណ៍ហើយស្តាប់ប្រតិបត្តិតាម, សោត-សព្ទ ប្រែថា ខ្សែ ព្រោះព្រះធម៌ដ៏ប្រសើរប្រកបដោយអង្គទាំង ៨ លោកពោលឲ្យឈ្មោះថា សោតៈ ប្រាកដស្មើដោយខ្សែទឹក, អាសព្ទ ប្រែថា ខាងដើម ឬទីមួយ បត្តិសព្ទ ប្រែថា កិរិយាដល់ ភ្ជាប់គ្នាជាអាបត្តិ ប្រែថា កិរិយាដល់ជាខាងដើមឬទីមួយ, ប្រជុំបទ ៣ តភ្ជាប់គ្នាជា

សោតាបត្តិ បានសេចក្ដីថា កិរិយាដល់ជាខាងដើមឬទីមួយនៃព្រះធម៌ដ៏ប្រសើដែលប្រកបដោយអង្គ ៨ បានឈ្មោះថា សោតៈ ប្រែថា ស្ដាប់ ព្រោះអាស្រ័យនូវព្រះនិព្វាន ធ្វើឲ្យជាអារម្មណ៍ហើយស្ដាប់ប្រតិបត្តិតាមគឺបង្អោន បង្ហូរ ជម្រុលចិត្តឲ្យចូលទៅជិតកាន់ព្រះនិព្វាន បានឈ្មោះថា សោតៈ ប្រែថា ខ្សែ ព្រោះព្រះធម៌ប្រសើរដែលប្រកបដោយអង្គទាំង ៨ នោះដ៏ប្រាកដស្មើដោយខ្សែទឹក បង្អោន បង្ហូរ ជម្រុលចិត្តឲ្យចូលទៅជ្រកនៅស៊ប់ស្ងួនក្នុងមហាសមុទ្រ គឺព្រះនិព្វាន មគ្គសព្ទ ប្រែថា ស្វែងរកនូវព្រះនិព្វាន សេចក្ដីអធិប្បាយថា ព្រះធម៌ដ៏ប្រសើរឯណា សម្រាប់ស្វែងរកព្រះនិព្វាន ឬថា ដែលបុគ្គលទាំងឡាយអ្នកមានប្រយោជន៍ដោយព្រះនិព្វាន ត្រូវស្វែងរកព្រះធម៌ដ៏ប្រសើរនោះ បានឈ្មោះថា មគ្គ ម៉្យាងទៀត ព្រះធម៌ដ៏ប្រសើរណា រមែងសម្លាប់ផ្ដាច់បង់នូវកិលេសទាំងឡាយ ដោយសមុច្ឆេទប្បហារហើយប្រព្រឹត្តទៅ ព្រះធម៌ដ៏ប្រសើរនោះ បានឈ្មោះថា មគ្គ គឺព្រះអរិយមគ្គប្រកបដោយអង្គ ៨ ពិត, កំកុសលចិត្តដែលកើតឡើងនឹងរលត់ទៅវិញជាមួយនឹងមគ្គ បានឈ្មោះថា មគ្គចិត្ត ប្រជុំបទទាំង ៣ តភ្ជាប់គ្នា បានឈ្មោះថា សោតាបត្តិមគ្គចិត្ត បានសេចក្ដីថា កុសលចិត្តកើតឡើងនឹងរលត់ទៅវិញ ជាមួយនឹងមគ្គ

ដែលជាផ្លូវសម្រាប់ស្វែងរកនូវព្រះនិព្វាន ឬថាផ្លូវដែលបុគ្គលទាំងឡាយ អ្នកមានប្រយោជន៍ដោយព្រះនិព្វានត្រូវស្វែងរក ឬថាជាធម៌ដ៏ប្រសើរ តែងសម្លាប់ផ្តាច់បង់នូវកិលេសទាំងឡាយ ដោយសមុច្ឆេទប្បហាររបស់ព្រះអរិយបុគ្គលទី ១ ដែលបានដល់ជាខាងដើមខ្សែទីមួយនៃព្រះអរិយ-មគ្គពិត ៗ ទី ២- សកឹសព្ទ ប្រែថា អស់វារៈមួយផង, អាគាមិសព្ទ ប្រែថា ត្រឡប់មក តភ្ជាប់គ្នាទាំងពីរបទជា សកិទាគាមិ បានសេចក្តីថាព្រះអរិយបុគ្គលត្រឡប់មកកាន់មនុស្សលោកនេះ ដោយអំណាចនៃបដិសន្ធិ-ចិត្តអស់វារៈមួយដងទៀត មគ្គសព្ទ ទី ២ នេះ អធិប្បាយដូចមគ្គសព្ទទី ១ ដែរ ក៏កុសលចិត្តដែលកើតឡើងនឹងរលត់ទៅវិញជាមួយនឹងមគ្គ បានឈ្មោះថា មគ្គចិត្ត តភ្ជាប់គ្នាទាំង ៤ បទ បានឈ្មោះថា សកិទាគាមិ-មគ្គចិត្ត បានសេចក្តីថា កុសលចិត្តកើតឡើងនឹងរលត់ទៅវិញជាមួយនឹងមគ្គដែលជាផ្លូវដ៏ប្រសើរសម្រាប់ស្វែងរកនូវព្រះនិព្វាន ឬថាជាផ្លូវដែលបុគ្គលទាំងឡាយ អ្នកមានប្រយោជន៍ដោយព្រះនិព្វានត្រូវស្វែងរក ឬថាជាធម៌ដ៏ប្រសើរតែងសម្លាប់ផ្តាច់បង់នូវកិលេសទាំងឡាយ ដោយសមុ-ច្ឆេទប្បហារ របស់ព្រះអរិយបុគ្គលទី ២ អ្នកត្រឡប់មកកាន់មនុស្សលោកនេះ ដោយអំណាចនៃបដិសន្ធិចិត្តអស់វារៈមួយដងទៀត ដោយពិត ៗ

ទី ៣- អនាគាមិសព្ទ ប្រែថា ព្រះអរិយបុគ្គលលោកពុំបានត្រឡប់មកកាន់កាមធាតុនេះដោយអំណាចនៃបដិសន្ធិចិត្តឡើយ មគ្គសព្ទទី ៣ នេះអធិប្បាយដូចមគ្គសព្ទទី ១ ដែរ គឺកុសលចិត្តកើតឡើងនឹងរលត់ទៅវិញជាមួយនឹងមគ្គ បានឈ្មោះថា មគ្គចិត្ត តភ្ជាប់គ្នាទាំង ៣ បទ បានឈ្មោះថា អនាគាមិមគ្គចិត្ត បានសេចក្តីថា កុសលចិត្តកើតឡើងនឹងរលត់ទៅវិញជាមួយនឹងមគ្គជាផ្លូវដ៏ប្រសើរ សម្រាប់ស្វែងរកនូវព្រះនិព្វាន ឬថាជាផ្លូវដែលបុគ្គលទាំងឡាយអ្នកមានប្រយោជន៍ ដោយព្រះនិព្វានត្រូវស្វែងរក ឬថាជាធម៌ដ៏ប្រសើរ តែងសម្លាប់ផ្តាច់បង់នូវកិលេសទាំងឡាយ ដោយសមុច្ឆេទប្បហារ របស់ព្រះអរិយបុគ្គលទី ៣ លោកពុំបានត្រឡប់មកកាន់កាមធាតុនេះដោយអំណាចនៃបដិសន្ធិចិត្តទៀតឡើយ ។ ទី ៤- អរហត្តមគ្គចិត្ត សេចក្តីអធិប្បាយថា កុសលចិត្តកើតឡើងនឹងរលត់ទៅវិញជាមួយនឹងមគ្គជាធម៌ដ៏ប្រសើរ អាចសម្លាប់ផ្តាច់បង់នូវកិលេសទាំងឡាយបានដោយសមុច្ឆេទប្បហារ របស់ព្រះអរិយបុគ្គលទី ៤ ដែលលោកបានសម្លាប់ផ្តាច់បង់នូវសត្រូវគឺកិលេសបាន លោកពុំបានធ្វើនូវអំពើបាបលាមកក្នុងទីស្ងាត់កំបាំងឡើយ លោកបានផ្តាច់បង់នូវកាំសង្សារវដ្តបាន ជាបុគ្គលគួរទទួលនូវបូជាដ៏វិសេស ដែលមនុស្សព្រមទាំងទេវតាទាំងឡាយ

នាំមកបូជាចំពោះលោក ដោយភាវៈនៃលោកជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរខ្ពង់ខ្ពស់ ។ ឯផលចិត្តទាំង ៤ មានសេចក្ដីអធិប្បាយដូចគ្នានឹងមគ្គចិត្តដែរ ប្លែកគ្នាតែត្រង់ពាក្យថា លោកុត្តរវិបាកចិត្ត លោកឲ្យឈ្មោះថា ផលចិត្តវិញ ព្រោះថាចិត្តជាផលដែលព្រះអរិយបុគ្គលលោកបានហើយ កើតមកអំពីលោកុត្តរកុសលចិត្តនោះឯង ។ រួមគ្នាទាំងអស់ត្រូវជាលោកុត្តរចិត្តទាំង ៨ ព្រោះពុំមានកិរិយាចិត្តឡើយ ។ វិសជ្ជនាមកអំពីលោកុត្តរសោភណចិត្តទាំង ៨ ដោយសេចក្ដីពិស្ដារខ្លះ សង្ខេបខ្លះតែប៉ុណ្ណោះឯង ។

៥៨- ធម្មវាទី បានស្ដាប់ហើយ សួរតទៅទៀតថា ម្នាលអត្តវាទី ចុះបើសម្ដែងជាបុគ្គលាធិដ្ឋានយកបុគ្គលជាទីតាំងវិញ ក្នុងបុគ្គលប្បភេទទាំងអស់មានប៉ុន្មានពួក? បែកផ្សេងគ្នាដូចម្ដេចខ្លះ? អធិប្បាយយ៉ាងណាខ្លះ? ចូរវិសជ្ជនារៀបរាប់ឲ្យសព្វគ្រប់មកយើងនឹងបានស្ដាប់ចូលចិត្តផងមើល។

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ក្នុងបុគ្គលប្បភេទលោកសម្ដែងបែកជា ១២ ពួក គឺព្រះអរិយបុគ្គល ៨ ពួក គឺបុគ្គលដែលបានសម្រេចសោតាបត្តិមគ្គពួក ១ ។ ល ។ បុគ្គលដែលបានសម្រេចព្រះ

អរហត្តផលពួក ១ ត្រូវជាព្រះអរិយបុគ្គលទាំង ៨ ពួក, បើសម្តែងរួបរួមនាមព្រះអរិយបុគ្គលទាំង ៨ ពួកនោះឲ្យខ្លីតិចចុះមកមាន ៤ ពួកគឺសោតាបន្នបុគ្គល ១ សកិទាគាមិបុគ្គល ១ អនាគាមិបុគ្គល ១ អរហន្តបុគ្គល ១ ត្រូវជា ៤ ពួក, បុថុជ្ជនបុគ្គលមាន ៤ ពួកគឺ តិហេតុកបុគ្គល ១ ទុហេតុកបុគ្គល ១ អហេតុកបុគ្គល ១ អាបាយិកាហេតុកសត្ត ១ ត្រូវជា ៤ ពួក បានសេចក្តីថាបើចែកដោយពិស្តារមាន ១២ ពួក ដោយសង្ខេបមាន ៨ ពួកព្រោះថាមគ្គចិត្តកើតឡើងហើយ ផលចិត្តក៏កើតឡើងជាលំដាប់នៃមគ្គចិត្តនោះដែរ តែថាដែលលោកចែកព្រះអរិយបុគ្គលទៅជា ៨ ពួកនោះគឺលោកចែកនិយមតាមលោកុត្តរកុសល វិបាកចិត្តនោះឯង ។

៥៩- ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា ម្នាលអត្តវាទី ចុះព្រះសោតាបន្នបុគ្គលទី ១ ក្តី ព្រះសកិទាគាមិបុគ្គលទី ២ ក្តី ព្រះអនាគាមិបុគ្គលទី ៣ ក្តី ព្រះអរហន្តបុគ្គលទី ៤ ក្តី លោកបានលះបង់នូវសំយោជនធម៌ប៉ុន្មាន? វៀរលែងចាកវិថិចិត្តប៉ុន្មាន? មានវិថិចិត្តប៉ុន្មាន ដែលឋិតនៅក្នុងសន្តានរបស់លោកដ៏សមគួរតាមបាន? សេចក្តីអធិប្បាយផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់យើងនឹងស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះសោតាបន្នបុគ្គលទី ១ នេះ លោកបានលះបង់នូវសំយោជនធម៌ទាំង ៣ បាន គឺសក្កាយទិដ្ឋិ សេចក្តីប្រកាន់វត្តប្បដិបត្តិតាមគំនិតយល់ឃើញរបស់ខ្លួន ១ វិចិកិច្ឆា សេចក្តីសង្ស័យមិនចេះដាច់ស្រេច ១ សីលព្វតបរាមាសោ សេចក្តីបបោសអង្អែលប្រកាន់សីលវត្តរបស់ខ្លួនថាប្រសើរវិសេស ១ និងវៀរលែងចាកវីថិចិត្ត ៣៨ គឺអហេតុកហសនកិរិយាចិត្ត ១ កាមាវចរមហាកិរិយាចិត្ត ៧ មហគ្គតកិរិយាចិត្ត ៩ (ជា ១៨) អកុសលចិត្តប្រកបដោយសោមនស្សវេទនាជាទិដ្ឋិគតសម្បយុត្ត ២ អកុសលចិត្តប្រកបដោយឧបេក្ខាវេទនាជាទិដ្ឋិគតសម្បយុត្ត ២ វិចិកិច្ឆាសម្បយុត្ត ១ (ជា ៥) មគ្គចិត្ត ៣ ផលចិត្ត ៣ មហគ្គតចិត្ត ៩ ត្រូវជា ៣៨ ពុំបានកើតឡើងក្នុងសន្តានលោកនោះឡើយ មានតែវីថិចិត្ត ៥១ គឺអហេតុកអកុសលវិបាកចិត្ត ៧ អហេតុកកុសលវិបាកចិត្ត ៨ សហេតុកមហាវិបាកចិត្ត ៨ (ជា ២៣) បញ្ចទ្វារាវជ្ជនចិត្ត ១ មនោទ្វារាវជ្ជនចិត្ត ១ (ជាអាវជ្ជនចិត្ត ២) សហេតុកកាមាវចរកុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ លោកុត្តរកុសលចិត្ត ១ (ជា ១៨) អកុសលចិត្ត ៧ សោតាបត្តិផលចិត្ត ១ រួមទាំងអស់ត្រូវជា ៥១ កើតឡើងប្រាកដក្នុង

សន្តានព្រះសោតាបន្នបុគ្គលនោះ សមគួរតាមបានដោយពិត ។

ទី ២- ព្រះសកិទាគាមិបុគ្គលនោះលោកបានលះបង់នូវសំយោជនធម៌ជាចំណែកនៃកាមធាតុទាំង ៥ បានគឺ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វត្តបរាមាសោ ១ កាមរាគោ សេចក្តីតម្រេកត្រេកត្រអាលក្នុងកាមតណ្ហា ១ បដិឃបិត្តំ សេចក្តីថ្នាំងថ្នាក់ក្តៅក្រហាយចិត្តប្រកបដោយទោមនស្ស ១ ត្រូវជា ៥ តែថាកាមរាគនិងបដិឃចិត្តទាំង ២ នេះ គ្រាន់តែតិចស្តើងប៉ុណ្ណោះ នឹងវៀរលែងចាកវីថិចិត្ត ៣៨ គឺ កិរិយាចិត្ត ១៨ អកុសលចិត្ត ៥ មគ្គចិត្ត ៣ ផលចិត្ត ៣ មហគ្គតកិរិយាចិត្ត ៩ ត្រូវជា ៣៨ ពុំបានកើតឡើងក្នុងសន្តានលោកនោះឡើយ មានតែវីថិចិត្ត ៥១ គឺវិបាកចិត្ត ២៣ អាវជ្ជនចិត្ត ២ កុសលចិត្ត ១៨ អកុសលចិត្ត ៧ សកិទាគាមិផលចិត្ត ១ រួមទាំងអស់ត្រូវជា ៥១ កើតឡើងប្រាកដក្នុងសន្តាននៃព្រះសកិទាគាមិបុគ្គលនោះ សមគួរតាមបានដោយពិត ។

ទី ៣- ព្រះអនាគាមិបុគ្គលនោះលោកបានលះបង់នូវសំយោជនធម៌ជាចំណែកនៃកាមធាតុទាំង ៥ ជាស្រឡះ នឹងវៀរលែងចាកវីថិចិត្ត ៤០ គឺ កិរិយាចិត្ត ១៨ អកុសលចិត្ត ៧ មគ្គចិត្ត ៣ ផលចិត្ត ៣ មហគ្គតវិបាកចិត្ត ៩ ត្រូវជា ៤០ ពុំបានកើតឡើងក្នុងសន្តានលោកនោះឡើយ

មានតែវិថិចិត្ត ៤៩ គឺកាមាវចរវិបាកចិត្ត ២៣ អាវជ្ជនចិត្ត ២ កុសលចិត្ត ១៨ អកុសលចិត្ត ៥ អនាគាមិផលចិត្ត ១ រួមទាំងអស់ត្រូវជា ៤៩ កើតឡើងប្រាកដក្នុងសន្តាននៃព្រះអនាគាមិបុគ្គលនោះ សមគួរតាមបានដោយពិត ។

ទី ៤- ព្រះអរហន្តបុគ្គលនោះលោកបានលះបង់នូវសំយោជនធម៌ទាំង ១០ គឺ សំយោជនធម៌ ជាចំណែកនៃកាមធាតុ ៥ និងសំយោជន-ធម៌ជាចំណែកនៃរូបារូបធាតុ ៥ គឺរូបរាគោ សេចក្តីតម្រេកត្រេកត្រអាលក្នុងរូបតណ្ហា ១ អរូបរាគោ សេចក្តីតម្រេកត្រេកត្រអាលក្នុងអរូបតណ្ហា ១ មានោ សេចក្តីប្រកាន់ចិត្តរបឹងរឹងរូសមាំ ១ ឧទ្ធច្ចំ ចិត្តរាយមាយហុយឡើងដូចផេះត្រូវខ្យល់ ១ អវិជ្ជា សេចក្តីមិនដឹងប្រាកដក្នុងព្រះអរិយសច្ចទាំងបួន ១ និងវៀរលែងចាកវិថិចិត្ត ៤៥ គឺអកុសលចិត្ត ១២ កាមាវចរ-កុសលចិត្ត ៨ រូបាវចរកុសលចិត្ត ៥ អរូបាវចរកុសលចិត្ត ៤ លោកុត្តរ-កុសលចិត្ត ៤ (ជា ៣៣) ផលចិត្ត ៣ មហគ្គតវិបាកចិត្ត ៩ ត្រូវជា ៤៥ ពុំបានកើតឡើងក្នុងសន្តានលោកនោះឡើយ មានតែវិថិចិត្ត ៤៤ គឺអកុសលអហេតុកវិបាកចិត្ត ៧ កុសលអហេតុកវិបាកចិត្ត ៨ សហេតុក-មហាវិបាកចិត្ត ៧ (ជា ២៣) អហេតុកកិរិយាចិត្ត ៣ មហាកិរិយាចិត្ត ៨ មហគ្គតកិរិយាចិត្ត ៩ (ជា ២០) អរហត្តផលចិត្ត ១ រួមទាំងអស់ត្រូវជា

៥៤ កើតឡើងប្រាកដក្នុងសន្តានវៃព្រះអរហន្តបុគ្គលនោះ សមគួរតាមបានដោយពិត ។ វិសជ្ជនាមកអំពីព្រះអរិយបុគ្គលទាំង ៤ ពួកដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះឯង ។

៦០- ធម្មវាទី បានស្ដាប់ហើយ សួរតទៅទៀតថា ម្នាលអត្ថវាទី ចុះបុថុជ្ជនបុគ្គលទាំង ៤ ពួកនោះ ក្នុងបុគ្គលមួយពួកៗ វៀរលែងចាកវីថិចិត្តប៉ុន្មាន? មានវីថិចិត្តប៉ុន្មាន ឋិតនៅក្នុងសន្តានខ្លួន? ផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្ដាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯបុថុជ្ជនបុគ្គលទាំង ៤ ពួកនោះគឺ ទី ១- តិហេតុកបុថុជ្ជនបុគ្គលនោះតែងវៀរលែងចាកវីថិចិត្ត ៣៥ គឺ អហេតុកកិរិយាហសិតុប្បាទចិត្ត ១ សហេតុកកាមាវចរកិរិយាចិត្ត ៨ មហគ្គតកិរិយាចិត្ត ៩ (ជា ១៨) លោកុត្តរចិត្ត ៨ មហគ្គតវិបាកចិត្ត ៩ (ជា ១៧) រួមទាំងអស់ត្រូវជា ៣៥ ពុំបានកើតឡើងក្នុងសន្តាននៃតិហេតុកបុថុជ្ជនបុគ្គលនោះឡើយ មានតែវីថិចិត្ត ៥៤ គឺអហេតុកអកុសល-វិបាកចិត្ត ៧ អហេតុកកុសលវិបាកចិត្ត ៨ សហេតុកកាមាវចរវិបាកចិត្ត ៨ (ជា ២៣) អាវជ្ជនចិត្ត ២ កាមាវចរកុសលចិត្ត ៨ មហគ្គតកុសលចិត្ត ៩ អកុសលចិត្ត ១២ (ជា ៣១) រួមទាំងអស់ត្រូវជា ៥៤ កើតឡើងប្រាកដ

ក្នុងសន្តាននៃតិហេតុកបុថុជ្ជនបុគ្គលនោះ សមគួរតាមបានដោយពិត ។

ទី ២- ទ្វិហេតុកបុថុជ្ជនបុគ្គលនោះតែងវៀរលែងចាកវីថិចិត្ត ១៣ គឺ សហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត ៤ មហគ្គតកុសលចិត្តជាអប្បនាជវន ៩ ត្រូវជា ១៣ ពុំបានកើតឡើងក្នុងសន្តាននៃទ្វិហេតុកបុថុជ្ជនបុគ្គលនោះឡើយ មានតែវីថិចិត្ត ៤១ គឺអហេតុកអកុសលវិបាកចិត្ត ៧ អហេតុកកុសលវិបាកចិត្ត ៨ សហេតុកកាមាវចរវិបាកចិត្ត ជាញាណវិប្បយុត្តដែលមានកម្លាំងខ្លាំងជាឧក្រិដ្ឋ ៤ អាវជ្ជនចិត្ត ២ សហេតុកកាមាវចរកុសលចិត្ត ៨ អកុសលចិត្ត ១២ រួមទាំងអស់ត្រូវជា ៤១ កើតឡើងប្រាកដក្នុងសន្តាននៃទ្វិហេតុកបុថុជ្ជនបុគ្គលនោះ សមគួរតាមបានដោយពិត ។

ទី ៣- អហេតុកបុថុជ្ជនបុគ្គលនោះតែងវៀរលែងចាកវីថិចិត្ត ១៣ គឺ សហេតុកកាមាវចរវិបាកចិត្តជាញាណសម្បយុត្ត ៤ មហគ្គតកុសលចិត្តជាអប្បនាជវន ៩ ត្រូវជា ១៣ ពុំបានកើតឡើងក្នុងសន្តាននៃអហេតុកបុថុជ្ជនបុគ្គលនោះឡើយ មានតែវីថិចិត្ត ៤១ គឺអហេតុកអកុសលវិបាកចិត្ត ៧ អហេតុកកុសលវិបាកចិត្ត ៨ សហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្តដែលមានកម្លាំងខ្សោយជាឱមកៈ ៤ អាវជ្ជនចិត្ត ២ សហេតុកកាមាវចរកុសលចិត្ត ៨ អកុសលចិត្ត ១២ រួមទាំងអស់ត្រូវជា ៤១ កើតឡើង

ប្រាកដក្នុងសន្តាននៃអហេតុកបុថុជ្ជនបុគ្គលនោះ សមគួរតាមបានដោយពិត ។ ទី ៤- អាបាយិកាហេតុកបុថុជ្ជនសត្តនោះតែងវៀរលែងចាកវីថិចិត្ត ១៧ គឺ សហេតុកកាមាវចរវិបាកចិត្ត ៨ មហគ្គតកុសលចិត្តជាអប្បនាជវន ៩ ត្រូវជា ១៧ ពុំបានកើតឡើងក្នុងសន្តាននៃអាបាយិកាហេតុកបុថុជ្ជន-សត្តនោះឡើយ មានតែវីថិចិត្ត ៣៧ គឺអហេតុកអកុសលវិបាកចិត្ត ៧ អហេតុកកុសលវិបាកចិត្ត ៨ អាវជ្ជនចិត្ត ២ សហេតុកកាមាវចរកុសល-ចិត្ត ៨ អកុសលចិត្ត ១២ រួមទាំងអស់ត្រូវជា ៣៧ កើតឡើងប្រាកដក្នុងសន្តាននៃអាបាយិកាហេតុកបុថុជ្ជនសត្តនោះ សមគួរតាមបានដោយពិត ។ វិសជ្ជនាមកអំពីបុថុជ្ជនបុគ្គលទាំង ៤ ពួកដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៦១- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្ថវាទី លោកវិសជ្ជនាមកនេះយើងស្តាប់បានខ្លះនៅសង្ស័យខ្លះ តែត្រង់ពាក្យដែលលោកពោលថា ទ្វិហេតុកបុគ្គលទី ២ ថាវៀរលែងចាកវីថិចិត្ត ១៣ ជាស្រឡះមានតែវីថិចិត្ត ៤១ កើតឡើងប្រាកដក្នុងសន្តាននៃទ្វិហេតុកបុគ្គលនោះ ព្រោះថាសហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត មានកម្លាំងខ្លាំងជាឧក្រិដ្ឋអហេតុកបុគ្គលទី ៣ ថាវៀរលែងចាកវីថិចិត្ត ១៣ ជាស្រឡះ

ដូចគ្នាដែរ មានវីថិចិត្ត ៤១ កើតឡើងប្រាកដក្នុងសន្តាននៃអហេតុ-កបុគ្គលនោះ ព្រោះថា សហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត មានកម្លាំងខ្សោយជាឱមកៈ តើមានសេចក្តីអធិប្បាយផ្សេងគ្នាដូចម្តេចខ្លះ? អាបាយិកាហេតុកសត្តទី ៤ ជាវៀរលែងវីថិចិត្ត ១៧ ជាស្រឡះមានតែវីថិចិត្ត ៣៧ កើតឡើងប្រាកដក្នុងសន្តាននៃអាបាយិកាហេតុកសត្តនោះ តើមានសេចក្តីអធិប្បាយផ្សេងគ្នា អំពីអហេតុកបុគ្គលនោះដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកម្តងទៀតឲ្យច្បាស់លាស់ យើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ទី ២ ទ្វិហេតុកបុគ្គលដែលវៀរលែងចាកវីថិចិត្ត ១៣ ពុំបានកើតឡើងក្នុងសន្តានខ្លួននោះឡើយ មានតែវីថិចិត្ត ៤១ កើតឡើងប្រាកដក្នុងសន្តានខ្លួន ព្រោះថា សហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្ត មានកម្លាំងខ្លាំងជាឧក្រិដ្ឋនោះ មានសេចក្តីអធិប្បាយថា បុគ្គលដែលប្រកបដោយកុសលចិត្តទី ៣-៤-៧-៨ ជាញាណវិប្បយុត្តអសង្ខារិកក្តី សសង្ខារិកក្តី ក៏ក្នុងខណៈដែលបរិច្ចាគទ្រព្យធ្វើទានក្តី តាំងសមាទានរក្សាសីលក្តី តាំងចម្រើនភាវនាព្រះកម្មដ្ឋានក្តី ជាបុគ្គលមានចិត្តដ៏ក្លៀវក្លាខ្លាំងខ្ជាប់ខ្ជួនប្រែងចាត់

បែងធ្វើការជាកុសលមិនបានខ្ពិលប្រអូសធុញទ្រាន់ឡើយ ដរាបដល់សម្រេចបុណ្យមួយលើកៗ ហើយមានចិត្តមិនបានក្តៅក្រហាយជាខាងក្រោយ តែងមានចិត្តត្រេកអរនឹករឭកបុណ្យដែលខ្លួនបានធ្វើកន្លងទៅហើយជាប់ជានិច្ចពុំបានភ្លេចឡើយ កើតជាសហេតុកកាមាវចរវិបាកចិត្តជាញាណវិប្បយុត្តអសង្ខារិកក្តី សសង្ខារិកក្តី ដ៏មានកម្លាំងខ្លាំងជាតួបដិសន្ធិកើតជាមនុស្សជាន់កណ្តាល មានសទ្ធាជឿកម្មផល តែងបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទាន តែងសមាទានរក្សាសីល ៥ សីលឧបោសថតែថាជាបុគ្គលល្ងង់ខ្លៅពុំសូវមានប្រាជ្ញានឹងចម្រើនមេត្តាភាវនាឡើយ បានឈ្មោះថា ទ្វិហេតុកបុថុជ្ជនបុគ្គលពិត ៗ ទី ៣- អហេតុកបុថុជ្ជនបុគ្គលដែលវៀរលែងចាកវីថិចិត្ត ១៣ ពុំបានកើតឡើងក្នុងសន្តានខ្លួន មានតែវីថិចិត្ត ៤១ កើតឡើងប្រាកដក្នុងសន្តានខ្លួនព្រោះថា សហេតុកកាមា-វចរវិបាកចិត្តជាញាណវិប្បយុត្តមានកម្លាំងខ្សោយជាឱមកៈនោះ មានសេចក្តីអធិប្បាយថា បុគ្គលដែលប្រកបដោយកុសលចិត្តទី ៣-៤-៧-៨ ជាញាណវិប្បយុត្ត អសង្ខារិកក្តី សសង្ខារិកក្តី ក្នុងខណៈដែលបានបរិ-ច្ចាគទ្រព្យធ្វើបុណ្យឲ្យទានក្តី តាំងសមាទានរក្សាសីលក្តី តាំងចម្រើនភាវនាព្រះកម្មដ្ឋានក្តី ជាបុគ្គលមានចិត្តឥតសទ្ធាមិនបានជឿកម្មផល មិនបាន

ត្រេកអរជ្រះថ្លាក្នុងការជាកុសលនោះប៉ុន្មានឡើយ ធ្វើដោយការទើសទាល់នឹងញាតិមិត្តសំឡាញ់ដែលនៅផ្ទះជិតខាង ដែលគេតែងធ្វើបុណ្យឲ្យទានរឿយៗ ឬថា គេបានមកបបួលដឹកនាំឲ្យចូលធ្វើបុណ្យនឹងគេក្តី ដែលនឹងធ្វើបុណ្យនោះទៀត មានសេចក្តីខ្ជិលច្រអូសធុញទ្រាន់ច្រើនអន្ទយស្មៀម មិនមានឧស្សាហ៍ ខំព្យាយាមជួយចាត់ចែងការជាកុសលនោះឡើយ លុះបានធ្វើបុណ្យឲ្យទានរួចស្រេចហើយ ក៏កើតវិប្បដិសារីមានសេចក្តីក្តៅក្រហាយជាខាងក្រោយ ក៏បុណ្យទានដែលបុគ្គលបានធ្វើប្រកបដោយកាមាវចរកុសលចិត្ត ជាញាណវិប្បយុត្តមានកម្លាំងខ្សោយយ៉ាងនេះ បានឈ្មោះថា សហេតុកកាមាវចរវិបាកចិត្តមានកម្លាំងខ្សោយជាឱមកៈ ដ៏ថោកទាប ពុំបានឲ្យបដិសន្ធិឡើយ នឹងធ្លាក់ចុះមកឲ្យបដិសន្ធិជាអហេតុកកំណើតវិញ គឺឧបេក្ខាសហគតសន្តីរណៈជាអហេតុកកុសលវិបាកទី ៨ ជាតួបដិសន្ធិ កើតជាមនុស្សជាន់ទាប មានភ្នែកខ្វាក់ត្រចៀកថ្លង់ និងគអំពីកំណើតជាដើម ជាមនុស្សអភ័ព្វមិនគួរដល់បព្វជ្ជានិងឧបសម្បទាក្នុងព្រះពុទ្ធសាសនាឡើយ បានឈ្មោះថា អហេតុកបុថុជ្ជនបុគ្គលដោយពិត ។ ៤- អាបាយិកាហេតុកបុថុជ្ជនសត្វ ដែលវៀរលែងចាកវីថិចិត្ត ១៧ ពុំបានកើតឡើងក្នុងសន្តានខ្លួន មានតែវីថិចិត្ត

៣៧ កើតឡើងប្រាកដក្នុងសន្តាននៃអាបាយិកាហេតុកសត្តនោះ ព្រោះថា វៀរលែងចាកសហេតុកកាមាវចរវិបាកចិត្ត ជាញាណវិប្បយុត្តជាស្រឡះ មានសេចក្តីអធិប្បាយថា បណ្តាអកុសលចិត្ត ១២ នោះ បុគ្គលដែលប្រកបដោយអកុសលចិត្តឯណានីមួយ ហើយប្រព្រឹត្តធ្វើនូវអំពើទុច្ចរិតទាំង ៣ មានកាយទុច្ចរិតជាដើម ដែលជាចិត្តមានកម្លាំងខ្សោយឲ្យផលជាអហេតុកកំណើត គឺ ឧបេក្ខាសហគតសន្តីរណៈជាអហេតុកអកុសលវិបាកចិត្តទី ៧ ជាតួបដិសន្ធិកើតក្នុងអបាយភូមិទាំង ៤ គឺ នរក ១ ប្រេត ១ អសុរកាយ ១ តិរច្ឆាន ១ សោយទុក្ខវេទនាដោយច្រើន បានឈ្មោះថា អាបាយិកាហេតុកសត្តដោយពិត ។

វិសជ្ជនាមកអំពីបុគ្គលទី ២-៣-៤ ដែលមានសេចក្តីផ្សេងគ្នាដោយសង្ខេបតែប៉ុណ្ណោះឯង ។

៦២- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី យើងនៅមានសង្ស័យក្នុងព្រះអរិយបុគ្គលទាំង ៤ ពួកតទៅទៀតតែត្រង់ព្រះអរិយបុគ្គលទាំង ៣ ពួក គឺព្រះសោតាបន្នបុគ្គលពួកទី ១ ផ្សេងគ្នាដោយឈ្មោះមាន ៣ យ៉ាង មានសត្តក្ខត្តុំបរមសោតាបន្នបុគ្គលជាដើម, ព្រះអនាគាមិបុគ្គលពួកទី ៣ ផ្សេងគ្នាដោយឈ្មោះមាន ៥ យ៉ាង មាន

អន្តរបរិនិព្វាយីអនាគាមិបុគ្គលជាដើម, ព្រះអរហន្តបុគ្គលពួកទី ៤ ផ្សេងគ្នាដោយឈ្មោះមាន ២ យ៉ាង មានព្រះអរហន្តបដិសម្ភិទាញាណជាដើម ក៏ព្រះអរិយបុគ្គលទាំង ៣ ពួកនេះយើងពុំបានសួរលោកឡើយ ព្រោះលោកអ្នកប្រាជ្ញទាំងឡាយលោកធ្លាប់សម្តែងមករឿយៗ ហើយ យើងនៅសង្ស័យតែត្រង់ព្រះសកិទាគាមិបុគ្គលពួកទី ២ ព្រោះពុំដែលឮលោកអ្នកប្រាជ្ញណាមួយសម្តែងប្រាប់ថា មានឈ្មោះផ្សេងគ្នាយ៉ាងណាសោះ ឬមានឈ្មោះតែមួយទេ បើមានឈ្មោះផ្សេងគ្នាដែរ តើមានឈ្មោះប៉ុន្មាន? គឺអ្វីខ្លះ? សេចក្តីអធិប្បាយថាដូចម្តេចខ្លះ។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះសកិទាគាមិបុគ្គលនោះមិនមែនមានឈ្មោះតែមួយទេ តាមន័យដីកាសង្គហៈលោកសម្តែងពន្យល់ថា ព្រះសកិទាគាមិបុគ្គលផ្សេងគ្នាដោយឈ្មោះមាន ៥ គឺ ឥធ បត្វា ឥធ បរិនិព្វាយី ព្រះសកិទាគាមិបុគ្គលលោកបានសម្រេចដល់សកិទាគាមិផលក្នុងឋានមនុស្សលោកនេះ ហើយបានចម្រើនវិបស្សនាកម្មដ្ឋានបានសម្រេចដល់ព្រះអរហត្តផល កម្ចាត់បង់នូវកងកិលេសទាំងអស់ ហើយបានរំលាយខន្ធចូលកាន់ព្រះនិព្វាន ក្នុងឋានមនុស្សលោកនេះ ១, តត្ថ បត្វា តត្ថ បរិនិព្វាយី ព្រះសកិទាគាមិបុគ្គលលោកបាន

សម្រេចដល់សកិទាគាមិផលក្នុងឋានទេវលោកនោះ ហើយបានចម្រើនវិបស្សនាកម្មដ្ឋានបានសម្រេចដល់ព្រះអរហត្តផល កម្ចាត់បង់នូវកងកិលេសទាំងអស់ ហើយបានរំលាយខន្ធចូលកាន់ព្រះនិព្វានក្នុងឋានទេវលោកនោះ ១, ឥធ បត្វា ឥត្ថ បរិព្វាយី ព្រះសកិទាគាមិបុគ្គលលោកបានសម្រេច ដល់សកិទាគាមិផលក្នុងឋានមនុស្សលោកនេះ ហើយបានច្យុតទៅកើតក្នុងឋានទេវលោកនាយ បានចម្រើនវិបស្សនាកម្មដ្ឋានបានសម្រេចដល់ព្រះអរហត្តផល កម្ចាត់បង់នូវកងកិលេសទាំងអស់ ហើយបានរំលាយខន្ធចូលកាន់ព្រះនិព្វានក្នុងឋានទេវលោកនោះ ១, ឥត្ថ បត្វា ឥធ បរិនិព្វាយី ព្រះសកិទាគាមិបុគ្គលលោកបានសម្រេចដល់សកិទាគាមិផលក្នុងឋានទេវលោកនោះ លុះបានច្យុតចុះមកកើតក្នុងឋានមនុស្សលោកវិញ ហើយបានចម្រើនវិបស្សនាកម្មដ្ឋានបានសម្រេចដល់ព្រះអរហត្តផលកម្ចាត់បង់នូវកងកិលេសទាំងអស់ ហើយបានរំលាយខន្ធចូលកាន់ព្រះនិព្វានក្នុងឋានមនុស្សលោកនេះ១, ឥធ បត្វា ឥត្ថ និព្វត្តេត្វា ឥធ បរិនិព្វាយី ព្រះសកិទាគាមិបុគ្គលលោកបានសម្រេចដល់សកិទាគាមិផលក្នុងឋានមនុស្សលោកនេះ លុះបានច្យុតទៅកើតក្នុងឋានទេវលោកនោះ ដល់អស់អាយុក៏ច្យុតចុះមកកើតក្នុងឋានមនុស្សលោកវិញ ហើយ

បានចម្រើនវិបស្សនាកម្មដ្ឋាន បានសម្រេចដល់ព្រះអរហត្តផលកម្ចាត់បង់នូវកងកិលេសទាំងអស់ ហើយបានរំលាយខន្ធចូលកាន់ព្រះនិព្វានក្នុងឋានមនុស្សលោកនេះ១, ត្រូវជាសកិទាគាមិបុគ្គលផ្សេងគ្នាដោយឈ្មោះមាន ៥ តែថាលោកលើកយកនាមព្រះសកិទាគាមិបុគ្គលជាគម្រប់ ៥ តែមួយយកមកឲ្យឈ្មោះថា សកិទាគាមិបុគ្គលដោយពិត បានសេចក្ដីថា ព្រះអរិយបុគ្គលលោកត្រឡប់មកកាន់ឋានមនុស្សលោកនេះដោយអំណាចនៃបដិសន្ធិចិត្តអស់វារៈមួយដងទៀត ទើបសម្រេចដល់ព្រះនិព្វានដោយពិត ។ វិសជ្ជនាមកអំពីព្រះសកិទាគាមិបុគ្គលផ្សេងគ្នាដោយឈ្មោះមាន ៥ ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៦៣- ធម្មវាទី បានស្ដាប់ហើយសួរប្រស្នាដទៃតទៅទៀតថា ម្នាលអត្ថវាទី ចុះធម៌ទាំងឡាយ ៥២ បានឈ្មោះថា ចេតសិក កើតនិងរលត់ព្រមជាមួយនឹងចិត្តនោះ បើចែកទៅតាមពួកក្រុមរបស់ចេតសិកមានប៉ុន្មានពួក? ក្នុងពួកមួយៗ មានចំនួនប៉ុន្មាន? ចូរលោកវិសជ្ជនារៀបរាប់តាមពួកក្រុមរបស់ចេតសិកមក យើងនឹងបានស្ដាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ធម៌ទាំងឡាយ ៥២

បានឈ្មោះថា ចេតសិកនោះ បើចែកទៅតាមពួកក្រុមរបស់ចេតសិក មាន ៣ ពួកគឺអញ្ញសមានាចេតសិកពួកទី ១ មានចំនួន ១៣ អកុសលចេតសិកពួកទី ២ មានចំនួន ១៤ សោភណចេតសិកពួកទី ៣ មានចំនួន ២៥ រួមទាំងអស់ត្រូវជា ៥២ ដោយពិត សូមជ្រាប ។

៦៤- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្ថវាទី លោកបានវិសជ្ជនាមកនេះត្រឹមត្រូវហើយ ចុះអញ្ញសមានាចេតសិកពួកទី ១ មានចំនួន ១៣ នោះ បើចែកទៅជាសព្វចិត្តសាធារណចេតសិកមានចំនួនប៉ុន្មាន? អធិប្បាយថាដូចម្តេចខ្លះ? ចែកទៅជាបកិណ្ណកចេតសិកមានចំនួនប៉ុន្មាន? សេចក្តីផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល ។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអញ្ញសមានាចេតសិក ១៣ នោះ គឺលោកសម្តែងញែកចែកជាសព្វចិត្តសាធារណចេតសិកគឺជាចេតសិកធម៌សាធារណៈទូទៅ កើតបានគ្រប់វិថីចិត្តទាំងអស់មាន ៧ គឺ ១- ផស្សៈ ចេតសិកធម៌ប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ មានការប៉ះពាល់នូវអារម្មណ៍ជាលក្ខណៈ មានការជុសខាត់នូវអារម្មណ៍ជាកិច្ច មានការប្រជុំជួបប្រទះគ្នាដោយចក្ខុនិងរូបជាដើមជាទីតម្កល់នៃឥដ្ឋានិដ្ឋារម្មណ៍ ។

២- វេទនា ធម្មជាតិប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ មានកិរិយាសោយបរិភោគជ្រះថ្លាព្រមនឹងដឹងច្បាស់នូវរសនៃអារម្មណ៍ជាលក្ខណៈ ជាផលជាទីតម្កល់នៃឥដ្ឋានិដ្ឋារម្មណ៍ ។ ៣- សញ្ញា ធម្មជាតិសម្រាប់ធ្វើសម្គាល់ចំណាំហើយដឹងច្បាស់នូវអារម្មណ៍ពណ៌ខៀវ ក្រហម លឿងជាដើមជាលក្ខណៈ ជាផលជាទីតម្កល់នៃឥដ្ឋានិដ្ឋារម្មណ៍ ។ ៤- ចេតនា ធម្មជាតិជាធំ អាចចាត់ចែងរិះគិតមានឧស្សាហ៍ព្យាយាមដំកៀវក្លាក្រៃលែងជាទ្វេគុណត្រៃគុណក្នុងឥដ្ឋានិដ្ឋារម្មណ៍ឲ្យជាធម៌ កើតនិងរលត់ព្រមដោយខ្លួនឯង ។ ៥- ឯកគ្គតា ភាវៈនៃចិត្តឋិតនឹងនៅក្នុងអារម្មណ៍តែមួយ ពុំបានរវើរវាយទៅក្នុងអារម្មណ៍ផ្សេងៗ ឡើយ ។ ៦- ជីវិតិន្ទ្រិយំ ធម្មជាតតែងប្រព្រឹត្តរស់នៅផង ញុំាងខ្លួនឲ្យធ្វើជាធំក្នុងកិច្ចទាំងឡាយដែលប្រព្រឹត្តទៅក្នុងធម៌ដំប្រកបកើតនិងរលត់ព្រមជាមួយគ្នាផង ។ ៧- មនសិការោ កិរិយាធ្វើកំណត់នូវអារម្មណ៍ផ្សេងៗ ទុកក្នុងចិត្ត គឺជាចេតសិកធម៌ដែលប្រកបកើតព្រមជាមួយនឹងវីថិចិត្តទី ៥ សម្រាប់ធ្វើកំណត់នូវអារម្មណ៍ទុកក្នុងចិត្ត បើធ្វើកំណត់នូវអារម្មណ៍ ខុសជាអនិដ្ឋារម្មណ៍មិនត្រូវតាមឧបាយនៃប្រាជ្ញាទេ នឹងកើតជាអកុសលផលបាបពិត បើធ្វើកំណត់នូវអារម្មណ៍ត្រូវជាឥដ្ឋារម្មណ៍ត្រូវត្រង់តាមឧបាយនៃប្រាជ្ញាហើយ នឹងកើត

ជាកុសលផលបុណ្យដោយពិត ។

លោកសម្ដែងចែកទៅជាបកិណ្ណកចេតសិក គឺ ជាចេតសិកធម៌ដែលប្រឡូកប្រឡំរោយរាយកើតនិងរលត់ជាមួយនឹងសោភណចិត្តខ្លះ អសោភណចិត្តខ្លះ ក្នុងវីថិចិត្តផ្សេងៗ មាន ៦ គឺ ១- វិតក្កោ ចេតសិកធម៌សម្រាប់ត្រិះរិះគិតនូវអារម្មណ៍ ឬថាញុំាងចិត្តឲ្យឡើងកាន់អារម្មណ៍ប្រព្រឹត្តទៅក្នុងសម្បយុត្តធម៌ មានកិរិយាលើកឡើងនូវវីថិចិត្តកាន់អារម្មណ៍ជាលក្ខណៈ ប្រកបកើតឡើងព្រមក្នុងវីថិចិត្ត ៥៥ គឺកាមាវចរចិត្ត ៤៤ បឋមជ្ឈាន ១១ វៀរលែងតែវិញ្ញាណ ១០ និងរូបាវចរចិត្ត ១២ អរូបាវចរចិត្ត ២ លោកុត្តរចិត្ត ៣២ ចេញពុំបានកើតឡើយ ។ ២- វិចារោ ចេតសិកធម៌សម្រាប់ពិចារណានូវអារម្មណ៍ មានកិរិយាដុសខាត់នូវអារម្មណ៍រឿយៗ ជាលក្ខណៈ ជាទីតាំង ប្រកបកើតឡើងព្រមក្នុងវីថិចិត្ត ៦៦ គឺកាមាវចរចិត្ត ៤៤ បឋមជ្ឈានចិត្ត ១១ ទុតិយជ្ឈានចិត្ត ១១ វៀរលែងតែវីថិចិត្ត ៥៥ គឺវិញ្ញាណ ១០ និងតតិយ-ចតុត្ថ-បញ្ចមជ្ឈានទាំង ៤៥ ចេញ ពុំបានកើតឡើយ ។ ៣- អធិមោក្ខោ ចេតសិកធម៌ដែលរួចផុតចេញចាកសេចក្ដីមិនជ្រះថ្លាហើយជ្រះថ្លា មានកិរិយាចូលចិត្តព្រមក្នុងអារម្មណ៍មិនកក្រើកជាលក្ខណៈ ជាទីតាំង ប្រកបកើតឡើងព្រមក្នុងវីថិចិត្ត ៧៨ គឺកាមា-

វចរចិត្ត ៤៣ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ វៀរលែងតែវិញ្ញាណ ១០ និងវិចិកិច្ឆាសម្បយុត្ត ១ ចេញ ពុំបានកើតឡើយ ។ ៤- វីរិយំ សេចក្ដីឧបត្ថម្ភទំនុកបម្រុងនូវកុសលធម៌ទាំងពួង មិនឲ្យសាបសូន្យទៅមានកិរិយាផ្គងឡើងនូវព្យាយាមដ៏មាំ គ្របសង្កត់នូវសេចក្ដីខ្ជិលជាលក្ខណៈ ជាមូលហេតុនៃសម្បត្តិទាំងពួង ប្រកបកើតឡើងព្រមក្នុងវីថិចិត្តទាំង ៧៣ គឺសោភណចិត្ត ៥៩ អសោភណចិត្ត ១៤ វៀរលែងតែវីថិចិត្ត ១៦ គឺវិញ្ញាណ ១០ បញ្ចទ្វារាវជ្ជនចិត្ត ១ សម្បដិច្ឆន្នចិត្ត ២ សន្តីរណចិត្ត ៣ ចេញ ពុំបានកើតឡើយ ។ ៥- បីតិ សេចក្ដីអំណរពេញចិត្ត មានឆ្អែតកាយឆ្អែតចិត្ត ជាលក្ខណៈ មានពេញកាយ ពេញចិត្តជាកិច្ចប្រកបកើតឡើងព្រមក្នុងវីថិចិត្តទាំង ៥១ គឺសោមនស្សសហគតកាមាវចរចិត្ត ១៨ បឋម-ទុតិយ-តតិយជ្ឈានចិត្ត ៣៣ វៀរលែងចាកវីថិចិត្ត ៧០ គឺឧបេក្ខាសហគតចិត្ត ៥៥ បដិឃចិត្ត ២ កាយវិញ្ញាណ ២ ចតុត្ថជ្ឈានចិត្ត ១១ ចេញ ពុំបានកើតឡើយ ។ ៦- ឆន្ទោ ចេតសិកធម៌ជាបុព្វភាគ មានភាវៈប្រាថ្នាដើម្បីធ្វើជាលក្ខណៈ មានកិរិយាស្វែងរកនូវអារម្មណ៍ជាកិច្ច ប្រកបកើតឡើងព្រមក្នុងវីថិចិត្តទាំង ៦៩ គឺកាមាវចរចិត្ត ៣៤ មហគ្គតចិត្ត ២៧

លោកុត្តរចិត្ត ៨ វៀរលែងចាកវីថិចិត្ត ២០ គឺអហេតុកចិត្ត ១៨ មោមូហ-ចិត្ត ២ ចេញ ពុំបានកើតឡើយ ។ រួមសព្វចិត្តសាធារណចេតសិក ៧ បកិណ្ណកចេតសិក ៦ ត្រូវជា ១៣ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៦៥- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀត ថាម្នាលអត្ថ-វាទី ចុះអកុសលចេតសិកពួកទី ២ មានចំនួន ១៤ នោះ គឺចេតសិកអ្វីខ្លះ? សេចក្ដីអធិប្បាយដូចម្ដេចខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្ដាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯអកុសលចេតសិកពួកទី ២ ទាំង ១៤ នោះគឺ ១- មោហោ សេចក្ដីវង្វេងភាន់ច្រឡំអា-រម្មណ៍សម្គាល់ខុសថា គុណព្រះរតនត្រ័យដែលជាឥដ្ឋារម្មណ៍ថាជាអនិ-ដ្ឋារម្មណ៍ទៅវិញ ភាន់ច្រឡំខុសថា ព្រះអរិយសច្ចទាំង ៤ មានទុក្ខសច្ចជាដើមនេះជាធម៌មិនពិតទេ បុគ្គលអ្នកធ្វើបុណ្យឲ្យទានរក្សាសីលចម្រើនភាវនា ថាបានបុណ្យច្រើនក៏មិនពិតដែរ សេចក្ដីវង្វេងភាន់ច្រឡំអា-រម្មណ៍យ៉ាងនេះជាដើម បានឈ្មោះថា មោហោ ដោយពិត ។ ២- អហិ-រិកំ សេចក្ដីមិនខ្មើមបាប មិនខ្មាសបាប ធ្វើខ្លួនមិនបានឲ្យបរិសុទ្ធ ឲ្យប្រ-ឡាក់ទៅដោយបាបធម៌ទាំងឡាយមានអកុសលកម្មបថទាំង ១០ ជាដើម ។

៣- អនោត្តប្បំ សេចក្តីមិនបានតក់ស្លុតខ្លាចបាប ធ្វើខ្លួនមិនបានឲ្យបរិសុទ្ធឲ្យក្តៅក្រហាយរោលរាលទៅដោយបាបធម៌ទាំងឡាយ មានអកុសលកម្មបថទាំង ១០ ជាដើម ។ ៤- ឧទ្ធច្ចំ សេចក្តីរាយមាយហុយឡើងដូចផេះត្រូវខ្យល់ឬថាផ្សាយហុយឡើងដូចផ្សែងភ្លើង ។ ចេតសិកធម៌ទាំង ៤ នេះ ប្រកបកើតឡើងព្រមតែក្នុងអកុសលចិត្តទាំង ១២ ដោយពិត ។ ៥- លោភោ សេចក្តីចង់បានហួសប្រមាណ មានចិត្តជំពាក់ជាប់នៅក្នុងអារម្មណ៍ទាំងពួងជាលក្ខណៈ ប្រកបកើតឡើងព្រមក្នុងលោភសហគតចិត្តទាំង ៨ ដោយពិត ។ ៦- ទិដ្ឋិ សេចក្តីយល់ឃើញខុស ប្រកាន់យកមាំតែតាមគំនិតរបស់ខ្លួនដែលគិតយល់ឃើញជាប្រមាណ មានមិនជឿគុណព្រះរតនត្រ័យជាដើមជាលក្ខណៈ ។ ៧- មានោ សេចក្តីរបឹងរឹងរូសប្រកាន់អស្មិមានះមិនស្តាប់ពាក្យប្រដៅល្អ មានប្រកាន់ជាតិកំណើតខ្លួនជាច់អហង្ការថា មានតែអញប្រសើរជាងគេជាដើមជាលក្ខណៈ ។ ចេតសិកធម៌ទាំងពីរនេះ ប្រកបកើតឡើងព្រមក្នុងអកុសលចិត្តជាទិដ្ឋិគតសម្បយុត្តទាំង ៤ ដោយពិត ។ ៨- ទោសោ សេចក្តីក្រោធខឹងប្រទូស្តសត្វនិងសង្ខារដទៃដើម្បីឲ្យវិនាសទៅ មានភាវៈកាចសាហាវជាលក្ខណៈ ។ ៩- ឥស្សា សេចក្តីច្រណែនឫស្យានិងទ្រព្យរបស់យសស័ក្តិអ្នកដទៃ មិន

ចង់ឲ្យគេមានបានប្រសើរលើសជាងខ្លួនជាដើម មានកិរិយាប្រុស្សានូវសម្បត្តិនៃបុគ្គលដទៃជាលក្ខណៈ ។ ១០- មច្ឆរិយំ សេចក្តីកំណាញ់ទីអាវាសត្រកូលញាតិមិត្ត សំឡាញ់មិនឲ្យអ្នកដទៃចូលទៅជិតបានខ្វាចខាតលាភ កំណាញ់លាភមិនឲ្យអ្នកដទៃគេមានលាភបាននូវបច្ច័យទាំង ៤ លើសខ្លួន កំណាញ់គុណវិសេសនិងធម៌មិនឲ្យអ្នកដទៃគេសរសើរអ្នកដទៃលើសខ្លួនឡើយ ។ ១១- កុក្កុច្ចំ សេចក្តីក្រៅក្រហាយជាខាងក្រោយ ដោយសម្គាល់ថាអំពើជាកុសលគឺអញមិនបានធ្វើហើយ អំពើដ៏លាមកអាក្រក់ជាអកុសលគឺអញបានធ្វើហើយជាដើម ។ កំចេតសិកធម៌ទាំង ៤ នេះ ប្រកបកើតឡើងព្រមក្នុងបដិឃចិត្តទាំង ២ ដោយពិត ។ ១២- ថីនំ សេចក្តីខ្ជិលប្រអូសធុញទ្រាន់ធ្ងន់កាយធ្ងន់ចិត្ត មានមិនចង់ក្រោកឡើងធ្វើការងារទាំងពួងជាលក្ខណៈ ។ ១៣- មិទ្ធំ សេចក្តីងងុយអន្តុយងោកធ្វើឲ្យធ្ងន់នាមកាយទាំង ៣ មានវេទនាខន្ធជាដើម មាននាមកាយទាំង ៣ មិនគួរដល់ការងារទាំងពួងជាលក្ខណៈ ។ ១៤- វិចិកិច្ឆា សេចក្តីសង្ស័យមិនចេះដាច់ស្រេចក្នុងវត្ថុទាំង ៨ យ៉ាង គឺ សង្ស័យក្នុងគុណព្រះពុទ្ធ ១, សង្ស័យក្នុងគុណព្រះនពលោកុត្តរធម៌ ១, សង្ស័យក្នុងគុណព្រះអរិយសង្ឃ ១, សង្ស័យក្នុង

សិក្ខាទាំង ៣ មានអធិសីលសិក្ខាជាដើម ១, សង្ស័យក្នុងខន្ធធាតុអាយ-តនៈជាអតីត ១, សង្ស័យក្នុងខន្ធធាតុអាយតនៈជាអនាគត ១, សង្ស័យក្នុងទីទាំងពីរ គឺខន្ធធាតុអាយតនៈជាអតីតនិងអនាគត ១, សង្ស័យក្នុងធម៌ទាំងឡាយជាកុសលនិងជាអកុសល ដែលកើតឡើងព្រមក្នុងបច្ចុប្បន្ននេះ ១ ។ ក៏ចេតសិកធម៌ ១ នេះប្រកបកើតឡើងព្រមក្នុងអកុសលចិត្តជាវិចិកិច្ឆាសហគតចិត្តតែ ១ ដោយពិត ។ វិសជ្ជនាមកអំពីអកុសលចេត-សិកពួកទី ២ ទាំង ១៤ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៦៦- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវាទី ចុះសោភណចេតសិកពួកទី ៣ មានចំនួន ២៥ នោះ គឺចេតសិកអ្វីខ្លះ? សេចក្តីអធិប្បាយថាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯសោភណចេតសិកពួកទី ៣ ទាំង ២៥ នោះគឺ ១- សទ្ធា ចេតនាដែលជ្រះថ្លាស្អាតជឿកម្ម ផលជាក់ច្បាស់ដោយខ្លួនឯង មានលក្ខណៈ ៣ យ៉ាង គឺសេចក្តីជឿជាក់ជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ មានកិរិយាបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានរក្សាសីល៥ សីលឧបោសថនិងចម្រើនព្រះកម្មដ្ឋានជាលក្ខណៈ ១, សេចក្តី

ជឿជាក់ទៅជាមុន មានកិរិយាស្ទុះទៅ ដើរបបួលដឹកនាំអ្នកដទៃឲ្យធ្វើបុណ្យឲ្យទានរក្សាសីល ៥ សីលឧបោសថ និងចម្រើនព្រះកម្មដ្ឋានជាលក្ខណៈ ១, សេចក្តីជឿជាក់ក្នុងគុណព្រះរតនត្រ័យមិនកក្រើក មានកិរិយាញ៉ាំងចិត្តដែលល្អក់មិនជ្រះថ្លាឲ្យវិនាសទៅ ហើយញ៉ាំងចិត្តដែលជ្រះថ្លាល្អឲ្យកើតឡើងជាលក្ខណៈ ១ ។ ឯសទ្ធាចេតសិកនេះ មានសេចក្តីឧបមាដូចកែវមណីជោតិ ដែលស្តេចព្រះបរមចក្រពោះទៅក្នុងទឹកប្រកបដោយកករដ៏ល្អក់ហើយ អាចកម្ចាត់បង់នូវមន្ទិលសៅហ្មងដែលល្អក់នោះឲ្យវិនាសបាត់អស់ទៅ ញ៉ាំងទឹកដែលរងថ្លាល្អដូចកញ្ចក់ឲ្យកើតឡើងយ៉ាងណាមិញ កំសទ្ធាចេតសិកនេះតែកើតឡើងក្នុងសន្តានចិត្តនៃបុគ្គលឯណាហើយ អាចញ៉ាំងដួងចិត្តដែលសៅហ្មងល្អក់នៃបុគ្គលនោះឲ្យជ្រះថ្លាល្អឡើងជាកុសល ឧបមាដូចកែវមណីជោតិយ៉ាងនោះឯង ។

២- សតិ ស្មារតីភ្ញាក់នឹករឭកនូវកុសលធម៌រឿយៗ ពុំបានភ្លេច ឧបមាដូចនាយឃ្លាំងរក្សាព្រះរាជទ្រព្យស្តេច តែងយកសេចក្តីក្រាបបង្គំទូលអំពីចំនួនព្រះរាជទ្រព្យទាំងអស់សព្វៗ ថ្ងៃ ឲ្យស្តេចទ្រង់ជ្រាបសព្វគ្រប់មិនឲ្យភ្លេចយ៉ាងណាមិញ ឯសតិចេតសិកនេះតែកើតឡើងក្នុងសន្តានចិត្តនៃបុគ្គលឯណាហើយ អាចញ៉ាំងសន្តានចិត្តនៃបុគ្គលនោះឲ្យ

ភ្ញាក់នឹករឭករឿយៗ នូវកុសលធម៌ទាំងពួងមិនឲ្យភ្លេចយ៉ាងនោះដែរ ។ ៣- ហិរិ សេចក្តីខ្មាសបាបខ្លាចបាបក្នុងលោកជាធំ លះបង់នូវអកុសល-កម្ម ហើយញ៉ាំងកុសលកម្មឲ្យកើតឡើងក្នុងសន្តានខ្លួនលះបង់នូវអំពើប្រ-កបដោយទោស ហើយញ៉ាំងអំពើដែលមិនប្រកបដោយទោសឲ្យកើតឡើងក្នុងសន្តានខ្លួន ខំព្យាយាមរក្សាខ្លួនឲ្យបរិសុទ្ធចាកអកុសលកម្មដ៏លា-មកក្នុងលោកជាលក្ខណៈ ។ ៤- ឱត្តប្បំ សេចក្តីក្តៅក្រហាយតក់ស្លុតខ្លាចបាបក្នុងលោកជាធំលះបង់នូវអកុសលកម្ម ហើយញ៉ាំងកុសលកម្មឲ្យកើតឡើងក្នុងសន្តានខ្លួនលះបង់នូវអំពើប្រកបដោយទោស ហើយញ៉ាំងអំពើដែលមិនប្រកបដោយទោសឲ្យកើតឡើងក្នុងសន្តានខ្លួន ខំព្យាយាមរក្សាខ្លួនឲ្យបរិសុទ្ធចាកអកុសលកម្ម ដ៏លាមកក្នុងលោកជាលក្ខណៈ ។ ៥- អលោភោ សេចក្តីមិនលោភហួសប្រមាណដែលជាបដិបក្ខដល់មន្ទិលគឺសេចក្តីកំណាញ់ ជាហេតុនឹងឲ្យមានសទ្ធាជឿកម្មផល អាចបរិច្ចាគទ្រព្យធ្វើបុណ្យឲ្យទានបាន មានកិរិយាមិនជំពាក់ជាប់ចិត្តក្នុងអា-រម្មណ៍ទាំងពួងជាលក្ខណៈ ។ ៦- អទោសោ សេចក្តីមិនបានក្រោធខឹងប្រទូស្តសត្វនិងសង្ខារដែលជាបដិបក្ខដល់មន្ទិល គឺភាវៈទ្រុស្តសីលជាហេតុនឹងឲ្យមានព្យាយាមរក្សាសីលបាន មានកិរិយាមិនបានកាចសា-

ហាវទឹងប្រទូស្តជាលក្ខណៈ ។ ៧- តត្រមជ្ឈត្តតា ភាវៈនៃចេតនា ដែលសម្ងឹងមើលដឹងច្បាស់នូវអារម្មណ៍ មិនបានកាន់ប្រឡំ ហើយប្រ-ព្រឹត្តទៅជាកណ្តាលនឹងនៅក្នុងអារម្មណ៍ទាំង ៦ នោះ ។ ៨- កាយប-ស្សទ្ធិ សេចក្តីរម្ងាប់ស្ងប់ស្ងាត់នៃនាមកាយគឺអរូបក្ខន្ធទាំង ៣ មានវេទនា-ខន្ធជាដើម មានកិរិយាចូលទៅជិតរម្ងាប់នូវសេចក្តីក្រវល់ក្រវាយនៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសមានឧទ្ធច្ចជាដើមជាលក្ខណៈ ។ ៩ បិត្តបស្សទ្ធិ សេចក្តីរម្ងាប់ស្ងប់ស្ងាត់នៃចិត្ត មានកិរិយាចូលទៅជិតរម្ងាប់នូវសេចក្តីក្រវល់ក្រវាយនៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេសមានឧទ្ធច្ចជាដើមជាលក្ខណៈ ។ ១០- កាយលហុតា ភាវៈប្រព្រឹត្តទៅស្រាលរហ័សនៃនាមកាយ មានកិរិយាចូលទៅជិតរម្ងាប់នូវភាវៈធ្ងន់នៃនាម-កាយ ដែលកើតជាបដិបក្ខដល់កិលេសគឺសេចក្តីខ្ជិលច្រអូស ងងុយងោកងក់ដែលជាហេតុធ្វើឲ្យធ្ងន់នៃនាមកាយជាលក្ខណៈ ។ ១១- បិត្តល-ហុតា ភាវៈប្រព្រឹត្តទៅស្រាលរហ័សនៃចិត្ត មានកិរិយាចូលទៅជិតរម្ងាប់នូវភាវៈធ្ងន់នៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេស គឺសេចក្តីខ្ជិលច្រអូស ងងុយងោកងក់ដែលជាហេតុធ្វើឲ្យធ្ងន់នៃចិត្តជាលក្ខណៈ ។ ១២- កាយមុទុតា ភាវៈរីករាយទន់ភ្លន់នៃនាមកាយមានកិរិយាចូល

ទៅជិតរម្ងាប់នូវភាវៈរបឹងរឹងរូសនៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសគឺទិដ្ឋិមានះ ជាហេតុធ្វើឲ្យរបឹងរឹងរូសនៃនាមកាយជាលក្ខណៈ ។ ១៣- បិត្តមុទុតា ភាវៈរីករាយទន់ភ្ជន់នៃចិត្ត មានកិរិយាចូលទៅជិតរម្ងាប់នូវភាវៈរបឹងរឹងរូសនៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេស គឺទិដ្ឋិមានះ ជាហេតុធ្វើឲ្យរបឹងរឹងរូសនៃចិត្តជាលក្ខណៈ ។ ១៤- កាយកម្មញ្ញតា ភាវៈស្អាតល្អក្នុងបរិកម្មនៃនាមកាយ មានកិរិយាចូលទៅជិតរម្ងាប់នូវភាវៈមិនស្អាតល្អក្នុងបរិកម្មនៃនាមកាយ ដែលកើតជាបដិបក្ខដល់នីវរណធម៌ទាំង ៥ មានកាមច្ឆន្ទៈជាដើមជាលក្ខណៈ ។ ១៥- បិត្តកម្មញ្ញតា ភាវៈស្អាតល្អក្នុងបរិកម្មនៃចិត្ត មានកិរិយាចូលទៅជិតរម្ងាប់នូវភាវៈមិនស្អាតល្អក្នុងបរិកម្មនៃចិត្ត ដែលកើតជាបដិបក្ខដល់នីវរណធម៌ទាំង ៥ មានកាមច្ឆន្ទៈជាដើមជាលក្ខណៈ ។ ១៦- កាយបាគុញ្ញតា ភាវៈស្ទាត់ជំនាញនៃនាមកាយ មានកិរិយាចូលទៅជិតរម្ងាប់នូវភាវៈលំបាកឈឺចាប់នៃនាម-កាយ ដែលកើតជាបដិបក្ខដល់កិលេសគឺអសទ្ធាមិនជឿកម្ម-ផល ជាហេតុធ្វើឲ្យលំបាកឈឺចាប់នៃនាមកាយជាលក្ខណៈ ។ ១៧- បិត្តបាគុញ្ញតា ភាវៈស្ទាត់ជំនាញនៃចិត្ត មានកិរិយាចូលទៅជិតរម្ងាប់នូវភាវៈលំបាកឈឺចាប់នៃចិត្ត ដែលកើតជាបដិបក្ខដល់កិលេស គឺអសទ្ធា មិនជឿកម្ម-ផល

ជាហេតុធ្វើឲ្យលំបាកឈឺចាប់នៃចិត្តជាលក្ខណៈ ។ ១៨- កាយុជុគ្គតា ភាវៈប្រព្រឹត្តទៅត្រង់នៃនាមកាយ មានកិរិយាពិចារណាឃើញជាក់ច្បាស់នូវភាវៈវៀចនៃនាមកាយ ដែលកើតជាបដិបក្ខដល់កិលេសគឺភាវៈខ្ជិលជាហេតុធ្វើឲ្យវៀចនៃនាមកាយជាលក្ខណៈ ។ ១៩- ចិត្តុជុគ្គតា ភាវៈប្រព្រឹត្តទៅត្រង់នៃចិត្ត មានកិរិយាពិចារណាឃើញជាក់ច្បាស់នូវភាវៈវៀចនៃចិត្តដែលកើតជាបដិបក្ខដល់កិលេស គឺភាវៈខ្ជិលជាហេតុធ្វើឲ្យវៀចនៃចិត្តជាលក្ខណៈ ។ ក៏ចេតសិកធម៌ទាំង ១៩ នេះបានឈ្មោះថា សោភណចេតសិក ប្រកបកើតឡើងព្រមទូទៅក្នុងសោភណចិត្តទាំង ៥៩ ដោយពិត ។ ២០- សម្មាវាចា ប្រព្រឹត្តពោលនូវពាក្យសម្តីដ៏ល្អប្រពៃ មានវៀរលែងចាកវចីទុច្ចរិតទាំង ៤ មិនពោលនូវពាក្យមុសាវាទជាដើមជាលក្ខណៈ ។ ២១- សម្មាកម្មន្តោ ប្រព្រឹត្តធ្វើនូវការងារដ៏ល្អប្រពៃ មានវៀរលែងចាកកាយទុច្ចរិតទាំង ៣ មិនប្រព្រឹត្តសម្លាប់សត្វលួចទ្រព្យគេជាដើមជាលក្ខណៈ ។ ២២- សម្មាអាជីវោ ប្រព្រឹត្តរកស៊ីចិញ្ចឹមជីវិតដ៏ល្អប្រពៃ គឺវៀរលែងចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ និងជំនួញទាំង ៥ ប្រការជាស្រឡះ (ចេតសិកធម៌ទាំង ៣ នេះបានឈ្មោះថា វិរតិចេតសិក សម្រាប់វៀរលែងចាកកុសលចិត្ត ដែលគួរគប្បីវៀរលែងប្រកបកើតឡើងព្រមក្នុងវីថិចិត្ត

ទាំង ១៦ គឺកាមាវចរកុសលចិត្ត ៨ លោកុត្តរចិត្ត ៨ ត្រូវជា ១៦ ដោយពិត) ។ ២៣- ករុណា សេចក្តីអាណិតអាសូរដល់សត្វទាំងឡាយដែលដល់នូវសេចក្តីទុក្ខលំបាកខ្លាំង មានប្រាថ្នាដើម្បីនឹងនាំចេញនូវសត្វទាំងឡាយ ដែលដល់នូវសេចក្តីទុក្ខលំបាកនោះឲ្យរួចផុតចេញចាកទុក្ខវេទនាជាលក្ខណៈ ។ ២៤- មុទិតា សេចក្តីរីករាយទន់ត្រជាក់ត្រេកអរចំពោះទ្រព្យរបស់យសស័ក្តិដែលបុគ្គលដទៃបានហើយ ពុំបានប្រស្យាប្រណែនឈ្នានីសឡើយ មានកិរិយាអនុមោទនាត្រេកអររីករាយនូវសម្បត្តិនៃបុគ្គលដទៃជាលក្ខណៈ (កំចេតសិកធម៌ទាំងពីរនេះបានឈ្មោះថាអប្បមញ្ញាចេតសិក ព្រោះមានចេតនាផ្សាយទៅកាន់សត្វនិងសង្ខារទាំងឡាយប្រមាណពុំបានជាអារម្មណ៍ ប្រកបកើតឡើងព្រមក្នុងវីថិចិត្តទាំង ២៨ គឺមហគ្គតចិត្ត ១២ កាមាវចរកុសលចិត្ត ៨ សហេតុកកាមាវចរកិរិយាចិត្ត ៨ ត្រូវជា ២៨) ។ ២៥- បញ្ញិន្ទ្រិយំ ធម្មជាតដែលដឹងច្បាស់ដោយអំណាចនៃលក្ខណៈទាំង ៣ មានអនិច្ចលក្ខណៈជាដើម បានឈ្មោះថា បញ្ញា តែថាបញ្ញានោះឯងព្រះអរហំសម្មាសម្ពុទ្ធទ្រង់ឲ្យឈ្មោះថាឥន្ទ្រិយ ព្រោះថាជាអធិបតី ជាធំក្នុងកិរិយាដឹងច្បាស់ដ៏សមគួរតាមសភាពពិត មានកិរិយាយល់ឃើញត្រូវជាលក្ខណៈ បញ្ញានោះឯង បានឈ្មោះថា

បញ្ញិន្ទ្រិយដោយពិត តែងប្រកបកើតឡើងព្រមក្នុងវីថិចិត្តទាំង ៤៧ គឺកាមាវចរសោភណចិត្តជាញាណសម្បយុត្ត ១២ មហគ្គតចិត្ត ២៧ លោកុត្តរ-ចិត្ត ៨ ត្រូវជា ៤៧ ដោយពិត ។ វិសជ្ជនាមកអំពីសោភណចេតសិកពួកទី ៣ ទាំង ២៥ ដោយសង្ខេបតែប៉ុណ្ណេះ ។

បូករួមអញ្ញសមានាចេតសិកពួកទី ១ មានចំនួន ១៣ អកុសលចេត-សិកពួកទី ២ មានចំនួន ១៤ សោភណចេតសិកពួកទី ៣ មានចំនួន ២៥ ត្រូវជាចេតសិកធម៌ ៥២ ដោយសង្ខេបតែត្រឹមប៉ុណ្ណេះឯង ។

៦៧- ធម្មវាទី បានស្តាប់ហើយពោលថា សាធុៗ ម្នាលអត្តវាទី លោកបានវិសជ្ជនាមកនេះប្រពៃណាស់ហើយ តែថាយើងលើកចិត្តនិងចេតសិកទុកសិនចុះ យើងនឹងសួរលោកអំពីរូបវិញចុះពាក្យថារូបៗ ស័ព្ទនេះប្រែថាដូចម្តេច? សេចក្តីអធិប្បាយថា យ៉ាងណាខ្លះ?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯរូបស័ព្ទនោះ សេចក្តីប្រែថា ធម្មជាតសម្រាប់វិនាសរលាយសូន្យទៅដោយត្រជាក់និងក្តៅជាដើម បានឈ្មោះថា រូប សេចក្តីអធិប្បាយថា រូបសត្វទាំងឡាយតែកើតមានឡើងហើយ តែងវិនាសទៅដោយរដូវត្រជាក់រងាមកបៀត

បៀនរូប ធ្វើឲ្យរូបគ្រាំគ្រាស្វិតស្រពោនជ្រួញជ្រីវទៅ ជាបច្ច័យឲ្យកើតជាជរាផង វិនាសទៅដោយកម្តៅព្រះអាទិត្យដែលរះឡើងនិងកម្តៅភ្លើងក្តៅស្អុះស្អាប់ចូលមកបៀតបៀនរូប ធ្វើឲ្យរូបគ្រាំគ្រាសៅហ្មងជ្រួញជ្រីវទៅផ្សេងៗ រាល់ថ្ងៃជាបច្ច័យឲ្យកើតជាជរាៗ ជាបច្ច័យឲ្យកើតព្យាធិជំងឺឈឺចាប់ មានឈឺក្បាលវិលមុខជាដើមផង វិនាសទៅដោយរមូលពោះឃ្លានបាយ ស្រេកទឹក និងប៉ះពាល់ដោយសម្ផស្សនៃសត្វរបោម មូសសុច សង្កើច និងខ្យល់ព្យុះ កម្តៅថ្ងៃ និងពស់តូចពស់ធំជាដើម ចូលមកបៀតបៀនរូបមានខាំជញ្ជក់យកជាតិឈាមជ័រជាដើម ជាបច្ច័យឲ្យកើតជាជរាគ្រាំគ្រាទៅជានិច្ចបន្តិចម្តងៗ តែរាល់ៗ ថ្ងៃទៅ ពុំយូរប៉ុន្មានក៏កើតជាបច្ច័យដល់ព្យាធិ ជំងឺឈឺចាប់យ៉ាងតិចៗ ជរាបដល់ជំងឺឈឺចាប់យ៉ាងធ្ងន់ខ្លាំងជាបច្ច័យដល់មរណៈសេចក្តីស្លាប់សូន្យទាំងកម្ម ចិត្ត រដូវ អាហារ អស់ទៅសល់នៅតែអនុបាទិន្នករូបគឺសាកសព សូន្យរលាយទៅ ជាដី ទឹក ភ្លើងខ្យល់អស់ទៅវិញ បានឈ្មោះថា រូប ព្រោះរូបទាំង ៤ មានឧបចយរូបជាដើម ប្រកបដោយលក្ខណៈ ៣ យ៉ាង គឺអនិច្ចលក្ខណៈ ១ ទុក្ខលក្ខណៈ ១ អនត្តលក្ខណៈ ១ ជារូបមិនទៀងតែងប្រែប្រួលទៅផ្សេងៗ តែងនាំមកនូវសេចក្តីទុក្ខលំបាកផ្សេងៗ ជារបស់ពុំបានប្រព្រឹត្តទៅតាមអំណាច

នៃខ្លួន គឺថាពុំបានស្តាប់បង្គាប់ខ្លួនដោយពិត ។ ខ្ញុំអត្តវាទី បានវិសជ្ជនាមកអំពីរូបស័ព្ទ ព្រមទាំងសេចក្តីអធិប្បាយដោយសង្ខេបតែប៉ុណ្ណោះ សូមជ្រាប ។

៦៨- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀត ម្នាលអត្តវាទី ចុះសភាវធម៌ទាំងពីរយ៉ាង គឺមហាភូតៈ ១ ឧបាទាយៈ ១ ដែលព្រះសព្វញ្ញូសម្ពុទ្ធព្រះអង្គទ្រង់លើកឡើងកាន់បញ្ញត្តិ ឲ្យឈ្មោះថា រូប, តែត្រង់រូប-ស័ព្ទនោះ លោកបានវិសជ្ជនាមករួចហើយ យើងពុំបានសួរទេ យើងនឹងសួរចំពោះតែត្រង់មហាភូតស័ព្ទនិងឧបាទាយស័ព្ទទាំងពីរបទនេះ មានសេចក្តីអធិប្បាយថាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯមហាភូតស័ព្ទនោះ ប្រែថា សភាវធម៌មានសភាពធំកើតឡើងប្រាកដហើយ, សេចក្តីអធិ-ប្បាយថា សភាវៈទាំងឡាយ ៤ គឺកម្ម ១ ចិត្ត ១ ឧតុ ១ អាហារ ១ ជាបច្ច័យប្រជុំព្រមស្មើគ្នា ញុំាងផលគឺរូបឲ្យកើតឡើងប្រាកដ ដូចមានបាលីក្នុងគម្ពីរដីកា និងយោជនាព្រះអភិធម្មពន្យល់ថា ឧបាទិន្នានុបា-ទិន្នសន្តានេសុ សសម្ភារធាតុវសេន មហន្តា ហុត្វា ភូតាតិ មហាភូតា

ធម្មា (ប្រែថា) សភាវធម៌ទាំងឡាយឯណា មានភាពធំប្រជុំកើតឡើងប្រាកដហើយ ក្នុងសន្តាននៃឧបាទិន្នករូបនិងអនុបាទិន្នករូបដោយអំណាចដែលប្រព្រឹត្តទៅជាមួយដោយសសម្ភារធាតុ សភាវធម៌ទាំងឡាយនោះ បានឈ្មោះថា មហាភូត សេចក្ដីអធិប្បាយថា ធាតុទាំង ៤ គឺបឋវីធាតុ ធាតុដែលមានសភាពរឹង ជាលក្ខណៈ ១, អាបោធាតុ ធាតុដែលមានសភាពទន់ជ្រាយរាវៗ ជាលក្ខណៈ ១, តេជោធាតុ ធាតុដែលមានសភាពអប់រំក្ដៅៗ ជាលក្ខណៈ ១, វាយោធាតុ ធាតុដែលមានភាពបក់មករហើយៗ ជាលក្ខណៈ ១ ធាតុទាំង ៤ នេះប្រជុំព្រមស្មើគ្នាក្នុងភពសម្រាប់កើតឯណា សភាវធម៌ទាំង ៤ មានកម្មជាដើម ចូលមកប្រជុំព្រមស្មើគ្នាក្នុងភពសម្រាប់កើតនោះហើយញុំាងផល គឺកលលរូបឲ្យកើតឡើងប្រាកដ ៧ ថ្ងៃៗ ជាលំដាប់គ្នាតៗ ទៅ ជាឧបាទិន្នករូបខ្លះ អនុបាទិន្នក-រូបខ្លះ ទើបបានឈ្មោះថា មហាភូត តភ្ជាប់គ្នានឹងរូប ហៅថា មហាភូតរូប ដោយពិត ។ ឧបាទាយស័ព្ទនោះ មានសេចក្ដីអធិប្បាយថា: ធម្មជាតឯណាដែលអាស្រ័យកាន់យកមាំនូវមហាភូតរូបទាំង ៤ ហើយញុំាងផល គឺរូបជាខាងក្នុងខ្លះ ខាងក្រៅខ្លះ ឲ្យកើតចម្រើនច្រើនឡើងសមគួរតាមលំដាប់ ធម្មជាតនោះបានឈ្មោះថា ឧបាទាយ តភ្ជាប់គ្នា

នឹងរូប ហៅថា ឧបាទាយរូប ដោយពិត ។ វិសជ្ជនាមកអំពីមហាភូតស័ព្ទ និងឧបាទាយស័ព្ទ ទាំងពីរបទនេះដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៦៩- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវាទី ចុះមហាភូតរូបនោះមានចំនួនប៉ុន្មាន? គឺរូបអ្វីខ្លះ? ចូរលោកវិសជ្ជនារាប់ចំនួនរូបព្រមទាំងសេចក្ដីប្រែអធិប្បាយឲ្យសព្វគ្រប់មក យើងនឹងបានស្ដាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី មហាភូតរូបនោះមាន ៤ គឺ ១- បឋវីធាតុ ធាតុដីមានចំនួន ២០ គឺ កេសា សក់ទាំងឡាយ ១ លោមា រោមទាំងឡាយ ១ នខា ក្រចកទាំងឡាយ ១ ទន្តា ធ្មេញទាំងឡាយ ១ តចោ ស្បែក ១ មំសំ សាច់ ១ នហារូ សរសៃទាំងឡាយ ១ អដ្ឋី ឆ្អឹងទាំងឡាយ ១ អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង ១ វក្កំ ទាចឬតម្រងបស្សាវៈ ១ ហទយំ បេះដូង ១ យកនំ ថ្លើម ១ កិលោមកំ វាវ ១ បិហកំ ក្រពះឬលំពែងអរីស ១ បប្ផាសំ សួត ១ អន្តំ ពោះវៀនធំ ១ អន្តគុណំ ពោះវៀនតូច ១ ឧទរិយំ អាហារថ្មី ១ ករីសំ អាហារចាស់ ១ មត្ថកេ មត្ថលុង្គំ ខួរក្នុងក្បាល ១ ។ ២- អាបោធាតុ ធាតុទឹកមានចំនួន ១២ គឺ បិត្តំ ទឹកប្រមាត់ ១ សេម្ហំ ទឹកស្លេស្ម ១

បុព្វោ ទឹកខ្ទុះ ១ លោហិតំ ទឹកឈាម ១ សេទោ ទឹកញើស ១ មេទោ ទឹកខ្លាញ់ខាប់ ១ អស្សុ ទឹកភ្នែក ១ វសា ទឹកខ្លាញ់រាវទាំងឡាយ ១ ខេឡោ ទឹកមាត់ ១ សិង្ឃាណិកា ទឹកសម្បោរ ១ លសិកា ទឹករំអិល ១ មុត្តំ ទឹកមូត្រ ១ ។ ៣- តេជោធាតុ ធាតុភ្លើងមានចំនួន ៤ គឺ សន្តប្បតិ ធាតុភ្លើងអប់រំក្តៅស្រួលផ្សាយទៅក្នុងកាយជាប្រក្រតី ១ បរិទយ្ហតិ ធាតុភ្លើងក្តៅពេលរាលផ្សាយទៅក្នុងកាយ ១ បរិណាមតិ ធាតុភ្លើងដុតអាហារឲ្យទ្រុឌទ្រោមផ្សាយឱជារសឲ្យជ្រួតជ្រាបទៅក្នុងសព្វាង្គកាយ ១ ជីរណតិ ធាតុភ្លើងដុតរាងកាយឲ្យជ្រួញជ្រីវគ្រាំគ្រាចាស់ជរាទៅ ១ ។ ៤- វាយោធាតុ ធាតុខ្យល់មានចំនួន ៦ គឺឧទ្ធង្គមា វាតា ខ្យល់ទាំងឡាយបក់ពីខាងក្រោមផ្សាយឡើងទៅខាងលើ ១ អធោគមា វាតា ខ្យល់ទាំងឡាយបក់ពីខាងលើផ្សាយចុះមកខាងក្រោម ១ កុច្ឆិសយា វាតា ខ្យល់ទាំងឡាយបក់វិលវល់ផ្សាយនៅក្នុងផ្ទៃ ១ កោដ្ឋាសយា វាតា ខ្យល់ទាំងឡាយបក់ផ្សាយនៅក្នុងពោះវៀនធំ-តូច ១ អង្គមង្គានុសារិនោ វាតា ខ្យល់ទាំងឡាយបក់ផ្សាយសព្វនៅក្នុងអវយវៈធំ តូច ១ អស្សាសបស្សាសវាតា ខ្យល់ទាំងឡាយសម្រាប់ដកដង្ហើមចេញនិងដកដង្ហើមចូល ១ ។ ក៏ធាតុទាំង ៤ នេះ បាន

ឈ្មោះថា មហាភូតរូបដោយពិត ។ វិសជ្ជនាមកអំពីមហាភូតរូបទាំង ៤ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះឯង ។

៧០- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវាទី ចុះឧបាទាយរូបនោះមានចំនួនប៉ុន្មាន? គឺរូបអ្វីខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្ដាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯឧបាទាយរូបនោះមានចំនួន ២៤ គឺ ១- ចក្ខុ រូបគឺភ្នែក ២- សោតៈ រូបគឺត្រចៀក ៣- ឃានៈ រូបគឺច្រមុះ ៤- ជិវ្ហា រូបគឺអណ្ដាត ៥- កាយៈ រូបគឺរាងកាយ (ក៏រូបទាំង ៥ នេះឈ្មោះថាបសាទរូប ជារូបខាងក្នុងសម្រាប់ជ្រះថ្លាប៉ះពាល់ត្រូវនូវអារម្មណ៍) ៦ រូបារម្មណៈ រូបគឺរូបជាអារម្មណ៍ ៧- សទ្ទារម្មណៈ រូបគឺសំឡេងជាអារម្មណ៍ ៨- គន្ធារម្មណៈ រូបគឺក្លិនជាអារម្មណ៍ ៩- រសារម្មណៈ រូបគឺរសជាអារម្មណ៍ (ក៏រូបទាំង ៤ នេះឈ្មោះថា វិសយរូបជារូបខាងក្រៅជាវិស័យជាទីគោចរ គឺជាជាចំណីអាហារនៃបញ្ចវិញ្ញាណដោយពិត) ១០- ឥត្ថីភាវៈ រូបគឺភាពជាស្រី ១១- បុមភាវៈ រូបគឺភាពជាប្រុស (រូប ២ នេះ ឈ្មោះថាភាវរូប) ១២- ហទយៈ រូបគឺហឫទ័យជាទីអាស្រ័យនៃមនោធាតុ ១៣- ជីវិតៈ រូបគឺជីវិតជាធំជាទីប្រព្រឹត្តរស់នៅ មានកិរិយា

រក្សារឿយៗ នូវកម្មជរូបដែលកើតឡើងជាមួយគ្នាជាលក្ខណៈ ១៤- អាហារ រូបគឺអាហារដែលបុគ្គលធ្វើឲ្យជាពំនូតហើយបរិភោគ សម្រាប់ទំនុកបម្រុងនូវរាងកាយ មានកិរិយានាំមកនូវរូបទាំង ៨ មានឱជរូបជាដើមជាលក្ខណៈ ។ ១៥- អាកាសៈ រូបគឺអាកាសធាតុដែលមានក្នុងចន្លោះៗនៃរូបគឺធម្មតាកំណត់មិនឲ្យច្រឡំដោយរូបកលាបៈនៃរូបទាំងឡាយ ដែលបានដល់នូវបាច់មួយៗ មានចក្ខុទសកៈជាដើម ។ ១៦- កាយវិញ្ញត្តិ វិញ្ញត្តិរូប គឺរូបដែលញ៉ាំងកាយឲ្យកម្រើកឡើងហើយបានដឹងច្បាស់នូវសេចក្តីអធិប្បាយ ដោយកាយដែលកម្រើកឡើងខ្លួនឯង ។ ១៧- វចីវិញ្ញត្តិ វិញ្ញត្តិរូបគឺរូបដែលញ៉ាំងពាក្យពោលឲ្យកម្រើកឡើង ហើយបានដឹងច្បាស់នូវសេចក្តីអធិប្បាយដោយវាចា ពោលគឺសំឡេង ដែលប្រព្រឹត្តទៅជាមួយនឹងវិញ្ញាណរបស់ខ្លួនឯង ។ ១៨- រូបស្ស លហុតា រូបគឺភាវៈប្រព្រឹត្តទៅឆាប់រហ័ស មានកិរិយាមិនយឺតយូរនិងលះបង់នូវភាវៈធ្ងន់នៃខ្លួនជាលក្ខណៈ ។ ១៩- រូបស្ស មុទុតា រូបគឺភាវៈទន់ភ្លន់ងាកបែរទៅមកបានមានកិរិយាមិនបានរឹងនិងលះបង់នូវភាវៈរឹងជាលក្ខណៈ ។ ២០- រូបស្ស កម្មញ្ញតា រូបគឺភាវៈប្រព្រឹត្តទៅ គួរដល់កម្មគឺការងារទាំងពួងមានភាវៈអនុកូលទៅតាមសរីរៈ ជាលក្ខណៈក៏រូបទាំង ៣ នេះ ឈ្មោះថា វិការរូបជា

រូបសម្រាប់ធ្វើនូវសរីរៈឲ្យប្រព្រឹត្តទៅប្លែកផ្សេងៗ ដោយពិត) ។ ២១- រូប-ស្ស ឱបចយោ ជាតិរូបគឺកិរិយាសន្សំប្រមូលមកនូវអាយតនៈ គឺរូបដែលកើតឡើងរឿយៗ ហើយកំណត់សម្គាល់ថា អាយតនរូប គឺថាសន្សំយកទីកន្លែងដែលកើតអារម្មណ៍ និងរូបដែលកើតឡើងហើយចូលជាមួយគ្នាកំណត់ឲ្យឈ្មោះថាឧបចយរូបដោយពិត ។ ២២- រូបស្ស សន្តតិ ជាតិ-រូបគឺទីតភ្ជាប់នូវអាយតនៈនិងរូបដែលកើតចម្រើនធំឡើង និងកិរិយាសន្សំប្រមូលមកនូវអាយតនៈនិងរូបដែលកើតឡើងហើយ លោកកំណត់ឲ្យឈ្មោះថា សន្តតិរូបដោយពិត ។ ២៣- រូបស្ស ជរតា ជាតិរូបគឺភាវៈនៃរូបដែលកើតឡើងហើយជាបច្ច័យដល់ជរាៗ ជាបច្ច័យដល់ព្យាធិៗ ជាបច្ច័យដល់មរណៈ សេចក្តីស្លាប់សូន្យទៅជាលក្ខណៈ ។ ២៤- រូបស្ស អនិច្ចតា ជាតិរូបគឺភាវៈនៃរូបដែលកើតឡើងហើយ ជារូបមិនទៀងស្ថិតស្ថេរតែងបែកធ្លាយសូន្យវិនាសទៅវិញជាលក្ខណៈ ក៏ជាតិរូបទាំង ៤ យ៉ាងនេះ បានឈ្មោះថា លក្ខណរូប ជារូបប្រកបដោយលក្ខណៈ ៣ យ៉ាងគឺ អនិច្ចលក្ខណៈ ១ ទុក្ខលក្ខណៈ ១ អនត្តលក្ខណៈ ១ ដោយពិត ។ វិសជ្ជនាមកអំពីឧបាទាយរូបទាំង ២៤ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៧១- ធម្មវាទី បានស្តាប់ហើយពោលថាម្នាលអត្តវាទី លោកបានវិសជ្ជនាមកអំពីមហាភូតរូបទាំង ៤ និងឧបាទាយរូបទាំង ២៤ ក្នុងប្រស្នាទាំងពីរ រាប់ចំនួនរូប ២៨ ព្រមទាំងសេចក្តីប្រែអធិប្បាយខ្លះ ក៏ឃើញថាល្អមស្តាប់បានដែរហើយ តែយើងសួរលោកតទៅទៀតចុះរូបទាំង ២៨ នោះ ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងឲ្យឈ្មោះផ្សេងៗ គ្នា ជាគូៗថា ឱឡារិករូបជាគូនឹងសុខុមរូបខ្លះ ថានិប្ផន្នរូបជាគូនឹងអនិប្ផន្នរូបខ្លះ ថាអជ្ឈត្តិករូបជាគូនឹងពហិទ្ធារូបខ្លះ ថាឥន្ទ្រិយរូបជាគូនឹងអនិន្ទ្រិយរូបខ្លះ ថាកម្មជរូបជាគូនឹងអកម្មជរូបខ្លះ តើព្រះអង្គដកយករូបទាំង ២៨ មកផ្លាស់ប្តូរកំណត់ឲ្យឈ្មោះផ្សេងៗ គ្នាដូចម្តេចខ្លះ? សេចក្តីពន្យល់យ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯរូបទាំង ២៨ នោះគឺព្រះអរហំសម្មាសម្ពុទ្ធទ្រង់សម្តែងចំណែកចែកឲ្យឈ្មោះផ្សេងៗ គ្នាដូច្នេះ ព្រះអង្គយករូបទាំង ១២ គឺ បឋវីធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ ចក្ខុប្បសាទរូប ១ សោតប្បសាទរូប ១ ឃានប្បសាទរូប ១ ជិវ្ហាបសាទរូប ១ កាយប្បសាទរូប ១ រូបរូប ១ សទ្ទរូប ១ គន្ធរូប ១ រសរូប ១

រូបទាំង ១២ នេះឲ្យឈ្មោះថា ឱឡារិករូប ជារូបដ៏ធំគ្រោតគ្រាត ហើយព្រះអង្គយករូបទាំង ១៦ គឺ អាបោធាតុរូប ១ ឥត្ថីភាវរូប ១ បុម-ភាវរូប ១ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ អាកាសរូប ១ កាយ-វិញ្ញត្តិរូប ១ វចីវិញ្ញត្តិរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ ឧបចយរូប ១ សន្តតិរូប ១ ជរតារូប ១ អនិច្ចតារូប ១ រូបទាំង ១៦ នេះ ឲ្យឈ្មោះថា សុខុមរូប ជារូបដ៏ល្អិតម៉ត់ផូរផង់ ។ យករូបទាំង ១៨ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ ចក្ខុប្បសាទរូប ១ សោតប្បសាទរូប ១ ឃានប្បសាទរូប ១ ជិវ្ហាបសាទរូប ១ កាយប្បសាទរូប ១ រូបរូប ១ សទ្ទរូប ១ គន្ធរូប ១ រសរូប ១ ឥត្ថីភា-វរូប ១ បុមភាវរូប ១ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ រូបទាំង ១៨ នេះ ឲ្យឈ្មោះថា និប្ផន្នរូប ជារូបកើតឡើងសម្រេចស្រេចដោយពិត ហើយយករូបទាំង ១០ គឺ អាកាសរូប ១ កាយវិញ្ញត្តិរូប ១ វចីវិញ្ញត្តិរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ ឧបចយរូប ១ សន្តតិរូប ១ ជរតារូប ១ អនិច្ចតារូប ១ រូបទាំង ១០ នេះ ឲ្យឈ្មោះថា អនិប្ផន្នរូប ជារូបកើតឡើងពុំបានសម្រេចស្រេចឡើយ គឺថាកើតឡើងតាមចិត្ត-សមុដ្ឋានជាដើមដោយពិត ។ យករូបទាំង ៥ គឺ ចក្ខុប្បសាទរូប ១ សោត-

ប្បសាទរូប ១ ឃានប្បសាទរូប ១ ជិវ្ហាបសាទរូប ១ កាយប្បសាទរូប ១ រូបទាំង ៥ នេះ ឲ្យឈ្មោះថា អជ្ឈត្តិករូប ជារូបកើតឡើងសម្រាប់ប្រព្រឹត្តទៅខាងក្នុងដោយពិត ហើយយករូបទាំង ២៣ គឺបឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ រូបរូប ១ សទ្ទរូប ១ គន្ធរូប ១ រសរូប ១ ឥត្ថីភាវរូប ១ បុមភាវរូប ១ ហទយរូប ១ ជីវិតរូប ១ អាហាររូប ១ អាកាសរូប ១ កាយវិញ្ញត្តិរូប ១ វចីវិញ្ញត្តិរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ ឧបចយរូប ១ សន្តតិរូប ១ ជរតារូប ១ អនិច្ចតារូប ១ រូបទាំង ២៣ នេះ ឲ្យឈ្មោះថា ពហិទ្ធារូប ជារូបកើតឡើងជាខាងក្រៅនៃបសាទរូបទាំង ៥ ដោយពិត ។ យករូបទាំង ៨ គឺចក្ខុន្ទ្រិយរូប ១ សោតិន្ទ្រិយរូប ១ ឃានិន្ទ្រិយរូប ១ ជិវ្ហិន្ទ្រិយរូប ១ កាយិន្ទ្រិយរូប ១ ឥត្ថិន្ទ្រិយរូប ១ បុរិសិន្ទ្រិយរូប ១ ជីវិតន្ទ្រិយរូប ១ រូបទាំង ៨ នេះ ឲ្យឈ្មោះថា ឥន្ទ្រិយរូប ជារូបធ្វើនូវភាវៈនៃខ្លួនជាធំ តាមទីកន្លែងរបស់ខ្លួនដោយពិត ។ ហើយយករូបទាំង ២០ គឺបឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ រូបរូប ១ សទ្ទរូប ១ គន្ធរូប ១ រសរូប ១ ហទយរូប ១ អាហាររូប ១ បរិច្ឆេទរូប ឬថាអាកាសរូប ១ កាយវិញ្ញត្តិរូប ១ វចី-

វិញ្ញត្តិរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ ឧបចយរូប ១ សន្តតិរូប ១ ជរតារូប ១ អនិច្ចតារូប ១ រូបទាំង ២០ នេះ ឲ្យឈ្មោះថា អនិន្ទ្រិយរូប ជារូបពុំបានធ្វើនូវភាវៈនៃខ្លួនជាធំឡើយ ។ យករូបទាំង ១៨ គឺហទយរូប ១ ឥត្ថីភាវរូប ១ បុមភាវរូប ១ ជីវិតរូប ១ ចក្ខុប្បសាទរូប ១ សោតប្បសាទរូប ១ ឃានប្បសាទរូប ១ ជិវ្ហាបសាទ-រូប ១ កាយប្បសាទរូប ១ គន្ធរូប ១ រសរូប ១ បឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ អាកាសធាតុរូប ១ ជា ១៦ ថែមវណ្ណរូប ជារូបមានពណ៌ផ្សេងៗ គ្នា មានពណ៌សនិងខ្មៅជាដើម ១ ឱជារូប ជារូបរសជាតអាហារដែលជ្រួតជ្រាបផ្សាយសព្វទៅក្នុងរាងកាយ ១ រូបទាំងពីរនេះ ជារូបមានឈ្មោះជាខាងក្រៅរួមបញ្ចូលមកនឹងរូបទាំង ១៦ ដែលបានអធិប្បាយរួចមកហើយ ត្រូវជា ១៨ ឈ្មោះថា កម្មជរូប ជារូបកើតមកអំពីកុសលកម្មនិងអកុសល-កម្មតាក់តែងឲ្យកើតឡើង ដោយពិត ។ ម្យ៉ាងទៀត រូបទាំង ១៨ នេះលោកឲ្យឈ្មោះថា ឧបាទិន្នករូប ជារូបមានជីវិតនិងវិញ្ញាណ ដែលកើតឡើងជាមួយគ្នាអាស្រ័យនៅឧបត្ថម្ភទំនុកបម្រុងរក្សាជាប់ជានិច្ច បើជីវិតនិងវិញ្ញាណទាំងនេះវិនាសឃ្លាតចេញចាករូបទាំង ១៨ នេះជាស្រឡះក្នុង

ពេលណាហើយ រូបទាំង ១៨ នោះនឹងត្រឡប់ទៅជាអនុបាទិន្នករូប ជារូបវិនាសរលាយសូន្យទៅជាដី ទឹក ភ្លើង ខ្យល់ អស់ទៅវិញដោយពិត ហើយយករូបទាំង ១២ គឺរូបរូប ១ សទ្ទរូប ១ អាហាររូប ១ អាកាសរូប ១ កាយវិញ្ញត្តិរូប ១ វចីវិញ្ញត្តិរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញ-តារូប ១ សត្តតិរូប ១ ជរតារូប ១ អនិច្ចតារូប ១ រូបទាំង ១២ នេះឲ្យឈ្មោះថា អកម្មជរូប ជារូបពុំបានកើតមកអំពីកុសលកម្ម និងអកុសលកម្មតាក់តែងឲ្យកើតឡើយ លោកឲ្យឈ្មោះថា អនុបាទិន្នករូប ជារូបឥតមានជីវិតនិងវិញ្ញាណអ្វីកើតឡើងជាមួយ អាស្រ័យនៅជួយឧបត្ថម្ភទំនុកបម្រុងថែរក្សាឡើយ ។ វិសជ្ជនាមកអំពីរូបទាំង ២៨ ដែលមានឈ្មោះផ្សេងៗ គ្នាដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះ ឯសេចក្ដីប្រែអធិប្បាយនោះ លោកអ្នកសិក្សារៀនសូត្រ បរមត្ថព្រះអភិធម្មត្រូវសង្កេតយកសេចក្ដីអត្ថរស ចំពោះក្នុងសេចក្ដីប្រែអធិប្បាយ អំពីមហាភូតរូបនិងឧបាទាយរូបទាំង ២៨ ខាងដើមនោះចុះ សេចក្ដីដូចគ្នាទេ ។

៧២- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវាទី ចុះរូបកលាបៈ សំណុំរូបទាំង ២១ ពួក គឺសំណុំរូបដែលកើតឡើងព្រមដោយកម្មមានប៉ុន្មានពួក? សំណុំរូបដែលកើតឡើងព្រមដោយចិត្តមាន

ប៉ុន្មានពួក? សំណុំរូបដែលកើតឡើងព្រមដោយរដូវមានប៉ុន្មានពួក? សំណុំរូបដែលកើតឡើងព្រមដោយអាហារមានប៉ុន្មានពួក? ក្នុងមួយពួកៗ មានរូបប៉ុន្មាន? រូបរួមរូបទាំងអស់មានចំនួនប៉ុន្មាន? ចូរលោកវិសជ្ជនាមកឲ្យសព្វគ្រប់យើងនឹងបានស្ដាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯសំណុំរូបទី ១ ដែលកើតឡើងព្រមដោយកម្មនោះមាន ៩ ពួកគឺ ១- ប្រជុំសំណុំរូបមានចក្ខុ-រូបជាគម្រប់ ១០ គឺបឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ ឱជារូប ១ ជីវិតរូប ១ ចក្ខុរូប ១ ត្រូវជា ១០ ឈ្មោះថា ចក្ខុទសកៈ ។ ២- ប្រជុំសំណុំរូបមានសោតរូបជាគម្រប់ ១០ គឺបឋវីធាតុរូប ១ អាបោធាតុរូប ១ ។ល។ ជីវិតរូប ១ សោតរូប ១ ត្រូវជា ១០ ឈ្មោះថា សោតទសកៈ ។ ៣- ប្រជុំសំណុំរូប មានឃានរូបជាគម្រប់ ១០ គឺបឋវីធាតុរូប ១ អាបោធាតុរូប ១ ។ល។ ជីវិតរូប ១ ឃានរូប ១ ត្រូវជា ១០ ឈ្មោះថា ឃានទសកៈ ។ ៤- ប្រជុំសំណុំរូបមានជិវ្ហារូបជាគម្រប់ ១០ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ ។ល។ ជីវិតរូប ១ ជិវ្ហារូប ១ ត្រូវជា ១០ ឈ្មោះថា ជិវ្ហាទសកៈ ។ ៥- ប្រជុំសំណុំរូបមានកាយរូបជាគម្រប់ ១០ គឺ បឋវី-

ធាតុរូប ១ អាបោធាតុរូប ១ ។ ល ។ ជីវិតរូប ១ កាយរូប ១ ត្រូវជា ១០ ឈ្មោះថា កាយទសកៈ ។ ៦- ប្រជុំសំណុំរូបមានឥត្ថីភាវរូបជាគម្រប់ ១០ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ ។ ល ។ ជីវិតរូប ១ ឥត្ថីភាវរូប ១ ត្រូវជា ១០ ឈ្មោះថា ឥត្ថីភាវទសកៈ ។ ៧- ប្រជុំសំណុំរូបមានបុមភាវរូបជាគម្រប់ ១០ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ ។ ល ។ ជីវិតរូប ១ បុម-ភាវរូប ១ ត្រូវជា ១០ ឈ្មោះថា បុមភាវទសកៈ ។ ៨- ប្រជុំសំណុំរូបមានហទយរូបជាគម្រប់ ១០ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ ។ ល ។ ជីវិតរូប ១ ហទយរូប ១ ត្រូវជា ១០ ឈ្មោះថា វត្ថុទសកៈ ។ ៩- ប្រជុំសំណុំរូប មានជីវិតរូបជាគម្រប់ ៩ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ ។ ល ។ ឱជារូប ១ ជីវិតរូប ១ ត្រូវជា ៩ ឈ្មោះថា ជីវិតនវកៈ ។ បូករួមសំណុំរូបទាំង ៩ ពួកនេះ ជារូបរាយមានចំនួន ៨៩ គត់ បានឈ្មោះថា កម្មសមុដ្ឋានកលាបៈ ជាសំណុំរូបកើតឡើងព្រមគ្នា ដោយកម្លាំងនៃកុសលកម្មនិងអកុសលកម្មតាក់តែងឲ្យកើតឡើងដោយពិត ។

សំណុំរូបទី ២ ដែលកើតឡើងព្រមដោយចិត្តនោះមាន ៦ ពួកគឺ ១- ប្រជុំសំណុំអវិនិព្ភោគរូបសុទ្ធ ដែលជារូបមិនត្រូវចំណែកចែកទៅ

ផ្សេងៗទាំង ៨ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វា-យោធាតុរូប ១ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ ឱជារូប ១ រូបទាំង ៨ នេះ ឲ្យឈ្មោះថា សុទ្ធដ្ឋករូប ជាសំណុំអវិនិព្ភោគរូបទាំង ៨ សុទ្ធ រូបដទៃពីនេះ ឲ្យឈ្មោះថាវិនិព្ភោគរូប ជារូបត្រូវចំណែកចែកទៅតាមលំដាប់រូបផ្សេងៗ ២- ប្រជុំសំណុំរូបមានកាយវិញ្ញត្តិរូបជាគម្រប់ ៩ គឺ បឋវីធាតុរូប ១ អាបោ-ធាតុរូប ១ ។ ល ។ ឱជារូប ១ កាយវិញ្ញត្តិរូប ១ ត្រូវជា ៩ ឈ្មោះថា កាយវិញ្ញត្តិនវកៈ ។ ៣- ប្រជុំសំណុំរូបមានវចីវិញ្ញត្តិរូបជាគម្រប់ ១០ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ ។ ល ។ វចីវិញ្ញត្តិរូប ១ សទ្ទរូប ១ ត្រូវជា ១០ ឈ្មោះថា វចីវិញ្ញត្តិទសកៈ ។ ៤ ប្រជុំសំណុំសុទ្ធដ្ឋករូប ៨ មានវិការរូប ៣ ជាគម្រប់ ១១ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ ។ ល ។ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ ត្រូវជា ១១ ឈ្មោះថា ឯកាទ-សកៈ ។ ៥- ប្រជុំសំណុំសុទ្ធដ្ឋករូប ៨ មានវិញ្ញត្តិ ១ វិការរូប ៣ ជាគម្រប់ ១២ គឺ បឋវីធាតុរូប ១ ។ ល ។ កាយវិញ្ញត្តិរូប ១ វិការរូប ៣ ត្រូវជា ១២ ឈ្មោះថា ទ្វាទសកៈ ។ ៦- ប្រជុំសំណុំរូប ១៣ គឺ សុទ្ធដ្ឋករូប ៨ វចីវិញ្ញត្តិរូប ១ សទ្ទរូប ១ វិការរូប ៣ ត្រូវជា ១៣ ឈ្មោះថា តេរ-សកៈ ។ បូករួមសំណុំរូបទាំង ៦ ពួកនេះ ជារូបរាយមានចំនួន ៦៣ គត់

បានឈ្មោះថា ចិត្តសមុដ្ឋានកលាបៈ ជាសំណុំរូបកើតឡើងព្រមដោយកម្លាំងនៃចិត្តគាត់តែងឲ្យកើតឡើងដោយពិត ។

សំណុំរូបទី ៣ ដែលកើតឡើងព្រមដោយរដូវនោះមាន ៤ ពួកគឺ ១- ប្រជុំសំណុំអវិនិព្ភោគរូបទាំង ៨ សុទ្ធគឺ បឋវីធាតុរូប ១ ។ ល ។ ឱជារូប ១ ត្រូវជា ៨ ឈ្មោះថា សុទ្ធដ្ឋកៈ ។ ២- ប្រជុំសំណុំអវិនិព្ភោគរូបសុទ្ធ មានសទ្ទរូបជាគម្រប់ ៩ គឺ បឋវីធាតុរូប ១ ។ ល ។ សទ្ទរូប ១ ត្រូវជា ៩ ឈ្មោះថា សទ្ទនវកៈ ។ ៣- ប្រជុំសំណុំអវិនិព្ភោគរូប ៨ សុទ្ធ មានវិការរូប ៣ ជាគម្រប់ ១១ គឺ បឋវីធាតុរូប ១ ។ ល ។ កម្មញ្ញតារូប ១ ត្រូវជា ១១ ឈ្មោះថា ឯកាទសកៈ ។ ៤- ប្រជុំសំណុំអវិនិព្ភោគរូប ៨ សុទ្ធ មានសទ្ទរូប ១ និងវិការរូប ៣ ជាគម្រប់ ១២ គឺ បឋវីធាតុរូប ១ ។ ល ។ កម្មញ្ញតារូប ១ ត្រូវជា ១២ ឈ្មោះថា ទ្វាទសកៈ ។ បូករួមសំណុំរូបទាំង ៤ ពួកនេះ ជារូបរាយមានចំនួន ៤០ គត់ បានឈ្មោះថា ឧតុសមុដ្ឋានកលាបៈ ជាសំណុំរូបកើតឡើងព្រមដោយកម្លាំងនៃរដូវគាត់តែងឲ្យកើតឡើងដោយពិត ។

សំណុំរូបទី ៤ ដែលកើតឡើងព្រមដោយអាហារនោះមាន ២ ពួកគឺ ១- ប្រជុំសំណុំអវិនិព្ភោគរូបទាំង ៨ សុទ្ធ គឺ បឋវីធាតុរូប ១ ។ ល ។

ឱជារូប ១ ត្រូវជា ៨ ឈ្មោះថា សុទ្ធដ្ឋកៈ ។ ២- ប្រជុំសំណុំអវិនិព្ភោគ-រូបទាំង ៨ សុទ្ធ មានវិការរូប ៣ ជាគម្រប់ ១១ គឺបឋវីធាតុរូប ១ ។ ល ។ កម្មញ្ញតារូប ១ ត្រូវជា ១១ ឈ្មោះថា ឯកាទសកៈ ។ បូករួមសំណុំរូបទាំង ២ ពួកនេះជារូបរាយមានចំនួន ១៩ គត់ បានឈ្មោះថា អាហារ-សមុដ្ឋានកលាបៈ ជាសំណុំរូបកើតឡើងព្រមដោយអាហារតាក់តែងឲ្យកើតឡើងដោយពិត ។ វិសជ្ជនាមកអំពីរូបកលាបៈ សំណុំរូបទាំង ២១ ពួក គឺកម្មសមុដ្ឋានកលាបៈ ៩ ពួក ចិត្តសមុដ្ឋានកលាបៈ ៦ ពួក ឧតុស-មុដ្ឋានកលាបៈ ៤ ពួក អាហារសមុដ្ឋានកលាបៈ ២ ពួក ត្រូវជា ២១ ពួក ចែកជារូបរាយមានចំនួន ២១១ រូប ដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះឯង ។

៧៣- ធម្មវាទី បានស្ដាប់ហើយពោលថាៈ អើអត្តវាទី លោកវិសជ្ជនាមកនេះយើងស្ដាប់បានហើយ តែយើងនៅសង្ស័យនឹងឈ្មោះរូបទាំង ៤ តទៅទៀត គឺកម្មជរូប រូបកើតដោយកម្ម ១ ចិត្តជរូប រូបកើតដោយចិត្ត ១ ឧតុជរូប រូបកើតដោយរដូវ ១ អាហារជរូប រូបកើតដោយអាហារ ១ ក៏រូបទាំង ៤ នេះ មានសេចក្ដីប្រែអធិប្បាយនិងចំនួនរូបដូចរូបកលាបៈ សំណុំរូបទាំង ៤ ផ្នែក មានកម្មសមុដ្ឋានកលាបៈជាដើមនោះដែរ ឬផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យច្បាស់លាស់មកយើង

នឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា: បពិត្រធម្មវាទី ឯឈ្មោះរូបទាំង ៤ នេះ មានសេចក្តីប្រែអធិប្បាយនិងចំនួនរូបពុំបានដូចរូបកលាបៈសំណុំរូបទាំង ៤ ផ្នែកមានកម្មសមុដ្ឋានកលាបៈជាដើមនោះទេ ដូចមានសេចក្តីប្រែអធិប្បាយខ្ទះតទៅនេះ ទី ១- កម្មជរូប រូបកើតអំពីកម្មនោះមានចំនួន ១៨ គឺ ហទយរូប ១ ឥត្ថីភាវរូប ១ បុមភាវរូប ១ ជីវិតរូប ១ ចក្ខុប្បសាទរូប ១ សោតប្បសាទរូប ១ ឃានប្បសាទរូប ១ ជិវ្ហាបសាទរូប ១ កាយប្បសាទរូប ១ បឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ វណ្ណរូបៗ គឺពណ៌សម្បុរផ្សេងៗ មានពណ៌សខ្មៅជាដើម ១ គន្ធរូប រូបគឺក្លិនផ្សេងៗ មានក្លិនក្រអូបប្រហើរជាដើម ១ រសរូប រូបគឺជាតិឆ្ងាញ់ពិសាដែលកើតមានក្នុងអាហារទាំងពួង ដែលបុគ្គលធ្វើឲ្យជាពំនូតដុំៗ ឬជាធ្វើផ្សំគ្រឿងជាសម្លឲ្យជាម្ហូបទឹករាវៗ ដំគ្រោតគ្រាតហើយបរិភោគ លេបចូលទៅតាមបំពង់កធ្លាក់ចុះទៅឋិតនៅក្នុងក្រពះបាយទឹកបានឈ្មោះថា រសរូប ១ ឱជារូប រូបគឺជាតិដែលឆ្ងាញ់ពិសាយ៉ាងល្អិតផូរផង់ ចំហាយចេញពីរសរូបផ្សាយជ្រួតជ្រាបទៅតាមដួរសរសៃធំតូចទាំងអស់ ជាគ្រឿងរក្សានូវសរីរកាយជាទឹកកម្លាំងដំរុងរឿងចិញ្ចឹមរក្សាជីវិត ជា

ធម្មជាតធ្វើជីវិតឲ្យប្រព្រឹត្តរស់នៅជាប្រក្រតី បានឈ្មោះថា ឱជារូប ១ អាកាសរូប រូបគឺអាកាសធាតុដែលមាននៅក្នុងចន្លោះៗ នៃសរីរកាយ ១ រូបទាំង ១៨ នេះ បានឈ្មោះថា កម្មជរូប ជារូបកើតឡើងដោយកម្លាំងនៃកុសលកម្មនិងអកុសលកម្មតាក់តែងឲ្យកើតឡើង ។ ទី ២- ចិត្តជរូប រូបកើតអំពីចិត្តនោះមានចំនួន ១៥ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ ឱជារូប ១ សទ្ទរូប ១ អាកាសរូប ១ កាយវិញ្ញត្តិរូប ១ វចីវិញ្ញត្តិរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ រូបទាំង ១៥ នេះ បានឈ្មោះថា ចិត្តជរូប ជារូបកើតឡើងដោយកម្លាំងនៃចិត្តតាក់តែងឲ្យកើតឡើង ។ ទី ៣ ឧតុជរូប រូបកើតអំពីរដូវនោះមានចំនួន ១៣ គឺ បឋ-វីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោធាតុរូប ១ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ ឱជារូប ១ សទ្ទរូប ១ អាកាសរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ រូបទាំង ១៣ នេះ បានឈ្មោះថា ឧតុជរូប ជារូបកើតឡើងដោយកម្លាំងនៃរដូវតាក់តែងឲ្យកើតឡើង ។ ៤- អាហារជរូប រូបកើតដោយអាហារនោះមានចំនួន ១២ គឺ បឋវីធាតុរូប ១ អាបោធាតុរូប ១ តេជោធាតុរូប ១ វាយោ-

ធាតុរូប ១ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ ឱជារូប ១ អាកាសរូប ១ លហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ រូបទាំង ១២ នេះ បាន ឈ្មោះថា អាហារជរូប ជារូបកើតឡើងដោយកម្លាំងនៃអាហារតាក់តែង ឲ្យកើតឡើង ។ បូករួមទាំងអស់ត្រូវជារូបរាយមានចំនួន ៥៨ ដោយ សង្ខេបតែប៉ុណ្ណេះឯង ។

៧៤- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថាៈ ម្នាលអត្ថវាទី ចុះសត្វទាំងឡាយ ដែលកើតឡើងក្នុងកាមភពនេះមានរូបទាំង ២៨ កើត ឡើងគ្រប់ពេញបរិបូណ៌ឬខ្វះខ្វះដែរ? សត្វទាំងឡាយដែលកើតឡើងក្នុង រូបភពមានរូបប៉ុន្មាន ខ្វះរូបប៉ុន្មាន? អសញ្ញីសត្វទាំងឡាយមានរូប ប៉ុន្មាន ខ្វះរូបប៉ុន្មាន? សត្វទាំងឡាយដែលកើតក្នុងរូបភពមានរូប ខ្វះដែរ ឬគ្មានសោះទេ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបាន ស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថាៈ បពិត្រធម្មវាទី សត្វទាំងឡាយដែលកើត ឡើងក្នុងកាមភពនេះមានរូប ទាំង ២៨ កើតឡើងគ្រប់ពេញបរិបូណ៌ខ្វះ មិន ពេញបរិបូណ៌ខ្វះ ដោយកម្លាំងនៃកុសលកម្មនិងអកុសលកម្មតាក់តែងរូបឲ្យ កើតឡើងផ្សេង ៗ គ្នា ។ ឯសត្វទាំងឡាយដែលកើតឡើងក្នុងរូបភព

នោះមានតែរូប ២៣ គត់ ខ្វះរូប ៥ គឺឃានប្បសាទរូប ១ ជិវ្ហាបសាទរូប ១ កាយប្បសាទរូប ១ ឥត្ថិភាវរូប ១ បុមភាវរូប ១ រូបទាំង ៥ នេះពុំបាន កើតឡើយ ។ អសញ្ញីសត្វមានតែរូប ១៧ គត់ ខ្វះរូប ១១ គឺឃាន-ប្បសាទរូប ១ ជិវ្ហាបសាទរូប ១ កាយប្បសាទរូប ១ ឥត្ថិភាវរូប ១ បុមភា-វរូប ១ ចក្ខុប្បសាទរូប ១ សោតប្បសាទរូប ១ ហទយវត្ថុរូប ១ សទ្ទរូប ១ គន្ធរូប ១ រសរូប ១ រូបទាំង ១១ នេះពុំបានកើតឡើយ ។ សត្វដែលកើត ក្នុងអរូបភពពុំមានរូបអ្វីបន្តិចបន្តួចឡើយ មានតែចិត្តជាអាយតនៈ និង សញ្ញាបន្តិចបន្តួចប៉ុណ្ណោះឯង ។ វិសជ្ជនាមកអំពីសត្វទាំងឡាយដែល កើតក្នុងភពទាំង ៣ មានរូបតិចច្រើនផ្សេងៗ គ្នា និងឥតរូបសោះដោយ សេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៧៥- ធម្មវាទី បានស្តាប់ហើយសួរប្រស្នាដទៃតទៅទៀតថា ម្នាលអត្តវាទី យើងនៅមានសេចក្តីសង្ស័យនឹងអនុបាទិន្នករូបតទៅទៀត តែត្រង់រូប ២៨ ដែលចែកជាកម្មជរូប ១៨ ឈ្មោះថា ឧបាទិន្នករូប អកម្មជរូប ១២ ឈ្មោះថា អនុបាទិន្នករូប សេចក្តីនេះយើងពុំបាន សង្ស័យឡើយ ព្រោះរូបទាំង ២៨ នេះកើតឡើងដោយបច្ច័យ ៤ មាន កម្មជាដើមដោយពិត យើងសង្ស័យតែត្រង់អនុបាទិន្នករូបសុទ្ធ ដែលជារូប

ឥតមានជីវិតនិងវិញ្ញាណអ្វីកើតឡើងជាមួយ អាស្រ័យនៅជួយឧបត្ថម្ភទំនុកបម្រុងថែរក្សានោះសោះទេ ដូចយ៉ាងរុក្ខជាតិ លតាជាតិ ធញ្ញជាតិ តិណជាតិ បឋវីជាតិ បាសាណជាតិ បព្វតជាតិ ជាដើម មានសភាវៈអ្វីជាបច្ច័យ? រស់នៅអាស្រ័យនឹងវត្ថុអ្វី? មានរូបប៉ុន្មាន? ចូរលោកវិសជ្ជនាឲ្យច្បាស់លាស់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថាៈ បពិត្រធម្មវាទី តាមន័យបរមត្ថព្រះអភិធម្មលោកពន្យល់ ដូចមានបាលីថា រុក្ខបព្វតាទីសុ វិនា លហុតាទិត្តយំ សេចក្តីអធិប្បាយថាៈ វៀរលែងតែវិការរូប ៣ គឺលហុតារូប ១ មុទុតារូប ១ កម្មញ្ញតារូប ១ ចេញ ឯអនុបាទិន្នករូបសុទ្ធទាំងអស់មានរុក្ខជាតិ និងបព្វតជាតិជាដើម កើតឡើងដោយរដូវត្រជាក់និងក្តៅជាបច្ច័យ ផ្សាយមកអំពីសសម្ភារធាតុ ដែលប្រជុំព្រមគ្នាតាក់តែងឲ្យអនុបាទិន្នករូបសុទ្ធកើតឡើង មានចំនួនរូប ១០ ដោយសង្ខេប តាមន័យនេះឃើញថា រុក្ខជាតិទាំងឡាយ គឺដើមឈើតូចធំក្តី លតាជាតិទាំងឡាយ គឺវល្លិតូចធំក្តី ធញ្ញជាតិទាំងឡាយ គឺស្រូវខ្សាយស្រូវដំណើបជាដើមក្តី តិណជាតិទាំងឡាយ គឺស្មៅតូចធំក្តី បឋវីជាតិទាំងឡាយ គឺដីខ្សាច់ដីកណ្តៀងជាដើមក្តី បាសាណជាតិទាំងឡាយ គឺថ្មប្កជុំក្រួសតូចធំជាដើមក្តី

បព្វតជាតិទាំងឡាយគឺភ្នំតូចធំជាដើមក្តី ដែលនឹងកើតឡើង គឺកើតឡើង ដោយរដូវត្រជាក់និងក្តៅ ជាចំហាយផ្សាយមកអំពីសសម្ភារធាតុទាំង ៤ គឺដីខ្សាច់ ដីកណ្តូង ដីរបាយ ដែលទន់ជ្រាយឬរឹងៗ ក្តី ដែលជាសសម្ភារធាតុជារូបទ្រទ្រង់នូវការៈទឹកភ្លើងខ្យល់ ប្រជុំព្រមលាយចូលគ្នាប្រព្រឹត្តទៅជាមួយនឹងដី បានឈ្មោះថា បឋវីធាតុ ១ ជាតិទឹកដែលរាវៗ គឺទឹកសមុទ្រ ទឹកទន្លេ ទឹកស្ទឹងបឹងឬទឹកភ្លៀងក្តី ដែលជាសសម្ភារ-ធាតុជារូបទ្រទ្រង់នូវការៈដី ភ្លើង ខ្យល់ ប្រជុំព្រមលាយចូលគ្នាប្រព្រឹត្តទៅជាមួយគ្នានឹងទឹក បានឈ្មោះថា អាបោធាតុ ១ ជាតិកម្តៅព្រះអាទិត្យ កម្តៅភ្លើងទាំងពួងក្តី ដែលជាសសម្ភារធាតុ ជារូបទ្រទ្រង់នូវការៈ ដី ទឹក ខ្យល់ប្រជុំព្រមលាយចូលគ្នាប្រព្រឹត្តទៅជាមួយគ្នានឹងកម្តៅ បានឈ្មោះថា តេជោធាតុ ១ ជាតិខ្យល់ព្យុះក្តី ខ្យល់បក់ទៅមកជាធម្មតាក្តី ខ្យល់កើតដោយរិទ្ធិទេវតាមានវាតពលាហកទេវតាជាដើមក្តី ដែលជាសសម្ភារធាតុ ជារូបទ្រទ្រង់នូវការៈដី ទឹក ភ្លើងប្រជុំព្រមលាយចូលគ្នាប្រ-ព្រឹត្តទៅជាមួយគ្នានឹងខ្យល់ បានឈ្មោះថា វាយោធាតុ ១ ក៏ធាតុទាំង ៤ នេះចែកជាពីរផ្នែកគឺ ខាងក្នុង ៤ ខាងក្រៅ ៤ ប្រជុំព្រមស្មើគ្នាក្នុងទីជាមួយគ្នា គឺថា ធាតុ ៤ ខាងក្នុងផ្សំនឹងធាតុ ៤ ខាងក្រៅ ជក់ជ្រាបចូលគ្នា

ព្រមស្មើភាគគ្នាកើតជាចំហាយផ្សាយឡើងដោយរដូវទាំង ៣ គឺហេមន្ត-រដូវ ១ គិម្ហន្តរដូវ ១ វស្សន្តរដូវ ១ ក៏រដូវទាំងបីនេះជាបច្ច័យឲ្យដុះលូតលាស់កើតឡើងជារុក្ខជាតិលតាជាតិ ធញ្ញជាតិ តិណជាតិ បឋវីជាតិ បាសាណ-ជាតិ បព្វតជាតិផ្សេងៗ ជាដម្បូងតាំងពីបឋមកប្បមក, លុះដល់ជាតិឈើជាតិវល្លិ ជាតិស្រូវ ជាតិស្មៅជាដើម កើតមានឡើងពេញបរិបូណ៌ហើយ ទើបលោកកំណត់កាន់យកគ្រាប់និងដើមវាជាពូជ គឺថា គ្រាប់និងដើមវាជាធាតុ ៤ ខាងក្នុងមិនខូចខ្វះធាតុមានដី ទឹក ភ្លើង ខ្យល់ពេញបរិបូណ៌ ឯធាតុទាំង ៤ នេះតែខ្វះធាតុណាមួយហើយ លោកវោហារតែងហៅថា ពូជស្អុយ ដាំពុំដុះឡើយ ព្រោះថា ពូជគ្រាប់ និងពូជដើមដែលមានធាតុទាំង ៤ ខាងក្នុងគ្រប់គ្រាន់បរិបូណ៌ហើយៗ យកទៅដាំក្នុងផែនដីដែលជាធាតុ ៤ ខាងក្រៅ ផ្សំធាតុខាងក្នុង ៤ និងធាតុខាងក្រៅ ៤ជាធាតុទាំង ៨ ប្រជុំព្រមស្មើគ្នាកើតជាចំហាយផ្សាយទៅតាមរដូវត្រជាក់និងក្តៅកើតជាពន្លកដុះទៅជាកូនឈើផ្សេងៗ តាមពូជគ្រាប់ បើពូជដើមនិងពកជាពន្លកបែកជាខ្នែងដុះទៅជាកូនឈើផ្សេងៗ តាមពូជដើមជាដើម ក៏ជាតិទាំង ៤ យ៉ាងមានរុក្ខជាតិជាដើមនោះ ដែលនឹងប្រព្រឹត្តរស់នៅព្រោះតែបានអាស្រ័យនូវធាតុទាំង ៤ ជាខាងក្រៅ តែខ្វះធាតុណា

មួយនឹងស៊ិតស្រពោនស្ងួតក្រៀមងាប់ទៅជាធម្មតាដោយពិត ឯបឋវីជាតិ បាសាណជាតិនិងបព្វតជាតិនេះ មិនមានគ្រាប់ឬដើមជាពូជឡើយ មានតែធាតុទាំង ៤ ខាងក្នុងបានអាស្រ័យនឹងធាតុទាំង ៤ ខាងក្រៅផ្សំចូលគ្នាជា ៨ កើតជាចំហាយផ្សាយទៅរីកធំក្រាស់ឡើងៗ លោកវោហារតែងហៅថា ដីដុះ ថ្មដុះ ភ្នំដុះធំក្រាស់ខ្ពស់ឡើងជាធម្មតាលោក ក៏សភាវៈទាំងអស់នេះ បានឈ្មោះថា អនុបាទិន្នករូប ជារូបកើតឡើងដោយរដូវតាក់តែងឲ្យកើតឡើងដោយពិត, ឯអនុបាទិន្នករូបសុទ្ធទាំង ១០ ដោយសង្ខេបនោះគឺ បឋវីធាតុរូប ជាតិដីជារូបទ្រទ្រង់នូវភារៈ ទឹក ភ្លើង ខ្យល់ប្រជុំព្រម ប្រព្រឹត្តទៅជាមួយគ្នានឹងដីជាលក្ខណៈ ១ អាបោធាតុរូប ជាតិទឹកទាំងអស់ជារូបទ្រទ្រង់នូវភារៈដីភ្លើង ខ្យល់ ប្រជុំព្រមប្រព្រឹត្តទៅជាមួយនឹងទឹកជាលក្ខណៈ ១ តេជោធាតុរូប ជាតិភ្លើងជារូបទ្រទ្រង់នូវភារៈដី ទឹក ខ្យល់ ប្រជុំព្រមប្រព្រឹត្តទៅជាមួយគ្នានឹងភ្លើងជាលក្ខណៈ ១ វាយោ-ធាតុរូប ជាតិខ្យល់ជារូបទ្រទ្រង់នូវភារៈ ដី ទឹក ភ្លើង ប្រជុំព្រមប្រព្រឹត្តទៅជាមួយគ្នានឹងខ្យល់ជាលក្ខណៈ ១ វណ្ណរូប ជារូបមានពណ៌សម្បុរផ្សេងៗ គ្នាមានពណ៌សក្រហមលឿងជាដើម ១ គន្ធរូប ជារូបមានក្លិនផ្សេង ៗ គ្នា មានក្លិនក្រអូបប្រហើរជាដើម ១ រសរូប ជារូបមានរសជាតិ

ឬជ័រផ្សេងៗ មានរសជាតិជូរចត់ល្វីងជាដើម ១ ឱជារូប ជារូបមានជីជាតិផ្សេងៗ ជាជីកើតអំពីធាតុខាងក្រៅ ជក់ជ្រាបផ្សាយចូលទៅកាន់ធាតុខាងក្នុងមានឫសគល់ដើមមែកជាដើម ជាគ្រឿងរក្សានូវជាតិទាំងឡាយ មានរុក្ខជាតិ លតាជាតិជាដើមនោះៗ ឲ្យស្រស់រស់នៅជាប្រ-ក្រតីមិនបានឲ្យរញោមស្វិតស្រពោនងាប់ទៅ ១ សទ្ទរូប ជារូបមានបញ្ចេញនូវសន្ធឹកសំឡេងផ្សេងៗ លាន់ឮចេញពីមែកសន្ទឹកជាដើម ដោយខ្យល់ឬព្យុះជាធាតុខាងក្រៅបក់ផ្សាយមកត្រូវ ១ អាកាសរូប ជារូបអាកាសវាលទទេជាតុទ្រទ្រង់នៅជាចន្លោះៗ ខាងក្នុងដើមសម្រាប់ផ្លូវខ្យល់ចេញចូលជាធម្មតា ១ ក៏រូបទាំង ១០ នេះបានឈ្មោះថា អនុបាទិន្នករូបសុទ្ធជារូបឥតមានជីវិតវិញ្ញាណអ្វីនៅអាស្រ័យជាមួយផងសោះ ក៏គង់ដោះគេចវេះចៀសចេញអំពីអនិច្ចលក្ខណៈពុំរួច ធ្លាក់ទៅនៅក្នុងសេចក្ដីមិនទៀងជាលក្ខណៈ តែងវិនាសសាបសូន្យរលាយបាត់ទៅដោយពិត នឹងនិយាយស្អីទៅថ្វីដល់ឧបាទិន្នករូប ដែលជារូបមានជីវិតវិញ្ញាណកើតឡើងព្រមគ្នា សេចក្ដីចាស់ជរាព្យាធិចេះតែដេញតាមញឹកៗញយៗ ជាប់ជានិច្ចនឹងបណ្ដោយទៅតាមសេចក្ដីប្រមាទដូចម្ដេចបាន ។ វិសជ្ជនាមកអំពីអនុបាទិន្នករូបសុទ្ធទាំង ១០ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៧៦- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃហើយ តែយើងនឹងសួរប្រស្នាជទៃតទៅទៀត អំពីកំណើតសត្វទាំង ៤ យ៉ាង គឺអណ្ឌជៈកំណើត ១ ជលម្ពុជៈកំណើត ១ សំសេទជៈកំណើត ១ ឧបបាតិកៈកំណើត ១ ដែលជាសត្វកើតមកអំពីសភាវធម៌ទាំង ៤ មានកម្មជាដើមជាបច្ច័យផ្សំនឹងសសម្ភារធាតុតាក់តែងរូបឲ្យកើតឡើង តើផ្សេងគ្នាយ៉ាងណាខ្លះ? អធិប្បាយប្លែកគ្នាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាឲ្យពិស្តារសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល។

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី សេចក្តីអធិប្បាយអំពីកំណើតទាំង ៤ យ៉ាងនោះដូចមានតទៅនេះ ៗ ទី ១- អណ្ឌជៈកំណើតនោះគឺកំណើតសត្វតិរច្ឆានដែលគ្មានត្រចៀក មានមាន់ជាដើម ជាសត្វមានកំណើតពីរដង គឺកើតជាស៊ុតឋិតនៅក្នុងផ្ទៃនៃមេវា ១ ដង លុះដល់ស៊ុតវាចាស់គ្រប់កំណត់ថ្ងៃហើយ មេវាសម្រាលចេញមកខាងក្រៅ ហើយក្រាបក្រុងអប់ហ៊ុមស៊ុតវាឲ្យក្តៅផ្សាយទៅសព្វ ដរាបដល់រូបកូនមាន់នោះកើតរូបទាំងអស់មានចក្ខុទសករូបជាដើម កើតឡើងពេញបរិបូណ៌ហើយទើបវាចឹកសម្បកស៊ុតនោះចេញមកខាងក្រៅ ១ ដង បានឈ្មោះថា អណ្ឌជៈ

កំណើតដោយពិត ។ ទី ២- ជលម្ពុជៈកំណើតនោះ គឺកំណើតសត្វទាំង-ឡាយដែលមានត្រចៀក មានជាតិមនុស្សជាដើម ដូចមានសេចក្ដីអធិ-ប្បាយក្នុងដីកានិងយោជនាព្រះអភិធម្មត្ថសង្គហៈថា លំអងធូលីយ៉ាងល្អិតដ៏ក្រៃលែងរបស់ជាតិភពកើតអំពីទឹកដ៏ភ្លឺស្អាត ដោយសេចក្ដីឧបមាថា ត្រូវយកសក់របស់មនុស្សក្នុងជម្ពូទ្វីបមួយសរសៃមកច្រៀកជា ៨ ចម្រៀក ហើយចោល ៧ ចម្រៀកចេញ យកតែមួយចម្រៀកយ៉ាងល្អិតតូចឆ្មារបំផុតបានប៉ុនសក់របស់មនុស្សក្នុងឧត្តរកុរុទ្វីបមួយសរសៃ ហើយយកសក់របស់មនុស្សក្នុងឧត្តរកុរុទ្វីបមួយសរសៃយ៉ាងល្អិតតូចឆ្មារបំផុតនោះ មកច្រៀកជា ៨ ចម្រៀកទៀត ហើយចោល ៧ ចម្រៀកចេញ យកតែមួយចម្រៀកមកជ្រលក់នឹងប្រេងល្ងដ៏ថ្លាស្អាតហើយលើកឡើង នៅសល់ជាតិប្រេងល្ងយ៉ាងតិចថ្លាស្អាតជាប់នឹងចម្រៀកសក់នោះប៉ុន្មាន ក៏ពាក្យដែលបណ្ឌិតពោលឲ្យឈ្មោះថា កលលរូបនោះ មានចំនួនយ៉ាងតិចដ៏ភ្លឺថ្លាស្អាតប៉ុណ្ណោះឯង ។

ឯរូបដែលកើតឡើងដោយកុសលកម្មនិងអកុសលកម្មនេះ តែងកើតឡើងព្រមជាមួយនឹងបដិសន្ធិចិត្តជាបឋម ដូចមានសេចក្ដីអធិប្បាយពិស្ដារថាៈ សត្តាហៈទី ១ កើតជាកលលរូប ចម្រើនបន្តិចៗ ឡើងអស់

វារៈ ៧ ថ្ងៃ សត្តាហៈទី ២ កើតជាអព្ពុទរូប គឺរូបមានពណ៌សម្បុរក្រហមព្រលៗ ដូចដំណក់ទឹកដែលបុគ្គលលាងសាច់ប្រឡាក់ដោយឈាមហើយស្រក់ចុះមក សត្តាហៈទី ៣ កើតជាបេសិរូប គឺរូបមានសណ្ឋានដូចដុំសាច់ដែលបុគ្គលហាន់កាត់ដាច់ជាដុំៗ សត្តាហៈទី ៤ កើតជាឃនរូប គឺរូបមានសណ្ឋានដូចសាច់ស៊ុតក្នុងស៊ុតមាន់ដ៏ក្រហមមូលទ្រង់ទ្រវែងបន្តិច សត្តាហៈទី ៥ កើតជាបសាទរូបយ៉ាងល្អិតជាខាងក្នុងទាំងប្រាំ គឺចក្ខុប្បសាទ ១ សោតប្បសាទ ១ ឃានប្បសាទ ១ ជិវ្ហាបសាទ ១ កាយប្បសាទ ១ សត្តាហៈទី ៦ កើតជាសាខរូប គឺរូបដូចជាមែកឈើជាខាងក្នុងយ៉ាងល្អិតទាំងប្រាំ គឺ សក់ ១ រោម ១ ក្រចក ១ ធ្មេញ ១ ស្បែក ១ ក៏ក្នុងរវាងសត្តាហៈទី ១ មកដល់សត្តាហៈទី ៦ នេះរាប់បញ្ចូលក្នុងបដិសន្ធិកាលកំណត់ ៤២ ថ្ងៃ កើតបានតែបសាទរូបយ៉ាងល្អិតទាំងប្រាំ និងសាខរូបយ៉ាងល្អិតទាំងប្រាំប៉ុណ្ណោះឯង ។ (ក្នុងបវត្តិកាល) សត្តាហៈទី ៧ កើតជាចក្ខុទសករូប គឺរូបមានចក្ខុរូបជាគម្រប់ដប់ ១, សត្តាហៈទី ៨ កើតជាសោតទសករូប គឺរូបមានសោតរូបជាគម្រប់ដប់ ១, សត្តាហៈទី ៩ កើតជាឃានទសករូប គឺរូបមានឃានរូបជាគម្រប់ដប់ ១, សត្តាហៈទី ១០ កើតជាជិវ្ហាទសករូប គឺរូបមានជិវ្ហារូបជាគម្រប់ដប់ ១, សត្តាហៈទី ១១ កើតជាកាយទសករូប

គឺរូបមានកាយរូបជាគម្រប់ដប់ ១, សត្តាហៈទី ១២ កើតជាភាវទសករូប គឺឥត្ថីភាវរូបទសកៈ រូបមានភាពស្រីជាគម្រប់ដប់ ឬបុមភាវទសកៈ រូបមានភាពប្រុសជាគម្រប់ដប់ ១, សត្តាហៈទី ១៣ កើតជាវត្ថុទសករូប គឺរូបមានហទយរូបជាគម្រប់ដប់ ១, សត្តាហៈទី ១៤ កើតជាជីវិតនវករូបគឺរូបមានជីវិតជាគម្រប់ប្រាំបួន ១, ក៏ក្នុងសត្តាហៈទាំង ៨ តាំងពីសត្តាហៈទី ៧ មកដល់សត្តាហៈទី ១៤ កើតជារូប ៨៩ ដោយរាប់បញ្ចូលគ្នាទាំងរូបស្រី-រូបប្រុស បើរាប់រូបស្រីនិងប្រុសញែកដាច់ចេញពីគ្នាកើតបានតែរូប ៧៩ រូបគត់ បានឈ្មោះថា កម្មសមុដ្ឋានកលាបៈ ជាសំណុំរូបកើតឡើងព្រមដោយកម្លាំងនៃកុសលកម្ម និងអកុសលកម្មតាក់តែងឲ្យកើតឡើងក្នុងបវត្តិកាល កំណត់ ៥៦ ថ្ងៃគត់ ។ សត្តាហៈ ទី ១៥ កើតជាសុទ្ធដ្ឋករូប គឺរូបមានឱជារូបជាគម្រប់ ៨ សុទ្ធមួយ, សត្តាហៈ ទី ១៦ កើតជាកាយ-វិញ្ញត្តិនវករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានកាយវិញ្ញត្តិរូបជាគម្រប់ ៩ មួយ សត្តាហៈទី ១៧ កើតជាវចីវិញ្ញត្តិទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវចីវិញ្ញត្តិរូបនិងសទ្ទរូបជាគម្រប់ ១០ មួយ, សត្តាហៈទី ១៨ កើតជាឯកាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវិការរូប ៣ ជាគម្រប់ ១១ មួយ, សត្តាហៈទី ១៩ កើតជាទ្វាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានកាយ-

វិញ្ញត្តិរូប ១ និងវិការរូប ៣ ជាគម្រប់ ១២ មួយ, សត្តាហៈទី ២០ កើតជាតេរសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវចីវិញ្ញត្តិរូប ១ សទ្ទរូប ១ វិការរូប ៣ ជាគម្រប់ ១៣ មួយ, ក្នុងសត្តាហៈទាំង ៦ នោះ កើតជារូប ៦៣ រូបគត់ បានឈ្មោះថា ចិត្តសមុដ្ឋានកលាបៈ សំណុំរូបកើតឡើងព្រមដោយកម្លាំងនៃចិត្តតាក់តែងកើតឡើង ក្នុងបវត្តិ-កាលកំណត់ ៤២ ថ្ងៃគត់ ។

សត្តាហៈទី ២១ កើតជាសុទ្ធដ្ឋករូបទាំង ៨ សុទ្ធ ចម្រើនធំឡើងមួយ, សត្តាហៈទី ២២ កើតជាសទ្ទនវករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានសទ្ទរូបជាគម្រប់ ៩ មួយ, សត្តាហៈទី ២៣ កើតជាឯកាទសករូបគឺអដ្ឋករូបទាំង ៨ សុទ្ធ មានវិការរូប ៣ ជាគម្រប់ ១១ មួយ, សត្តាហៈទី ២៤ កើតជាទ្វាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានសទ្ទរូបនិងវិការ-រូប ៣ ជាគម្រប់ ១២ មួយ, ក្នុងសត្តាហៈទាំង ៤ នេះ កើតជារូប ៤០ គត់ បានឈ្មោះថា ឧតុសមុដ្ឋានកលាបៈជាសំណុំរូបកើតឡើងព្រម ដោយកម្លាំងនៃរដូវតាក់តែងឲ្យកើតឡើងក្នុងបវត្តិកាលកំណត់ ២៨ ថ្ងៃគត់ ។

សត្តាហៈទី ២៥ កើតជាសុទ្ធដ្ឋករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានបឋវីធាតុរូបជាដើម កើតពេញបរិបូណ៌ឡើងមួយ, សត្តាហៈទី ២៦ កើត

ជាឯកាទសករូប គឺអដ្ឋករូបទាំង ៨ សុទ្ធ មានវិការរូប ៣ ជាគម្រប់ ១១ មួយ, ក្នុងសត្តាហៈទាំង ២ នេះ កើតជារូប ១៩ គត់ បានឈ្មោះថា អាហារសមុដ្ឋានកលាបៈ ជាសំណុំរូបកើតឡើងព្រមដោយកម្លាំងនៃអាហារគាក់តែងឲ្យកើតឡើងក្នុងបវត្តិកាលកំណត់ ១៤ ថ្ងៃគត់ ។ តាមន័យបរមត្ថព្រះអភិធម្មនេះដោយសភាពពិតថាៈ ជាតិមនុស្សទាំងឡាយដែលជាជលម្ពុជៈកំណើតកើតឋិតនៅក្នុងគភ៌នៃមាតា ដែលនឹងមានរូបកាយពេញបរិបូណ៌ប្រាកដថាជាស្ត្រីនិងបុរសនោះ បើគិតក្នុងបវត្តិកាលតាំងពីសត្តាហៈទី ៧ មកដល់សត្តាហៈទី ២០ បានចំនួន ១៤០ ថ្ងៃ គិតជាខែបាន ៤ ខែ និង ២០ ថ្ងៃគត់ បើគិតក្នុងបដិសន្ធិកាលតាំងពីចាប់បដិសន្ធិជាកលលរូបមកបាន ៦ សត្តាហៈទៀត មានចំនួន ១៨២ ថ្ងៃ គិតជាខែបាន ៦ ខែនិង ២ ថ្ងៃគត់ ។ ឯកុមារតូចដែលស្ថិតនៅក្នុងផ្ទៃនៃមាតានោះ អង្គុយប្រហោងត្របោមក្បាលជង្គង់ដៃឱបចង្កាដាក់លើក្បាលជង្គង់ បែរមុខឈមទៅកាន់ឆ្អឹងខ្នងនៃមាតា មាតារបស់ទារកនោះបរិភោគនូវភោជនមួយអន្ទើដោយបាយនិងទឹកឯណា ទារកតូចដែលនៅក្នុងផ្ទៃនៃមាតានោះ ញុំាំងអត្តភាពឲ្យចម្រើនធំឡើងដោយឱជារសនៃភោជននោះឯង ដេកត្រាំក្នុងគភ៌នៃមាតាសោយទុក្ខវេទនាជាទម្ងន់ លុះ

ដល់គភ៌ចាស់កំណត់បាន ៨-៩-១០ ខែ ទើបប្រសូតចេញមកអំពីផ្ទៃនៃមាតា ប្រកបដោយសេចក្តីទុក្ខលំបាកយ៉ាងខ្លាំងពន់ពេកណាស់ បើកុមារតូចនៅក្នុងផ្ទៃពុំទាន់ដល់កំណត់ថ្ងៃខែទេ គភ៌នៅខ្ចី ហើយប្រសូតចេញមកអំពីផ្ទៃនៃមាតា កុមារតូចនោះច្រើនតែស្លាប់ពុំបានរស់ឡើយ ។ ម្យ៉ាងទៀត សត្វទាំងឡាយដែលនឹងចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាហើយឋិតនៅបាននោះ លុះតែប្រកបព្រមដោយកាលទាំងពីរ គឺមាតាបិតុសន្និបាតកាល កាលដែលមាតានិងបិតាប្រជុំព្រមគ្នា ១ មាតុឧតុសមុដ្ឋានកាល កាលដែលមាតាមានរដូវកើតឡើងព្រម ១ ទើបសត្វចាប់បដិសន្ធិបាន បើពុំទាន់ប្រកបព្រមដោយកាលទាំងពីរនេះទេ សត្វនោះនៅរង់ចាំឋិតនៅកំណត់ ៧ ថ្ងៃជាធម្មតា បានឈ្មោះថា ជលម្ពុជៈកំណើតដោយពិត ។

ទី ៣- សំសេទជៈកំណើតនោះ គឺកំណើតសត្វទាំងឡាយដែលកើតដោយសភាវធម៌ទាំងឡាយ ៤ មានកម្មជាដើម ប្រជុំព្រមគ្នាអាស្រ័យនឹងញើសក្អែលមានប្រមាណតិចពន់ពេក មានញើសក្អែលក្នុងផ្កាឈើនិងដើមឈើ ឬមន្ទិលគភ៌ជាដើម ហើយតាក់តែងរូបឲ្យកើតឡើងមានទឹកស្លេស្ម ឬទឹកមាត់របស់ខ្លួនជាអាហារចម្រើនរូបទាំងអស់មានចក្ខុ-

ទសករូបជាដើម ឲ្យចម្រើនធំឡើងពេញបរិបូណ៌មួយរំពេច បានឈ្មោះថា សំសេទជៈកំណើតដោយពិត ។

ទី ៤- ឧបបាតិកៈកំណើតនោះ គឺកំណើតសត្វទាំងឡាយ ដែលអាស្រ័យនឹងភពកើតឡើងដោយសភាវធម៌ទាំងឡាយ ៤ មានកម្មជាដើម ប្រជុំគ្នាតាក់តែងរូបទាំងអស់ឲ្យកើតឡើងមួយរំពេច មានទឹកមាត់ចេញអំពីបបូរមាត់របស់ខ្លួនជាអាហារ ចម្រើនរូបធំឡើងពេញបរិបូណ៌ ហើយទ្រទ្រង់នូវគ្រឿងអលង្ការគ្រប់ប្រដាប់មួយរំពេច មានកំណើតទេវតាក្នុងឋានសួគ៌ ចាតុម្មហារាជិកាជាដើម បានឈ្មោះថា ឧបបាតិកៈកំណើតដោយពិត ។ វិសជ្ជនាមកអំពីកំណើតសត្វទាំង ៤ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៧៧- ធម្មវាទី បានស្ដាប់ហើយពោលថាៈ អើអត្តវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះត្រឹមត្រូវហើយ តែយើងនឹងសួរលោកអំពីកាយកោដ្ឋាសៈ ចំណែកកាយទាំង ៣ ក្នុងគម្ពីរអត្ថសាលិនីអដ្ឋកថា ធម្មសង្គណីតទៅទៀត ម្នាលអត្តវាទី ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្ដែងនូវទីប្រជុំរូបទាំងអស់ ឲ្យឈ្មោះថារាងកាយ គឺសភាវៈជាទីប្រជុំនៃអាការៈទាំង ៣២ មានសក់ជាដើម ថាមាន ៣ ចំណែកនោះ

តើគឺចំណែកកាយមានឈ្មោះដូចម្តេចខ្លះ? ក្នុងកាយមួយៗ មានរូបប៉ុន្មាន ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯចំណែកកាយទាំង ៣ នោះគឺ ទី ១- ហេដ្ឋិមកាយ វាងកាយជាចំណែកខាងក្រោមរាប់តាំងពីបាតជើងទៅដល់ផ្ចិតមានរូប ៤៤ គឺ កាយទសករូប ១០ ភាវទសករូប ១០ អដ្ឋករូបសុទ្ធ ដែលមានសមុដ្ឋានកើតអំពីចិត្ត ៨ មានសមុដ្ឋានកើតអំពីរដូវ ៨ មានសមុដ្ឋានកើតអំពីអាហារ ៨ ត្រូវជា ៤៤ រូបគត់ បានឈ្មោះថា ហេដ្ឋិមកាយ ដោយពិត ។ ទី ២ មជ្ឈិមកាយ វាងកាយជាចំណែកកណ្តាល រាប់ពីត្រឹមផ្ចិតឡើងទៅដល់បំពង់កមានរូប ៥៤ គឺ កាយទសករូប ១០ ភាវទសករូប ១០ វត្ថុទសករូប ១០ អដ្ឋក-រូប សុទ្ធ ដែលមានសមុដ្ឋានកើតអំពីចិត្ត ៨ មានសមុដ្ឋានកើតអំ-ពីរដូវ ៨ មានសមុដ្ឋានកើតអំពីអាហារ ៨ ត្រូវជា ៥៤ រូបគត់ បានឈ្មោះថា មជ្ឈិមកាយ ដោយពិត ។ ទី ៣- ឧបរិមកាយ វាងកាយជាចំណែកខាងលើ (ក្បាល) មានរូប ៨៤ គឺ ចក្ខុទសករូប ១០ សោតទសករូប ១០ ឃានទសករូប ១០ ជិវ្ហាទសករូប ១០ កាយទសករូប ១០ ភាវទសករូប ១០ អដ្ឋករូប សុទ្ធ ដែលមានសមុដ្ឋានកើតអំពីចិត្ត

៨ មានសមុដ្ឋានកើតអំពីរដូវ ៨ មានសមុដ្ឋានកើតអំពីអាហារ ៨ ត្រូវជា ៨៤ រូបគត់ បានឈ្មោះថា ឧបរិមកាយ ដោយពិត ។ វិសជ្ជនាមក អំពីចំណែករាងកាយទាំង ៣ កំណាត់ ដោយសង្ខេបតែប៉ុណ្ណោះឯង ។

៧៨- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្តវាទី យើងបានបុច្ឆាវិសជ្ជនាគ្នាមកអំពីរូបសង្គហៈនេះ ក៏ឃើញថា ល្មមសមគួរស្តាប់បានហើយ ឥឡូវនេះ យើងនឹងសួរលោក ក្នុងបកិណ្ណកសង្គហៈ វិញ ម្នាលអត្តវាទី ក៏ក្នុងចិត្ត ៨៩ ដួងនោះ ថាមានវេទនា ៥ គឺសុខវេទនា ១ ទុក្ខវេទនា ១ ទោមនស្សវេទនា ១ សោមនស្សវេទនា ១ ឧបេក្ខាវេទនា ១ ក៏ក្នុងវេទនាមួយៗ តើប្រកបកើតព្រមបិតនៅក្នុងចិត្តចំនួនតិចច្រើនផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ទី ១- សុខវេទនា ធម្មជាតិសម្រាប់សោយនូវរសនៃអារម្មណ៍ ជាសុខសប្បាយប្រព្រឹត្តទៅស្រួលក្នុងកាយ ប្រកបកើតព្រមបិតនៅក្នុងចិត្តតែមួយ គឺសុខសហគតកាយវិញ្ញាណជាកុសលវិបាកចិត្តដោយពិត ។ ទី ២- ទុក្ខវេទនា ធម្មជាតិសម្រាប់សោយនូវរសនៃអារម្មណ៍ ជាទុក្ខព្រួយ ប្រព្រឹត្តទៅលំបាក

ក្នុងកាយ ប្រកបកើតព្រមឋិតនៅក្នុងចិត្តតែមួយ គឺទុក្ខសហគតកាយ-វិញ្ញាណជាអកុសលវិបាកចិត្តដោយពិត ។ ទី ៣- ទោមនស្សវេទនា ធម្មជាតិសម្រាប់សោយនូវរសនៃអារម្មណ៍ ជាគ្រឿងទំនាស់ទាស់ដល់ចិត្ត ថ្នាំងថ្នាក់ចិត្ត ប្រព្រឹត្តទៅក្តៅក្រហាយគ្នាន់ក្នាញ់ក្នុងចិត្ត ប្រកបកើតព្រមឋិតនៅក្នុងចិត្តទាំងពីរ គឺទោមនស្សសហគតបដិឃចិត្តអសង្ខារិក សសង្ខារិក ជាអកុសលចិត្ត ដោយពិត ។ ទី ៤- សោមនស្សវេទនា ធម្មជាតិសម្រាប់សោយនូវរសនៃអារម្មណ៍ ជាទីត្រេកអររីករាយចិត្តប្រព្រឹត្តទៅស្រួលសប្បាយក្នុងចិត្តប្រកបកើតព្រមឋិតនៅក្នុងចិត្តទាំង ៦២ គឺ សោមនស្សសហគតលោភចិត្ត ៤ សោមនស្សសហគតកាមាវចរកុសល-ចិត្ត ៤ វិបាកចិត្ត ៤ កិរិយាចិត្ត ៤ សោមនស្សសហគតសន្តីរណចិត្ត ១ ហសិតុប្បាទចិត្ត ១ បឋម-ទុតិយ-តតិយ-ចតុត្ថមហគ្គតជ្ឈាន ១២ បឋម-ទុតិយ-តតិយ-ចតុត្ថលោកុត្តរជ្ឈាន ៣២ ត្រូវជា ៦២ ដោយពិត ។ ទី ៥- ឧបេក្ខាវេទនា ធម្មជាតិសម្រាប់សោយនូវរសនៃអារម្មណ៍និងនៅមិនកក្រើក ប្រព្រឹត្តទៅជាកណ្តាលក្នុងចិត្ត ប្រកបកើតព្រមឋិតនៅក្នុងចិត្តទាំង ៥៥ គឺឧបេក្ខាសហគតលោភចិត្ត ៤ ឧបេក្ខាសហគតឧទ្ធច្ច-សម្បយុត្ត ១ វិចិកិច្ឆាសម្បយុត្ត ១ ឧបេក្ខាសហគតចក្ខុវិញ្ញាណ ២

សោតវិញ្ញាណ ២ ឃានវិញ្ញាណ ២ ជិវ្ហាវិញ្ញាណ ២ សម្បដិច្ឆន្ន ២ បដិសន្ធិយុគល ២ ឧបេក្ខាសហគតកាមាវចរសោភណចិត្ត ១២ បញ្ចម-ជ្ឈានិកចិត្ត ៣២ ត្រូវជា ៥៥ ដោយពិត ។ វិសជ្ជនាមកអំពីវេទនាទាំង ៥ ដែលប្រកបកើតព្រមឋិតនៅក្នុងចិត្ត មានចំនួនតិចច្រើនផ្សេងគ្នាដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៧៩- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្ថវាទី ប្រស្នានេះប្រពៃហើយ តែយើងនឹងសួរលោកតទៅទៀត ចុះក្នុងហេតុសង្គ-ហៈ ចិត្តទាំង ៨៩ ដួងនោះព្រះអរហំសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងចែកជាហេតុមានប៉ុន្មាន? ជាអហេតុកចិត្តមានប៉ុន្មាន? ជាឯកហេតុកចិត្តមានប៉ុន្មាន? ជាទុហេតុកចិត្តមានប៉ុន្មាន? ជាតិហេតុកចិត្តមានប៉ុន្មាន? ជាអព្យាក្រិតដូចម្តេច? ចូរលោកវិសជ្ជនា ឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ក្នុងហេតុសង្គហៈនោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងថា ទី ១- ហេតុមាន ៦ គឺលោភៈ សេចក្តីលោភចង់បានហួសប្រមាណ ១ ទោសៈ សេចក្តីក្រោធខឹងប្រទូស្តសត្វនិងសង្ខារ ១ មោហៈ សេចក្តីវង្វេងភាន់ច្រឡំអារម្មណ៍

១ ហេតុទាំង ៣ នេះ ហៅថា អកុសលហេតុ ជាហេតុបណ្តាលឲ្យកើតជាអកុសលផលបាបពេញទី, អលោភៈ សេចក្តីមិនលោភចង់បានហួសប្រមាណ ១ អទោសៈ សេចក្តីមិនក្រោធខឹងប្រទូស្តសត្វនិងសង្ខារ ១ អមោហៈ សេចក្តីមិនវង្វេងកាន់ប្រឡំអារម្មណ៍ ១ ហេតុទាំង ៣ នេះហៅថាកុសលហេតុ ជាហេតុបណ្តាលឲ្យកើតជាកុសលផលបុណ្យពេញទី ត្រូវជាហេតុទាំង ៦ គត់ ។ ទី ២- ព្រះអង្គទ្រង់លើកយកចិត្តទាំង ១៨ គឺ អហេតុកអកុសលវិបាក ៧ អហេតុកកុសលវិបាក ៨ អហេតុកកិរិយាចិត្ត ៣ ឲ្យឈ្មោះថា អហេតុកចិត្ត ជាចិត្តឥតហេតុឥតផល មិនអាចញ៉ាំងគុណវិសេស មានឈានសមាបត្តិជាដើម ឲ្យកើតឡើងបានឡើយ ។ ទី ៣- ព្រះអង្គទ្រង់លើកយក មោមូហចិត្តទាំងពីរ ដែលជាចិត្តវង្វេងកាន់ប្រឡំអារម្មណ៍ពុំបានប្រាកដ កំណត់ឲ្យឈ្មោះថា ឯកហេតុកចិត្ត ជាចិត្តមានហេតុតែមួយ មិនអាចឲ្យបដិសន្ធិបានឡើយ ។ ទី ៤- ព្រះអង្គទ្រង់លើកយកចិត្តទាំង ២២ គឺអកុសលចិត្ត ១០ វៀរលែងតែមោមូហចិត្តពីរចេញ កាមាវចរសោភណចិត្ត ១២ កំណត់ឲ្យឈ្មោះថា ទុហេតុកចិត្ត ជាចិត្តប្រកបដោយហេតុ ២ តែថាអកុសលចិត្តទាំង ១០ នោះជាចិត្តមានកម្លាំងខ្សោយពន់ពេក ព្រោះពុំអាចនឹងចាប់យកព្រះ

និព្វានជាអារម្មណ៍បានឡើយ នឹងឲ្យផលទៅជាអហេតុកវិបាកចិត្តវិញ ដោយពិត ឯកាមាវចរសោភណចិត្តទាំង ១២ នោះជាចិត្តមានកម្លាំងខ្លាំង អាចនឹងចាប់យកព្រះនិព្វាន ជាអារម្មណ៍ បាននឹងឲ្យផលទៅជាទុហេតុកវិ-បាកចិត្តដដែលដោយពិត ។ ទី ៥- ព្រះអង្គទ្រង់លើកយកចិត្តទាំង ៤៧ គឺកាមាវចរសោភណចិត្តជាញាណសម្បយុត្ត ១២ មហគ្គតចិត្ត ២៧ លោកុត្តរចិត្ត ៨ ជា ៤៧ គត់ កំណត់ឲ្យឈ្មោះថា គឺហេតុកចិត្តជាចិត្ត ប្រកបដោយត្រៃហេតុ ដោយពិត ។ ទី ៦- ព្រះអង្គទ្រង់លើកយករូបទាំង ២៨ វិបាកចិត្តទាំង ២៣ កិរិយាចិត្តតាំង ២០ ព្រះនិព្វាន ១ កំណត់ឲ្យ ឈ្មោះថា អព្យាក្រិត ដោយពិត ។ វិសជ្ជនាមកអំពីហេតុសង្គហៈ ៦ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៨០- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី ចុះក្នុងកិច្ចសង្គហៈ សម្ដែងអំពីចិត្តុប្បាទ គឺចិត្តនិងចេតសិកទាំងឡាយ ដែលកើតឡើងព្រមជាមួយគ្នា មានបដិសន្ធិចិត្តជាដើម អាចញុំាង កិច្ចទាំង ១៤ ឲ្យសម្រេចបានគឺកិច្ចអ្វីខ្លះ? សេចក្ដីអធិប្បាយដូចម្ដេច? ចូរលោកវិសជ្ជនាមកយើងនឹងបានស្ដាប់ចូលចិត្តផងមើល?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ចិត្តុប្បាទទាំងឡាយអាច

ញ៉ាំងកិច្ចទាំង ១៤ ឲ្យសម្រេចនោះ គឺបដិសន្ធិកិច្ច អំពើធ្វើបដិសន្ធិចិត្ត ១ ភវង្គកិច្ច អំពើធ្វើឲ្យកើតជាតួភវង្គ ១ អាវជ្ជនកិច្ច អំពើធ្វើឲ្យពិចារណានូវអារម្មណ៍ក្នុងទ្វារទាំងប្រាំ ១ ទស្សនកិច្ច អំពើធ្វើឲ្យឃើញដឹងច្បាស់នូវរូបារម្មណ៍ ១ សវនកិច្ច អំពើធ្វើឲ្យទទួលស្តាប់នូវសទ្ទារម្មណ៍ ១ ឃាយនកិច្ច អំពើធ្វើឲ្យហិតស្រង់នូវគន្ធារម្មណ៍ ១ សាយនកិច្ច អំពើធ្វើឲ្យស្រូបភ្លក់នូវរសារម្មណ៍ ១ ផុស្សនកិច្ច អំពើធ្វើឲ្យប៉ះពាល់នូវផោដ្ឋព្វារម្មណ៍ ១ សម្បដិច្ឆន្នកិច្ច អំពើធ្វើឲ្យទទួលព្រមនូវអារម្មណ៍ទាំងឡាយ ១ សន្តីរណកិច្ច អំពើធ្វើឲ្យត្រិះរិះស្ទង់មើលនូវអារម្មណ៍ទាំងឡាយ ១ វោដ្ឋព្វនកិច្ច អំពើធ្វើឲ្យកំណត់កត់ត្រានូវអារម្មណ៍ទាំង-ឡាយ ១ ជវនកិច្ច អំពើធ្វើឲ្យទទួលសោយនូវរសនៃអារម្មណ៍ទាំង-ឡាយ ១ តទារម្មណកិច្ច អំពើធ្វើឲ្យទទួលកាន់យកនូវរសារម្មណ៍ដែលជវនសោយហើយនោះៗ ជាអារម្មណ៍ ១ ចុតិកិច្ច អំពើធ្វើឲ្យច្យុតឃ្លាតចេញចាកហទយៈ ១ ត្រូវជាកិច្ចទាំង ១៤ ពិត ។ ឯចិត្តុប្បាទដែលកើតឡើងមានកិច្ចផ្សេងៗ គ្នា ដូចមានសេចក្តីអធិប្បាយតទៅនេះ៖ ក៏ក្នុងចិត្តុប្បាទទាំងឡាយ ៦៨ ចិត្តុប្បាទទាំង ៧ ក្នុងចិត្តមួយៗ ញ៉ាំងកិច្ចបានតែមួយ ៗ ឲ្យសម្រេចគឺចក្ខុវិញ្ញាណ ញ៉ាំងទស្សនកិច្ចឲ្យសម្រេច ១

សោតវិញ្ញាណ ញុំាងសវនកិច្ចឲ្យសម្រេច ១ ឃានវិញ្ញាណ ញុំាងឃាយនកិច្ចឲ្យសម្រេច ១ ជិវ្ហាវិញ្ញាណ ញុំាងសាយនកិច្ចឲ្យសម្រេច ១ កាយវិញ្ញាណ ញុំាងផុស្សនកិច្ចឲ្យសម្រេច ១ សម្បដិច្ឆន្នចិត្ត ញុំាងសម្បដិច្ឆន្នកិច្ចឲ្យសម្រេច ១ បញ្ចទ្វារាវជ្ជនចិត្ត ញុំាងអាវជ្ជនកិច្ចឲ្យសម្រេចក្នុងទ្វារទាំងប្រាំ ១ ជវនចិត្តទាំង ៥៥ គឺកុសលចិត្ត ២១ អកុសលចិត្ត ១២ ផលចិត្ត ៤ កិរិយាចិត្ត ១៨ ញុំាងកិច្ចតែមួយគឺជវនកិច្ច ឲ្យសម្រេចគ្រប់ចំនួនចិត្តទាំង ៥៥ គឺចិត្តមួយៗ ញុំាងជវនកិច្ចមួយៗ ឲ្យសម្រេចត្រូវជាជវនចិត្ត ៥៥ ដោយពិត ។ ក៏ចិត្តទាំងពីរ គឺសុខសន្តីរណចិត្ត ១ មនោទ្វារាវជ្ជនចិត្ត ១ ញុំាងកិច្ចពីរៗ ឲ្យសម្រេច គឺសុខសន្តីរណចិត្ត ញុំាងសន្តីរណកិច្ចផង តទារម្មណកិច្ចផងឲ្យសម្រេច មនោទ្វារាវជ្ជនចិត្តញុំាងវោដ្ឋព្វនកិច្ចក្នុងបញ្ចទ្វារផង ញុំាងអាវជ្ជនកិច្ចក្នុងមនោទ្វារផង ឲ្យសម្រេចដោយពិត ។ មហគ្គតវិបាកចិត្តទាំង ៩ ក្នុងចិត្តមួយៗ ញុំាងកិច្ចបីៗ ឲ្យសម្រេចគឺបដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ ។ មហាវិបាកចិត្តទាំង ៨ ក្នុងមហាវិបាកចិត្តមួយៗ ញុំាងកិច្ចបួនៗ ឲ្យសម្រេចគឺបដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ តទារម្មណកិច្ច ១ ចុតិកិច្ច ១ ។ ឯចិត្តទាំងពីរ គឺ ឧបេក្ខាសហគតសន្តីរណអកុសលវិបាកចិត្ត ១ ឧបេក្ខាសហគតសន្តីរណកុសល-

វិបាកចិត្ត ១ ក្នុងចិត្តមួយៗ ញុំាងកិច្ចប្រាំៗ ឲ្យសម្រេច គឺបដិសន្ធិកិច្ច ១ ភវង្គកិច្ច ១ សន្តីរណកិច្ច ១ តទារម្មណកិច្ច ១ ចុតិកិច្ច ១ ដោយពិត ។ វិសជ្ជនាមកអំពីកិច្ចទាំង ១៤ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៨១- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី ចុះឋានដែលជាទីតាំងឋិតនៅនៃចិត្តុប្បាទទាំងឡាយ មានបដិសន្ធិចិត្តជាដើម មានចំនួនប៉ុន្មាន? គឺឋានអ្វីខ្លះ? សេចក្តីអធិប្បាយផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាមក យើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឋានដែលជាទីតាំងឋិតនៅនៃចិត្តុប្បាទទាំងឡាយ មានបដិសន្ធិចិត្តជាដើមនោះមាន ១០ គឺ បដិសន្ធិដ្ឋានំ ឋានជាទីតាំងឋិតនៅនៃបដិសន្ធិចិត្ត ១ ភវង្គដ្ឋានំ ឋានជាទីតាំងឋិតនៅនៃភវង្គចិត្ត ១ អាវជ្ជនដ្ឋានំ ឋានជាទីតាំងឋិតនៅនៃអាវជ្ជនចិត្ត ១ បញ្ចវិញ្ញាណដ្ឋានំ ឋានជាទីតាំងឋិតនៅនៃវិញ្ញាណទាំងប្រាំ ១ សម្បដិច្ឆនដ្ឋានំ ឋានជាទីតាំងឋិតនៅនៃសម្បដិច្ឆនចិត្ត ១ សន្តីរណដ្ឋានំ ឋានជាទីតាំងឋិតនៅនៃសន្តីរណចិត្ត ១ វោដ្ឋព្វនដ្ឋា-

ឆំ ឋានជាទីតាំងឋិតនៅនៃវោដ្ឋព្វនចិត្ត ១ ជវនដ្ឋានំ ឋានជាទីតាំងឋិតនៅនៃជវនចិត្ត ១ តទារម្មណដ្ឋានំ ឋានជាទីតាំងឋិតនៅនៃតទារម្មណ-ចិត្ត ១ ចុតិដ្ឋានំ ឋានជាទីតាំងឋិតនៅនៃចុតិចិត្ត ១ ត្រូវជាឋានទាំង ១០ ដូចសេចក្តីអធិប្បាយតទៅនេះ ។ ទី ១- ឋានជាទីតាំងនៃបដិសន្ធិចិត្ត ឋិតនៅក្នុងរវាងជាចន្លោះនៃចុតិកិច្ចនិងភវង្គកិច្ច ។ ទី ២- ឋានជាទីតាំងនៃភវង្គចិត្ត ឋិតនៅក្នុងរវាងជាចន្លោះនៃបដិសន្ធិកិច្ចនិងអាវជ្ជនកិច្ចក៏មានខ្លះ ជាចន្លោះនៃជវនកិច្ចនិងអាវជ្ជនកិច្ចក៏មានខ្លះ ជាចន្លោះនៃតទារម្មណកិច្ចនិងអាវជ្ជនកិច្ចក៏មានខ្លះ ជាចន្លោះនៃវោដ្ឋ-ព្វនកិច្ចនិងអាវជ្ជនកិច្ចក៏មានខ្លះ ជាចន្លោះនៃជវនកិច្ចនិងចុតិកិច្ច ក៏មានខ្លះ ជាចន្លោះនៃតទារម្មណកិច្ចនិងចុតិកិច្ចក៏មានខ្លះ ។ ទី ៣- ឋានជាទីតាំងនៃអាវជ្ជនចិត្ត ឋិតនៅក្នុងរវាងជាចន្លោះនៃភវង្គកិច្ចនិងបញ្ចវិញ្ញាណ ។ ទី ៤- ឋានជាទីតាំងនៃបញ្ចវិញ្ញាណ ឋិតនៅក្នុងរវាងជាចន្លោះនៃបញ្ច-ទ្វារាវជ្ជនកិច្ចនិងសម្បដិច្ឆន្នកិច្ច ។ ទី ៥- ឋានជាទីតាំងនៃសម្បដិច្ឆន្ន-ចិត្ត ឋិតនៅក្នុងរវាងជាចន្លោះនៃបញ្ចវិញ្ញាណនិងសន្តីរណកិច្ច ។ ទី ៦- ឋានជាទីតាំងនៃសន្តីរណចិត្ត ឋិតនៅក្នុងរវាងជាចន្លោះនៃសម្បដិច្ឆន្នកិច្ចនិងវោដ្ឋព្វនកិច្ច ។ ទី ៧- ឋានជាទីតាំងនៃវោដ្ឋព្វនចិត្ត ឋិតនៅក្នុង

វាងជាចន្លោះនៃសន្តីរណកិច្ចនិងជវនកិច្ចក៏មានខ្លះ ជាចន្លោះនៃសន្តីរណ-កិច្ចនិងភវង្គកិច្ចក៏មានខ្លះ ។ ទី ៨- ឋានជាទីតាំងនៃជវនចិត្ត ឋិតនៅក្នុងវាងជាចន្លោះនៃវោដ្ឋព្វនកិច្ចនិងតទារម្មណកិច្ចក៏មានខ្លះ ជាចន្លោះនៃវោដ្ឋព្វនកិច្ចនិងភវង្គកិច្ចក៏មានខ្លះ ជាចន្លោះនៃវោដ្ឋព្វនកិច្ចនិងចុតិកិច្ចក៏មានខ្លះ ជាចន្លោះនៃមនោទ្វារាវជ្ជនកិច្ចនិងតទារម្មណកិច្ចក៏មានខ្លះ ជាចន្លោះនៃមនោទ្វារាវជ្ជនកិច្ចនិងភវង្គកិច្ចក៏មានខ្លះ ជាចន្លោះនៃមនោ-ទ្វារាវជ្ជនកិច្ចនិងចុតិកិច្ចក៏មានខ្លះ ។ ទី ៩- ឋានជាទីតាំងនៃតទា-រម្មណចិត្ត ឋិតនៅក្នុងវាងជាចន្លោះនៃជវនកិច្ចនិងភវង្គកិច្ចក៏មានខ្លះ ជាចន្លោះនៃជវនកិច្ចនិងចុតិកិច្ចក៏មានខ្លះ ។ ទី ១០- ឋានជាទីតាំងនៃចុតិ-ចិត្ត ឋិតនៅក្នុងវាងជាចន្លោះនៃជវនកិច្ចនិងបដិសន្ធិកិច្ចក៏មានខ្លះ ជាចន្លោះនៃតទារម្មណកិច្ចនិងបដិសន្ធិកិច្ច ក៏មានខ្លះ ជាចន្លោះនៃភវង្គកិច្ចនិងបដិសន្ធិកិច្ច ក៏មានខ្លះ ឯឋានរបស់បដិសន្ធិចិត្ត បញ្ចវិញ្ញាណ សម្បដិច្ឆន្នចិត្ត សន្តីរណចិត្ត មានឋានតែមួយៗ ឋានរបស់អាវជ្ជនចិត្ត វោដ្ឋព្វនចិត្ត តទារម្មណចិត្ត មានឋានពីរៗ, ឋានរបស់ចុតិចិត្តមានឋានបីៗ, ឋានរបស់ភវង្គចិត្ត ជវនចិត្ត មានឋានប្រាំមួយៗ ដូចគ្នា ។ វិសជ្ជនាមកអំពីឋានទាំង ១០ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៨២- ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា: ម្នាលអត្ថ-វាទី ចុះក្នុងទ្វារសង្គហៈ ព្រះសព្វញ្ញូសម្ពុទ្ធ ជាម្ចាស់ទ្រង់ត្រាស់សម្តែង អំពីទ្វារមានប៉ុន្មាន? គឺទ្វារអ្វីខ្លះ? វីថិចិត្តទាំងឡាយដែលកើតឡើងក្នុង ទ្វារមួយៗ ផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនា មកយើងនឹងបាន ស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះសក្យមុនីជាម្ចាស់ ទ្រង់ត្រាស់សម្តែង អំពីទ្វារមាន ៦ គឺចក្ខុប្បសាទ ឲ្យឈ្មោះថា ចក្ខុទ្វារ ១ សោតប្បសាទ ឲ្យឈ្មោះថា សោតទ្វារ ១ ឃានប្បសាទ ឲ្យឈ្មោះថា ឃានទ្វារ ១ ជិវ្ហាបសាទ ឲ្យឈ្មោះថា ជិវ្ហាទ្វារ ១ កាយប្បសាទ ឲ្យ ឈ្មោះថា កាយទ្វារ ១ ភវង្គចិត្ត ឲ្យឈ្មោះថា មនោទ្វារ ១ ព្រោះ ថាបសាទទាំង ៥ និងភវង្គចិត្តនេះ ជាប្រធានតែងប្រព្រឹត្តត្រាច់ទៅមកនៃ វីថិចិត្តទាំងឡាយដោយពិត ។ ឯវីថិចិត្តដែលកើតឡើង ប្រកបព្រម ក្នុងទ្វារទាំងនោះ នឹងមិនប្រកបព្រមរួចផុតស្រឡះចាកទ្វារទាំងនោះ ដូចមានសេចក្តីតទៅនេះ ។ ទី ១- វីថិចិត្តទាំង ៣៦ គឺវិញ្ញាណ ១០ មហគ្គតកុសលជវន ៩ មហគ្គតកិរិយាជវន ៩ លោកុត្តរចិត្ត ៨ ត្រូវជា ៣៦ ប្រកបកើតព្រមត្រាច់ទៅក្នុងទ្វារមួយៗ ដោយពិត ។ ទី ២- មនោ-

ធាតុទាំង ៣ គឺកិរិយាមនោធាតុ ១ វិបាកមនោធាតុ ១ វិបាកមនោ-វិញ្ញាណធាតុ ១ ត្រូវជាមនោធាតុ ៣ ប្រកបកើតព្រមត្រាច់ទៅក្នុងទ្វារទាំង ៥ ដោយពិត ។ ទី ៣- វីថិចិត្តទាំង ៣១ គឺសុខ-សន្តីរណ ១ វោដ្ឋពូន ១ កាមាវចរអកុសលជវន ១២ កាមាវចរ-កុសលជវន ៨ កាមាវចរកិរិយាជវន ៨ អហេតុកហសិតកិរិយាជវន ១ ត្រូវជា ៣១ ប្រកបកើតព្រមត្រាច់ទៅក្នុងទ្វារទាំង ៦ ដោយពិត ។ ទី ៤- វីថិចិត្តទាំង ១០ គឺឧបេក្ខាសហគតសន្តីរណចិត្ត ២ មហា-វិបាកចិត្ត ៨ ត្រូវជា ១០ ប្រកបកើតព្រមត្រាច់ទៅក្នុងទ្វារទាំង ៦ ខ្លះ រួចផុតស្រឡះចាកទ្វារទាំង ៦ ខ្លះ ។ ទី ៥- មហគ្គតវិបាកចិត្ត ទាំង ៩ ជាវីថិចិត្តរួចផុតចាកទ្វារទាំងអស់ ដោយបដិសន្ធិកិច្ច ភវង្គកិច្ច-ចុតិកិច្ច ដោយពិត ។ វិសជ្ជនាមកអំពីទ្វារទាំង ៦ និងវីថិចិត្តដែលប្រកប កើតព្រមក្នុងទ្វារនោះៗ នឹងរួចផុតស្រឡះចាកទ្វារនោះៗ ដោយសេចក្តី សង្ខេបតែប៉ុណ្ណោះឯង ។

៨៣- ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា ម្នាល អត្តវាទី ចុះក្នុងអារម្មណសង្គហៈ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ សម្តែងចែកជាអារម្មណ៍មានប៉ុន្មាន? គឺអារម្មណ៍អ្វីខ្លះ? ប្រកបដោយកាល

មានប៉ុន្មាន? គឺកាលអ្វីខ្លះ? សេចក្តីយ៉ាងណាខ្លះ? មានខណៈចិត្តតិចច្រើនកើនឡើងដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី សម្តេចព្រះមុនីនាថ ជាម្ចាស់ទ្រង់ត្រាស់សម្តែងចែកជាអារម្មណ៍មាន ៦ គឺ រូបារម្មណំ អារម្មណ៍គឺរូប ១ សទ្ទារម្មណំ អារម្មណ៍គឺសំឡេង ១ គន្ធារម្មណំ អារម្មណ៍គឺក្លិនផ្សេងៗ ១ រសារម្មណំ អារម្មណ៍គឺរសឆ្ងាញ់ផ្សេងៗ ១ ផោដ្ឋព្វារម្មណំ អារម្មណ៍គឺសម្ផស្សផ្សាយផ្សព្វមកប៉ះពាល់ត្រូវកាយ ១ ធម្មារម្មណំ អារម្មណ៍គឺសភាវធម៌ដែលជាពាក្យប្រដៅល្អរបស់អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធោវាទជាដើម ដែលខ្លួនបានសិក្សារៀនសូត្រទ្រទ្រង់ចំណាំចាំទុកក្នុងចិត្ត ១ ត្រូវជាអារម្មណ៍ទាំង ៦ ដោយពិត ។ អារម្មណ៍នេះប្រកបដោយកាលមាន ៦ គឺ អតីតកាលារម្មណំ អារម្មណ៍ដែលប្រព្រឹត្តកន្លងទៅជាអតីតកាល ១ បច្ចុប្បន្នកាលារម្មណំ អារម្មណ៍ដែលកើតមានក្នុងបច្ចុប្បន្នកាលនេះ ១ អនាគតកាលារម្មណំ អារម្មណ៍ដែលនឹងមានទៅក្នុងអនាគតកាល ១ អតីត-

កាលវិមុត្តារម្មណំ *អារម្មណ៍ដែលរួចផុតស្រឡះ ចាកអតីតកាល* ១ បច្ចុប្បន្នកាលវិមុត្តារម្មណំ *អារម្មណ៍ដែលរួចផុតស្រឡះចាកបច្ចុប្បន្នកាល* ១ អនាគតកាលវិមុត្តារម្មណំ *អារម្មណ៍ដែលរួចផុតស្រឡះចាកអនាគតកាល ១ ត្រូវជា ៦ តែងកើតឡើងប្រាកដដល់វីថិចិត្តទាំងឡាយដោយសមគួរដល់ជវន មានកាមាវចរជវន និងអ-ភិញ្ញាជវន និងមហគ្គតជវនជាដើម តែជាត្រូវវៀរលែងហសិតុប្បាទ-ចិត្តចេញ, ឯកាមាវចរជវនទាំងឡាយ មានអារម្មណ៍ប្រកបដោយកាល ៦ គឺកាលទាំង ៣ ខ្លះ រួចស្រឡះចាកកាលទាំង ៣ ខ្លះ, ឯហសិតុប្បាទចិត្តមានអារម្មណ៍ប្រកបដោយកាលទាំង ៣ តែម៉្យាងពិត ។ អភិញ្ញាជវន ដែលប្រព្រឹត្តទៅដោយអំណាចទិព្វ មានទិព្វចក្ខុជាដើម មានអារម្មណ៍ប្រកបដោយកាលទាំង ៣ ខ្លះ រួចផុតស្រឡះចាកកាលទាំង ៣ ខ្លះ មហគ្គតជវននិងលោកុត្តរជវនដ៏វិសេសមានអារម្មណ៍រួចផុតស្រឡះចាកអតីតកាលតែម៉្យាងពិត ។ ម៉្យាងទៀតអារម្មណ៍ទាំង ៥ មានរូបារម្មណ៍ជាដើម របស់បដិសន្ធិចិត្តនិងភវង្គចិត្តជាកាមាវចរជវន ដែលមរណាសន្នជវនបានកាន់យក ប្រព្រឹត្តទៅក្នុងទ្វារទាំង ៦ ជាអារម្មណ៍គឺបណ្ឌិតកំណត់ថា កម្មនិមិត្តជាបច្ចុប្បន្នខ្លះ ជា*

អតីតខ្លះដោយពិត, ឯអារម្មណ៍ទាំង ៥ មានរូបារម្មណ៍ជាដើម របស់ចុតិចិត្ត ជាកាមាវចរជវន ជាអារម្មណ៍គឺបណ្ឌិតកំណត់ថា កម្មនិមិត្ត ជាអតីតកាលតែម្យ៉ាងពិត ។ ក៏អារម្មណ៍ដែលបណ្ឌិតកំណត់ថាកម្មនិមិត្ត ជាបច្ចុប្បន្នខ្លះ ជាអតីតខ្លះ ប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ នោះដូចអធិប្បាយតទៅនេះ សេចក្ដីថា បុគ្គលឯណាមួយដែលមានជំងឺឈឺជាទម្ងន់ ដេកនៅលើមរណមញ្ចាសនៈ អាសនៈគ្រែសម្រាប់ស្លាប់ ហើយបានឃើញអារម្មណ៍ទាំង ៥ មានរូបទង់ជាយទង់ជ្រុងព្រមទាំងគ្រឿងសក្ការបូជាផ្សេងៗ ជាដើម ដែលញាតិសាច់សាលោហិតព្រមទាំងមិត្រសំឡាញ់ទាំងឡាយនាំមកតាក់តែងឲ្យដើម្បីបូជា នឹករឭកចំពោះគុណព្រះរតនត្រ័យជាកុសល ឯបុគ្គលដែលមានជំងឺឈឺជាទម្ងន់នោះបានឃើញគ្រឿងសក្ការបូជាទាំងនោះហើយ ក៏មានកវេគ្គចិត្តជាកាមាវចរកុសលកើតឡើងចាប់យកអារម្មណ៍ មានរូបជាដើមនោះមកជាទីត្រេកអរ បើខណចិត្តទាំង ១៧ ខណៈ កើតឡើងព្រមតាំងអំពីអតីតភវង្គចិត្តក្ខណៈនោះដរាបដល់បដិសន្ធិចិត្តក្ខណៈជាគម្រប់ ១៧ ខណៈពេញបរិបូណ៌ ក៏អារម្មណ៍ទាំង ៥ មានរូបជាដើមនោះ ជាអារម្មណ៍របស់បដិសន្ធិចិត្ត គឺបណ្ឌិតកំណត់ថា កម្មនិមិត្ត ជាបច្ចុប្បន្នតែម្យ៉ាងពិត, ចំណែកឯអារម្មណ៍របស់

ភវង្គចិត្តដែលកើតឡើងជាខាងនាយ អំពីបដិសន្ធិចិត្តនោះ ជាអារម្មណ៍ គឺបណ្ឌិតកំណត់ថាកម្មនិមិត្តជាអតីតតែម្យ៉ាងពិត, បើខណៈចិត្តកើតឡើង មិនគ្រប់ ១៧ ខណៈចិត្តនោះទេ បញ្ចារម្មណ៍មានរូបជាដើមជារបស់ បដិសន្ធិចិត្តនិងភវង្គចិត្តទាំងឡាយនោះ ជាអារម្មណ៍គឺបណ្ឌិតកំណត់ថា ជាកម្មនិមិត្តជាបច្ចុប្បន្នតែម្យ៉ាងពិត, បើខណៈចិត្តកើតឡើងច្រើនជាង ១៧ ខណៈចិត្តនោះ បញ្ចារម្មណ៍មានរូបជាដើមជារបស់បដិសន្ធិចិត្តនិងភវង្គចិត្ត នោះជាអារម្មណ៍ គឺបណ្ឌិតកំណត់ថា កម្មនិមិត្ត ជាអតីតតែម្យ៉ាងពិត ។

ក្នុងមហន្តារម្មណៈ អារម្មណ៍មានខណៈចិត្តច្រើន ពេញបរិបូណ៌ នោះមាន ១៨ ខណៈចិត្ត គឺអតីតភវង្គៈ ៣ ភវង្គចលនៈ ១ ភវង្គុ-បច្ឆេទៈ ១ បញ្ចទ្វារាវជ្ជនៈ ១ បញ្ចវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តី-រណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ៥ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៨ គត់ ក៏វីថិចិត្តកើតឡើងមានខណចិត្តពេញបរិបូណ៌យ៉ាងនេះ បញ្ចារម្មណ៍មានរូបជាដើមជារបស់បដិសន្ធិចិត្តនោះជាបច្ចុប្បន្ន ឯអារម្មណ៍ របស់ភវង្គចិត្តគឺបណ្ឌិតកំណត់ថា កម្មនិមិត្ត ជាអតីតតែម្យ៉ាងពិត ។

អារម្មណ៍មានខណចិត្តច្រើនដែរ តែខ្វះមិនពេញបរិបូណ៌នោះ មាន ១៦ ខណចិត្តគឺអតីតភវង្គៈ ១ ភវង្គចលនៈ ១ ភវង្គុបច្ឆេទៈ ១ បញ្ចទ្វា-

រាវជ្ជនៈ ១ បញ្ចវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ៥ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៦ គត់ ក៏វីថិចិត្តកើតឡើងមានខណចិត្តខ្វះយ៉ាងនេះ បញ្ចារម្មណ៍មានរូបជាដើម ជារបស់បដិសន្ធិចិត្តនិងភវង្គចិត្តនោះ ជាអារម្មណ៍គឺបណ្ឌិតកំណត់ថា កម្មនិមិត្ត ជាបច្ចុប្បន្នតែម្យ៉ាងពិត ។ ខណចិត្តកើតឡើងដ៏ច្រើនក្រៃលែង នោះមានខណចិត្ត ១៩ គឺអតីតភវង្គ ៣ ភវង្គចលនៈ ១ ភវង្គុបច្ឆេទៈ ១ បញ្ចទ្វារាវជ្ជនៈ ១ បញ្ចវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ៥ ភវង្គៈ ១ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គ-ចិត្ត ១ ត្រូវជា ១៩ គត់ ក៏វីថិចិត្តកើតឡើងមានខណចិត្តច្រើនយ៉ាងនេះ បញ្ចារម្មណ៍មានរូបជាដើមជារបស់បដិសន្ធិចិត្ត និងភវង្គចិត្តទាំងឡាយ នោះជាអារម្មណ៍ គឺបណ្ឌិតកំណត់ថា កម្មនិមិត្តជាអតីតតែម្យ៉ាងពិត ។

ក្នុងអតិមហន្តារម្មណ៍ អារម្មណ៍មានខណចិត្តច្រើនខ្លាំងនោះ មាន ២ យ៉ាងគឺ ទី ១- អារម្មណ៍មានខណចិត្ត ១៨ គឺអតីតភវង្គៈ ១ ភវង្គ-ចលនៈ ១ ភវង្គុបច្ឆេទៈ ១ បញ្ចទ្វារាវជ្ជនៈ ១ បញ្ចវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ៥ តទារម្មណៈ ២ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៨ គត់ ក៏វីថិចិត្ត

កើតឡើងមានខណចិត្តកើតច្រើនខ្ទង់យ៉ាងនេះ បញ្ចារម្មណ៍មានរូបជាដើមជារបស់បដិសន្ធិចិត្ត ជាអារម្មណ៍គឺបណ្ឌិតកំណត់ថា កម្មនិមិត្តជាបច្ចុប្បន្នពិត, អារម្មណ៍ជារបស់ភវង្គចិត្ត ជាអារម្មណ៍គឺបណ្ឌិតកំណត់ថា កម្មនិមិត្តជាអតីតដោយពិត ។ ទី ២- អារម្មណ៍មានខណចិត្ត ១៩ គឺអតីតភវង្គៈ ១ ភវង្គចលនៈ ១ ភវង្គុប្បច្ឆេទៈ ១ បញ្ចទ្វារាវជ្ជនៈ ១ បញ្ចវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ៥ តទារម្មណៈ ២ ភវង្គ ១ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៩ គត់ ក៏វីថិចិត្តកើតឡើងមានខណចិត្តច្រើនខ្ទង់ដ៏ក្រៃលែងយ៉ាងនេះ បញ្ចារម្មណ៍មានរូបជាដើម ជារបស់បដិសន្ធិចិត្ត និងភវង្គ-ចិត្តទាំងឡាយនោះ ជាអារម្មណ៍គឺបណ្ឌិតកំណត់ថា កម្មនិមិត្តជាអតីតតែម្យ៉ាងពិត ។ សេចក្តីអធិប្បាយថា បណ្តាអារម្មណ៍ទាំង ៥ នោះ អារម្មណ៍ឯណាគឺបណ្ឌិតកំណត់ថា កម្មនិមិត្តរបស់បដិសន្ធិចិត្តខាងដើម អារម្មណ៍នោះឯង បានឈ្មោះថា ជាអារម្មណ៍របស់ចុតិចិត្តដោយពិត ។ ព្រោះហេតុនោះ អារម្មណ៍ទាំង ៦ មានរូបជាដើម បានឈ្មោះថា ជាអា-រម្មណ៍របស់ចុតិចិត្តទាំងអស់ជាអតីតតែម្យ៉ាងពិត ។ តែថាក្នុងដីកាអភិ-ធម្មត្ថសង្គហៈ លោកពន្យល់ថា ធម្មារម្មណ៍ដែលមរណាសន្នជវន គឺ

ជវនជិតស្លាប់ កាន់យកប្រព្រឹត្តទៅក្នុងមនោទ្វារជាអារម្មណ៍របស់ចុតិចិត្ត បដិសន្ធិចិត្ត ភវង្គចិត្តទាំងឡាយជាកាមាវចរវិបាក គឺបណ្ឌិតកំណត់ជា កម្មារម្មណ៍ ជាកម្មនិមិត្តជាអតីតតែម៉្យាងពិត ។ ឯចំណែករូបារម្មណ៍ មួយដែលមរណាសន្នជវន កាន់យកប្រព្រឹត្តទៅក្នុងមនោទ្វារជាអារម្មណ៍ របស់ចុតិចិត្ត បដិសន្ធិចិត្ត ភវង្គចិត្តទាំងឡាយជាកាមាវចរវិបាក គឺបណ្ឌិត កំណត់ថា គតិនិមិត្ត ជាបច្ចុប្បន្នដោយចំណែកមួយពិត ។ ឯវីថិចិត្ត ប្រព្រឹត្តទៅក្នុងមនោទ្វារមាន ខណចិត្តតិច ច្រើនដូចមានសេចក្តីអធិប្បាយ តទៅនេះ ទី ១- អវិភូតារម្មណ៍ វីថិចិត្តកើតឡើងក្នុងអារម្មណ៍ដែល មិនបានប្រាកដ មានខណចិត្តយ៉ាងតិច ១២ គឺភវង្គៈ ១ ភវង្គចលនៈ ១ ភវង្គុប្បច្ឆេទៈ មនោទ្វារាវជ្ជនៈ ១ ជវនៈ ៥ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១២ គត់ មានខណចិត្តយ៉ាងច្រើន ១៣ គឺភវង្គៈ ១ ភវង្គចលនៈ ១ ភវង្គុប្បច្ឆេទៈ ២ មនោទ្វារាវជ្ជនៈ ១ ជវនៈ ៥ ភវង្គៈ ១ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៣ គត់ ។ ទី ២- វិភូតារម្មណ៍ វីថិចិត្តកើតឡើង ក្នុងអារម្មណ៍ដែលកើតឡើងប្រាកដ មានខណចិត្តយ៉ាងតិច ១៣ គឺភវង្គៈ ១ ភវង្គចលនៈ ១ ភវង្គុប្បច្ឆេទៈ ១ មនោទ្វារាវជ្ជនៈ ១ ជវនៈ ៥ តទាលម្ពណៈ ១ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១

ភវង្គចិត្ត ១ ត្រូវជា ១៣ គត់ មានខណចិត្តយ៉ាងច្រើន ១៤ គឺ ភវង្គចលនៈ ១ ភវង្គុបច្ឆេទៈ ១ មនោទ្វារាវជ្ជនៈ ១ ជវនៈ ៥ តទាលម្ពណៈ ២ ភវង្គៈ ១ ចុតិចិត្ត ១ បដិសន្ធិចិត្ត ១ ភវង្គចិត្ត ១ ត្រូវជា ១៤ គត់ ។

សេចក្តីពន្យល់ថា អារម្មណ៍ទាំង ៦ ជាអារម្មណ៍របស់វីថិចិត្តទាំងឡាយដែលប្រព្រឹត្តទៅក្នុងមនោទ្វារ ជាអារម្មណ៍កើតឡើងប្រាកដក្នុងខណៈដែលភវង្គចលនចិត្ត ជាបឋមកើតឡើងដោយពិត អធិប្បាយថាៈ បុគ្គលឯណាមួយ ប្រព្រឹត្តធ្វើអំពើបាបលាមក នឹងច្យុតទៅកើតក្នុងនរកឯរូបារម្មណ៍ មានអណ្តាតភ្លើងនរកជាដើម ជាទុគ្គតិនិមិត្តដល់បុគ្គលនោះ កើតឡើងប្រាកដក្នុងមនោទ្វារជាបច្ចុប្បន្នដោយចំណែកមួយពិត ។ បុគ្គលឯណាមួយប្រព្រឹត្តធ្វើអំពើល្អជាកុសល មានឲ្យទានរក្សាសីលជាដើម នឹងច្យុតទៅកើតក្នុងកាមាវចរទេវលោក ឯរូបារម្មណ៍មានដើមកប្បព្រឹក្ស និងវិមានជាដើម ជាសុគតិនិមិត្តដល់បុគ្គលនោះ កើតឡើងប្រាកដក្នុងមនោទ្វារជាបច្ចុប្បន្នដោយចំណែកមួយពិត ។ ក៏អារម្មណ៍ទាំង ៦ របស់សត្វទាំងឡាយ មានកាមាវចរបដិសន្ធិសត្វជាដើម ដែលមរណាសន្នជវនៈកាន់យកក្នុងទ្វារទាំង ៦ ប្រព្រឹត្តទៅតាមសភាពពិត ជាបច្ចុប្បន្នខ្លះ ជាអតីតខ្លះ ដែលបណ្ឌិតកំណត់ថា កម្មនិមិត្តនិងគតិនិមិត្ត ដូចន័យដែល

បានអធិប្បាយមកយ៉ាងនេះឯង ។ ចំណែកធម្មារម្មណ៍របស់សត្វទាំងឡាយ ជារូបាវចរបដិសន្ធិក្តី ជាបឋមារូបាវចរបដិសន្ធិនិងតតិយារូបាវចរបដិសន្ធិក្តី ដែលមរណាសន្នជវនៈ កាន់យកក្នុងមនោទ្វារ គឺបណ្ឌិតកំណត់ថា កម្មនិមិត្ត កើតតាមបញ្ញត្តិជាអតីតតែម្យ៉ាងពិត, ឯធម្មារម្មណ៍របស់សត្វជារូបាវចរបដិសន្ធិទី ២ ទី ៤ ជាកម្មនិមិត្ត ជាអតីតារម្មណ៍ដូចគ្នាដែរ ។ វិសជ្ជនាមកក្នុងអារម្មណសង្គហៈ ជាសេចក្តីសង្ខេបតែប៉ុណ្ណេះ ។

៨៤- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវាទី ប្រស្នាដែលលោកវិសជ្ជនាមកនេះប្រពៃហើយ តែយើងនៅមានសង្ស័យអំពីវត្ថុនិងវិញ្ញាណធាតុតទៅទៀត ចុះវត្ថុមានប៉ុន្មាន? គឺវត្ថុអ្វីខ្លះ? វិញ្ញាណធាតុមានប៉ុន្មាន? គឺវិញ្ញាណធាតុអ្វីខ្លះ? វិញ្ញាណធាតុទាំងអស់នោះទៀត កើតឡើងអាស្រ័យនូវវត្ថុផ្សេងៗគ្នា ដោយភពទាំង ៣ ដូចម្តេចខ្លះ?

អត្ថវាទី វិសជ្ជនាតបថាៈ បពិត្រធម្មវាទី តាមន័យបរមត្ថព្រះអភិធម្ម ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងថា វត្ថុមាន ៦ គឺ ទីកន្លែងសម្រាប់ជ្រះថ្លា ត្រេកអរនូវរូបារម្មណ៍ដោយភ្នែកឃើញរូបផ្សេងៗ

បានឈ្មោះថា ចក្ខុវត្ថុ ១ ទីកន្លែងសម្រាប់ជ្រះថ្លាត្រេកអរនូវសទ្ទារម្មណ៍ ដោយត្រចៀកស្តាប់សំឡេងផ្សេងៗ បានឈ្មោះថា សោតវត្ថុ ១ ទីកន្លែងសម្រាប់ជ្រះថ្លាត្រេកអរនូវគន្ធារម្មណ៍ ដោយច្រមុះស្រង់ក្លិនផ្សេងៗ បានឈ្មោះថា ឃានវត្ថុ ១ ទីកន្លែងសម្រាប់ជ្រះថ្លាត្រេកអរនូវរសារម្មណ៍ ដោយអណ្តាតស្រូបក្លក់រសឆ្ងាញ់ផ្សេងៗ បានឈ្មោះថា ជិវ្ហាវត្ថុ ១ ទីកន្លែងសម្រាប់ជ្រះថ្លាត្រេកអរនូវផោដ្ឋព្វារម្មណ៍ ដោយកាយប៉ះពាល់នូវរូបារម្មណ៍ផ្សេងៗ បានឈ្មោះថា កាយវត្ថុ ១ ទីកន្លែងសម្រាប់កើតឡើងនៃធម្មារម្មណ៍ ដោយបេះដូង ជាទីលំនៅរបស់មនោធាតុ តែងឱនទៅកាន់ធម្មារម្មណ៍ផ្សេងៗ បានឈ្មោះថា ហទយវត្ថុ ១ ត្រូវជាវត្ថុ ៦ ពិត ។ ធម្មជាតិ សម្រាប់ដឹងច្បាស់នូវអារម្មណ៍ផ្សេងៗ គ្រាន់តែជាធាតុទ្រទ្រង់នៅក្នុងគុហាគឺមហាភូតរូបទាំង ៤ មិនមែនសត្វ មិនមែនជីវិត សម្រាប់សូន្យសោះទៅវិញជាធម្មតា បានឈ្មោះថា វិញ្ញាណធាតុមាន ៧ គឺចក្ខុវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវចក្ខុវត្ថុហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ១ សោតវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវសោតវត្ថុ ហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ១ ឃានវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវឃានវត្ថុហើយប្រព្រឹត្តទៅ

គ្រាន់តែជាធាតុ ១ ជិវ្ហាវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវជិវ្ហាវត្ថុហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ១ កាយវិញ្ញាណធាតុ វិញ្ញាណអាស្រ័យនូវកាយវត្ថុហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ១ មនោធាតុ ចិត្តសម្រាប់ទទួលដឹងច្បាស់នូវធម្មារម្មណ៍អាស្រ័យនូវហទយវត្ថុ ហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ១ មនោវិញ្ញាណធាតុ ចិត្តសម្រាប់ឱនទៅកាន់អារម្មណ៍ដឹងច្បាស់នូវអារម្មណ៍ផ្សេងៗ អាស្រ័យនូវហទយវត្ថុខ្លះ មិនបានអាស្រ័យនូវហទយវត្ថុខ្លះ ហើយប្រព្រឹត្តទៅគ្រាន់តែជាធាតុ ១ ត្រូវជាវិញ្ញាណធាតុទាំង ៧ ពិត ។ ឯវិញ្ញាណធាតុទាំង ៧ ដែលអាស្រ័យនូវវត្ថុផ្សេងៗ ក្នុងភពទាំង ៣ នោះ ដូចអធិប្បាយតទៅនេះ ក៏ក្នុងកាមភព វិញ្ញាណធាតុទាំង ៧ នេះ តែងអាស្រ័យនូវវត្ថុទាំង ៦ ដោយពិត ក្នុងរូបភពមានតែវិញ្ញាណធាតុ ៤ គឺចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ តែងអាស្រ័យនូវវត្ថុទាំង ៣ គឺចក្ខុវត្ថុ ១ សោតវត្ថុ ១ ហទយវត្ថុ ១ ដោយពិត ក្នុងអរូបភព មានតែមនោវិញ្ញាណធាតុ ១ ពុំបានអាស្រ័យនូវវត្ថុអ្វីឡើយ មានចិត្តជាអាយតនៈដោយពិត ។ វិសជ្ជនាមកអំពីវត្ថុ និងវិញ្ញាណធាតុជាសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៨៥- ធម្មវាទី បានស្តាប់ហើយ សួរក្នុងវិសយប្បវត្តិសង្គហៈតទៅទៀតថាៈ ម្នាលអត្តវាទី ចុះក្នុងវិសយប្បវត្តិសង្គហៈ វីថិចិត្តដែលត្រាច់ទៅមកក្នុងទ្វារទាំង ៦ នោះមានឈ្មោះដូចម្តេច? គឺវីថិចិត្តអ្វី? សេចក្តីអធិប្បាយ ថាដូចម្តេចខ្លះ?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី វីថិចិត្តដែលត្រាច់ទៅមកក្នុងទ្វារទាំង ៦ នោះមាន ៦ គឺវីថិចិត្តសម្រាប់ត្រាច់ទៅមកក្នុងចក្ខុទ្វារ បានឈ្មោះថា ចក្ខុទ្វារវីថិ ១ វីថិចិត្តសម្រាប់ត្រាច់ទៅមកក្នុងសោតទ្វារ បានឈ្មោះថា សោតទ្វារវីថិ ១ វីថិចិត្តសម្រាប់ត្រាច់ទៅមកក្នុងឃានទ្វារ បានឈ្មោះថា ឃានទ្វារវីថិ ១ វីថិចិត្តសម្រាប់ត្រាច់ទៅមកក្នុងជិវ្ហាទ្វារ បានឈ្មោះថា ជិវ្ហាទ្វារវីថិ ១ វីថិចិត្តសម្រាប់ត្រាច់ទៅមកក្នុងកាយទ្វារ បានឈ្មោះថា កាយទ្វារវីថិ ១ វីថិចិត្តសម្រាប់ត្រាច់ទៅមកក្នុងមនោទ្វារ បានឈ្មោះថា មនោទ្វារវីថិ ១ ត្រូវជា ៦ យ៉ាងដោយពិត ។

៨៦- ធម្មវាទី បានស្តាប់ហើយ សួរតទៅទៀតថា ម្នាលអត្តវាទី ចុះអារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ មានឈ្មោះផ្សេងគ្នា ប៉ុន្មាន? គឺឈ្មោះអ្វីខ្លះ? អារម្មណ៍ដែលប្រព្រឹត្តទៅក្នុងមនោទ្វារមានឈ្មោះផ្សេងគ្នា

ប៉ុន្មាន? គឺឈ្មោះអ្វីខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី អារម្មណ៍ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ មានឈ្មោះ ៤ គឺអតិមហន្តារម្មណ៍ ១ មហន្តារម្មណ៍ ១ បរិត្តារម្មណ៍ ១ អតិបរិត្តារម្មណ៍ ១ អារម្មណ៍ដែលប្រព្រឹត្តទៅក្នុងមនោទ្វារមានឈ្មោះ ២ គឺវិភូតារម្មណ៍ ១ អវិភូតារម្មណ៍ ១ ត្រូវជាឈ្មោះ ៦ ដោយពិត ។

៨៧- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា: ម្នាលអត្ថវាទី ចុះខណចិត្តធំទាំង ១៧ គឺខណចិត្តអ្វីខ្លះ? ក្នុងខណចិត្តធំមួយៗ មានខណចិត្តតូច ៣ ៗ ដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាព្រមទាំងសេចក្តីឧបមាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា: បពិត្រធម្មវាទី ឯខណចិត្តធំទាំង ១៧ នោះគឺ អតីតភវង្គ: ១ ភវង្គចលនៈ ១ ភវង្គុបច្ឆេទ: ១ បញ្ចទ្វារាវជ្ជន: ១ ចក្ខុវិញ្ញាណ: ១ សម្បដិច្ឆន្ន: ១ សន្តីរណ: ១ វោដ្ឋព្វន: ១ ជវន: ៧ តទាលម្ពណ: ២ ត្រូវជា ១៧ ដូចមានសេចក្តីអធិប្បាយមកក្នុងអហេតុកអកុសលវិបាកទាំង ៧ និងអហេតុកអកុសលវិបាកទាំង ៨

ជាខាងដើមមករូបហើយ បណ្ដាខណចិត្តធំទាំង ១៧ នេះ ខណចិត្តធំមួយៗ មានខណចិត្តតូច ៣ៗ ដូចគ្នាទាំងអស់គឺ ឧប្បាទ: វីថិចិត្តកើតឡើងមួយរំពេច ១ ឋិតិ វីថិចិត្តជួបប្រទះនឹងអារម្មណ៍ដែលចិត្តនឹងនៅក្នុងទ្វារនោះៗ មួយរំពេច ១ ភង្គ: វីថិចិត្តបែកចេញអំពីអារម្មណ៍ធ្លាក់ចុះមកកាន់ទីភវង្គៈវិញមួយរំពេច ១ ត្រូវជា ៣ ខណចិត្តតូច ឲ្យបែកយ៉ាងនេះដូចគ្នាទាំងអស់ បូករួមខណចិត្តធំទាំង ១៧ ត្រូវជាខណចិត្តតូច ៥១ គត់ ។

ម្យ៉ាងទៀត ខណចិត្តធំដែលពេញបរិបូណ៌យ៉ាងនេះ វីថិចិត្តដែលកើតឡើងទទួលនូវអារម្មណ៍មួយខណៈៗ នេះ តែងមានខណចិត្តធំមួយប្រព្រឹត្តកន្លងទៅជាអតីតភវង្គ ហើយមានខណចិត្តធំ ១៦ ជាអាយុរបស់រូបធម៌ទាំងឡាយពិត វៀរលែងតែវិញ្ញត្តិរូបពីរនិងលក្ខណៈរូប ៤ ចេញ ព្រោះវិញ្ញត្តិរូបទាំង ២ មានខណចិត្តមួយៗ ជាអាយុពិត ជាតិរូប ២ និងអនិច្ចតារូប ១ មានខណចិត្តមួយកើតឡើង ស្មើគ្នាដោយឧប្បាទខណៈនិងភង្គខណៈទាំងឡាយជាអាយុពិត, ចំណែកឯជរតារូប ១ មានខណចិត្ត ៤៩ ជាអាយុដោយពិត ។ មួយទៀត វីថិចិត្តទាំង ១៤ ដែលនឹងកើតឡើងក៏កើតឡើងតែដោយអំណាចនៃភវង្គចិត្តទាំងអស់ បើភវង្គ-

ចិត្តពុំបានកើតឡើងទេ វិថីចិត្តទាំងអស់ក៏កើតឡើងពុំបានឡើយ ដូចមានសេចក្តីពន្យល់ក្នុងយោជនា ព្រះអភិធម្មត្ថសង្គហៈថា: មានបុរសម្នាក់ បានយកសម្ពត់សាដកមកដណ្តប់ទទូរក្បាលដេកលក់ជិតគល់ស្វាយមានផ្លែមួយដើម លុះដល់មានផ្លែស្វាយទុំ ១ ជ្រុះមកក្នុងទីជិតខ្លួនហើយភ្ញាក់ឡើង ដោយសូរសន្ធឹកផ្លែស្វាយដែលជ្រុះមកនោះ ហើយយកដៃចាប់បកសំពត់ចេញអំពីក្បាលបើកភ្នែកសំឡឹងមើលផ្លែស្វាយ បានឃើញហើយក៏យកដៃចាប់យកផ្លែស្វាយទុំនោះមកច្របាច់មើល ហើយហិតស្រង់ក្លិន បានដឹងច្បាស់ថា ផ្លែស្វាយនោះជាផ្លែស្វាយទុំពិត ហើយបរិភោគលេបសាច់ស្វាយទុំ ដែលនៅក្នុងមាត់លាយដោយស្លេស្មចូលទៅក្នុងបំពង់កឋិតនៅក្នុងក្រពះបាយ ស្រេចហើយក៏ដេកលក់ទៅវិញក្នុងទីដដែលនោះឯង ។

សេចក្តីអធិប្បាយពន្យល់ថា កាលដែលវិថីចិត្តធ្លាក់ចុះមកកាន់ទីភវង្គដ្ឋានស៊ប់ស្ងួនហើយឋិតនៅស្ងៀម ដូចជាកាលដែលបុរសនោះដេកលក់ស៊ប់ស្ងួនដែរ កាលដែលអារម្មណ៍ចូលមកប៉ះខ្ទប់នឹងចក្ខុបសាទហើយញ័រដល់ភវង្គចិត្តនោះ ដូចជាកាលផ្លែស្វាយទុំជ្រុះចុះមកប៉ះខ្ទប់នឹងផែនដី ឮសូរសំឡេងប៉ះខ្ទប់នឹងត្រចៀកបុរសដែលដេកលក់នោះ

ដែរ កាលដែលអាវជ្ជនវីថិចិត្តកើតឡើងដោយអំណាចនៃភង្គៈ ហើយពិចារណាមើលនូវរូបារម្មណ៍ ថា រូបអ្វីនេះ ដូចជាកាលដែលបុរសនោះភ្ញាក់ឡើង ដោយសន្ទឹកសំឡេងផ្លែស្វាយប៉ះខ្ទប់នឹងសោតបសាទនោះដែរ កាលដែលចក្ខុវិញ្ញាណកើតឡើងប្រព្រឹត្តទៅសំឡឹងមើលដឹងច្បាស់នូវរូបារម្មណ៍ ដូចជាកាលដែលបុរសនោះបើកភ្នែកហើយក្រឡេករកមើលឃើញផ្លែស្វាយនោះជាក់ច្បាស់ដែរ កាលដែលសម្បដិច្ឆន្នវីថិចិត្តកើតឡើងហើយទទួលចាប់យក ព្រមនូវរូបារម្មណ៍ដូចជាកាលដែលបុរសនោះយកដៃលូកទៅចាប់ផ្លែស្វាយទុំនោះយកមកដែរ កាលដែលសន្តីរណាវីថិចិត្តកើតឡើងហើយត្រិះរិះរំពឹងគិតនូវរូបារម្មណ៍ ដូចជាកាលដែលបុរសនោះយកដៃចាប់ប្របាច់ផ្លែស្វាយទុំនោះដែរ កាលដែលវោដ្ឋព្វនវីថិចិត្តកើតឡើង ហើយកំណត់កត់សម្គាល់ នូវរូបារម្មណ៍ដឹងច្បាស់ទុកក្នុងចិត្ត ដូចជាកាលដែលបុរសនោះហិតស្រង់ក្លិនស្វាយទុំនោះ ដឹងច្បាស់ក្នុងចិត្តថា ផ្លែស្វាយនេះជាស្វាយទុំពិតមែន កាលដែលជវនវីថិចិត្តកើតឡើងហើយទទួលសោយនូវរសនៃអារម្មណ៍ ដូចជាកាលដែលបុរសនោះបរិភោគនូវសាច់ស្វាយទុំនោះដែរ កាលដែលតទាលម្ពណវីថិចិត្តកើតឡើង ហើយទទួលកាន់យកនូវរសនៃអារម្មណ៍ដែលជវនចិត្ត

សោយហើយនោះយកមកជាអារម្មណ៍ ដូចជាកាលដែលបុរសនោះលេបនូវសាច់ស្វាយទុំនៅក្នុងមាត់ ប្រឡាក់លាយដោយស្ទេស្មចូលទៅក្នុងបំពង់កនោះដែរ កាលដែលវីថិចិត្តធ្លាក់ចុះមកកាន់ទីភវង្គវិញស៊ប់ស្ងួនទៀត ដូចជាកាលដែលបុរសនោះដេកលក់ទៅវិញក្នុងទីនោះដដែលដោយពិត ។ ឯខណចិត្តទាំង ១៧ ពេញបរិបូណ៌ដោយសេចក្តីអធិប្បាយមានប្រមាណប៉ុណ្ណោះឯង តែថាក្នុងយោជនាព្រះអភិធម្មត្ថ-សង្គហៈនេះ លោកសម្តែងពន្យល់ថា ខណចិត្តទាំង ១៧ នេះ បើសម្តែងញែកចែកជាតួភវង្គមាន ៣ គឺ អតីតភវង្គ ១ ភវង្គចលនៈ ១ ភវង្គុប្បច្ឆេទៈ ១ ចែកជាវីថិចិត្តមានឈ្មោះជាសរុបមាន ៧ គឺ បញ្ចទ្វារា-វជ្ជនៈ ១ ចក្ខុវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ១ តទាលម្ពណៈ ១ បើចែកជាវីថិចិត្តមានឈ្មោះរាយផ្សេងៗ គ្នាមាន ១៤ គឺ បញ្ចទ្វារាវជ្ជន ១ ចក្ខុវិញ្ញាណ ១ សម្បដិច្ឆន្ន ១ សន្តី-រណ ១ វោដ្ឋព្វន ១ ជវន ១ ជវន ១ជវន ១ជវន ១ជវន ១ ជវន ១ ជវន ១ តទាលម្ពណ ១ តទាលម្ពណ ១ ត្រូវជាវីថិចិត្ត ១៤ រួមនឹងភវង្គចិត្ត ៣ ទៀតត្រូវជា ១៧ ហៅថាខណចិត្តធំ ១៧ មានខណចិត្តតូច ៥១ គត់ ជាសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៨៨- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា: ម្នាលអត្ថវាទី ចុះអតិមហន្តារម្មណ៍ដែលប្រព្រឹត្តទៅក្នុងតទាលម្ពណវារៈ អធិប្បាយថាដូចម្តេចខ្លះ? មហន្តារម្មណ៍ដែលប្រព្រឹត្តទៅក្នុងជវនវារៈ អធិប្បាយថាដូចម្តេចខ្លះ? បរិត្តារម្មណ៍ដែលប្រព្រឹត្តទៅក្នុងវោដ្ឋព្វនវារៈ អធិប្បាយថាដូចម្តេចខ្លះ? អតិបរិត្តារម្មណ៍ដែលប្រព្រឹត្តទៅក្នុងមោឃវារៈ ប្លែកផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនារៀបរាប់ឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា: បពិត្រធម្មវាទី ឯអារម្មណ៍ទាំង ៤ នោះ ទី ១ អតិមហន្តារម្មណ៍ អារម្មណ៍ច្រើនក្រៃលែងមានកម្លាំងខ្លាំងដែលប្រព្រឹត្តទៅក្នុងតទាលម្ពណវារៈ មានខណចិត្ត ១៧ ចែកជាភវង្គ ៣ ជាវីថិចិត្ត ១៤ ដូចបានអធិប្បាយមកក្នុងប្រស្នាលេខ ៨៧ មករួចហើយ ក៏ក្នុងតទាលម្ពណវារៈនេះ ពុំបានសូន្យវីថិចិត្តអ្វីឡើយ ។ ទី ២- មហន្តារម្មណ៍ អារម្មណ៍ច្រើនមានកម្លាំងល្មមដែលប្រព្រឹត្តទៅក្នុងជវនវារៈនោះ ផ្សេងគ្នាមានពីរយ៉ាង ទី ១- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ៤ កើតជាភវង្គវីថិ ៤ គឺអតីតភវង្គ: ២ ភវង្គចលនៈ ១ ភវង្គុបច្ឆេទៈ ១ តទៅអំពីភវង្គវីថិទាំង ៤ នោះ ខណចិត្ត ១២ កើតជា

វីថិចិត្ត ១២ គឺបញ្ចទ្វារាវជ្ជនៈ ១ ចក្ខុវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ ជវនៈ ១ តទៅអំពីវីថិចិត្តទាំង ១២ នោះ កើតអាគន្តុកភវង្គចិត្ត ១ ទៀត ត្រូវជាខណចិត្ត ១៧ គត់ ។ ទី ២- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ៥ កើតជាភវង្គវីថិ ៥ គឺអតីតភវង្គៈ ៣ ភវង្គចលនៈ ១ ភវង្គុប្បច្ឆេទ ១ តទៅអំពីភវង្គវីថិទាំង ៥ នោះ ខណចិត្ត ១២ កើតជាវីថិចិត្ត ១២ គឺបញ្ចទ្វារាវជ្ជនៈ ១ ។ ល ។ ជវនៈ ១ ត្រូវជាវីថិចិត្ត ១២ គត់ សូន្យអាគន្តុកភវង្គចិត្តពុំបានកើតឡើយ ។ ក្នុងជវនវារៈនេះ សូន្យតទាលម្ពណវារៈជាបឋមដូចបានអធិប្បាយមកនេះពិត ។

ទី ៣- បរិត្តារម្មណ៍ អារម្មណ៍មានប្រមាណតិចដែលប្រព្រឹត្តទៅក្នុងវោដ្ឋព្វនវារៈនោះផ្សេងគ្នាមាន ៥ យ៉ាង ទី ១- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ៦ កើតជាភវង្គវីថិ ៦ គឺអតីតភវង្គៈ ៤ ភវង្គចលនៈ ១ ភវង្គុប្បច្ឆេទៈ ១ ខណចិត្ត ៤ កើតជាវីថិចិត្ត ៤ គឺបញ្ចទ្វារាវជ្ជនៈ ១ ចក្ខុវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ ខណចិត្ត ១ កើតជាវោដ្ឋព្វនវីថិចិត្ត ៣ ដង តទៅអំពីវោដ្ឋព្វនវីថិចិត្តនោះកើតតែអាគន្តុកភវង្គចិត្ត ៤ គឺ ភវង្គ ១ ភវង្គ ១ ភវង្គ ១ ភវង្គ ១ ត្រូវ

ជាខណចិត្ត ១៧ គត់ ។ ទី ២- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ៧ កើតជាភវង្គវីថិ ៧ គឺអតីតភវង្គ: ៥ ភវង្គចលនៈ ១ ភវង្គុបច្ឆេទៈ ១ ខណចិត្ត ៤ កើតជាវីថិចិត្ត ៤ គឺបញ្ចទ្វារាវជ្ជនៈ ១ ចក្ខុវិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ ខណចិត្ត ១ កើតជាវោដ្ឋព្វនវីថិចិត្ត ៣ ដង តទៅអំពីវោដ្ឋព្វនវីថិចិត្តនោះ សូន្យអាគន្តុកភវង្គ ១ កើតតែអាគន្តុកភវង្គ ៣ គឺភវង្គ ១ ភវង្គ ១ ភវង្គ ១ ត្រូវជាខណចិត្ត ១៧ គត់ ។ ទី ៣- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ៨ កើតជាភវង្គវីថិចិត្ត ៨ គឺអតីតភវង្គ ៦ ភវង្គចលន ១ ភវង្គុបច្ឆេទ ១ ខណចិត្ត ៤ កើតជាវីថិចិត្ត ៤ ដូចគ្នា ខណចិត្ត ១ កើតជាវោដ្ឋព្វនវីថិចិត្ត ៣ ដង ដូចគ្នាដែរ តទៅអំពីវោដ្ឋព្វនវីថិចិត្តនោះសូន្យអាគន្តុកភវង្គ ១ កើតតែអាគន្តុកភវង្គ ២ គឺភវង្គ ១ ភវង្គ ១ ត្រូវជាខណចិត្ត ១៧ គត់ ។ ទី ៤- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ៩ កើតជាភវង្គវីថិ ៩ គឺអតីតភវង្គ ៧ ភវង្គចលន ១ ភវង្គុបច្ឆេទ ១ ខណចិត្ត ៤ កើតជាវីថិចិត្ត ២ ដូចគ្នា ខណចិត្ត ១ កើតជាវោដ្ឋព្វនវីថិចិត្ត ៣ ដង ដូចគ្នាដែរ តទៅអំពីវោដ្ឋព្វនវីថិចិត្តនោះ សូន្យអាគន្តុកភវង្គ ១ កើតតែអាគន្តុកភវង្គ ១ ត្រូវជាខណចិត្ត ១៧ គត់ ។ ទី ៥- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ១០ កើតជាភវង្គ-

វិថិ ១០ គឺអតីតភវង្គ ៨ ភវង្គចលន ១ ភវង្គុបច្ឆេទ ១ ខណចិត្ត ៤ កើតជាវីថិចិត្ត ៤ ដូចគ្នា ខណចិត្ត ១ កើតជាវោដ្ឋព្វនវីថិចិត្ត ៣ ផង ដូចគ្នាដែរ សូន្យអាគន្តុកភវង្គទាំងអស់ពុំបានកើតឡើយ ត្រូវជាខណចិត្ត ១៧ គត់ ប្រព្រឹត្តទៅក្នុងវោដ្ឋព្វនវារៈនេះ សូន្យជវនវារៈជាគម្រប់ពីរដូចអធិប្បាយមកនេះពិត ។ សេចក្តីពន្យល់ថា: អតិមហន្តារម្មណ៍ប្រព្រឹត្តទៅក្នុងភវង្គវីថិទី ១ មហន្តារម្មណ៍ប្រព្រឹត្តទៅក្នុងភវង្គវីថិទី ២ បរិត្តារម្មណ៍ប្រព្រឹត្តទៅក្នុងភវង្គវីថិទី ៥ ដោយពិត ។

ទី ៤- អតិបរិត្តារម្មណ៍ អារម្មណ៍មានប្រមាណតិចក្រៃលែង មានកម្លាំងខ្សោយពន់ពេក គឺបណ្ឌិតគប្បីកំណត់ដឹងដោយវារៈសូន្យទាំង ៧ យ៉ាងដែលប្រព្រឹត្តទៅក្នុងមោឃវារៈ ដូចនេះ, ទី ១- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ៩ កើតជាអតីតភវង្គ ៩ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ តទៅអំពីអតីតភវង្គទាំង ៩ នោះ កើតតែភវង្គចលន ២ គឺភវង្គចលន ១ ភវង្គចលន ១ តទៅអំពីភវង្គចលនទាំង ២ នោះ កើតអាគន្តុកភវង្គ ៦ គឺភវង្គ ១ ។ ល ។ ភវង្គ ១, ត្រូវជាខណចិត្ត ១៧ ជាមោឃវារៈ ជាវារៈសូន្យទី ១ ។ ទី ២- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ១០ កើតជាអតីតភវង្គ ១០ គឺអតីត-

ភវង្គ ១ ฯ ល ฯ អតីតភវង្គ ១ តទៅអំពីអតីតភវង្គទាំង ១០ នោះ កើតតែភវង្គចលន ២ ដួចគ្នា តទៅអំពីភវង្គចលនទាំង ២ នោះ សូន្យ អាគន្តុកភវង្គ ១ កើតតែអាគន្តុកភវង្គ ៥ គឺភវង្គ ១ ฯ ល ฯ ភវង្គ ១ ត្រូវជាខណចិត្ត ១៧ ជាមោឃវារៈ ជាវារៈសូន្យទី ២ ฯ ទី ៣- ខណ-ចិត្តទាំង ១៧ នោះ ខណចិត្ត ១១ កើតជាអតីតភវង្គ ១១ គឺអតីតភវង្គ ១ ฯ ល ฯ អតីតភវង្គ ១ តទៅអំពីអតីតភវង្គទាំង ១១ នោះ កើតតែភវង្គចលន ២ ដួចគ្នា តទៅអំពីភវង្គចលនទាំង ២ នោះ សូន្យ អាគន្តុកភវង្គ ១ កើតតែអាគន្តុកភវង្គ ៤ គឺភវង្គ ១ ฯ ល ฯ ភវង្គ ១ ត្រូវជាខណចិត្ត ១៧ ជាមោឃវារៈ ជាវារៈសូន្យទី ៣ ฯ ទី ៤- ខណ-ចិត្តទាំង ១៧ នោះ ខណចិត្ត ១២ កើតជាអតីតភវង្គ ១២ គឺអតីត-ភវង្គ ១ ฯ ល ฯ អតីតភវង្គ ១ តទៅអំពីអតីតភវង្គទាំង ១២ នោះ កើតតែភវង្គចលន ២ ដួចគ្នា តទៅអំពីភវង្គចលនទាំង ២ នោះ សូន្យ អាគន្តុកភវង្គ ១ កើតតែអាគន្តុកភវង្គ ៣ គឺភវង្គ ១ ភវង្គ ១ ភវង្គ ១ ត្រូវជាខណចិត្ត១៧ ជាមោឃវារៈ ជាវារៈសូន្យទី ៤ ฯ ទី ៥-ខណចិត្តទាំង ១៧ នោះ ខណចិត្ត ១៣ កើតជាអតីតភវង្គ ១៣ គឺអតីត-ភវង្គ ១ ฯ ល ฯ អតីតភវង្គ ១ តទៅអំពីអតីតភវង្គទាំង ១៣ នោះ

កើតតែភវង្គចលន ២ ដូចគ្នា តទៅអំពីភវង្គចលនទាំង ២ នោះ សូន្យអាគន្តុកភវង្គ ១ កើតតែអាគន្តុកភវង្គ ២ គឺ ភវង្គ ១ ភវង្គ ១ ត្រូវជាខណចិត្ត ១៧ ជាមោឃវារៈ ជាវារៈសូន្យទី ៥ ។ ទី ៦- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ១៤ កើតជាអតីតភវង្គ ១៤ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ តទៅអំពីអតីតភវង្គទាំង ១៤ នោះ កើតតែភវង្គ-ចលន ២ ដូចគ្នា តទៅអំពីភវង្គចលនទាំង ២ នោះ សូន្យអាគន្តុក-ភវង្គ ១ កើតតែអាគន្តុកភវង្គ ១ ត្រូវជាខណចិត្ត ១៧ ជាមោឃវារៈ ជាវារៈសូន្យទី ៦ ។ ទី ៧- ខណចិត្តទាំង ១៧ នោះ ខណចិត្ត ១៥ កើតជាអតីតភវង្គ ១៥ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ តទៅអំពីអតីតភវង្គទាំង ១៥ នោះ កើតតែភវង្គចលនៈ ២ គឺភវង្គចលនៈ ១ ភវង្គចលនៈ ១ ត្រូវជាខណចិត្ត ១៧ ជាមោឃវារៈ ជាវារៈសូន្យទី ៧ ពិត ។

ឯវារៈសូន្យទាំង ៧ យ៉ាង ដូចបានអធិប្បាយមកនេះ គឺសូន្យវីថិ-ចិត្ត ដែលមានឈ្មោះជាសរូបទាំង ៧ គឺបញ្ចទ្វារាវជ្ជនៈ ១ បញ្ច-វិញ្ញាណៈ ១ សម្បដិច្ឆន្នៈ ១ សន្តីរណៈ ១ វោដ្ឋព្វនៈ ១ ជវនៈ ១ តទា-លម្ពណៈ ១ ត្រូវជាវីថិចិត្ត ៧ ពិត តែថាអារម្មណ៍ទាំង ៤ នេះ បាន

តែអារម្មណ៍ទាំង ៥ គឺរូបារម្មណ៍ ១ សទ្ទារម្មណ៍ គន្ធារម្មណ៍ ១ រសារម្មណ៍ ១ ផោដ្ឋព្វារម្មណ៍ ១ ដែលប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ដោយពិត ។

វិសជ្ជនាមកអំពីអារម្មណ៍ទាំង ៤ មានអតិមហន្តារម្មណ៍ជាដើម ដែលមានសេចក្ដីប្លែកផ្សេងៗ គ្នា ជាសង្ខេបតែប៉ុណ្ណោះឯង ។

៨៩- ធម្មវាទី បានស្ដាប់ហើយពោលថា ម្នាលអត្ថវាទី ប្រស្នា ដែលលោកវិសជ្ជនាមកនេះយើងស្ដាប់បានហើយ តែថាយើងនឹងសួរ លោកជានិគមវចនៈ បញ្ជាក់សេចក្ដីអំពីអារម្មណ៍ទាំង ៤ មានអតិម-ហន្តារម្មណ៍ជាដើមនេះឲ្យជាក់ច្បាស់តទៅទៀត ចុះអតិមហន្តារម្មណ៍ក្ដី មហន្តារម្មណ៍ក្ដី បរិត្តារម្មណ៍ក្ដី អតិបរិត្តារម្មណ៍ក្ដី ទាំង ៤ នេះ ក្នុងអារម្មណ៍មួយៗ មានខណចិត្តប្រព្រឹត្តកន្លងទៅប៉ុន្មាន? ប្លែកផ្សេងគ្នាយ៉ាងណាខ្លះ? មានខណចិត្តប៉ុន្មានជាអាយុនៃរូបធម៌ទាំងឡាយ ប្លែកផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្ដាប់ចូលចិត្តផងមើល!

អត្ថវាទី វិសជ្ជនាតបថាៈ បពិត្រធម្មវាទី ទី ១ អតិមហន្តា-រម្មណ៍ជាអារម្មណ៍មានខណចិត្តទាំង ១៧ ពេញបរិបូណ៌នោះ អារម្មណ៍

មានខណចិត្ត ១ គឺអតីតភវង្គប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១៦ ជាអាយុរបស់រូបធម៌ទាំងឡាយ វៀរលែងតែវិញ្ញត្តិរូប ២ និងជាតិរូប, អនិច្ចតារូប, ជរតារូបចេញដោយពិត ។

ទី ២- មហន្តារម្មណ៍នោះជាអារម្មណ៍មានខណចិត្តផ្សេងៗ គ្នាមានពីរយ៉ាងគឺអារម្មណ៍មានខណចិត្ត ២ គឺអតីតភវង្គ ១ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១៥ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ៣ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១៤ ជាអាយុរបស់រូបធម៌ទាំងឡាយ ។

ទី ៣- បរិត្តារម្មណ៍នោះជាអារម្មណ៍មានខណចិត្តផ្សេងៗ គ្នាមាន ៦ យ៉ាង គឺអារម្មណ៍មានខណចិត្ត ៤ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១៣ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ៥ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១២ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ៦ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្ត

កន្ទុងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១១ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ៧ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្ទុងទៅ សល់នៅអារម្មណ៍មានខណចិត្ត ១០ ជាអាយុរបស់រូបធម៌ទាំងឡាយ១ អារម្មណ៍មានខណចិត្ត ៨ គឺ អតីត-ភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្ទុងទៅ សល់នៅអា-រម្មណ៍មានខណចិត្ត ៩ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ៩ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្ទុងទៅ សល់នៅអារម្មណ៍មានខណចិត្ត ៨ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ ។

ទី ៤- អតិបរិត្តារម្មណ៍នោះ ជាអារម្មណ៍មានខណចិត្តផ្សេងៗគ្នាមាន ៦ យ៉ាងគឺអារម្មណ៍មានខណចិត្ត ១០ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្ទុងទៅ សល់នៅអារម្មណ៍មានខណចិត្ត ៧ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ១១ គឺអតីត-ភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្ទុងទៅ សល់នៅអារម្មណ៍មានខណចិត្ត ៦ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណ-ចិត្ត ១២ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្ទុងទៅ សល់នៅ

អារម្មណ៍មានខណចិត្ត ៥ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ១៣ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ៤ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ១៤ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ៣ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ អារម្មណ៍មានខណចិត្ត ១៥ គឺអតីតភវង្គ ១ ។ ល ។ អតីតភវង្គ ១ ប្រព្រឹត្តកន្លងទៅ សល់នៅអារម្មណ៍មានខណចិត្ត ២ ជាអាយុរបស់រូបធម៌ទាំងឡាយ ១ ។

វិសជ្ជនាមកអំពីអារម្មណ៍ទាំង ៤ យ៉ាង មានអតិមហន្តារម្មណ៍ជាដើម ដែលមានខណចិត្តប្រព្រឹត្តកន្លងទៅនិងសល់នៅជាអាយុរបស់រូបធម៌ទាំងឡាយជាសង្ខេបសេចក្ដីតែប៉ុណ្ណេះឯង ។

៩០- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀតថា: ម្នាលអត្ថវាទី ចុះចំណែកខាងវិភូតារម្មណ៍ អារម្មណ៍ដែលកើតឡើងប្រាកដចូលមកកាន់រន្ធង់ក្នុងមនោទ្វារ តើចិត្តប្បាទខណចិត្តដែលកើតឡើងជាភវង្គវិថីប៉ុន្មាន? ជាវិថិចិត្តប៉ុន្មាន? គឺចិត្តអ្វីខ្លះ? អវិភូតារម្មណៈ អារម្មណ៍ដែលពុំបានកើតឡើងប្រាកដ ពុំបានចូលមកកាន់រន្ធង់ក្នុងមនោទ្វារ តើចិត្តប្បាទ-

ខណចិត្តដែលកើតឡើងជាភវង្គវិថិនិងវិថិចិត្តប្លែកផ្សេងគ្នាដូចម្តេច?

អគ្គវាទី វិសជ្ជនាតបថាៈ បពិត្រធម្មវាទី ឯវិភូតារម្មណៈ អារម្មណ៍ដែលកើតឡើងប្រាកដនោះមានខណចិត្ត ១៣ គឺខណចិត្ត ៣ កើតជាភវង្គ ៣ គឺអតីតភវង្គ ១ ភវង្គចលន ១ ភវង្គុបច្ឆេទ ១ ខណចិត្ត ១០ កើតជាវិថិចិត្តទាំង ១០ គឺមនោទ្វារាវជ្ជន ១ ជវន ៧ តទាលម្ពណ ២ ជា ១០ រួមទាំងអស់ត្រូវជា ១៣ គត់ ជាខណចិត្តមានអារម្មណ៍កើតឡើងប្រាកដប្រព្រឹត្តទៅក្នុងមនោទ្វារដោយពិត ។

អវិភូតារម្មណៈ អារម្មណ៍ដែលពុំបានកើតឡើងប្រាកដនោះ មានខណចិត្ត ១១ គឺខណចិត្ត ៣ កើតជាភវង្គ ៣ គឺអតីតភវង្គ ១ ភវង្គចលន ១ ភវង្គុបច្ឆេទ ១ ខណចិត្ត ៨ កើតជាវិថិចិត្តទាំង ៨ គឺមនោទ្វារាវជ្ជន ១ ជវន ៧ ជា ៨ គត់ សូន្យតទាលម្ពណវិថិពុំបានកើតឡើយ ត្រូវជាខណចិត្ត ១១ គត់ ជាខណចិត្តមានអារម្មណ៍ពុំបានកើតឡើងប្រាកដក្នុងមនោទ្វារដោយពិត ។ វិសជ្ជនាមកអំពីវិភូតារម្មណ៍និងអវិភូតារម្មណ៍ជាសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៩១- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថាៈ ម្នាលអគ្គវាទី ចុះជវនសម្ភវៈ របស់បុថុជ្ជនទាំងឡាយនិងសេក្ខបុគ្គល និងអសេក្ខបុគ្គល

ទាំងឡាយ មានខណចិត្តកើតឡើងព្រមជាជវនសម្រាប់សោយនូវអារម្មណ៍អស់វារៈ តិចច្រើនប្លែកផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាមក យើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា: បពិត្រធម្មវាទី ឯជវនសម្ភវទី ១ របស់បុថុជ្ជនទាំងឡាយ ក្នុងកាលដែលស្លាប់ក្តី កាលដែលសន្លប់បាត់ស្មារ-តីក្តី យ៉ាងឆាប់រហ័ស គង់មានខណចិត្តកើតឡើងព្រម ជាជវនសោយនូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈ ៥ ដងដែរ បើយ៉ាងយូរក្នុងកាលដែលសន្លប់បាត់ស្មារតីក្តី កាលដែលបុថុជ្ជនទាំងឡាយបានឃើញនូវសរីរៈទាំងអស់របស់ប្រេតមានរូបអាក្រក់ផ្សេងៗ គួរខ្លាចកិតភ័យតក់ស្លុតបាត់ស្មារតីក្តី តែងមានខណចិត្តកើតឡើងព្រម ជាជវនសោយនូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈ ៦ ដង ក៏ក្នុងកាលដែលសេសសល់អំពីកាលនេះ ទោះបីមានអារម្មណ៍ប្រព្រឹត្តទៅក្នុងបញ្ចទ្វារក្តី មនោទ្វារក្តី ក៏គង់មានខណចិត្តកើតឡើងព្រម ជាជវនសោយនូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈ ៧ ដងដោយពិត ៗ ទី ២- ជវនសម្ភវៈរបស់យោគា-វចរកុលបុត្រជាបុថុជ្ជនដែលបានចម្រើនបរិកម្មភាវនាព្រះកម្មដ្ឋាន បានសម្រេចដល់អប្បនាឈាននោះ តែងមានខណចិត្តកើតឡើងព្រមជា

មហគ្គតជវនសោយនូវរសនៃធម្មារម្មណ៍ ប្រព្រឹត្តទៅក្នុងមនោទ្វារអស់វារៈតែម្តងបានឋិតនៅស៊ប់ស្ងួន ក្នុងអប្បនាឈានទាំងអស់តាំងអំពីអប្បនាឈានទី ១ ដរាបដល់អប្បនាឈានទី ៩ ដោយចំណែកមួយដូចគ្នាដោយពិត តែជាអភិញ្ញាជវនប្លែកផ្សេងមិនដូចគ្នាទេ ព្រោះកុសលាភិញ្ញាកើតមកអំពីរូបាវចរកុសលចិត្តឈានទី ៥ កិរិយាភិញ្ញាកើតមកអំពីរូបាវចរកិរិយាចិត្តឈានទី ៥ ដែរ អាចឲ្យបានសម្រេចនូវមគ្គទាំង ៤ និងឫទ្ធិទាំងពួងមានទិព្វចក្ខុជាដើម មានខណចិត្តកើតឡើងព្រមជាអភិញ្ញាជវនសោយនូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈតែម្តងពិត តទៅអំពីអភិញ្ញាជវននោះ វីថិចិត្តធ្លាក់ចុះមកកាន់ទីភវង្គដ្ឋានវិញដដែល ។ ទី ៣-ជវនសម្ភវៈ កិរិយាដែលកើតឡើងនៃមគ្គទាំង ៤ គឺសោតាបត្តិមគ្គ ១ សកិទាគាមិមគ្គ ១ អនាគាមិមគ្គ ១ អរហត្តមគ្គ ១ ប្រកបកើតព្រមក្នុងខណចិត្តតែមួយ គឺថាបើបុគ្គលបានកសាងអភិនីហារមកច្រើននឹងបានសម្រេចមគ្គផលជាទិប្បាភិញ្ញា កាមាវចរកុសលចិត្តកើតឡើងព្រមជាអភិញ្ញាជវនសោយនូវអារម្មណ៍ ប្រព្រឹត្តទៅអស់វារៈមួយដង មគ្គចិត្តក៏កើតឡើង សោយនូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈបួនដងយ៉ាងងាយឆាប់រហ័ស អប្បនាចិត្តជាផលក៏កើតឡើងជាលំដាប់នៃកាមាវចរជវន

ដែលប្រព្រឹត្តទៅអស់វារៈ ៣ ដង នៃបុគ្គលជាខិប្បាភិញ្ញាដោយពិត ។ បើបុគ្គលបានកសាងអភិនីហារមកតិចពេកនឹងបានសម្រេចមគ្គ ផល ជាទន្ធាភិញ្ញា កាមាវចរកុសលចិត្តកើតឡើងព្រមជាអភិញ្ញាជវនសោយនូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈមួយដង មគ្គចិត្តក៏កើតឡើងសោយនូវអារម្មណ៍ប្រព្រឹត្តទៅអស់វារៈ ៥ ដងយ៉ាងលំបាកយឺតយូរ អប្បនាចិត្តជាផលក៏កើតឡើងជាលំដាប់នៃកាមាវចរជវនដែលប្រព្រឹត្តទៅអស់វារៈ ៤ ដងនៃបុគ្គលជាទន្ធាភិញ្ញាដោយពិត តទៅអំពីផលចិត្តនោះ អភិញ្ញាជវនវីថិក៏ធ្លាក់ចុះមកកាន់ទីភវង្គដ្ឋានវិញដដែល ។

ចំណែកឯព្រះអនាគាមិបុគ្គលនិងព្រះអរហន្ត ក្នុងកាលដែលលោកចូលកាន់និរោធសមាបត្តិនោះ អរូបាវចរកុសលចិត្តទី ៤ របស់ព្រះអនាគាមិបុគ្គលកើតឡើងជាកុសលជវន អរូបាវចរកិរិយាចិត្តរបស់ព្រះខីណាស្រព កើតឡើងជាកិរិយាជវនសោយនូវអារម្មណ៍អស់វារៈ ២ ដង ហើយរលត់ទៅវិញ ទើបពាល់ត្រូវនិរោធសមាបត្តិ គឺជាចូលកាន់និរោធសមាបត្តិស៊ប់ស្ងួនពិត ក៏កាលដែលចេញចាកនិរោធសមាបត្តិកើតឡើងហើយរលត់ទៅវិញ អនាគាមិផលក៏កើតឡើងឋិតនៅក្នុងអនាគាមិផលវិញដដែល ព្រះអរហត្តផលក៏កើតឡើងឋិតនៅក្នុងព្រះអរហត្ត-

ផលវិញដដែល កិរិយាជវនសោយនូវអារម្មណ៍អស់វារៈមួយជង តាមសមគួរដល់បុគ្គលនោះៗ ពិត ។ ទី ៤- ជវនសម្ភវៈកាមាវចរកិរិយាចិត្តដែលជាញាណសម្បយុត្តរបស់ព្រះដ៏មានព្រះភាគកើតឡើង ជាកិរិយាជវនសោយនូវអារម្មណ៍ ប្រព្រឹត្តទៅអស់វារៈ ៤ ជង យ៉ាងរហ័ស បើយ៉ាងយឺតយូរប្រព្រឹត្តទៅអស់វារៈ ៥ ជង ក្នុងកាលដែលព្រះអង្គទ្រង់សម្តែងនូវយមកប្បាដិហារិយ៍ ដោយពិត ។

ឯកាមាវចរជវនទាំង ៩ គឺហសនចិត្ត ១ សហេតុកកាមាវចរកិរិយាចិត្ត ៨ និងមហគ្គតជវន ៩ លោកុត្តរជវន ៨ រួមទាំងអស់ត្រូវជា ២៦ ពុំបានកើតឡើងដល់ទុហេតុកបដិសន្ធិបុគ្គល និងអហេតុកបដិសន្ធិបុគ្គលទាំងឡាយឡើយ ។ ដូចមានសេចក្តីវិនិច្ឆ័យរបស់ព្រះធម្មសង្គិតិកាចារ្យលោកវិនិច្ឆ័យសម្រេចកាត់សេចក្តីថា កាមាវចរកុសលកម្មអំពើដែលបុគ្គលធ្វើយ៉ាងប្រឹងប្រែងក្លៀវក្លាមាំមួនជាកាមាវចរកុសល ដ៏ឧត្តមខ្ពង់ខ្ពស់ជាត្រៃហេតុឧក្រិដ្ឋ រមែងឲ្យបដិសន្ធិជាត្រៃហេតុហើយញ៉ាំងកាមាវចរវិបាកទាំង ១៦ ឲ្យៗ ផលជាក់ច្បាស់ក្នុងបវត្តិកាល គឺអហេតុកកុសលវិបាក ៨ មហាវិបាក ៨ កើតឡើងប្រាកដដល់បុគ្គលទាំងឡាយ ជាត្រៃហេតុឧក្រិដ្ឋនោះឯង ។ បើកាមាវចរកុសលកម្ម

អំពើដែលបុគ្គលធ្វើដោយការទើសទាល់ធុញទ្រាន់ ជាកាមាវចរកុសលទាបថោកពន់ពេកជាត្រៃហេតុឱមកក្តី កាមាវចរកុសលកម្ម អំពើដែលបុគ្គលធ្វើដោយឧស្សាហៈ ព្យាយាមប្រឹងប្រែងក្លៀវក្លាជាកាមាវចរ-កុសល ដ៏ឧត្តមខ្ពង់ខ្ពស់ជាទ្វិហេតុឧក្រិដ្ឋក្តី នឹងឲ្យបដិសន្ធិជាទ្វិហេតុក-បដិសន្ធិពិត ហើយញុំាងវិបាកទាំង ១២ ប្រាសចេញចាកត្រៃហេតុក-វិបាកឲ្យៗ ផលជាក់ច្បាស់ក្នុងបវត្តិកាលគឺវិបាកទាំង ១២ គឺអហេតុកកុសល-វិបាក ៨ សហេតុកកុសលវិបាកជាញាណវិប្បយុត្ត ៤ កើតឡើងប្រាកដដល់បុគ្គលទាំងឡាយ ជាត្រៃហេតុឱមកនិងទ្វិហេតុឧក្រិដ្ឋនោះឯង ។ កាមាវចរកុសលកម្ម អំពើដែលបុគ្គលធ្វើប្រកបដោយសេចក្តីធុញទ្រាន់ឱ្ធិលប្រអូសពន់ពេក យ៉ាងទាបថោកជាទ្វិហេតុឱមកនឹងត្រឡប់ឲ្យបដិសន្ធិជាអហេតុកបដិសន្ធិវិញ ហើយញុំាងអហេតុកកុសលវិបាកទាំង ៨ ឲ្យៗ ផលជាក់ច្បាស់ក្នុងបវត្តិកាល (បច្ចុប្បន្ន) ក្នុងកាមសុគតិភពនេះដោយពិត ព្រោះថាភវង្គចិត្តរបស់បុគ្គលទាំងឡាយ ជាសហេតុកជាបច្ច័យដោយបច្ច័យជាលំដាប់នៃភវង្គចិត្តជាអហេតុកពិត ។ ក៏បណ្តាបុគ្គលទាំង ៩ ពួក គឺបុថុជ្ជនបុគ្គល ១ សេក្ខបុគ្គល ៧ ព្រះខីណាស្រព ១ ត្រូវជា ៩ ពួក នោះកុសលជវនទិងអកុសលជវនទាំងឡាយពុំបានកើត

ឡើងដល់ព្រះខីណាស្រពទាំងឡាយឡើយ គឺថាកើតឡើងបានដល់តែបុថុជ្ជនបុគ្គលនិងសេក្ខបុគ្គលប៉ុណ្ណោះឯង ។

ឯកិរិយាជវនទាំង ១៨ គឺអហេតុកហសនកិរិយាជវន ១ កាមាវចរសោភណកិរិយាជវន ៨ មហគ្គតកិរិយាជវន ៩ ពុំបានកើតឡើងប្រាកដដល់សេក្ខបុគ្គលទាំង ៧ ពួក និងបុថុជ្ជនបុគ្គលទាំងឡាយឡើយ ក៏អកុសលជវនជាទិដ្ឋិគតសម្បយុត្ត ៤ និងវិចិកិច្ឆាជវន ១ ត្រូវជា ៥ ពុំបានកើតឡើងប្រាកដដល់សេក្ខបុគ្គលទាំង ៧ ពិត ព្រោះសេក្ខបុគ្គលទាំងពីរ គឺសោតាបន្នបុគ្គល ១ សកិទាគាមិបុគ្គល ១ លោកមានសំយោជនធម៌ទាំងពីរ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ បានលះបង់ជាស្រឡះហើយដោយបឋមមគ្គមែនពិត ។ ចំណែកព្រះអនាគាមិបុគ្គលទាំងឡាយលោកមានទោមនស្សជវន ២ ទិដ្ឋិគតសម្បយុត្តជវន ៤ វិចិកិច្ឆាសហគតជវន ១ ត្រូវជា ៧ បានលះបង់ជាស្រឡះហើយដោយតតិយមគ្គពិត ។ ម្យ៉ាងទៀត លោកុត្តរជវនទាំងឡាយ កើតឡើងព្រមដល់ព្រះអរិយបុគ្គលទាំងឡាយ ដោយសមគួរតាមសភាពខ្លួនពិត គឺថាសោតាបត្តិមគ្គជវនកើតឡើង ដល់ព្រះអរិយបុគ្គលស្ថិតនៅក្នុងសោតាបត្តិមគ្គពិត សោតាបត្តិផលជវនកើតឡើងដល់ព្រះអរិយបុគ្គលស្ថិតនៅ

ក្នុងសោតាបត្តិផលពិត សកិទាគាមិមគ្គជវនកើតឡើងដល់ព្រះអរិយ-បុគ្គលស្ថិតនៅក្នុងសកិទាគាមិមគ្គពិត សកិទាគាមិផលជវនកើតឡើងដល់ព្រះអរិយបុគ្គលស្ថិតនៅក្នុងសកិទាគាមិផលពិត អនាគាមិមគ្គជវនកើតឡើងដល់ព្រះអរិយបុគ្គលស្ថិតនៅក្នុងអនាគាមិមគ្គពិត អនាគា-មិផលជវនកើតឡើងដល់ព្រះអរិយបុគ្គល ស្ថិតនៅក្នុងអនាគាមិផលពិត អរហត្តមគ្គជវនកើតឡើងដល់ព្រះអរិយបុគ្គល ស្ថិតនៅក្នុងអរហត្តមគ្គពិត អរហត្តផលជវនកើតឡើងដល់ព្រះអរិយបុគ្គល ស្ថិតនៅក្នុងអរហត្តផលពិត ។ វិសជ្ជនាមកអំពីជវនសម្ភពនៃបុថុជ្ជនបុគ្គល និងសេក្ខបុគ្គល និងអសេក្ខបុគ្គលទាំងឡាយ ជាសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៩២- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្តវាទី ប្រស្នាដែលលោកវិសជ្ជនាមកទាំងអស់នេះ យើងស្តាប់បានចូលចិត្តហើយ តែថាយើងនឹងសួរប្រស្នាដទៃតទៅទៀត ម្នាលអត្តវាទី ចុះបដិសន្ធិចតុក្កប្រជុំបដិសន្ធិទាំង ៤ សេចក្តីប្លែកគ្នាដូចម្តេច? សត្វទាំងឡាយដែលកើតក្នុងភូមិទាំង ៤ កំណត់អាយុពុំបាន នឹងកំណត់អាយុបានតិចច្រើនប្លែកផ្សេងៗ គ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មក យើងនឹងស្តាប់ចូលចិត្តផងមើល!

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯប្រជុំបដិសន្ធិទាំង ៤ នោះ ទី ១- កាមទុគ្គតិបដិសន្ធិមានតែ ១ គឺឧបេក្ខាសហគតសន្តីរណៈ ជាអហេតុកអកុសលវិបាកជាជនកកម្ម ជាពូជតបដិសន្ធិត្រាច់ទៅញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបឬក្នុងអបាយភូមិ ៤ ណាមួយក្នុងបដិសន្ធិកាល តទៅអំពីបដិសន្ធិកាលនោះ កើតជាភវង្គចិត្តឋិតនៅអស់កំណត់កាលមានកម្មជាអាយុពិត ហើយញ៉ាំងអហេតុកអកុសលវិបាកទាំង ៧ ឲ្យៗ ផលសោយទុក្ខវេទនាជាទម្ងន់រងទុក្ខលំបាកតាមបាបគ្រោះ ចំពោះអកុសលកម្មរបស់ខ្លួនក្នុងបវត្តិកាល លុះដល់អកុសលកម្មអស់ទៅដរាបឯណា សត្វនោះក៏អស់អាយុកើតជាជវនកិរិយាច្យុតសូន្យទៅក្នុងកាលជាទីបំផុតនៃភវង្គចិត្តដរាបនោះឯង បានឈ្មោះថា អបាយបដិសន្ធិ ១ ។ ទី ២- កាមសុគតិបដិសន្ធិមាន ៩ គឺឧបេក្ខាសហគតសន្តីរណៈជាអហេតុក-កុសលវិបាក ជាជនកកម្ម ជាពូជតបដិសន្ធិ ត្រាច់ទៅញ៉ាំងផលរបស់ខ្លួនឲ្យកើតជានាមរូបឬក្នុងកាមសុគតិភូមិ គឺថាកើត ជាមនុស្សមានរោគផ្សេងៗ មានខ្វាក់ភ្នែកអំពីកំណើតជាដើមផង កើតជាវិនិបាតិកអសុរទាំងឡាយ ប្រាសចេញចាកសេចក្ដីសុខតែងអាស្រ័យនូវផែនដី ប្រាកដស្មើដោយទីជាទីលំនៅនៃភូមិទេវតាទាំងឡាយផង ប្រព្រឹត្តទៅដោយ

បដិសន្ធិ ភវង្គ ចុតិក្នុងកាមសុគតិភូមិដោយពិត បានឈ្មោះថា កុសល-
វិបាកអហេតុកបដិសន្ធិ ១ ។ ឯមហាវិបាកទាំង ៨ ជាសហេតុក-
បដិសន្ធិប្រកបដោយត្រៃហេតុផង ប្រកបដោយទ្វិហេតុផង ប្រព្រឹត្ត
ទៅក្នុងកាមសុគតិភូមិទាំង ៧ ជាន់ គឺឋានមនុស្ស ១ ឋានសួគ៌ ៦ ជាន់
ដោយបដិសន្ធិ ភវង្គ ចុតិក្នុងឋានមនុស្សនិងឋានសួគ៌ជាសហេតុកកាមា-
វចរបដិសន្ធិមាន ៨ រួមទាំងអស់ត្រូវជាកាមាវចរបដិសន្ធិ ១០ ក្នុងកាមភូមិ
ទាំង ១១ ជាន់ ។ ម្យ៉ាងទៀត សត្វទាំងឡាយដែលកើតក្នុងអបាយភូមិ
ទាំង ៤ ក្ដី កើតក្នុងជម្ពូទ្វីបនេះក្ដី លោកពុំបានកំណត់អាយុឡើយ
ព្រោះសត្វទាំងអស់នេះមានអាយុខ្លីខ្លះ មានអាយុវែងខ្លះសមគួរតាមកម្ម
របស់ខ្លួនដោយពិត ឯមនុស្សកើតក្នុងឧត្តរកុរុទ្វីប មានអាយុ ១ ពាន់
ឆ្នាំមនុស្សជាកំណត់ មនុស្សកើតក្នុងអមរគោយានទ្វីប បុព្វវិទេហទ្វីប
មានអាយុ ៥០០ ឆ្នាំមនុស្សជាកំណត់ ចំណែកសត្វទាំងឡាយ ដែល
កើតក្នុងឋានសួគ៌ ៦ ជាន់ លោកកំណត់អាយុបាន ដោយថ្ងៃ ខែ ឆ្នាំ
របស់មនុស្សយកទៅគុណនឹងថ្ងៃ ខែ ឆ្នាំទិព្វរបស់ទេវតាទាំងឡាយ
ដូចអធិប្បាយតទៅនេះ ទី ១- អាយុរបស់មនុស្ស ៥០ ឆ្នាំ បាន ១
យប់ ១ ថ្ងៃក្នុងឋានចាតុម្មហារាជិកាជាថ្ងៃទិព្វមួយ ៣០ ថ្ងៃទិព្វបាន

១ ខែទិព្វ ១២ ខែទិព្វបាន ១ ឆ្នាំទិព្វ អាយុទេវតាក្នុងឋានចាតុម្មហា-រាជិកា ៥០០ ឆ្នាំទិព្វ គិតរាប់ជាឆ្នាំរបស់មនុស្សបាន ៩ លានឆ្នាំគត់ ។ ទី ២- អាយុទេវតាក្នុងឋានតាវត្តិង្ស ១ ពាន់ឆ្នាំទិព្វ គិតរាប់ជាឆ្នាំរបស់មនុស្សបាន ៣ កោដិ ៦ លានឆ្នាំគត់ ។ ទី ៣- អាយុទេវតាក្នុងឋានយាមា ២ ពាន់ឆ្នាំទិព្វ គិតរាប់ជាឆ្នាំរបស់មនុស្សបាន ១៤ កោដិ ៤ លានឆ្នាំ គត់ ។ ទី ៤- អាយុទេវតាក្នុងឋានតុសិត ៤ ពាន់ឆ្នាំទិព្វ គិតរាប់ជាឆ្នាំរបស់មនុស្សបាន ៥៧ កោដិ ៦ លានឆ្នាំគត់ ។ ទី ៥- អាយុទេវតាក្នុងឋាននិម្មានរតី ៨ ពាន់ឆ្នាំទិព្វ គិតរាប់ជាឆ្នាំរបស់មនុស្សបាន ២៣០ កោដិ ៤ លានឆ្នាំគត់ ។ ទី ៦- អាយុទេវតាក្នុងឋានបរនិម្មិត-វសវតី ១ ម៉ឺន ៦ ពាន់ឆ្នាំទិព្វ គិតរាប់ជាឆ្នាំរបស់មនុស្សបាន ៩២១ កោដិ ៦ លានឆ្នាំគត់ ។

ទី ៣- រូបាវចរបដិសន្ធិមាន ៤ គឺ ១- បឋមជ្ឈានវិបាកជាជនក-កម្មជាពូជតបដិសន្ធិត្រាច់ទៅ ញុំាងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្មីក្នុងបឋមជ្ឈានភូមិ ៣ ជាន់ គឺព្រហ្មបារិសជ្ជា ១ ព្រហ្មបុរោហិតា ១ មហាព្រហ្មា ១ ដោយអំណាចនៃបដិសន្ធិ ភវង្គ ចុតិដ៏សមគួរតាមកម្លាំងរបស់ឈាន ។ ២- ទុតិយជ្ឈានវិបាកជាជនកកម្មជាពូជតបដិសន្ធិ

ត្រាច់ទៅញុំាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្មីក្នុងទុតិយជ្ឈាន ៣ ជាន់ គឺបរិត្តាភា ១ អប្បមាណាភា ១ អាភស្សរា ១ ដោយអំណាចនៃបដិសន្ធិ ភវង្គ ចុតិដ៏សមគួរតាមកម្លាំងរបស់ឈាន ។ ៣- តតិយជ្ឈានវិបាកជាជនកកម្ម ជាពូជតបដិសន្ធិត្រាច់ទៅញុំាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្មីក្នុងតតិយជ្ឈានភូមិ ៣ ជាន់ គឺបរិត្តសុភា ១ អប្បមាណសុភា ១ សុភកិណ្ហា ១ ដោយអំណាចនៃបដិសន្ធិ ភវង្គ ចុតិដូចគ្នា ។ ៤- ចតុត្ថជ្ឈានវិបាកជាជនកកម្មជាពូជតបដិសន្ធិត្រាច់ទៅញុំាំងផលរបស់ខ្លួនឲ្យកើតជានាមរូបថ្មី ក្នុងចតុត្ថជ្ឈានភូមិ ៣ ជាន់គឺវេហប្ផលា ១ អសញ្ញីសត្តា ១ សុទ្ធាវាសទាំងប្រាំ ១ ដោយអំណាចនៃបដិសន្ធិភវង្គ ចុតិដូចគ្នា តែថាសុទ្ធាវាសភូមិទាំងប្រាំបានតែខាងព្រះអនាគាមិបុគ្គលទាំងឡាយប៉ុណ្ណោះរួមឋានរូបព្រហ្មទាំងអស់ត្រូវជា ១៦ គត់ កើតដោយរូបាវចរវិបាកទាំង ៤ ឲ្យបដិសន្ធិដោយពិត បានឈ្មោះថា រូបាវចរបដិសន្ធិទាំង ៤ ប៉ែកតែអសញ្ញីសត្វ ១ បានឈ្មោះថា រូបបដិសន្ធិវិញ ព្រោះថា ព្រះយោគាវចរកុលបុត្រដែលបានចម្រើនបញ្ចមជ្ឈានមានវាយោកសិណជាអារម្មណ៍ ជារូបាវចរកុសលហើយមានចិត្តនឿយណាយប្រាសចេញចាកសញ្ញាជាស្រឡះ ច្យុតទៅកើតក្នុងអសញ្ញីសត្វទាំង-

ឡាយនោះ បើស្លាប់ទៅដោយឥរិយាបថឯណា ក៏កើតឡើងក្នុងអសញ្ញីសត្វនោះជាជីវិតនវករូបជារូបមានជីវិតជាគម្រប់ ៩ ដោយឥរិយា-បថនោះឯង គឺថាបើស្លាប់ទៅដេក កើតឡើងក៏ដេកដែរ ស្លាប់ទៅដើរ កើតឡើងក៏ដើរដែរ ស្លាប់ទៅឈរ កើតឡើងក៏ឈរដែរ ស្លាប់ទៅអង្គុយ កើតឡើងក៏អង្គុយដែរ បានឈ្មោះថា រូបបដិសន្ធិតែម្យ៉ាងដោយពិត ។ ឯអាយុរូបព្រហ្មទាំងអស់នោះមានខ្លីវែងផ្សេងៗគ្នា ពុំបានកំណត់អាយុដោយថ្ងៃ ខែ ឆ្នាំឡើយ គឺថាកំណត់ដោយកប្បដូចអធិប្បាយតទៅនេះ ។ ១- កប្បមួយចែកជា ៣ ចំណែក អាយុព្រហ្មបារិសជ្ជាបាន ១ ចំណែកកប្បជាប្រមាណ ។ ២- ព្រហ្មបុរោហិតា មានអាយុកន្លះកប្បជាប្រមាណ ។ ៣- មហាព្រហ្មា មានអាយុ ១ កប្បជាប្រមាណ ។ ៤- ព្រហ្មបរិត្តាភា មានអាយុ ២ កប្បជាប្រមាណ ។ ៥- ព្រហ្មអប្បមា-ណាភា មានអាយុ ៤ កប្បជាប្រមាណ ។ ៦- ព្រហ្មអាភស្សរា មានអាយុ ៨ កប្បជាប្រមាណ ។ ៧- ព្រហ្មបរិត្តសុភា មានអាយុ ១៦ កប្បជាប្រ-មាណ ។ ៨- ព្រហ្មអប្បមាណសុភា មានអាយុ ៣២ កប្បជាប្រមាណ ។ ៩- ព្រហ្មសុភកិណ្ហា មានអាយុ ៦៤ កប្បជាប្រមាណ ។ ១០- ព្រហ្ម-វេហប្ផលា មានអាយុ ៥០០ កប្បជាប្រមាណ ។ ១១- ព្រហ្មអសញ្ញីសត្វ

មានអាយុ ៥០០ កប្បជាប្រមាណដូចគ្នា ។ ១២- ព្រហ្មអវិហា មានអាយុ ១ ពាន់កប្បជាប្រមាណ ។ ១៣- ព្រហ្មអតប្បា មានអាយុ ២ ពាន់កប្បជាប្រមាណ ។ ១៤- ព្រហ្មសុទស្សាមានអាយុ ៤ ពាន់កប្បជាប្រមាណ។ ១៥- ព្រហ្មសុទស្សី មានអាយុ ៨ ពាន់កប្បជាប្រមាណ ។ ១៦- ព្រហ្មអកនិដ្ឋាមានអាយុ ១ ម៉ឺន ៦ ពាន់កប្បជាប្រមាណ ។

ទី ៤- អរូបាវចរបដិសន្ធិមាន ៤ គឺ ១- អរូបវិបាកទី ១ ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ភវង្គ ចុតិកើតឡើងក្នុងអាកាសានញ្ចាយតនអរូបភូមិទី ១ ។ ២- អរូបវិបាក ទី ២ ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ភវង្គ ចុតិកើតឡើងក្នុងវិញ្ញាណញ្ចាយតនអរូបភូមិទី ២ ។ ៣- អរូបវិបាកទី ៣ ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ភវង្គ ចុតិកើតឡើងក្នុងអកិញ្ចញ្ញាយតនអរូបភូមិ ទី ៣ ។ ៤- អរូបវិបាកទី ៤ ប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ភវង្គ ចុតិកើតឡើងក្នុងនេវសញ្ញានាសញ្ញាយតនអរូបភូមិទី ៤ ។ ក៏អរូបព្រហ្មទាំង ៤ នេះកើតឡើងពុំមានរូបអ្វីបន្តិចបន្តួចមែនពិត មានតែមនោធាតុជាអាយតនៈ ពុំបានអាស្រ័យនូវវត្ថុអ្វីឡើយ ។ ឯកំណត់អាយុ អរូបព្រហ្មទាំង ៤ នេះ អរូបព្រហ្មទី ១ មានអាយុ ២ ម៉ឺនកប្បជាប្រមាណ អរូបព្រហ្មទី ២ មានអាយុ ៤ ម៉ឺនកប្ប

ជាប្រមាណ, អរូបព្រហ្មទី ៣ មានអាយុ ៦ ម៉ឺនកប្បជាប្រមាណ, អរូបព្រហ្មទី ៤ មានអាយុ ៨ ម៉ឺន ៤ ពាន់កប្បជាប្រមាណ ។ វិសជ្ជនាមកអំពីបដិសន្ធិចតុក្កដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៩៣- ធម្មវាទី បានស្ដាប់ហើយពោលថា ម្នាលអត្ថវាទី ចុះកម្ម-ចតុក្កប្រជុំកម្ម ៤ ដោយអាការៈទាំងឡាយ មានបួនៗ អធិប្បាយប្លែកផ្សេងៗគ្នាដូចម្ដេចខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្ដាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថាៈ បពិត្រធម្មវាទី ឯកម្មចតុក្កប្រជុំកម្ម ៤ ដោយអាការៈទាំងឡាយមានបួនៗ នោះ ដូចមានសេចក្ដីក្នុងអដ្ឋកថាមហាដីកា, អនុដីកា, ព្រមទាំងយោជនា, លោកសម្ដែងអធិប្បាយពន្យល់ថាៈ ប្រជុំកម្ម ៤ គឺកិច្ចកម្ម អំពើជាកុសលនិងអកុសលអាចញុំាងកិច្ចរបស់ខ្លួនៗ មានបដិសន្ធិកិច្ចជាដើមឲ្យសម្រេច ដោយអាការៈមានបួន ១ ។ បាកទានកម្ម អំពើជាកុសលនិងអកុសលអាចឲ្យនូវផលផ្សេងៗ គ្នា ដោយអាការៈមានបួន ១ ។ បាកកាលកម្ម អំពើជាកុសលនិងអកុសលអាចឲ្យនូវផលផ្សេងៗ គ្នាតាមកាលដោយអាការៈមានបួន ១ ។ បាកដ្ឋានកម្ម អំពើជាកុសលនិងអកុសល ដែលជាហេតុបណ្ដុះ

បណ្តាលឲ្យកើតឡើងជាផលផ្សេងៗ ដោយអាការៈមានបួន ១ ។ ត្រូវជាកម្ម ៤ ដោយពិត ។

ទី ១- កិច្ចកម្មដែលលោកចែកដោយអាការៈបួននោះគឺកុសលចេតនា និងអកុសលចេតនា ដែលពុំបានកាត់ផ្តាច់បង់នូវវិបាកជាផលនៃកម្មដទៃ ហើយញ៉ាំងវិបាកជាផលរបស់ខ្លួនឲ្យកើតឡើង គឺជាតាក់តែងរូបធម៌ឲ្យកើតចម្រើនធំឡើងពេញបរិបូណ៌ ក្នុងបដិសន្ធិកាលនិងបវត្តិកាលដោយផលដែលខ្លួនបានធ្វើសន្សំទុកមកហើយ បានឈ្មោះថាជនកកម្ម ១, អំពើជាកុសលនិងអកុសល ដែលមិនអាចញ៉ាំងវិបាកជាផលរបស់ខ្លួនឲ្យកើតឡើងបាន ហើយកើតជាបច្ច័យក្នុងកិរិយាទំនុកបម្រុងតាក់តែងវិបាកជាផលនៃកម្មដទៃ ដែលខ្លួនបានធ្វើសន្សំទុកមកអស់កាលជាយូរអង្វែងមកហើយឲ្យកើតឡើង ឬជាឲ្យកើតជាបច្ច័យ នៃវិបាកជាផលប្រព្រឹត្តទៅអស់កាលជាយូរអង្វែងប្រាកដស្មើដោយជនកកម្ម ដើម្បីកើតឡើងជាបច្ច័យសម្រាប់ទំនុកបម្រុងកាត់ផ្តាច់បង់នូវវិបាកជាផលកើតឡើង ឲ្យសោយនូវសេចក្តីសុខ និងទុក្ខក្នុងបវត្តិកាល គឺថាបើកុសលវិបាកមានកម្លាំងខ្លាំងនឹងកាត់ផ្តាច់បង់នូវសេចក្តីទុក្ខលំបាកចេញ ហើយឲ្យបានសោយនូវសេចក្តីសុខក្សេមក្សាន្តវិញ បើអកុសលវិបាកមានកម្លាំងខ្លាំងនឹងកាត់

ផ្តាច់បង់នូវសេចក្តីសុខក្រែមក្សាន្តចេញ ហើយឲ្យបានសោយនូវសេចក្តីទុក្ខលំបាកវិញផង ដើម្បីកើតឡើងជាបច្ច័យឲ្យបានចូលទៅជិតចម្រើនតៗទៅខាងមុខផង បានឈ្មោះថា ឧបត្ថម្ភកកម្ម ១ អំពើឯណានីមួយដែលជាប់អាស្រ័យនូវវិបាកជាផលដែលខ្លួនឲ្យកើតឡើង ដោយកម្មដទៃប្រព្រឹត្តទៅអស់កាលជាយូរអង្វែងមកហើយ ដោយការបៀតបៀននូវនិមិត្តមានព្រមព្រៀងដោយព្យាធិធាតុជាដើម ឬថាបៀតបៀននូវវិបាកជាផលនៃកម្មដទៃអំពីចន្ទោះនិងចន្ទោះ ដោយកិរិយាប្រមូលមកនូវបច្ច័យមានភាវៈបៀតបៀនច្រើនជាដើម ក៏កាត់ផ្តាច់បង់នូវអំពើហាមឃាត់នោះដោយប្រការទាំងពួង ហើយឲ្យនូវឱកាសដល់កម្មដទៃឲ្យៗ ផលក្នុងបវត្តិកាល ពុំបានញុំាងផលឲ្យកើតឡើង ដោយខ្លួនឯងឡើយ បានឈ្មោះថា ឧបបីឡិកកម្ម ១, អំពើជាកុសលនិងអកុសលដែលហាមឃាត់ផ្តាច់បង់នូវផលនៃកម្មនោះៗ ហើយញុំាងវិបាកជាផលរបស់ខ្លួនឲ្យកើតឡើងដោយខ្លួនឯង ដោយកិរិយាកើតជាបច្ច័យបៀតបៀនផ្តាច់បង់នូវកម្មដ៏មានកម្លាំងថយមែនពិត បានឈ្មោះថា ឧបឃាដកកម្ម ១ ត្រូវជាកិច្ចកម្មមាន ៤ ដោយពិត ។

ទី ២- បាកទានកម្ម ដែលលោកចែកដោយអាការ ៤ នោះគឺអំពើ

ជាកុសលក្តី អកុសលក្តី ដែលមានផលធ្ងន់ គឺថាមានទោសធំធ្ងន់អំពើជាអកុសលបានខាងអនន្តរិយកម្មទាំងប្រាំមានសម្លាប់មាតាជាដើម មានអានុភាពធំធ្ងន់អំពើជាកុសលបានខាងមហគ្គតគុណទាំង ៩ មានបឋមជ្ឈានជាដើម ជាអំពើមានផលគឺកម្មដទៃពុំអាចនឹងហាមឃាត់បានឡើយ បានឈ្មោះថាគរុកម្ម ១, អំពើជាកុសលក្តី ជាអកុសលក្តីដែលបុគ្គលបានធ្វើក្នុងកាលជិតស្លាប់នឹងឲ្យផលមុនជាងកម្មទាំងពួងបានឈ្មោះថា អាសន្នកម្ម១, អំពើជាកុសលខ្លះ ជាអកុសលខ្លះ ដែលបុគ្គលធ្វើសន្សំរឿយៗ គឺថាធ្វើម្តងហើយម្តងទៀត កម្មនេះក៏ធ្វើកម្មនោះក៏ធ្វើ សេពគប់ហើយដោយច្រើនបានឈ្មោះថាអាចិណ្ណកម្ម ១ អំពើជាកុសលក្តី ជាអកុសលក្តី ដែលបុគ្គលធ្វើរោយរាយមិនប្រាកដជាអំពើណាឡើយ ធ្វើតាមតែប្រទះដោយមិនមានចេតនាតែថាមិនមែនជាគរុកម្ម អាសន្នកម្ម អាចិណ្ណកម្មឡើយ បានឈ្មោះថាកដត្តាកម្ម ១ ត្រូវជាបាកទានកម្ម ៤ ដោយពិត ។ សេចក្តីលោកពន្យល់ថាបើបុគ្គលម្នាក់បានធ្វើកម្មគ្រប់ទាំង ៤ គរុកម្មនឹងឲ្យផលមុន បើមិនមានគរុកម្មទេ អាសន្នកម្មនឹងឲ្យផល បើមិនមានអាសន្នកម្មទេ អាចិណ្ណកម្មនឹងឲ្យផល បើមិនមានអាចិណ្ណកម្មទេ កដត្តាកម្មនឹងឲ្យផលដោយចំណែកមួយ ។

ទី ៣- បាកកាលកម្មអំពើជាកុសលនិងអកុសលអាចឲ្យផល ផ្សេងៗ គ្នា តាមកាល ដោយអាការមាន ៤ នោះ គឺ អំពើជាកុសល និងអកុសលដែលបុគ្គលធ្វើសម្រេចដោយបឋមជវនចេតនា គឺជាកុសល-ចេតនាក្តី អកុសលចេតនាក្តី កើតជាជវនវីថិសោយនូវរសនៃអារម្មណ៍ អស់វារៈតែម្តងស្រេច រមែងឲ្យផលជាក់ច្បាស់នឹងភ្នែកក្នុងបច្ចុប្បន្នជាតិ នេះដោយពិត បានឈ្មោះថា ទិដ្ឋធម្មវេទនិយកម្ម ១, អំពើជាកុសលក្តី ជាអកុសលក្តី ដែលបុគ្គលធ្វើឲ្យសម្រេចដោយសត្តមជវនចេតនា គឺជា កុសលចេតនាក្តី អកុសលចេតនាក្តី កើតជាជវនវីថិសោយនូវរសនៃ អារម្មណ៍ កើតឡើងនិងរលត់ទៅវិញអស់វារៈ ជាគម្រប់ ៧ ដង រមែងឲ្យ ផលជាលំដាប់អំពីបច្ចុប្បន្នជាតិនេះ គឺជាដល់ជាតិខាងក្រោយនឹងឲ្យ បដិសន្ធិកើតជាមនុស្ស ឬទេវតា ឬជាកើតក្នុងអបាយភូមិក្តី ក្នុងជាតិ ជាបន្ទាប់ជាតិនេះតទៅទៀតនឹងកើតជាវិបាកឲ្យផលរាល់ៗ ជាតិទៅ បាន ឈ្មោះថា ឧបបជ្ជវេទនិយកម្ម ១, អំពើជាកុសលក្តី ជាអកុសលក្តី ដែលបុគ្គលធ្វើឲ្យសម្រេចដោយបញ្ចមជវនចេតនា គឺជាកុសលចេតនាក្តី អកុសលចេតនាក្តី កើតជាជវនវីថិសោយនូវរសនៃអារម្មណ៍អស់វារៈ ជាគម្រប់ប្រាំដង រមែងរង់ចាំបាននូវទីឱកាស បើទិដ្ឋធម្មវេទនិយកម្មនិង

ឧបបជ្ជវេទនិយកម្មឈប់ឲ្យផលពេលណា នឹងឲ្យផលពេលនោះឯង បានឈ្មោះថា អបរាបរវេទនិយកម្ម ១, អំពើជាកុសលក្តី អកុសលក្តី ដែលបុគ្គលធ្វើជាអបរាបរវេទនិយកម្ម បើពុំបានឱកាសនឹងឲ្យផលទេ នឹងបានឈ្មោះថា អហោសិកម្ម ១ ត្រូវជាបាកកាលកម្ម ៤ ដោយពិត ។

ទី ៤- បាកដ្ឋានកម្ម អំពើជាកុសលក្តី អកុសលក្តី ដែលជាហេតុបណ្តុះបណ្តាលឲ្យកើតឡើងជាផលផ្សេងៗ ដោយអាការមាន ៤ នោះគឺ អំពើជាអកុសលដែលបុគ្គលធ្វើប្រព្រឹត្តទៅក្នុងកាយទ្វារ ១ វចីទ្វារ ១ មនោទ្វារ ១ ដោយអកុសលចិត្តទាំង ១២ ហៅថាអកុសល-កម្ម សេចក្តីអធិប្បាយពន្យល់ថា: អំពើដែលបុគ្គលប្រព្រឹត្តធ្វើអាក្រក់ដោយកាយមាន ៣ យ៉ាងគឺ

ទី ១- សម្លាប់សត្វ ១ លួចទ្រព្យគេ ១ មិនសន្តោសប្រព្រឹត្តធ្វើខុសក្នុងកាមគុណទាំងឡាយ គឺសេចក្តីតម្រេកត្រេកត្រអាលនឹងរូប-សំឡេង ក្លិន រស សម្ផស្ស ឬត្រេកអរសេពផឹកនូវសុរានិងមេរយ ក៏ដោយ ក៏គង់រាប់បញ្ចូលក្នុងរសតណ្ហាកាមគុណដែរ ក៏ការដែលត្រេកអរហួសប្រមាណមិនប្រព្រឹត្តធម៌សន្តោសក្នុងកាមគុណទាំង ៥ នេះ បានឈ្មោះថា កាមេសុមិច្ឆាចារ ១ រួមអំពើទាំង ៣ នេះ បានឈ្មោះថា

កាយទុច្ចរិត សេចក្ដីប្រព្រឹត្តអាក្រក់លាមកដោយកាយមាន ៣ ពិត ។

ទី ២- ពោលពាក្យកុហកឲ្យខូចប្រយោជន៍អ្នកដទៃ ហៅថា មុសាវាទ ១ បុគ្គលដែលមានចេតនាដ៏អាក្រក់ និយាយពាក្យញុះញង់បំបែកមិត្តអ្នកដទៃឲ្យបែកចេញពីគ្នា ហើយយកមកជាមិត្តរបស់ខ្លួនវិញ ហៅថា បិសុណាវាចា ១, បុគ្គលដែលមានចេតនាដ៏អាក្រក់ ពោលពាក្យអាក្រក់នាំឲ្យក្ដៅក្រហាយដល់បុគ្គលដទៃ ហៅថា ផរុសវាចា ១, បុគ្គលដែលមានចេតនាដ៏សៅហ្មង ពោលពាក្យឥតប្រយោជន៍មានញុាំងបុគ្គលឲ្យដឹងនូវរឿងរ៉ាវនាងសិតាក្នុងរាមកេរ្ដិ៍ជាដើម ដែលជារឿងពុំពិតឥតខ្លឹមសារឥតមូលដ្ឋាន ហៅថា សម្ផប្បលាប ១ រួមអំពើទាំង ៤ នេះ បានឈ្មោះថាវចីទុច្ចរិតប្រព្រឹត្តអាក្រក់ដោយវាចាមាន ៤ ពិត ។

ទី ៣- បុគ្គលដែលមានចិត្តបង្អោនទៅកាន់ទ្រព្យអ្នកដទៃ ដើម្បីយកមកឲ្យជារបស់ខ្លួន ដោយលោភចិត្ត ហៅថា អភិជ្ឈា ១ បុគ្គលដែលមានចិត្តខឹងប្រទូស្តអ្នកដទៃឲ្យគេវិនាស ហៅថា ព្យាបាទ ១ បុគ្គលដែលពិចារណាយល់ឃើញខុសដ៏វិបរិតផ្សេងៗ មិនត្រូវតាមគន្លងធម៌ពិត ហៅថា មិច្ឆាទិដ្ឋិ ១ រួមអំពើទាំង ៣ នេះ បានឈ្មោះថា មនោទុច្ចរិតប្រព្រឹត្តអាក្រក់ដោយចិត្តមាន ៣ ពិត ។

រួមអំពើដែលបុគ្គលប្រព្រឹត្តអាក្រក់ដោយប្រជុំទ្វារទាំង ៣ នេះ ហៅថា អកុសលកម្មបថមាន ១០ ជាគន្លងផ្លូវប្រព្រឹត្តធ្វើនូវអំពើអាក្រក់ដោយអកុសលចិត្តទាំង ១២ ដែលជាហេតុបណ្តុះបណ្តាលឲ្យកើតជាអហេតុកអកុសលវិបាកទាំង ៧ គឺឧបេក្ខាសហគតសន្តីរណអហេតុកវិបាកទី ៧ ជាតួបដិសន្ធិកើតក្នុងអបាយភូមិទាំង ៤ គឺ នរក ១ ប្រេត ១ តិរច្ឆាន ១ អសុរកាយ ១ សោយទុក្ខវេទនា ដោយចំណែកមួយ បានឈ្មោះថា កាមាវចរអកុសលកម្ម ១ ។

អំពើកុសលដែលបុគ្គលប្រព្រឹត្តធ្វើទៅក្នុងកាយទ្វារ ១ វចីទ្វារ ១ មនោទ្វារ ១ ដោយមហាកុសលចិត្តទាំង ៨ ហៅថា កុសលកម្ម, សេចក្តីអធិប្បាយថា បុគ្គលដែលប្រព្រឹត្តធ្វើនូវអំពើដ៏ស្អាតម៉ត់ចត់ល្អដោយកាយទ្វារ វចីទ្វារ មនោទ្វារ គឺ ទី ១- វៀរលែងនូវអំពើប្រព្រឹត្តអាក្រក់លាមកដោយកាយទ្វារទាំង ៣ យ៉ាងជាស្រឡះ គឺ មិនសម្លាប់សត្វ ១ មិនលួចទ្រព្យគេ ១ ប្រព្រឹត្តធម៌សន្តោសក្នុងកាមគុណទាំងឡាយ មិនត្រេកត្រអាលហួសប្រមាណ ១ ។ ទី ២- វៀរលែងនូវអំពើប្រព្រឹត្តអាក្រក់លាមកដោយវចីទ្វារទាំង ៤ យ៉ាងជាស្រឡះ មានមិនពោលពាក្យកុហកឲ្យខូចប្រយោជន៍អ្នកដទៃជាដើម ១ ។ ទី ៣ វៀរ

លែងនូវអំពើប្រព្រឹត្តអាក្រក់លាមកដោយមនោទ្វារទាំង ៣ យ៉ាង ជាស្រឡះមានអនភិជ្ឈា មិនបង្អោនចិត្តទៅកាន់ទ្រព្យអ្នកដទៃដោយលោភ-ចិត្តជាដើម ១ រួមទាំងអស់ត្រូវជា ១០ គត់ ហៅថា កុសលកម្មបថទាំង ១០ ជាគន្លងផ្លូវប្រព្រឹត្តធ្វើនូវអំពើដ៏ស្អាតម៉ត់ចត់ល្អ ដោយមហា-កុសលចិត្តទាំង ៨ ដែលជាចិត្តមានពន្លឺរស្មីល្អដ៏ថ្លៀវថ្លាសវាងវៃអាចលះបង់នូវអកុសលកម្មបថទាំង ១០ បានជាស្រឡះ ហើយចម្រើនកុសល-កម្មបថទាំង ១០ ឲ្យកើតមានច្រើនឡើងក្នុងសន្តានខ្លួន ជាហេតុបណ្តុះបណ្តាលឲ្យកើតឡើងជាសហេតុកកុសលវិបាកទាំង ៨ ជាតួបដិសន្ធិកើតឡើងសោយសុខក្នុងកាមសុគតិភពទាំង ៧ ជាន់ គឺឋានមនុស្ស ១ កាមាវចរសួគ៌ ៦ ជាន់ ដោយពិត ។ ម្យ៉ាងទៀត កុសលកម្ម អំពើដែលបុគ្គលធ្វើដោយមហាកុសលចិត្តទាំង ៨ នេះ មិនមានតែប៉ុណ្ណោះទេ អាចញ៉ាំងអំពើជាកុសលឲ្យកើតឡើងជាអនេករាប់ពុំអស់ឡើយ ក៏ក្នុងមហាកុសលចិត្តមួយៗ អាចញ៉ាំងបុញ្ញកិរិយាវត្ថុដប់ៗ ឲ្យកើតឡើងបានត្រូវជាបុញ្ញរាសីគំនរបុណ្យ ៨០ គត់ ហើយយកទៅគុណនឹងអារម្មណ៍ទាំង ៦ មានរូបារម្មណ៍ជាដើម ក្នុងអារម្មណ៍មួយៗ កើតបុញ្ញរាសីគំនរបុណ្យប៉ែតសិបៗ ត្រូវជា ៤៨០ បុណ្យគត់ ដូចបានអធិប្បាយមកអំពី

មហាកុសលចិត្តទាំង ៨ ក្នុងប្រស្នាខាងដើមនោះរួចហើយ, លោកអ្នកសិក្សាបរមត្ថព្រះអភិធម្ម បើចង់ដឹងសេចក្ដីច្បាស់លាស់ ត្រូវពិនិត្យមើលក្នុងប្រស្នាខាងដើម ដែលមានពាក្យចោទ ឆ្លើយអំពីមហាកុសលចិត្តនោះចុះ អាចនឹងដឹងសេចក្ដីអធិប្បាយបានដោយងាយ, ក៏រួមសេចក្ដីទាំងអស់ដោយសង្ខេប បានឈ្មោះថា កាមាវចរកុសលកម្ម ១ ។

អំពើដែលយោគាវចរកុលបុត្រខំព្យាយាមចម្រើនសមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋានក្នុងមនោទ្វារសម្រេចដោយភាវនា ដោយរូបាវចរ-កុសលចិត្តទាំង ៥ ហើយបានសម្រេចដល់អប្បនាឈានជាលំដាប់នឹងលំដាប់ជាហេតុបណ្ដុះបណ្ដាលឲ្យកើតឡើងជារូបាវចរវិបាក ជាតួបដិ-សន្ធិកើតឡើងក្នុងរូបភពទាំង ១៦ ជាន់ តាមលំដាប់នៃឈានជាន់ទាបជាន់ខ្ពស់ បានឈ្មោះថា រូបាវចរកុសលកម្ម ១ ។

អំពើដែលយោគាវចរកុលបុត្រខំព្យាយាមចម្រើនសមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋានក្នុងមនោទ្វារសម្រេចដោយភាវនា ដោយអរូបាវចរ-កុសលចិត្តទាំង ៤ ហើយបានសម្រេចដល់អប្បនាឈានជាលំដាប់និងលំដាប់ ជាហេតុបណ្ដុះបណ្ដាលឲ្យកើតឡើង ជាអរូបាវចរវិបាកជាតួបដិសន្ធិកើតឡើងក្នុងអរូបភពទាំង ៤ ជាន់ តាមលំដាប់នៃឈានជាន់ទាប

ជាន់ខ្ពស់ បានឈ្មោះថា អរូបាវចរកុសលកម្ម ១ ។

បពិត្រធម្មវាទី ខ្ញុំអត្តវាទីបានវិសជ្ជនាមកអំពីចតុកម្មចតុក្កៈ ប្រជុំកម្មបួនៗដង គឺ កិច្ចកម្ម ៤ បាកទានកម្ម ៤ បាកកាលកម្ម ៤ បាកដ្ឋានកម្ម ៤ ត្រូវជាកម្ម ១៦ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះឯង ។

៩៤- ធម្មវាទី បានស្ដាប់ហើយពោលថា: ម្នាលអត្តវាទី ចុះអកុសលកម្ម អំពើបាបលាមកដែលបុគ្គលបានធ្វើហើយដោយអកុសលចិត្តទាំង ១២ នឹងត្រឡប់ឲ្យផលជាអហេតុកបដិសន្ធិវិញ គឺថា: ឧបេក្ខាសហគតសន្តីរណ ជាអហេតុកអកុសលវិបាក ជាជនកកម្ម តាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីៗ ក្នុងកាមទុគ្គតិភូមិណាមួយក្នុងបដិសន្ធិកាល ហើយថាញាំងអហេតុកអកុសលវិបាកទាំង ៧ ឲ្យៗ ផលសោយទុក្ខវេទនាក្នុងបវត្តិកាល ចុះចំណែកខាងកុសលវិបាក ដែលកើតជាប់មកក្នុងសន្តានខ្លួនបានឲ្យផលសោយសុខវេទនាក្នុងបវត្តិកាលខ្លះដែរឬទេ?

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី សត្វទាំងឡាយដែលប្រព្រឹត្តធ្វើនូវអំពើបាបលាមកហើយស្លាប់ទៅនោះ នឹងមានអកុសលចេតនាជាជនកកម្មតាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីៗ ក្នុងកាមទុគ្គតិភូមិណាមួយក្នុងបដិសន្ធិកាល, តែថាក្នុងបវត្តិកាលបើអហេតុកអកុសលកម្មមាន

កម្លាំងខ្លាំងញ៉ាំងអហេតុកអកុសលវិបាកឲ្យៗ ផលសោយទុក្ខវេទនាជាដរាបតទៅ, បើអហេតុកអកុសលកម្មមានកម្លាំងខ្សោយហើយ អហេតុកកុសលកម្មមានកម្លាំងខ្លាំងវិញ នឹងញ៉ាំងអហេតុកកុសលវិបាកឲ្យៗ ផលសោយសុខវេទនាក្នុងបច្ចុប្បន្ននេះដោយពិត រួមអហេតុកអកុសលវិបាក ៧ និងអហេតុកកុសលវិបាក ៨ ត្រូវជា ១៥ តែងផ្លាស់ប្តូរគ្នាឲ្យផលសោយទុក្ខខ្លះ សុខខ្លះ ដ៏សមគួរតាមកម្លាំងខ្លាំងនិងកម្លាំងខ្សោយក្នុងកាមទុគ្គតិភូមិក្នុងបវត្តិកាលដោយចំណែកមួយ ឯមហាកុសលវិបាកទាំង ៨ ពុំបានប្រព្រឹត្តទៅឲ្យផលក្នុងកាមទុគ្គតិភូមិទាំង ៤ ជាន់នោះឡើយ ។ ចំណែកខាងសត្វទាំងឡាយដែលប្រព្រឹត្តធ្វើនូវអំពើជាកុសលមានផលបុណ្យល្អហើយស្លាប់ទៅនោះ នឹងមានកុសលចេតនាណាមួយជាជនកកម្ម តាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីៗ ក្នុងកាមសុគតិភូមិទាំង ៧ ជាន់ មានឋានមនុស្សជាដើមក្នុងបដិសន្ធិកាលតែថាក្នុងបវត្តិកាល បើអកុសលកម្មមានកម្លាំងបានឱកាសនឹងញ៉ាំងអហេតុកអកុសលវិបាកឲ្យៗ ផលសោយទុក្ខវេទនាជាទម្ងន់ក្នុងបច្ចុប្បន្ននេះ បើពុំបានឱកាសទេ អហេតុកកុសលកម្មមានកម្លាំងបានឱកាសវិញនឹងញ៉ាំងអហេតុកកុសលវិបាកឲ្យៗ ផលសោយសុខវេទនា ជាសុខយ៉ាងតិចក្នុង

បច្ចុប្បន្ននេះ បើពុំបានឱកាសទេ សហេតុកកុសលកម្មមានកម្លាំងខ្លាំង បានឱកាសវិញនឹងញ៉ាំងសហេតុកមហាកុសលវិបាកទាំង ៨ ឲ្យៗ ផល សោយសុខវេទនា ជាសុខក្សេមក្សាន្តដ៏ប្រសើរក្នុងបច្ចុប្បន្ននេះដោយពិត, រួមអហេតុកអកុសលវិបាក ៧ អហេតុកកុសលវិបាក ៨ សហេតុក-មហាកុសលវិបាក ៨ ត្រូវជា ២៣ សម្រាប់ឲ្យផលដល់សត្វទាំងឡាយ ដែលកើតក្នុងកាមសុគតិភូមិទាំង ៧ ជាន់ដោយចំណែកមួយពិត ។ វិសជ្ជ-នាមកអំពីអកុសលកម្ម និងកុសលកម្មឲ្យផលដោយសេចក្ដីសង្ខេបតែ ប៉ុណ្ណេះឯង ។

៩៥- ធម្មវាទី បានស្ដាប់ហើយពោលថា: សាធុៗ អើ អត្តវាទី ប្រស្នាដែលលោកបានវិសជ្ជនាមកនេះប្រពៃណាស់ហើយ តែយើងនឹង សួរប្រស្នាដទៃតទៅទៀត ម្នាលអត្តវាទី ចុះអំពើដែលបុគ្គលបានធ្វើ ជាកុសលយ៉ាងឧត្តមខ្ពង់ខ្ពស់ឈ្មោះថា ត្រៃហេតុឧក្រិដ្ឋមានប៉ុន្មានយ៉ាង? សេចក្ដីផ្សេងគ្នាដូចម្ដេចខ្លះ? អំពើដែលបុគ្គលបានធ្វើជាកុសលយ៉ាងជាន់ ទាបថយថោកឈ្មោះថា ត្រៃហេតុឱមក: មានប៉ុន្មានយ៉ាង? សេចក្ដី ផ្សេងគ្នាដូចម្ដេចខ្លះ? អំពើដែលបុគ្គលបានធ្វើជាកុសលយ៉ាងឧត្តម ខ្ពង់ខ្ពស់ ឈ្មោះថា ទ្វិហេតុឧក្រិដ្ឋមានប៉ុន្មានយ៉ាង? សេចក្ដីផ្សេងគ្នាដូច

ម្តេចខ្លះ? អំពើដែលបុគ្គលបានធ្វើជាកុសលយ៉ាងជាន់ទាបថយថោក ឈ្មោះថា ទ្វិហេតុឱមកៈ មានប៉ុន្មានយ៉ាង? សេចក្តីផ្សេងគ្នាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាឲ្យសព្វគ្រប់មកយើងនឹងបានស្តាប់ចូលចិត្តផងមើល?

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី សេចក្តីវិនិច្ឆ័យរបស់ព្រះធម្មសង្គីតិកាចារ្យ លោកបានសម្រេចកាត់សេចក្តីថា ឧក្កដ្ឋកម្ម អំពើដែលបុគ្គលបានធ្វើយ៉ាងឧត្តមខ្ពង់ខ្ពស់ជាឧក្រិដ្ឋក្តី អំពើដែលបុគ្គលបានធ្វើយ៉ាងជាន់ទាបថយថោកជាឱមកៈក្តី នោះយើងបានអធិប្បាយមកក្នុងប្រស្នាទី ៦០ ៦១ និងទី ៩១ ជាខាងដើមមករួចសព្វគ្រប់ហើយ មិនបាច់អធិប្បាយតទៅទៀតទេ សប្បុរសទាំងឡាយ អ្នកសិក្សារៀនបរមត្ថព្រះអភិធម្ម ត្រូវរំពឹងយកសេចក្តីអធិប្បាយក្នុងប្រស្នាទី ៦០ ៦១ និង ៩១ នោះចុះ គង់ជ្រាបសេចក្តីបានដោយងាយ ។ ក្នុងប្រស្នានេះនឹងសម្តែងតែត្រង់សេចក្តីដែលប្លែកគ្នា តាមសេចក្តីវិនិច្ឆ័យដូចអធិប្បាយតទៅនេះ៖

ទី ១- ត្រៃហេតុឧក្រិដ្ឋ បែកចេញជាពីរយ៉ាងតាមអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាយ៉ាងឧត្តមខ្ពង់ខ្ពស់ ។ ទី ២- ត្រៃហេតុឱមកៈ បែកចេញជាពីរយ៉ាង តាមអំពើដែលបុគ្គលបានធ្វើដោយកុសល-

ចេតនាយ៉ាងជាន់ទាបថយថោក ។ ទី ៣- ទ្វិហេតុឧក្រិដ្ឋ ចែកចេញជាពីរយ៉ាង តាមអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាយ៉ាងឧត្តមខ្ពង់ខ្ពស់ ។ ទី ៤- ទ្វិហេតុឱមកៈ ចែកចេញជាពីរយ៉ាង តាមអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាយ៉ាងជាន់ទាបថយថោក រួបរួមសេចក្តីអធិប្បាយតាមបាលី អដ្ឋកថា មហាដីកា អនុដីកា យោជនានៃអភិធម្មត្ថសង្គហថាៈ ទី ១- ត្រៃហេតុឧក្រិដ្ឋចែកចេញជាពីរយ៉ាងនោះគឺអំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ ហើយមានឧស្សាហ៍ខំព្យាយាមប្រឹងប្រែងក្លៀវក្លាចាត់ការជាកុសលពុំបានធុញទ្រាន់ខ្ជិលច្រអូសឡើយ មានចាត់ចែងធ្វើការជាកុសលដទៃៗ យ៉ាងច្រើន ដំរុងរឿងជាបរិវារចោមរោមបុណ្យជាប្រធានដែលខ្លួនបានប្រារព្ធនឹងធ្វើនោះ ដរាបដល់សម្រេចបុណ្យមួយលើកៗ ហើយតែងមានចិត្តនឹករលឹកបុណ្យដែលខ្លួនបានធ្វើហើយនោះរឿយៗ ពុំដាច់ ដោយអសង្ខារិកមហាកុសលចិត្តទាំង ៤ វៀរលែងចាកសសង្ខារិកមហាកុសលចិត្ត ៤ ចេញគឺបឋមកុសលចិត្តទី ១ ដែលប្រកបដោយសោមនស្សវេទនាជាញាណសម្បយុត្តអសង្ខារិក ១ តតិយកុសលចិត្តទី ៣ ដែលប្រកបដោយសោមនស្សវេទនាជាញាណ-

វិប្បយុត្តអសង្ខារិក ១ បញ្ចមកុសលចិត្តទី ៥ ដែលប្រកបដោយឧបេក្ខា-វេទនាជាញាណសម្បយុត្តអសង្ខារិក ១ សត្តមកុសលចិត្តទី ៧ ដែលប្រកបដោយឧបេក្ខាវេទនាជាញាណវិប្បយុត្តអសង្ខារិក ១ ត្រូវជា ៤ ជាកុសលចិត្ត មានឧស្សាហ៍ខំព្យាយាមប្រឹងប្រែងកើតឡើងដោយខ្លួនឯង ពុំមានបុគ្គលណាមួយមកដឹកនាំឲ្យធ្វើឡើយ លុះដល់បុគ្គលនោះទទួលមរណភាពទៅនឹងមានកុសលចេតនា ណាមួយមានកម្លាំងខ្លាំងជាងដែលខ្លួនបានធ្វើហើយក្នុងបច្ចុប្បន្ននេះកើតជាជនកកម្ម តាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីក្នុងកាមសុគតិភូមិទាំង ៧ ជាន់ មានឋានមនុស្សជាដើមក្នុងបដិសន្ធិកាល ហើយញុំាងអសង្ខារិកមហាវិបាក ៤ និងអហេតុ-កកុសលវិបាក ៨ ត្រូវជា ១២ ឲ្យៗ ផលក្នុងបវត្តិកាល បានឈ្មោះថាត្រៃហេតុឧក្រិដ្ឋទី ១ ។

អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ ហើយមានឧស្សាហ៍ខំព្យាយាមប្រឹងប្រែងដំកៀវក្លា ចាត់ការ ជាកុសល ពុំបានខ្ជិល ច្រអូសធុញទ្រាន់ឡើយ មានចាត់ចែងធ្វើការជាកុសលដទៃៗ យ៉ាងច្រើន ដំរុងរឿងចោមរោមជាបរិវារបុណ្យជាប្រធានដែលខ្លួនបានប្រារព្ធនឹងធ្វើនោះ ដរាបដល់

សម្រេចបុណ្យមួយលើកៗ ហើយតែងមានចិត្តនឹករលឹកបុណ្យដែលខ្លួនបានធ្វើហើយនោះរឿយៗ ពុំដាច់ ដោយសសង្ខារិកមហាកុសលចិត្តទាំង ៤ វៀរលែងចាកអសង្ខារិកមហាកុសលចិត្ត ៤ ចេញ គឺកុសលចិត្ត ទី ២-៤ ដែលប្រកបដោយសោមនស្សវេទនា ជាញាណសម្បយុត្តសសង្ខារិក ១ ជាញាណវិប្បយុត្តសសង្ខារិក ១ និងកុសលចិត្ត ទី ៦-៨ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណសម្បយុត្តសសង្ខារិក ១ ជាញាណវិប្បយុត្តសសង្ខារិក ១ ត្រូវជា ៤ ជាកុសលចិត្តមានបុគ្គលដទៃដឹកនាំទើបធ្វើ លុះដល់បុគ្គលនោះទទួលមរណភាពទៅ នឹងមានកុសលចេតនាណាមួយដែលមានកម្លាំងជាងដែលខ្លួនបានធ្វើហើយក្នុងបច្ចុប្បន្ននេះ កើតជាជនកកម្មតាក់តែងបដិសន្ធិឲ្យកើតជានាមរូបបដិសន្ធិក្នុងកាមសុគតិភូមិទាំង ៧ ជាន់ក្នុងបដិសន្ធិកាល ហើយញុំាងសសង្ខារិកមហាវិបាក ៤ និងអហេតុកកុសលវិបាក ៨ ត្រូវជា ១២ ឲ្យៗផលក្នុងបវត្តិកាល បានឈ្មោះថា ត្រៃហេតុឧក្រិដ្ឋទី ២ ។

ទី ២- ត្រៃហេតុឱមកៈ ចែកចេញជាពីរយ៉ាងនោះគឺ អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ គ្រាន់តែផ្ដើមបុណ្យឲ្យកើតឡើង ហើយបណ្ដោត

បណ្តោយឲ្យតែអ្នកដទៃគេធ្វើ, ឥតមានឧស្សាហ៍ខំព្យាយាមប្រឹងប្រែងដំកៀវក្លាចាត់ការជាកុសលឡើយ មានសេចក្តីខ្ជិលច្រអូសធុញទ្រាន់ច្រើន បណ្តោយឲ្យអកុសលកម្មទាំងឡាយ ចូលមកលុកលុយចោមរោមជាបរិវារបុណ្យជាប្រធាន ដែលខ្លួនបានប្រារព្ធនឹងធ្វើនោះឲ្យថយផលានិសង្សតិចទៅ មានទឹងជេរបន្ទោសអ្នកដទៃឲ្យធ្វើជាដើម ដរាបដល់សម្រេចបុណ្យមួយលើកៗ ហើយមានវិប្បដិសារី សេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដោយគិតថា អំពើដែលអញបានធ្វើហើយនេះជាអំពើដ៏អាក្រក់ពេក, ក៏បុគ្គលធ្វើបុណ្យដោយអសង្ខារិកមហាកុសល-ចិត្ត ៤ វៀរលែងចាកសសង្ខារិកកុសលចិត្ត ៤ចេញគឺ កុសលចិត្តទី ១-៣ ដែលប្រកបដោយសោមនស្សវេទនា ជាញាណសម្បយុត្ត-អសង្ខារិក ១ ជាញាណវិប្បយុត្តអសង្ខារិក ១ និងកុសលចិត្តទី ៥-៧ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណសម្បយុត្តអសង្ខារិក ១ ជាញាណវិប្បយុត្តអសង្ខារិក ១ ត្រូវជា ៤ ជាកុសលចិត្តឥតមានបុគ្គលដទៃដឹកនាំឡើយ ក៏អំពើដែលបុគ្គលបានធ្វើដោយអសង្ខារិកកុសលចិត្តទាំង ៤ ដែលជាត្រៃហេតុមានកម្លាំងខ្សោយពេក យ៉ាងនេះនឹងត្រឡប់ឲ្យផលប្រាកដស្មើដោយទ្វិហេតុឧក្រិដ្ឋវិញ គឺថានឹងមានកុសលចេតនា

ណាមួយជាជនកកម្ម តាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីក្នុងកាមសុគតិ-ភូមិទាំង ៧ ជាន់ក្នុងបដិសន្ធិកាល ហើយញ៉ាំងអសង្ខារិកមហាវិបាកជាញាណវិប្បយុត្ត ២ និងអហេតុកកុសលវិបាក ៨ ត្រូវជា ១០ ឲ្យៗ ផលក្នុងបវត្តិកាល បានឈ្មោះថា ត្រៃហេតុឱមកៈ ទី ១ ។

អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ គ្រាន់តែចូលមកផ្ដើមបុណ្យឲ្យកើតឡើងហើយបណ្ដែតបណ្ដោយឲ្យតែអ្នកដទៃគេធ្វើ ឥតមានឧស្សាហ៍ខំព្យាយាមប្រឹងប្រែងដំកៀវក្ដាចាត់ការជាកុសលឡើយ មានសេចក្ដីខ្ជិលប្រអូសធុញទ្រាន់ច្រើន បណ្ដោយឲ្យអកុសលកម្មទាំងឡាយចូលមកលុកលុយចោមរោមជាបរិវារបុណ្យជាប្រធាន ដែលខ្លួនបានប្រារព្ធនឹងធ្វើនោះឲ្យខាតផលានិសង្សតិចទៅ មានទឹងជេរបន្ទោសអ្នកដទៃជាដើម ដរាបដល់សម្រេចបុណ្យមួយលើកៗ ហើយមានវិប្បដិសារីក្ដៅក្រហាយក្នុងកាលជាខាងក្រោយ ដោយគិតថាៈ អំពើដែលអញបានធ្វើហើយនេះជាអំពើដ៏អាក្រក់ពេក ក៏បុគ្គលបានធ្វើបុណ្យដោយសសង្ខារិកមហាកុសលចិត្ត ៤ វៀរលែងចាកអសង្ខារិកមហា-កុសលចិត្ត ៤ ចេញគឺ កុសលចិត្ត ទី ២ - ៤ ដែលប្រកបដោយសោ-

មនស្សវេទនា ជាញាណសម្បយុត្តសសង្ខារិក ១ ជាញាណវិប្បយុត្តសសង្ខារិក ១ និងកុសលចិត្តទី ៦-៨ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណសម្បយុត្តសសង្ខារិក ១ ជាញាណវិប្បយុត្តសសង្ខារិក ១ ត្រូវជា ៤ ជាកុសលចិត្តមានបុគ្គលដទៃដឹកនាំទើបធ្វើ ក៏អំពើដែលបុគ្គលបានធ្វើដោយសសង្ខារិកមហាកុសលចិត្ត ៤ ជាត្រៃហេតុមានកម្លាំងខ្សោយពេកយ៉ាងនេះ នឹងត្រឡប់ឲ្យផលប្រាកដស្មើដោយទ្វិហេតុឧក្រិដ្ឋ គឺថានឹងមានកុសលចេតនាណាមួយជាជនកកម្ម តាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីក្នុងកាមសុគតិភូមិទាំង ៧ ជាន់ក្នុងបដិសន្ធិកាល ហើយញ៉ាំងសសង្ខារិកមហាវិបាកជាញាណវិប្បយុត្ត ២ និងអហេតុកកុសលវិបាក ៨ ត្រូវជា ១០ ឲ្យៗ ផលក្នុងបវត្តិកាល បានឈ្មោះថាត្រៃហេតុឱមកៈទី ២ ។

ទី ៣- ទ្វិហេតុឧក្រិដ្ឋចែកចេញជាពីរយ៉ាងនោះគឺ អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ ហើយមានឧស្សាហ៍ខំព្យាយាមប្រឹងប្រែងដ៏ក្លៀវក្លា ចាត់ការជាកុសលពុំបានខ្ជិលច្រអូសធុញទ្រាន់ឡើយ មានចាត់ចែងធ្វើការជាកុសលដទៃ ៗ យ៉ាងច្រើនជាបរិវារបុណ្យជាប្រធានដែល

ខ្លួនបានប្រារព្ធនឹងធ្វើនោះ ដរាបដល់សម្រេចបុណ្យមួយលើកៗ ហើយតែងមានចិត្តនឹករឭកបុណ្យដែលខ្លួនបានធ្វើហើយនោះរឿយៗ ពុំដាច់ដោយអសង្ខារិកមហាកុសលចិត្តទាំង ២ វៀរលែងចាកសសង្ខារិកមហាកុសលចិត្ត ២ ចេញ គឺកុសលចិត្តទី ៣ ដែលប្រកបដោយសោមនស្សវេទនា ជាញាណវិប្បយុត្តអសង្ខារិក ១ និងកុសលចិត្តទី ៧ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណវិប្បយុត្តអសង្ខារិក ១ ជាកុសលចិត្តកើតសេចក្តីជ្រះថ្លាដោយខ្លួនឯងឥតមានបុគ្គលដទៃដឹកនាំឡើយ លុះដល់បុគ្គលនោះទទួលមរណភាពទៅ នឹងមានកុសលចេតនាណាមួយមានកម្លាំងខ្លាំងជាង កើតជាជនកកម្មតាក់តែងបដិសន្ធិឲ្យកើតជានាមរូបថ្មីក្នុងកាមសុគតិភូមិទាំង ៧ ជាន់ ក្នុងបដិសន្ធិកាល ហើយញុំាងអសង្ខារិកមហាវិបាកជាញាណវិប្បយុត្ត ២ និងអហេតុកកុសលវិបាក ៨ ត្រូវជា ១០ ឲ្យៗ ផលក្នុងបវត្តិកាល បានឈ្មោះថា ទ្វិហេតុឧក្រិដ្ឋទី ១ ។ អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ រមែងមានឧស្សាហ៍ព្យាយាមប្រឹងប្រែងដំកៀវក្លា ចាត់ការជាកុសលពុំបានខ្ជិលច្រអូសធុញទ្រាន់ឡើយ មានចាត់ចែងធ្វើការជាកុសលដទៃៗ យ៉ាងច្រើនជាបរិវារបុណ្យ ជាប្រធាន

ដែលខ្លួនបានប្រារព្ធនឹងធ្វើនោះ ដរាបដល់សម្រេចបុណ្យមួយលើកៗ ហើយតែងមានចិត្តនឹករឭកបុណ្យ ដែលខ្លួនបានធ្វើហើយនោះរឿយៗ ពុំដាច់ ដោយសសង្ខារិកមហាកុសលចិត្តទាំង ២ វៀរលែងចាកអសង្ខា-រិកមហាកុសលចិត្ត ២ ចេញ គឺកុសលចិត្តទី ៤ ដែលប្រកបដោយសោមនស្សវេទនា ជាញាណវិប្បយុត្តសសង្ខារិក ១ និងកុសលចិត្តទី ៨ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណវិប្បយុត្តសសង្ខារិក ១ ត្រូវជា ២ ជាកុសលចិត្តកើតដោយបុគ្គលដទៃដឹកនាំ ទើបកើតសេចក្តីជ្រះថ្លា ក្មៀវក្លាឡើងហើយធ្វើ លុះដល់បុគ្គលនោះទទួលមរណកាលទៅ នឹងមានកុសលចេតនាណាមួយមានកម្លាំងខ្លាំងជាងកើតជាជនកកម្មតាក់តែងបដិសន្ធិឲ្យកើតជានាមរូបប្អូក្នុងកាមសុគតិភូមិទាំង ៧ ជាន់ ក្នុងបដិសន្ធិកាល ហើយញ៉ាំងសសង្ខារិកមហាវិបាកជាញាណវិប្បយុត្ត ២ និងអហេតុកកុសលវិបាក ៨ ត្រូវជា ១០ ឲ្យៗ ផលក្នុងបវត្តិកាលបានឈ្មោះថា ទ្វិហេតុឧក្រិដ្ឋ ទី ២ ។

ទី ៤- ទ្វិហេតុឱមកៈបែកចេញជាពីរយ៉ាងនោះ គឺ អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ ជាបុគ្គលឥតមានសទ្ធាពុំបានជឿកម្មផល ពុំបាន

ត្រេកអរជ្រះថ្លាក្នុងការជាកុសលប៉ុន្មានឡើយ ធ្វើដោយមានសេចក្ដីរង្កៀសទើសទាល់នឹងញាតិមិត្តសំឡាញ់ ដែលនៅផ្ទះជិតខាងគេតែងធ្វើបុណ្យឲ្យទានរឿយៗ ហើយក៏ចាត់ចែងធ្វើទៅ ព្រោះខ្លាចគេរិះគន់ប៉ុណ្ណោះ មានសេចក្ដីខ្ជិលច្រអូសធុញទ្រាន់ច្រើន ពុំបានជួយចាត់ចែងការជាកុសលមាំមួនឡើយ ធ្វើដោយអសង្ខារិកមហាកុសលចិត្តទាំង ២ គឺកុសលចិត្តទី ៣ ដែលប្រកបដោយសោមនស្សវេទនា ជាញាណវិប្បយុត្តអសង្ខារិក ១ កុសលចិត្តទី ៧ ដែលប្រកបដោយឧបេក្ខាវេទនា ជាញាណវិប្បយុត្តអសង្ខារិក ១ ត្រូវជា ២ ជាកុសលចិត្តកើតឡើងដោយខ្លួនឯង ឥតមានអ្នកដទៃដឹកនាំឡើយ លុះបានធ្វើបុណ្យឲ្យទានរួចហើយមានវិប្បដិសារី ក្ដៅក្រហាយជាខាងក្រោយពុំមានសេចក្ដីជ្រះថ្លារីករាយឡើយ ក៏អំពើបុណ្យទានដែលបុគ្គលបានធ្វើដោយអសង្ខា-រិកកុសលចិត្តទាំង ២ មានកម្លាំងខ្សោយពេកយ៉ាងនេះនឹងត្រឡប់ឲ្យផលជាអហេតុកកំណើតវិញគឺ ឧបេក្ខាសហគតសន្តីរណអហេតុកវិបាកជាតួបដិសន្ធិតាក់តែងនាមរូបថ្មី ឲ្យកើតឡើងក្នុងឋានមនុស្សនេះ មានកើតជាមនុស្សខ្វាក់ ថ្លង់ គអំពីកំណើតជាដើមក្នុងបដិសន្ធិកាល ហើយញុំាងអហេតុកកុសលវិបាកទាំង ៨ ឲ្យៗ ផលក្នុងបវត្តិកាល បានឈ្មោះ

ថា ទ្វិហេតុឱមកៈ ទី ១ ។

អំពើដែលបុគ្គលបានធ្វើដោយកុសលចេតនាមួយ ក្នុងខណៈធ្វើបុណ្យឲ្យទានមួយលើកៗ ក្នុងជាតិនេះ ជាបុគ្គលឥតមានសទ្ធាពុំបានជឿកម្ម-ផល ពុំបានត្រេកអរជ្រះថ្លាក្នុងការជាកុសលប៉ុន្មានឡើយ ធ្វើដោយមានញាតិ មិត្តសំឡាញ់ចូលមកនិយាយបបួលដឹកនាំឲ្យចូលធ្វើបុណ្យឲ្យទាន ក៏មានសេចក្តីទើសទាល់ចូលធ្វើបុណ្យនឹងគេទៅ ហើយមានសេចក្តីខ្ជិលច្រអូសធុញទ្រាន់ច្រើន ពុំបានជួយចាត់ចែងការជាកុសលមាំមួនឡើយ ធ្វើដោយសសង្ខារិកកុសលចិត្តទាំង ២ គឺកុសល-ចិត្តទី ៤ ដែលប្រកបដោយសោមនស្សវេទនា ជាញាណវិប្បយុត្ត-សសង្ខារិក ១ កុសលចិត្តទី ៨ ដែលប្រកបដោយឧបេក្ខាវេទនាជាញាណ-វិប្បយុត្តសសង្ខារិក ១ ត្រូវជា ២ ជាកុសលចិត្តមានបុគ្គលដទៃចូលមកដឹកនាំទើបធ្វើ លុះធ្វើបុណ្យឲ្យទានរួចហើយមានវិប្បដិសារី ក្តៅក្រហាយជាខាងក្រោយ ពុំមានសេចក្តីជ្រះថ្លារីករាយឡើយ ក៏អំពើបុណ្យទានដែលបុគ្គលបានធ្វើដោយសសង្ខារិកកុសលចិត្តទាំង ២ មានកម្លាំងខ្សោយពេកយ៉ាងនេះនឹងត្រឡប់ឲ្យផលជាអហេតុកកំណើតវិញ គឺ ឧបេក្ខាសហ-គតសន្តីរណអហេតុកវិបាកជាតួបដិសន្ធិតាក់តែងនាមរូបថ្មី ឲ្យកើតឡើង

ក្នុងឋានមនុស្សនេះ ក្នុងបដិសន្ធិកាល ហើយញ៉ាំងអហេតុកកុសល វិបាកទាំង ៨ ឲ្យៗ ផលក្នុងបវត្តិកាល បានឈ្មោះថា ទ្វិហេតុឱមកៈ ទី ២ ។ សម្តែងចំណែកខាងកាមាវចរកុសលកម្ម អំពើដែលបុគ្គលបានធ្វើដោយកាមាវចរកុសលចិត្តប្រព្រឹត្តទៅដោយទ្វារទាំង ៣ មានកាយទ្វារជាដើម ចប់ដោយសង្ខេប ។

ឯរូបាវចរកុសលកម្ម អំពើដែលយោគាវចរកុលបុត្រខំហាត់ចិត្តចំរើនសមថកម្មដ្ឋាន និងវិបស្សនាកម្មដ្ឋាន ដោយភាវនាប្រព្រឹត្តទៅក្នុងមនោទ្វារនោះ លោកសម្តែងចែកជា ៣ យ៉ាងគឺ បរិត្ត យ៉ាងតិចស្តើង ១ មជ្ឈិម យ៉ាងមធ្យមជាកណ្តាល ១ បណីត យ៉ាងឧត្តមខ្ពង់ខ្ពស់ ១ សេចក្តីថា បើយោគាវចរកុលបុត្រចម្រើនបានបឋមជ្ឈានយ៉ាងតិចស្តើងច្យុតទៅកើតក្នុងជាន់ព្រហ្មបារិសជ្ជា យ៉ាងមធ្យមជាកណ្តាល ច្យុតទៅកើតក្នុងជាន់ព្រហ្មបុរោហិតា យ៉ាងឧត្តមខ្ពង់ខ្ពស់ច្យុតទៅកើតក្នុងជាន់មហាព្រហ្ម កើតតាមលំដាប់ឈានជាន់ទាប កណ្តាល ខ្ពង់ខ្ពស់ គ្រប់ឋានព្រហ្មទាំង ១០ ជាន់ វៀរលែងតែអសញ្ញីសត្វនិងសុទ្ធាវាសភូមិទាំង ៥ ជាន់ចេញ ។ ចំណែកឯអរូបាវចរកុសលកម្ម អំពើដែលយោគាវចរកុលបុត្របានចម្រើនបានអរូបជ្ឈានទាំង ៤ ហើយ នឹងច្យុតទៅ

កើតក្នុងឋានអរូបព្រហ្មទាំង ៤ ជាន់តាមលំដាប់ឈានដោយពិត ។ ចំណែកឯព្រះអនាគាមិបុគ្គលទាំងឡាយ ដែលលោកបានចម្រើនបញ្ចមជ្ឈាន កើតឡើងហើយ តែលោកច្យុតទៅតែងកើតក្នុងសុទ្ធាវាសភូមិទាំង ៥ ជាន់ដោយចំណែកមួយពិត ។ បពិត្រធម្មវាទី ខ្ញុំអត្ថវាទីបានវិសជ្ជនាមកអំពីឧក្កដ្ឋកម្មនិងឱមកកម្ម អំពើដែលបុគ្គលបានធ្វើយ៉ាងឧត្តមខ្ពង់ខ្ពស់ និងអំពើដែលបុគ្គលបានធ្វើយ៉ាងជាន់ទាបថយថោក តែងឲ្យផលផ្សេងៗ គ្នាជាសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

៩៦- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវាទី ចុះចំណែកខាងលោកុត្តរធម៌ទី ៩ ដែលមានឈ្មោះថា ព្រះនិព្វានៗ នោះ សម្ដែងដោយសភាវៈមាន ១ សម្ដែងដោយហេតុមាន ២ សម្ដែងដោយអាការៈមាន ៣ មានសេចក្ដីផ្សេងគ្នាដូចម្ដេចខ្លះ? ចូរលោកវិសជ្ជនាឲ្យពិស្ដារសព្វគ្រប់មកយើងនឹងបានស្ដាប់ចូលចិត្តផងមើល!

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ទី ១ ព្រះនិព្វានសម្ដែងដោយសភាវៈ មាន ១ នោះអធិប្បាយថា មគ្គញ្ញាណ ប្រាជ្ញាដឹងច្បាស់នូវព្រះនិព្វានកើតរលត់ប្រព្រឹត្តទៅជាមួយនឹងមគ្គទាំង ៤ ឯណា ផលញ្ញាណ ប្រាជ្ញាដឹងច្បាស់នូវព្រះនិព្វានកើតរលត់ប្រព្រឹត្តទៅជាមួយនឹង

ផលទាំង ៤ ឯណា មគ្គញ្ញាណផលញ្ញាណទាំងពីរនោះៗ តែងឱន ហូរជ្រុលទៅជ្រកស៊ប់សួនក្នុងសន្តិលក្ខណដ្ឋាន ទីកន្លែងដែលស្ងប់រម្ងាប់ចាកកងទុក្ខទាំងពួងជាលក្ខណៈរបស់ផលញ្ញាណ ហើយចាប់ថ្ពក់តោង ជាប់នូវសន្តិលក្ខណដ្ឋានរបស់ខ្លួននោះមកជាអារម្មណ៍ ជាទីត្រេកអរពុំ ដាច់ ឬថា មគ្គញ្ញាណនិងផលញ្ញាណបានចេញចាកព្រៃគឺតណ្ហា ១០៨ ទិដ្ឋិ ៦២ មានះ ៩ ជាស្រឡះ ពុំបានជាប់ជំពាក់សោះឡើយ ឬថា ផលញ្ញាណរំលត់រលាស់កាត់ចោលចេញនូវព្រៃស្បាត គឺតណ្ហា ទិដ្ឋិ មានះ ជាស្រឡះពុំបានឲ្យសេសសល់ឡើយ បានឈ្មោះថា ព្រះនិព្វាន ពិត ។ មួយវិញទៀត សម្តេចព្រះសព្វញ្ញូសម្ពុទ្ធជាអម្ចាស់ទ្រង់ត្រាស់សម្តែងសរសើរថា បទំ ចំណែកបរមត្ថធម៌ដ៏ខ្ពង់ខ្ពស់ប្រសើរឯក ប្លែក ជាងលោកិយធម៌ទាំងអស់ អច្ចុតំ មានគុណវិសេសជាថាវរដ្ឋាន ទីកន្លែង មាំមួននៅពុំបានកក្រើកឃ្លាតចេញគឺមិនបានស្លាប់សោះ អច្ចន្តំ មាន គុណអាចប្រព្រឹត្តកន្លងបង់នូវទីបំផុត ចាកកិលេសធម៌ទាំងអស់មានរាគៈជាដើមជាស្រឡះ អសំខតំ ជាគុណជាតគឺបច្ច័យប្រជុំតាក់តែងពុំបានឡើយ អនុត្តរំ រកវត្ថុដទៃប្រសើរលើសលុបពុំមាន ធិព្វានំ ព្រះអង្គទ្រង់ឲ្យ

ឈ្មោះថាព្រះនិព្វានដោយពិត ។ ទី ២- សម្តែងដោយហេតុមាន ២ នោះគឺ សឧប្បាទិសេសានិព្វានធាតុ ព្រះនិព្វានធាតុដែលប្រព្រឹត្តទៅជាមួយនឹងបញ្ចក្ខន្ធជាគ្រឿងសៅហ្មងគឺតណ្ហា ទិដ្ឋិ មានះ តែងប្រកាន់មាំដ៏សល់នៅដោយកិរិយាធ្វើឲ្យជាអារម្មណ៍ ១ អនុបាទិសេសានិព្វានធាតុ ព្រះនិព្វានធាតុដែលប្រព្រឹត្តទៅជាមួយនឹងបញ្ចក្ខន្ធជាគ្រឿងសៅហ្មងដែលតណ្ហា ទិដ្ឋិ មានះ តែងប្រកាន់មាំសល់នៅពុំមានសោះឡើយ គឺជាព្រះខីណាស្រពដែលលោកបានរំលត់ខន្ធទាំងប្រាំដែលជាគ្រឿងប្រកាន់មាំនៃតណ្ហា ទិដ្ឋិ មានះ ឲ្យសូន្យអស់ពុំឲ្យមានសេសសល់ឡើយ ហើយលោកចូលកាន់ព្រះនិព្វាន ១ ។ ទី ៣- សម្តែងដោយអាការៈមាន ៣ នោះគឺ ១- សុន្ទរដ្ឋាន ទីតាំងយ៉ាងល្អប្រពៃជាឋានសូន្យស្ងាត់ ចាកសម្បយោគធម៌ ដែលជាគ្រឿងប្រកបព្រមនៃកងកិលេសកើតឡើងជាអារម្មណ៍ផង សូន្យស្ងាត់ចាករាគៈ ទោសៈ មោហៈទាំងឡាយផង សូន្យស្ងាត់ចាកសង្ខារធម៌ទាំងឡាយផង បានឈ្មោះថាសុញ្ញតនិព្វានពិត ។ ២- សុន្ទរដ្ឋាន ទីតាំងយ៉ាងល្អប្រពៃប្រាសចេញចាកនិមិត្ត គឺជារាគៈ ទោសៈ មោហៈ និងសង្ខារធម៌ទាំងឡាយជានិមិត្តតាក់តែងនាមរូបថ្មីឲ្យកើតទៀតពុំបានឡើយ បានឈ្មោះថា អនិមិត្ត-

និព្វានពិត ។ ៣- សុន្ទរដ្ឋាន ទីតាំងយ៉ាងល្អប្រពៃឥតទីតាំងទីតម្កល់នៃរាគៈ ទោសៈ មោហៈ និង តណ្ហា ទិដ្ឋិ មានះ សោះឡើយ ជាសិវដ្ឋាន ជាឋានដ៏ទៀងសម្រាប់សោយសុខក្សេមក្សាន្តដោយចំណែកមួយពិត បានឈ្មោះថាអប្បណិហិតនិព្វានពិត ។ មួយទៀត តាមន័យក្នុងព្រះសូត្រលោកសម្តែងសរសើរគុណនាមព្រះនិព្វានមាន ៨ យ៉ាង គឺ មទនិមទនដ្ឋានំ ទីឋានដែលញាំញីលម្អិតនូវគ្រឿងស្រវឹង គឺ វយៈ អរោគៈ ជីវិតៈ ជាដើមឲ្យវិនាសអស់ទៅជាស្រឡះ ១ បិបាសវិនយដ្ឋានំ ទីឋានសម្រាប់បន្ទោបង់នូវសេចក្តីសម្រេកស្រេកឃ្លានក្នុងកាមគុណទាំងប្រាំជាស្រឡះ ១ អាលយសមុគ្ឃាតដ្ឋានំ ទីឋានសម្រាប់ដីកគាស់រំលើងឡើង នូវសេចក្តីអាល័យជំពាក់ជាប់នៅក្នុងកាមគុណទាំងប្រាំជាស្រឡះ ១ វដ្តុប្បច្ឆេទដ្ឋានំ ទីឋានសម្រាប់កាត់ផ្តិលផ្តាច់នូវចក្រដែលវិលត្រឡប់ទៅមកក្នុងភពទាំង ៣ ជាស្រឡះ ១ តណ្ហាក្ខយដ្ឋានំ ទីឋានសម្រាប់ក្ស័យអស់ទៅនៃតណ្ហាទាំងអស់ជាស្រឡះ ១ វិរាគដ្ឋានំ ទីឋានសម្រាប់ដល់នូវសេចក្តីនឿយណាយ ចាកតណ្ហាទាំងអស់ជាស្រឡះ ១ និរោធដ្ឋានំ ទីឋានសម្រាប់រំលត់បង់នូវកងទុក្ខទាំងអស់ដែលប្រជុំកើត

ឡើងអំពីតណ្ហាជាស្រឡះ ១ និព្វានដ្ឋានំ ទីឋានសម្រាប់ចេញចាកវានបទេសគឺ តណ្ហាជាស្រឡះ ១ ក៏ទីកន្លែងទាំងអស់ ៨ ឋាននេះបានឈ្មោះថា ព្រះនិព្វានដោយពិត ។ វិសជ្ជនាមកអំពីរឿងព្រះនិព្វានមាន ១ ២ ៣ ជាសេចក្តីពិស្តារខ្លះ សង្ខេបខ្លះ តែប៉ុណ្ណោះឯង ។

៩៧- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី ចុះទីឋានព្រះនិព្វាននោះឋិតនៅក្នុងឋានមនុស្សឬឋានទេវតាឋានព្រហ្ម ឬព្រះនិព្វាននោះឋិតនៅក្នុងឋានដទៃអំពីឋានទាំងនេះទៅឬដូចម្តេច? ចូរលោកវិសជ្ជនាឲ្យច្បាស់លាស់មក យើងនឹងស្តាប់ចូលចិត្តអស់សង្ស័យផងមើល!

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯទីឋានព្រះនិព្វាននោះឋិតនៅក្នុងលោកទាំង ៣ ឬថាក្នុងភពទាំង ៣ ក៏មាន ឋិតនៅក្នុងទីបំផុតលោកទាំង ៣ ឬថាទីបំផុតភពទាំង ៣ ក៏មាន ព្រោះព្រះនិព្វាននោះមានឈ្មោះ ២ យ៉ាង គឺ ១ កិលេសនិព្វាន បានខាងព្រះអរិយ-បុគ្គលទាំង ៨ ពួក ដែលលោកបានពិចារណាឃើញទោសក្នុងលោកឬភពទាំង ៣ ជាក់ច្បាស់ហើយខំព្យាយាមចម្រើនភាវនាសមថកម្មដ្ឋាន ឬវិបស្សនាកម្មដ្ឋាន ហើយបានយឹតយោងទាញយកលោកិយចិត្តជាកាមា-

វចរក្ដី រូបាវចរក្ដី អរូបាវចរក្ដី ឲ្យបែរឆាកមកកាន់ព្រះអរិយគោត្រ កើតរលត់ព្រមជាមួយនឹងមគ្គដែលប្រកបដោយអង្គទាំង ៨ មានសម្មាទិដ្ឋិជាដើម បានឈ្មោះថា សោតាបត្តិមគ្គចិត្ត ហៅថា លោកុត្តរកុសល-ចិត្តទី ១ វិបាកជាផលកើតមកអំពីលោកុត្តរកុសលចិត្តទី ១ នោះ បានឈ្មោះថា សោតាបត្តិផលចិត្ត ហៅថា លោកុត្តរវិបាកចិត្តទី ២ ក៏ព្រះអរិយបុគ្គលដែលលោកបានសម្រេចមគ្គ ផលតាំងពីសោតាបត្តិមគ្គជាដើមឡើងទៅជាលំដាប់ៗ ហើយលោកលះបង់នូវកងកិលេសទាំងពួង តាំងពីកងកិលេសយ៉ាងតូចតិចជាលំដាប់ឡើងទៅ លុះដល់លោកបានសម្រេចព្រះអរហត្តផលញ្ញាណពេញទី ទើបលោកអាចកាត់ផ្ដិលផ្ដាច់នូវកងកិលេសទាំងឡាយ ដោយសមុច្ឆេទប្បហានអស់ពុំមានសេស-សល់ក្នុងសន្ដានលោកឡើយ បានឈ្មោះថា កិលេសនិព្វាន រំលត់កិលេសអស់ជាអង្គព្រះខីណាស្រពពិត ឋិតនៅក្នុងលោកនេះ ភពនេះព្រោះអាយុសង្ខាររបស់លោកពុំទាន់អស់នៅឡើយ បើលោកបានសម្រេចកិលេសនិព្វានឋានមនុស្ស ក៏លោកឋិតនៅក្នុងឋានមនុស្សដែរ បើលោកបានសម្រេចកិលេសនិព្វាននាឋានសួគ៌ ឬឋានព្រហ្ម ក៏លោកឋិតនៅក្នុងឋានសួគ៌ ឬឋានព្រហ្មនោះដែរ តាមកំណត់អាយុសង្ខាររបស់

លោកដោយពិត ។ ២ ខន្ធនិព្វាន បានខាងព្រះខីណាស្រព ដែលលោកមានអាយុសង្ខារដល់កំណត់អស់ហើយៗ លោករំលត់ខន្ធទាំង ប្រាំជាលោកិយអស់ពុំមានសេសសល់ឡើយ នៅមានតែផលញ្ញាណ ដ៏ថ្លាស្អាតបរិសុទ្ធភ្លឺស្វាងរុងរឿង ជាសារធម៌ដ៏មានខ្លឹមសារល្អិតវិសេស ក្រៃលែង ចូលកាន់មហានគរកែវ គឺព្រះនិព្វាន មានផលជវនសោយនូវ រសនៃព្រះនិព្វានជាអារម្មណ៍ ជាអព្យាកតធម៌ ជាសុខក្សេមក្សាន្តពុំបាន លាយច្រឡំទៅដោយកងទុក្ខឡើយ បានឈ្មោះថាខន្ធនិព្វាន ឋិតនៅក្នុង ទីបំផុតលោក ទីបំផុតភព ដោយចំណែកតែមួយពិត ។

វិសជ្ជនាមកអំពីទីឋានព្រះនិព្វានឋិតនៅក្នុងលោក ក្នុងភព និងឋិត នៅក្នុងទីបំផុតលោក ទីបំផុតភព ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

៩៨- ធម្មវាទី បានស្តាប់ហើយសួរទៀតថា ម្នាលអត្តវាទី ចុះពាក្យថា ទីបំផុតលោកមាន ៣ និងទីបំផុតភពមាន ៣ សេចក្តីដូច គ្នាទេ ឬផ្សេងគ្នាយ៉ាងណាខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបាន ស្តាប់ផងមើល!

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឯពាក្យថា ទីបំផុត លោកមាន ៣ និងទីបំផុតភពមាន ៣ នោះ មានអត្ថរសដូចគ្នាខ្លះ ផ្សេង

គ្មាខ្វះ ដូចអធិប្បាយតទៅនេះ ។ ក៏ទីបំផុតលោក ទីបំផុតភពចែកជា ៣ យ៉ាង គឺ កាមភូមិទាំង ១១ ជាន់ រាប់តាំងពីឋាននរកទី ១ ដរាបទៅដល់ឋាន បរនិម្មិតវសវត្តីទី ១១ ត្រូវជា ១១ ជាន់ បានឈ្មោះថា ទីបំផុតកាម-លោក កាមភពទី ១ ជាខាងក្រោម រូបភូមិទាំង ១៦ ជាន់ រាប់តាំង ពីឋានព្រហ្មបារិសជ្ជាទី ១ ដរាបទៅដល់ឋានអកនិដ្ឋព្រហ្មទី ១៦ ត្រូវជា ១៦ ជាន់ បានឈ្មោះថា ទីបំផុតរូបលោក រូបភពទី ២ ជាកណ្តាល ។ អរូបភូមិទាំង ៤ ជាន់ រាប់តាំងពីឋានអាកាសានញ្ចាយតនអរូបព្រហ្មទី ១ ដរាបទៅដល់ឋាននេវសញ្ញានាសញ្ញាយតនអរូបព្រហ្ម ទី ៤ ត្រូវជា ៤ ជាន់ បានឈ្មោះថា ទីបំផុតអរូបលោក អរូបភពទី ៣ ជាខាង លើបំផុតគ្មានលោកគ្មានភពតទៅទៀតឡើយ ។ ក៏ពាក្យថា ទីបំផុត លោកមាន ៣ សេចក្តីអធិប្បាយដូចគ្នាពិត ប្លែកគ្នាតែត្រង់លោកស័ព្ទ និងភវស័ព្ទមានអត្ថរសផ្សេងគ្នាដូច្នេះ លោកស័ព្ទប្រែថា កើតឡើង ហើយតែងវិនាសរលាយសូន្យទៅវិញ ឬថាលិចអណ្តែតៗ គ្មានទៀង សោះឡើយ ភវស័ព្ទ ប្រែថា ញ៉ាំងនាមរូបថ្មីឲ្យកើតឡើង គឺថាអំពើ ដែលសត្វទាំងឡាយបានធ្វើល្អក្តី អាក្រក់ក្តី ដោយចេតនាឯណា, ចេតនានោះកើតជាជនកកម្ម ញ៉ាំងផលរបស់ខ្លួនឲ្យតាក់តែងនាមរូបថ្មី ឲ្យ

កើតឡើងក្នុងឋាននោះៗ បានឈ្មោះថា ភពឬកម្មភព ដោយពិត ។

វិសជ្ជនាមកអំពីពាក្យថា លោក ៣ ភព ៣ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណេះឯង ។

៩៩- ធម្មវាទី បានស្ដាប់ហើយសួរតទៅទៀតថា ម្នាលអត្ថវាទី ចុះទីបំផុតលោក ទីបំផុតភព មាន ៣ នោះ តើឋានព្រះនិព្វាន ឋិតនៅក្នុងទីបំផុតលោក ទីបំផុតភពណា? មានចម្ងាយអំពីឋានមនុស្សនេះទៅប៉ុន្មាន? វាស់បានដែរឬទេ? បើវាស់ពុំបានទេ តើមានសេចក្ដីឧបមាដូចម្ដេច? ចូរលោកវិសជ្ជនាឲ្យច្បាស់លាស់មក យើងនឹងស្ដាប់ចូលចិត្តបានដោយងាយផងមើល!

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី អ្នកប្រាជ្ញទាំងឡាយលោកតែងសម្ដែងប្រាប់ពន្យល់ថា លោកគ្គំ និព្វានំ ភវគ្គំ និព្វានំ សេចក្ដីថា ព្រះនិព្វានឋិតនៅក្នុងទីបំផុតលោក ទីបំផុតភពទី ៣ ជាខាងលើឋាននេវសញ្ញានាសញ្ញាយតនអរូបព្រហ្មទី ៤ ដូចមានបាលីបទវិគ្គហៈក្នុងដីកា អនុដីកាព្រះអភិធម្មត្ថសង្គហៈជាដើមថា "កាមរូបារូបសំខាតលោកតោ ឧត្តរតិ គតោ វា សត្តេ ឧទ្ធំ និព្វានំ តារេតីតិ

លោកុត្តរំ” សេចក្ដីថា អគ្គមគ្គញ្ញាណឯណា បានឆ្លងផុត ចាកកាមលោក រូបលោក អរូបលោក ជាស្រឡះ អគ្គមគ្គញ្ញាណនោះបានឈ្មោះថា លោកុត្តរៈ ឆ្លងផុតចាកលោកទាំង ៣ ជាស្រឡះពិត ម្យ៉ាងវិញទៀតអគ្គផលញ្ញាណឯណា ញុំាងសត្វទាំងឡាយឲ្យឆ្លងផុតទៅ កាន់ឋានព្រះនិព្វានជាខាងលើបំផុត ចាកលោកទាំង ៣ ជាស្រឡះ អគ្គផលញ្ញាណនោះបានឈ្មោះថា លោកុត្តរៈ ញុំាងសត្វទាំងឡាយឲ្យឆ្លងផុតទៅកាន់ឋាននិព្វានជាខាងលើចាកលោកទាំង ៣ ជាស្រឡះពិត ។ បានសេចក្ដីថា ឋានព្រះនិព្វាននោះ ស្ថិតនៅក្នុងទីបំផុតលោកទាំង ៣ ដ៏ឆ្ងាយក្រៃលែងណាស់អំពីឋានមនុស្សលោកយើងនេះ វាស់រាប់យោជន៍ក៏ពុំបាន ស្មានក៏ពុំត្រូវឡើយ, តែថាមានសេចក្ដីធៀបឧបមាក្នុងគម្ពីរលោកទីបកកថា លោកបានសម្ដែងធៀបពន្យល់ ល្មមស្ដាប់បានដោយបាលីឧបមាថា សព្វភវគ្គេ បតិតាន កុដាគារសមាសិលា បាតិតា តីហិ វស្សេហិ ទ្វិមាសេហិ ប អដ្ឋហិ រត្តិន្ទិវេហិ អធិកំ ។ ល ។ ឯវន្តុ តីហិ វស្សេហិ ទ្វេ-មាសដ្ឋទិនេហិ តុ បតុវីសតិតាទីហិ ភូមិតលមុបាបុណិ ។ អធិប្បាយថា ផែនថ្មយ៉ាងធំប៉ុនផ្ទះកំពូលដែលទេវតាវិសេសមានមហិទ្ធានុ-ភាពច្រើន ឋិតនៅក្នុងទីបំផុតភពហើយលើកឡើងទម្លាក់ចុះមកកាន់ឋាន

មនុស្សលោកយើងនេះធ្លាក់មកយ៉ាងរហ័សអស់កាលយូរចំនួន ៣ ឆ្នាំ ២ ខែ ក្រៃលែងដោយយប់និងថ្ងៃ ៨ ថែមទៀត ។ ល ។ លុះដល់ផែនថ្មនោះធ្លាក់ចុះមកជាយូរអង្វែងណាស់ ចំនួន ៣ ឆ្នាំ ២ ខែ ៨ ថ្ងៃ ២៤ នាទី ទើបដល់ផ្ទៃនៃផែនដីមនុស្សលោកយើងនេះ គ្រាន់តែសឹកដោយខ្យល់សល់នៅប៉ុនផ្លែក្រូចសើចប៉ុណ្ណោះ ឃើញថាឆ្ងាយណាស់ ឧបមាយ៉ាងណាទីឋានព្រះនិព្វានដែលឋិតនៅក្នុងទីបំផុតកពកឆ្ងាយណាស់ ឧបមាយ៉ាងនោះដែរ ។ វិសជ្ជនាមកអំពីឋានព្រះនិព្វាន ឋិតនៅក្នុងទីបំផុតលោកបំផុតកភព និងសេចក្តីឧបមា ដោយសង្ខេបតែប៉ុណ្ណោះឯង ។

១០០- ធម្មវាទី បានស្តាប់ហើយពោលថា អើអត្តវាទី បើឋានព្រះនិព្វាន ឋិតនៅក្នុងទីឆ្ងាយពេកយ៉ាងនេះ តើព្រះវិញ្ញាណស្រពដែលលោករំលត់ខន្ធទាំងប្រាំជាស្រឡះហើយ ឡើងទៅកាន់ឋានព្រះនិព្វានចំនួនប៉ុន្មានឆ្នាំ ខែ ថ្ងៃទៅ ទើបដល់ឋានព្រះនិព្វាន ឬទៅដល់មួយរំពេចទេ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល!

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ឋានព្រះនិព្វាននៅឆ្ងាយពិតមែនហើយ តែថាព្រះវិញ្ញាណស្រពដែលលោកបានរំលត់ខន្ធចូលកាន់ឋានព្រះនិព្វានមិនយឺតយូរទេ ដល់មួយរំពេច ព្រោះព្រះវិញ្ញាណស្រព

ទាំងអស់លោកមានផលញ្ញាណ ឱនហូរជ្រុលទៅជ្រកស៊ប់សួនក្នុង ព្រះនិព្វាន ចាប់ថ្ពក់តោងយកព្រះនិព្វានមកជាអារម្មណ៍ជាប់ជានិច្ច តែលោកបានរំលត់ខន្ធទាំងប្រាំជាស្រឡះហើយ លោកចូលកាន់ឋាននិព្វានមួយរំពេច ពុំបានយឺតយូរឡើយ ដូចបុរសឈរលើកាំជណ្តើរខាងលើបំផុត តែឈានជើងឡើងផុតពីកាំជណ្តើរហើយ បានឈ្មោះថា បុរសនោះចូលក្នុងប្រាសាទស៊ប់សួនមួយរំពេចពិត មានឧបមាយ៉ាងណា ព្រះខីណាស្រពទាំងអស់ តែលោកបានរំលត់ខន្ធទាំងប្រាំជាស្រឡះហើយលោកចូលកាន់ប្រាសាទកែវ គឺឋានព្រះនិព្វានមួយរំពេចពិត មានឧបមេយ្យដូច្នោះឯង ។ មួយវិញទៀត មនុស្សដែលមានជំងឺឈឺជាទម្ងន់ជិតស្លាប់ បើជវនចិត្តឱនហូរជ្រុលទៅជ្រកស៊ប់សួនក្នុងភពណា តែច្យុតទៅហើយកើតឡើងក្នុងភពនោះមួយរំពេច ពុំបានយឺតយូរឡើយមានឧបមាយ៉ាងណា ព្រះអរហន្តទាំងឡាយ លោកតែងមានផលញ្ញាណឱនហូរជ្រុលទៅជ្រកស៊ប់សួនក្នុងព្រះនិព្វានជាអារម្មណ៍ ជាប់មិនដាច់ តែលោកបានរំលត់ខន្ធទាំងប្រាំជាស្រឡះហើយ លោកកើតឡើងក្នុងមហានគរគឺព្រះនិព្វានមួយរំពេចពុំបានយឺតយូរឡើយ មានឧបមេយ្យយ៉ាងនោះឯង ។ វិសជ្ជនាមកអំពីព្រះខីណាស្រពរំលត់ខន្ធ

ចូលកាន់ព្រះនិព្វានយូរឆាប់ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

១០១- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាល អត្ថវាទី ចុះពាក្យថា មហានគរ គឺព្រះនិព្វាន និងពាក្យថា មហានគរក្នុងលោកិយនេះ គ្រឿងប្រដាប់សម្រាប់លម្អក្នុងមហានគរទាំងពីរនេះ មានផ្សេងគ្នា ឬដូចគ្នាទេ? ធម្មតាមហានគរក្នុងលោកនេះតែងមានគ្រឿងប្រដាប់សម្រាប់លម្អព្រះនគរ មានផ្លូវថ្នល់តូច ធំ ខ្វាត់ខ្វែងជាដើមជាទីលម្អព្រះនគរ ចុះមហានគរគឺព្រះនិព្វាន មានគ្រឿងប្រដាប់សម្រាប់លម្អព្រះនិព្វានដូចគ្នាដែរ ឬផ្សេងគ្នាដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកយើងនឹងបានស្តាប់ចូលចិត្តផងមើល!

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះមហានគរគឺព្រះនិព្វាន និងមហានគរក្នុងលោកិយនេះ មានគ្រឿងប្រដាប់សម្រាប់លម្អដ៏រុងរឿងវិសេសវិសាលដូចគ្នាដែរ តែថាអត្ថរសផ្សេងគ្នា ដូចមានក្នុងគម្ពីរនិព្វានសូត្រ អធិប្បាយទៅនេះថា លោកិយមហានគរក្រុងដែលធំទូលាយជាលោកិយ មានរូបធម៌ គឺ ឧបាទិន្នករូបនិងអនុបាទិន្នករូប គឺរូបមនុស្សទាំងឡាយនិងសត្វទាំងឡាយច្រើនកុះករនិងផ្លូវថ្នល់តូច ធំ សួនច្បារ ប្រាសាទ វិមាន មាស ប្រាក់ កែវកងជាដើមពេញពាសបរិបូណ៌

កើតដោយកម្លាំងសង្ខារ រចនាតាក់តែងឲ្យកើតឡើងជាទីលម្អដ៏រុងរឿង វិសេសផ្សេងៗ ក្នុងលោកិយមហានគរ មានសេចក្ដីឧបមាយ៉ាងណា លោកុត្តរមហានគរក្រុងកែវ គឺព្រះនិព្វាន ដ៏ទូលំទូលាយប្រសើរវិសេស វិសាលធ្ងន់ផុតចាកលោកទាំង ៣ ជាស្រឡះ មានអរូបធម៌ជាបរមត្ថធម៌ ឥតរូបមានខ្លឹមសារដ៏ល្អិតផូរផង់ គឺផលញ្ញាណ សោយសុខក្សេមក្សាន្ត រចនាតាក់តែងយកផលសីល ធ្វើជាកំពែង យកផលបញ្ញា ធ្វើជាក្លោងទ្វារ យកផលសមាធិ ធ្វើជាសើន យកផលមេត្តា ធ្វើជាស្នាមភ្លោះ យកផលព្រះកម្មដ្ឋានទាំង ៤០ ធ្វើជាផ្លូវថ្នល់កែវខ្វាត់ខ្វែងជាក្រឡាចត្រង្គ យកផលពោធិបក្ខិយធម៌ទាំង ៣៧ ធ្វើជារានផ្សារធំ ៣៧ យកផលសម្មប្បធានទាំង ៤ ធ្វើជាសសរ យកផលព្រះអភិធម្មទាំង ៧ គម្ពីរ ធ្វើជាល្វែងប្រាសាទកែវ ៧ ជាន់ យកផលនេក្ខម្មៈធ្វើជាទីដំណេក យកផលវិមុត្តិញ្ញាណ ធ្វើជាបល្ល័ង្ក យកផលវិមុត្តិញ្ញាណទស្សនៈ ធ្វើជាប្រទីបជ្វាលាដ៏ភ្លឺរុងរឿងព្រោងព្រាត យកផលភាវនា ធ្វើជាស្រះមង្គលបោក្ខរណី យកផលករុណា ធ្វើជាទឹកថ្លាស្អាតដ៏ពេញបរិបូណ៌ យកផលអដ្ឋារសញ្ញាណទាំង ១៨ ធ្វើជាដីខ្សាច់ពេជ្រ មានពួកអមរជាតិនិងហ្វូងសកុណជាតិ គឺព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះខីណាស្រពទាំងឡាយ

តែងសេពគប់ដោយច្រើនជានិច្ច ជាគ្រឿងប្រដាប់សម្រាប់លម្អដ៏ភ្លឺស្វាង រុងរឿងវិសេសផ្សេងៗ ក្នុងលោកុត្តរមហានគរក្រុងកែវដ៏ធំទូលាយបរិសុទ្ធ ខ្ពង់ផុតចាកលោកទាំង ៣ គឺព្រះនិព្វាន មានសេចក្តីឧបមេយ្យដូចលោកិយ-មហានគរនោះឯង ។ មួយទៀតព្រះអរហំសម្មាសម្ពុទ្ធទ្រង់សម្តែងបុច្ឆាវិសជ្ជ-នាដោយព្រះអង្គឯងថា កេនត្ថេន និព្វានំ បវុច្ចតិ សុន្ទរដ្ឋានដែលតថាគតពោលឲ្យឈ្មោះថាព្រះនិព្វានដោយអត្ថរសដូចម្តេច? ហើយវិសជ្ជ-នាដោយព្រះអង្គឯង សីតលត្ថេន បត្តោ វិយ និព្វានំ ។ ល ។ សមោធានត្ថេន សុធម្មោ វិយ និព្វានំ ព្រះនិព្វានដូចជាព្រះចន្ទ្រ ដោយអត្ថរសថាត្រជាក់សប្បាយ ព្រះនិព្វានដូចជាព្រះអាទិត្យ ដោយអត្ថរសថា ញុំាងកងកិលេសទាំងអស់ឲ្យរីងស្ងួតសូន្យសោះ ព្រះនិព្វានដូចជាផែនដី ដោយអត្ថរសថា ជាទីតាំងចំពោះនៃព្រះខីណាស្រពទាំងឡាយ ព្រះនិព្វានដូចជាថ្មកែវ ដោយអត្ថរសថា មិនចេះកក្រើកញាប់ញ័រដោយកងកិលេស ព្រះនិព្វានដូចជាមហាសមុទ្រសាគរ ដោយអត្ថរសថា ញុំាងកែវវិសេសទាំង ៣ គឺ ពុទ្ធរតនៈ ១ ធម្មរតនៈ ១ សង្ឃរតនៈ ១ ឲ្យកើតឡើងព្រមក្នុងលោក ព្រះនិព្វានដូចជាធម្មិល្អប្រពៃ ដោយអត្ថរសថាជាទីប្រជុំព្រមដែលព្រះខីណាស្រព ទាំងឡាយមានព្រះសព្វញ្ញូសម្ពុទ្ធ

ជាដើមតែងសេពគប់ តែថាព្រះនិព្វាននោះជាផែនដីពិតមែន ក៏ទេដែរ ជាទឹកពិតមែនក៏ទេដែរ ជាភ្លើងពិតមែនក៏ទេដែរ ជាខ្យល់ពិតមែន ក៏ទេដែរ ព្រះនិព្វាននោះជាគុណជាតមិនត្រជាក់ពេកមិនក្តៅពេកឡើយ គឺចំណែកបរមត្ថធម៌យ៉ាងឯកដ៏ឧត្តមប្រសើរ ប្លែកឥតគូមិនចេះចាស់ជរាមិនចេះឈឺចាប់មិនចេះស្លាប់កើត ជាសុខយ៉ាងល្អិតដ៏សំខាន់ស្ងប់រម្ងាប់ ចាកកងទុក្ខទាំងអស់ ជាទីក្សេមក្សាន្តមិនបានច្រឡំដោយកងទុក្ខណាមួយឡើយ បានឈ្មោះថា មហានគរក្រុងកែវដ៏ប្រសើរ គឺព្រះនិព្វានដោយចំណែកមានតែមួយស្ថាននេះឯង ។ វិសជ្ជនាមកអំពីលោកុត្តរមហានគរនិងលោកិយមហានគរ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

១០២- ធម្មវាទី បានស្តាប់ហើយពោលថា ម្នាលអត្តវាទី លោកបានវិសជ្ជនាមកនេះប្រពៃហើយ តែថាយើងនៅមានសង្ស័យតទៅទៀត ចុះផលញ្ញាណជាអរូបធម៌គ្មានរូប ជាធម៌ឯកតែមួយគ្មានគូទេ សោយសុខដូចម្តេចបាន ឬមានវេទនាសម្រាប់សោយសុខដែរឬដូចម្តេច? ពួកបុគ្គលជាបុថុជ្ជនច្រើនចូលចិត្ត បើព្រះនិព្វានគ្មានរូបសោះទេ បានអ្វីសោយសុខ លុះតែមានរូបបុរស ស្ត្រី ប្តីប្រពន្ធ កូនចៅ ទ្រព្យសម្បត្តិពេញបរិបូណ៌ជាដើម ទើបនឹងសោយសុខសប្បាយបាន បើព្រះនិព្វាន

មានតែផលញ្ញាណមួយគ្មានរូបអ្វីសោះទេ នឹងសោយសុខសប្បាយដូចម្តេចបាន? ចូរលោកវិសជ្ជនាប្រស្នានេះឲ្យច្បាស់ស្រឡះមក យើងនឹងបានស្តាប់ចូលចិត្តផងមើល!

អត្ថវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ផលញ្ញាណគ្មានរូបជាធម៌ឯក មានតែមួយឥតគូក៏ពិតមែនហើយ តែជាគង់មានផលជវន ១ ជាអព្យាកតវេទនាយ៉ាងវិសេស ផ្សេងអំពីវេទនាជាលោកិយទាំងអស់កើតអំពីព្រះអរហត្តផលសម្រាប់សោយសុខក្សេមក្សាន្តដោយចំណែកមួយពិត ។

ឯពួកបុគ្គលជាបុថុជ្ជនច្រើនចូលចិត្តថា បើព្រះនិព្វានគ្មានរូបសោះទេ បានអ្វីនឹងសោយសុខនោះ ព្រោះតែបុគ្គលជាបុថុជ្ជនកើតក្រាស់ទៅដោយកងកិលេសមានអវិជ្ជាជាដើម តែងគ្របសង្កត់បិទបាំងប្រាជ្ញាវង្វេងកាន់ច្រឡំអារម្មណ៍ សម្គាល់អនិដ្ឋារម្មណ៍ថាជាឥដ្ឋារម្មណ៍វិញ ចូលចិត្តគាប់ចិត្ត ស្រឡាញ់រាប់អានបញ្ចក្ខន្ធមានរូបក្ខន្ធជាដើម គឺបុរស ស្ត្រីមានប្តីប្រពន្ធកូនចៅនិងទ្រព្យសម្បត្តិជាដើម ដែលព្រះអរិយបុគ្គលទាំងឡាយ លោកមិនប្រាថ្នាមិនស្រឡាញ់គាប់ចិត្តសោះ លោកបានពិចារណាឃើញទោសជាក់ច្បាស់ថា ជាគ្រឿងប្រជុំកងទុក្ខទាំងពួងឲ្យកើតឡើងដោយពិត ហើយបុគ្គលជាបុថុជ្ជននោះកាន់យកអនិដ្ឋារម្មណ៍

នោះមកជាឥដ្ឋារម្មណ៍ ចូលចិត្តស្រឡាញ់រាបអានគាប់ចិត្តនឹងបញ្ចក្ខន្ធមានរូបក្ខន្ធជាដើមនោះថាជាសុខសប្បាយស្រួលល្អវិញ ព្រោះតែកង់កិលេសមានអវិជ្ជាជាដើម មកគ្របសង្កត់សន្តានខ្លួនឲ្យងងឹតសូន្យឈឹងវង្វេងភាន់ច្រឡំអារម្មណ៍មិនសមគួរតាមសភាពពិតឡើយ ។ ចំណែកឯព្រះខីណាស្រពទាំងឡាយលោកបានពិចារណាឃើញទោស ឧប្បាទ-ធម៌ជាក់ច្បាស់ថា សត្វទាំងឡាយតែមានបញ្ចក្ខន្ធមានរូបក្ខន្ធជាដើមកើតឡើងហើយ តែងប្រជុំសោយទុក្ខវេទនាជាទម្ងន់យ៉ាងច្រើនបំផុតគឺទុក្ខកើតអំពីការរកស៊ីចិញ្ចឹមជីវិតបានដោយលំបាកខ្លាំងផង ទុក្ខកើតអំពីកិច្ចការចិញ្ចឹមរក្សាខ្លួន និងចិញ្ចឹមរក្សាប្រពន្ធកូនចៅជាដើម ពុំពេញលេញផង ទុក្ខកើតអំពីសេចក្តីចាស់ជរាតែងបៀតបៀនខន្ធជាប់ជានិច្ចផងទុក្ខកើតអំពីការមានជំងឺឈឺចាប់ខ្លួនឯងនិងប្រពន្ធកូនចៅជាដើមផង ទុក្ខកើតអំពីការព្រាត់ប្រាសគ្នានិងស្លាប់ប្រពន្ធកូនចៅជាដើមផង ទុក្ខកើតអំពីបុគ្គលពាលនិងអ្នកដទៃបៀតបៀនខន្ធរបស់ខ្លួនជាដើមផង ក៏ព្រះខីណាស្រពទាំងឡាយ លោកបានពិចារណាឃើញទោស ឧប្បាទធម៌នេះជាក់ច្បាស់ហើយ ទើបលោកបានពិចារណាឃើញផលានិសង្សអនុប្បាទធម៌គឺធម៌ដែលពុំបានកើតបញ្ចក្ខន្ធទៀតពុំបានស្លាប់វិញជាធម៌មាន

ខ្ទឹមសារបរិសុទ្ធម៉ត់ចត់ល្អដ៏ទៀង គឺអមតមហានិព្វានពិត ហើយលោកមានឧស្សាហ៍ខំព្យាយាមប្រឹងប្រែងចម្រើនភាវនានូវសមថកម្មដ្ឋាននិងវិបស្សនាកម្មដ្ឋានដរាបដល់បានសម្រេចព្រះអរហត្តផលញ្ញាណដោយពិត លុះដល់អាយុសង្ខាររបស់លោកអស់ហើយ ទើបលោករំលត់ខន្ធទាំងប្រាំជាលោកិយជ្រះស្រលះហើយលោកចូលកាន់ព្រះបរមនិព្វាន ជាសិវដ្ឋានបានសោយសុខក្សេមក្សាន្តមិនប្រឡំដោយកងទុក្ខទាំងពួងឡើយ ។

វិសជ្ជនាមកអំពីសោយសុខក្នុងព្រះនិព្វានយ៉ាងឧត្តម ជាងសុខទាំងអស់ជាលោកិយ ដោយសេចក្តីសង្ខេបតែប៉ុណ្ណោះឯង ។

១០៣- ធម្មវាទី បានស្តាប់ហើយសួរតទៅទៀតថា ម្នាលអត្តវាទី ចុះព្រះនិព្វានបានឈ្មោះថាចិត្តដែរ ឬថាពុំបានឈ្មោះថាចិត្តទេ? បើពុំបានឈ្មោះថាចិត្តទេ បានឈ្មោះដទៃអំពីចិត្តវិញ តើអធិប្បាយដូចម្តេចខ្លះ? ចូរលោកវិសជ្ជនាមកឲ្យសព្វគ្រប់យើងនឹងបានស្តាប់ចូលចិត្តផលមើល!

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី ព្រះនិព្វាននោះកើតមកអំពីចិត្តពិតមែន តែថាព្រះបរមគ្រូជាម្ចាស់ព្រះអង្គពុំបានត្រាស់សម្តែងឲ្យឈ្មោះថាចិត្តឡើយ ព្រះអង្គទ្រង់ត្រាស់សម្តែងឲ្យឈ្មោះថាផល-

ញ្ញាណមានឈ្មោះផ្សេងអំពីចិត្តវិញដូចអធិប្បាយតទៅនេះ សេចក្តីថា ព្រះនិព្វាននោះកើតមកអំពីចិត្តក៏ពិតមែនហើយ តែពុំបានឈ្មោះថា ចិត្តទេ បានឈ្មោះថាផលញ្ញាណវិញ ព្រោះប្លែកអំពីចិត្តជាលោកិយពិត ចំណែកឯចិត្តជាលោកិយតែងលាយច្រឡំទៅដោយលោភៈ ទោសៈ មោហៈជាអកុសលខ្លះ លាយច្រឡំទៅដោយអលោភៈ អទោសៈ អមោហៈ ជាកុសលខ្លះ ជាចិត្តត្រូវការសន្សំនូវអារម្មណ៍ល្អក៏យក អារម្មណ៍អាក្រក់ ក៏យកពុំបានរើសអារម្មណ៍ឡើយ គឺថាបុណ្យក៏ធ្វើបាបក៏ធ្វើ ជាចិត្តអាប់ ឥតពន្លឺរស្មីដ៏សៅហ្មងដោយឧបក្កិលេសទាំងឡាយ តែងចូលមកជ្រៀត ជ្រកអប់រំជាប់ជានិច្ចដ៏ល្អក់ពុំបានជ្រះថ្លា ស្អាតផូរផង់ឡើយ បានឈ្មោះ ថាលោកិយចិត្តដ៏គ្រោតគ្រាត ព្រោះជំពាក់ដោយកិច្ចទាំង ១៦ ពុំទាន់ បានធ្វើឲ្យសម្រេចស្រេច ចំណែកឯព្រះនិព្វានកើតមកអំពីញាណដ៏ល្អិត ផូរផង់ជាផលរបស់ព្រះអរហត្ត បានឈ្មោះថា ផលញ្ញាណប្រាជ្ញាដ៏ថ្លា ស្អាតផូរផង់ ភ្លឺស្វាងរុងរឿងវិសេសបំផុត រួចស្រឡះចាកកងកិលេស-ធម៌ទាំងអស់ពុំមានសេសសល់សោះ បានឈ្មោះថា ផលញ្ញាណវិញ នឹងហៅថាចិត្តពុំបានឡើយ ព្រោះព្រះអរិយបុគ្គលទាំងឡាយលោក បានសូចម្រាញ់ បណ្តេញចេញនូវគ្រឿងសៅហ្មងទឹកចិត្តរបស់លោក

ដោយមគ្គទាំង ៤ ក្នុងព្រះអរិយសច្ចទាំង ៤ ដោយកិច្ចបួនៗ គឺ ទី ១- ព្រះអរិយបុគ្គលដែលលោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ច ៤ គឺ បរិញ្ញាកិច្ច អំពើធ្វើកំណត់កត់សម្គាល់ដឹងច្បាស់នូវកងទុក្ខសច្ច ១ បហានកិច្ច អំពើធ្វើព្យាយាមលះបង់នូវសមុទយសច្ច គឺ តណ្ហាជាហេតុប្រជុំតាក់តែងកងទុក្ខទាំងពួងឲ្យកើតឡើង ១ សច្ចិកិរិយា អំពើធ្វើឲ្យថ្វាស្អាតជាក់ច្បាស់នូវនិរោធសច្ចដែលជាគ្រឿងរំលត់បង់នូវតណ្ហា ១ ភាវនាកិច្ច អំពើធ្វើព្យាយាមប្រឹងប្រែងចម្រើននូវមគ្គសច្ច ដែលជាផ្លូវដំណើរទៅកាន់ទីរំលត់នូវកងទុក្ខទាំងពួង ១ ហើយញ៉ាំងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយសោតាបត្តិមគ្គចិត្តពិត ។ ទី ២- ព្រះអរិយបុគ្គលដែលលោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ចទាំង ៤ ដូចគ្នាដែរ ហើយញ៉ាំងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយសកិទាគាមិមគ្គចិត្តពិត ។ ទី ៣- ព្រះអរិយបុគ្គលដែលលោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ចទាំង ៤ ដូចគ្នា ហើយញ៉ាំងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយអនាគាមិមគ្គចិត្តពិត ។ ទី ៤- ព្រះអរិយបុគ្គលដែលលោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ចទាំង ៤ ដូចគ្នា

ហើយញ៉ាំងកិច្ចទាំង ៤ ឲ្យសម្រេចស្រេចដោយព្រះអរហត្តមគ្គចិត្តពិត ។ ក៏ព្រះអរិយបុគ្គលទាំងឡាយ ដែលលោកបានបណ្ដេញបង់នូវគ្រឿងសៅហ្មងគឺកិលេសតណ្ហាទាំងអស់ ក្នុងព្រះអរិយសច្ចទាំង ៤ សម្រេចដោយកិច្ចទាំង ៤ ធ្វើឲ្យហើយស្រេចដោយមគ្គចិត្តទាំង ៤ គឺសោតាបត្តិ-មគ្គចិត្តមានកិច្ច ៤ សកិទាគាមិមគ្គចិត្តមានកិច្ច ៤ អនាគាមិមគ្គចិត្តមានកិច្ច ៤ ព្រះអរហត្តមគ្គចិត្តមានកិច្ច ៤ ត្រូវជាសោឡសកិច្ចទាំង ១៦ សម្រេចស្រេចពិត កាលបើព្រះអរិយបុគ្គលទាំងឡាយ លោកបានញ៉ាំងកិច្ចទាំង ១៦ នេះឲ្យសម្រេចស្រេចហើយទើបលោកបានសម្រេចដល់ព្រះអរហត្តផលចិត្តពេញទី តែថាព្រះសម្មាសម្ពុទ្ធជាអម្ចាស់ព្រះអង្គពុំបានត្រាស់ឲ្យឈ្មោះថា ផលចិត្តទេ ព្រះអង្គត្រឡប់ឲ្យឈ្មោះថា ផល-ញ្ញាណវិញ គឺប្រាជ្ញដ៏ភ្លឺថ្លាស្អាតចាប់តោងយកព្រះនិព្វានមកជាអារម្មណ៍ជាប់ពុំដាច់ដែលជាផលរបស់សន្ដានលោក ដែលថ្លាស្អាតផូរផង់បរិសុទ្ធផុតស្រឡះចាកកងកិលេសធម៌ទាំងអស់ពុំមានសេសសល់ ហើយព្រះអង្គឲ្យឈ្មោះថាព្រះនិព្វានគឺផលញ្ញាណពិត ព្រះអង្គពុំបានឲ្យឈ្មោះថាចិត្តឡើយ មានសេចក្ដីឧបមាដូចបុគ្គលយកស្រូវមកហាលថ្ងៃហើយកិននឹងត្បាល់កិនស្រូវ ធ្វើឲ្យអស់សម្បកក្រាស់ៗចេញអស់ ហៅថា អង្ករសំរូប

វិញ គេពុំបានហៅថាស្រូវឡើយ ទើបគេយកអង្ករសំរូបនោះទៅដាក់ក្នុងត្បាល់ជាន់ឬត្បាល់បុក ហើយគេជាន់ឬបុកធ្វើឲ្យអស់សម្បកស្តើងៗចេញអស់ហៅថាអង្ករសំរិតវិញ គេពុំបានហៅថាអង្ករសំរូបឡើយ ទើបគេយកអង្ករសំរិតនោះ ទៅត្រាំទឹកហើយស្រង់ឡើងសំដិលហាលឲ្យស្ងួតទន់ជ្រាយស្រេចហើយ យកទៅកិនទឹងត្បាល់កិនម្សៅធ្វើឲ្យល្អិតផង់ម៉ត់ចត់អស់ហៅថាម្សៅវិញ គេពុំបានហៅថាអង្ករសំរិតឡើយ ទើបគេយកម្សៅនោះទៅទទាក់ឬរែងទឹងចង្អេរឬក្រតៅជាដើម ធ្វើឲ្យអស់ម្សៅដែលលាយដោយដុំធំគ្រោតគ្រាតចេញ ឲ្យសល់នៅតែម្សៅដែលល្អិតម៉ត់ផូរផង់ហៅថាម្សៅផង់សុទ្ធវិញ គេពុំបានហៅថាម្សៅគ្រោតគ្រាតឡើយ មានសេចក្តីឧបមាយ៉ាងណា ព្រះអរិយបុគ្គលទាំងឡាយលោកបានពិចារណាឃើញទោសឧប្បាទធម៌ជាក់ច្បាស់ថា សត្វទាំងឡាយតែមានបញ្ចក្ខន្ធមានរូបក្ខន្ធជាដើមកើតឡើងហើយ តែងប្រជុំសោយទុក្ខវេទនាជាទម្ងន់ដោយក្រៃលែង ទើបលោកបានពិចារណាឃើញផលានិសង្សអនុប្បាទធម៌គឺធម៌ដែលពុំបានកើតបញ្ចក្ខន្ធទៀត ពុំបានស្លាប់វិញថាជាធម៌មានខ្លឹមសារបរិសុទ្ធម៉ត់ចត់ល្អដ៏ទៀង គឺព្រះនិព្វានជាក់ច្បាស់ហើយ ទើបលោកខំព្យាយាមប្រឹងប្រែងចម្រើនភាវនានូវសមថកម្មដ្ឋាន

និងវិបស្សនាកម្មដ្ឋាន ដំម៉ត់ចត់កំណត់យកលោកិយចិត្តទាំង ៣ គឺកាមាវចរចិត្ត ១ រូបាវចរចិត្ត ១ អរូបាវចរចិត្ត ១ ដូចជាស្រូវពូជ ទើបលោកខំព្យាយាមកម្តៅចិត្តទាំងនោះ ឲ្យក្តៅសព្វដូចជាយកស្រូវមកហាលកម្តៅថ្ងៃ លោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ ដូចជាយកស្រូវមកចាក់ចុះក្នុងត្បាល់កិនស្រូវ លោកបានធ្វើកិច្ចទាំង ៤ មានបរិញ្ញាកិច្ចជាដើមឲ្យសម្រេចហើយបានលះបង់នូវសញ្ញោជនៈទាំង ៣ និងអកុសលចិត្តទាំង ៥ ជាស្រឡះ ដូចជាកិនស្រូវធ្វើសម្បកក្រាស់ៗ ឲ្យអស់ចេញ សម្រេចដោយមគ្គចិត្តទី ១ ដូចជាដៃត្បាល់កិនសម្រាប់ចាប់កិនស្រូវ លោកបានធ្វើកិច្ចទាំង ៤ ឲ្យហើយស្រេចសម្រេចដល់ផលចិត្តទី ១ ដែលជាផលកើតមកអំពីមគ្គចិត្តទី ១ ហៅថា សោតាបត្តិផល ដូចជាពាក្យហៅថាអង្ករសំរូប ដែលជាផលកើតមកអំពីស្រូវនោះដែរ ព្រះអរិយបុគ្គលទាំងឡាយ ដែលលោកបានខំព្យាយាមចម្រើនកម្តៅលោកិយចិត្តដែលសល់នៅទាំងអស់ឲ្យក្តៅសព្វហើយ លោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ ដូចជាយកអង្ករសំរូបមកដាក់ក្នុងត្បាល់ជាន់ឬត្បាល់បុក លោកបានធ្វើកិច្ចទាំង ៤ មានបរិញ្ញាកិច្ចជាដើម ឲ្យសម្រេចស្រេចហើយបានលះបង់នូវសញ្ញោជនៈជាចំណែកនៃកាមធាតុទាំងប្រាំគឺ ៣ ខាងដើមលះបង់អស់

២ ខាងចុងគ្រាន់តែស្ដើងតិចប៉ុណ្ណោះ នឹងលះបង់អកុសលចិត្តទាំង ៧ គឺ ៥ ខាងដើមដាច់ជាស្រឡះ ២ ខាងចុង គឺបដិឃចិត្តទាំង ២ គ្រាន់តែស្ដើងតិចប៉ុណ្ណោះ ដូចជាជាន់ឬបុកអង្ករសំរូប នឹងត្បាល់ជាន់ឬត្បាល់បុកធ្វើសម្បកអង្ករសំរូបយ៉ាងស្ដើងៗ ឲ្យអស់ចេញ សម្រេចដោយមគ្គ-ចិត្តទី ២ ដូចជាអង្រែសម្រាប់ជាន់ឬសម្រាប់បុក លោកបានធ្វើកិច្ចទាំង ៤ ឲ្យហើយស្រេចសម្រេចដល់ផលចិត្តទី ២ ដែលជាផលកើតមកអំពីមគ្គ-ចិត្តទី ២ ហៅថា សកិទាគាមិផល ដូចពាក្យហៅថាអង្ករសំរិតជាផលកើតមកអំពីអង្ករសំរូបនោះដែរ ព្រះអរិយបុគ្គលទាំងឡាយដែលលោកបានខំព្យាយាមចម្រើនកម្ដៅលោកិយចិត្ត ដែលនៅសល់ទាំងអស់ឲ្យក្ដៅសព្វ លោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ ដូចជាយកអង្ករសំរិតដែលត្រាំទឹកហើយស្រង់ឡើងហាលសំដិល ឲ្យស្ងួតទន់ជ្រាយដាក់ក្នុងត្បាល់កិនម្សៅ លោកបានធ្វើកិច្ចទាំង ៤ មានបរិញ្ញាកិច្ចជាដើមឲ្យសម្រេចស្រេចហើយបានលះបង់នូវសញ្ញោជនៈ ជាចំណែកនៃកាមធាតុជាខាងក្រោមទាំង ៥ ជាស្រឡះ និងអកុសលចិត្តទាំង ៧ ជាស្រឡះ ដូចជាកិនអង្ករសំរិតដែលដាក់ក្នុងត្បាល់កិនម្សៅ កិនធ្វើឲ្យល្អិតម៉ត់ជាម្សៅ សម្រេចដោយមគ្គចិត្តទី ៣ ដូចជាដៃត្បាល់កិនម្សៅ លោកបានធ្វើកិច្ច

ទាំង ៤ ឲ្យហើយស្រេចសម្រេចដល់ផលចិត្តទី ៣ ដែលជាផលកើតមក អំពីមគ្គចិត្តទី ៣ ហៅថាអនាគាមិផលដូចជាពាក្យហៅថាម្សៅដែលជាផល កើតមកអំពីអង្ករសំរិតនោះដែរ ព្រះអរិយបុគ្គលទាំងឡាយដែលលោក បានព្យាយាមចម្រើនកម្តៅលោកិយចិត្ត ដែលសល់នៅទាំងអស់ឲ្យក្តៅ សព្វ លោកបានពិចារណាក្នុងព្រះអរិយសច្ចទាំង ៤ ដូចជាបុគ្គលយក ម្សៅដាក់ក្នុងចង្អេរ ឬ ក្រតៅជាដើមសម្រាប់ទទាក់ ឬ រែងម្សៅ លោក បានធ្វើកិច្ចទាំង ៤ មានបរិញ្ញាកិច្ចជាដើម ឲ្យសម្រេចស្រេចហើយ បានលះបង់នូវសញ្ញោជនៈទាំង ១០ និងអកុសលចិត្តទាំង ១២ មហា- កុសលចិត្តទាំង ៨ ជាស្រឡះ ដូចជាទទាក់ ឬរែងម្សៅធ្វើឲ្យមានដុំធំគ្រោត គ្រាតអស់ចេញ ឲ្យសល់នៅតែម្សៅផង់សុទ្ធ សម្រេចដោយមគ្គចិត្តទី ៤ ដូចជាចង្អេរ ឬក្រតៅជាដើម សម្រាប់ទទាក់ ឬរែង លោកបានធ្វើកិច្ច ទាំង ៤ ឲ្យហើយស្រេចសម្រេចដល់ផលចិត្តទី ៤ ដែលជាផលកើតមក អំពីមគ្គចិត្ត ៤ ហៅថា ព្រះអរហត្តផល ដូចជាម្សៅផង់សុទ្ធជាផលកើត មកអំពីម្សៅលាយដោយដុំធំគ្រោតគ្រាតនោះដែរ ក៏សន្តិលក្ខណដ្ឋាន ទីកន្លែងដែលស្ងប់រម្ងាប់ចាកកងកិលេសធម៌ទាំងអស់ជាលក្ខណៈ គឺព្រះ អមតមហានិព្វាន កើតមកអំពីចិត្តពិតមែន តែព្រះសម្មាសម្ពុទ្ធជាអម្ចាស់

ពុំបានហៅថា ចិត្តទេ ព្រះអង្គហៅថា ផលញ្ញាណវិញ ឧបមេយ្យដូចមេឡាផង់សុទ្ធនោះឯង ។

១០៤- ធម្មវាទី បានស្តាប់ហើយពោលថា សាធុៗ ម្នាលអត្តវាទី ប្រស្នានេះពីរោះប្រពៃណាស់ហើយ តែយើងនឹងសួរប្រស្នា ១ តទៅទៀត ចុះបុគ្គលទាំងឡាយដែលមានប្រាថ្នានឹងត្រាច់ទៅកាន់មហានគរ គឺ ព្រះនិព្វាន ដែលជាទីពឹងជ្រកកោនស្ងប់រម្ងាប់ចាកកងកិលេសទាំងពួងជាគុណធម៌មានដំណើរដ៏ទៀងប្រព្រឹត្តទៅខាងមុខ ជាសុខក្សេមក្សាន្តយ៉ាងនេះ តើនឹងត្រាច់ទៅដោយយានជំនិះអ្វី ដែលអាចនឹងធ្វើដំណើរឲ្យបានដល់មហានគរ គឺព្រះនិព្វានយ៉ាងឆាប់រហ័សបាន? ចូរលោកវិសជ្ជនាឲ្យមានពាក្យឧបមាឧបមេយ្យប្រៀបសេចក្តីឲ្យងាយស្តាប់ យើងនឹងបានស្តាប់ចូលចិត្តដោយសព្វគ្រប់ផងមើល!

អត្តវាទី វិសជ្ជនាតបថា បពិត្រធម្មវាទី បុគ្គលទាំងឡាយដែលមានសេចក្តីប្រាថ្នានឹងដោះរំខ្លួនឲ្យរួចផុតស្រឡះ ចាកសង្សារទុក្ខទាំងពួងនឹងដោះខ្លួនគេចវេះចៀសចេញទៅកាន់មហានគរ គឺព្រះនិព្វាន ដែលជាសុខក្សេមក្សាន្តឲ្យបានដល់ឆាប់រហ័សនោះ នឹងត្រាច់ទៅដោយយានដំរីក៏ពុំបាន ដោយយានសេះក៏ពុំបាន ដោយយានរថក៏ពុំបាន

ដោយយាន មានវិមាស អង្រឹងស្នែងជាដើមក៏ពុំបាន ដោយយានស្បែកជើងក៏ពុំបាន ដោយដំណើរដើរទៅដោយជើងក៏ពុំបាន លុះតែត្រាច់ទៅដោយពុទ្ធយាន គឺបុគ្គលមានសទ្ធាជឿជាក់ក្នុងព្រះពុទ្ធសាសនា បានបង្វែរកាយថ្វាយជីវិតខ្លួន ចំពោះព្រះពុទ្ធជាទីពឹងទីរឭកមាំមួនមិនកក្រើកជាយាន ១ ដោយធម្មយាន គឺបុគ្គលមានសទ្ធាជឿជាក់ក្នុងព្រះពុទ្ធសាសនា បានបង្វែរកាយថ្វាយជីវិតខ្លួនចំពោះព្រះធម៌ជាទីពឹងទីរឭកមាំមួន មិនកក្រើកជាយាន ១ ដោយសង្ឃយាន គឺបុគ្គលមានសទ្ធាជឿជាក់ក្នុងព្រះពុទ្ធសាសនា បានបង្វែរកាយថ្វាយជីវិតខ្លួនចំពោះព្រះសង្ឃជាទីពឹងទីរឭកមាំមួនមិនកក្រើកជាយាន ១ ដោយធម្មស្សវនយាន គឺបុគ្គលមានសទ្ធាជឿជាក់ក្នុងផលានិសង្ស ស្តាប់ព្រះធម៌ខំព្យាយាមស្តាប់ព្រះធម៌ហើយបដិបត្តិតាមសភាពពិតមិនកក្រើកជាយាន ១ ទើបអាចនឹងត្រាច់ទៅកាន់មហានគរ គឺព្រះនិព្វានយ៉ាងឆាប់រហ័សបាន ក៏បុគ្គលទាំងឡាយដែលមានប្រាថ្នានឹងត្រាច់ទៅមហានគរ គឺព្រះនិព្វាននោះ វៀរលែងតែយានទាំង ៤ នេះចេញហើយ ក៏មិនអាចនឹងត្រាច់ទៅកាន់មហានគរគឺព្រះនិព្វាននោះបានឡើយ ។ ឯមហានគរជាលោកិយ ដែលធំទូលាយជាទីមនោរម្យសុខក្សេមក្សាន្តសប្បាយស្ថិតនៅក្នុងទីឆ្ងាយជាងពាន់យោជន៍ បើ

បុគ្គលទាំងឡាយមានប្រាថ្នានឹងត្រាច់ទៅកាន់មហានគរនោះ ហើយឡើងជិះយានជំនិះឥតរិទ្ធិ មានកម្លាំងខ្សោយមានយានរទេះចាស់ទឹមគោចាស់ជាដើម មានអានុភាពតិចមិនអាចញ៉ាំងកិច្ចដំណើរនោះ ឲ្យដល់មហានគរបានឡើយ មុខជានឹងដល់នូវសេចក្តីអន្តរាយជីវិតក្នុងទីពាក់កណ្តាលផ្លូវនោះពុំខាន លុះតែបានស្វែងជ្រើសរើសរកយានជំនិះយ៉ាងលឿនខ្លាំងពូកែ មានរិទ្ធិអានុភាពច្រើន មានអាកាសយន្តឬរថយន្តជាដើមជិះត្រាច់ទៅ ទើបអាចនឹងធ្វើដំណើរដែលនឹងត្រាច់នោះទៅឲ្យបានដល់នូវមហានគរនោះ តាមប្រាថ្នាយ៉ាងឆាប់រហ័សបានដោយពិត មានសេចក្តីឧបមាដូចម្តេច?

ចំណែកខាងមហានគរ គឺព្រះនិព្វានដ៏ប្រសើរឧត្តមខ្ពង់ខ្ពស់ធំទូលាយ ជាទីអភិរម្យស្ងប់រម្ងាប់ចាកកងកិលេសធម៌ទាំងពួង ជាសុខក្សេមក្សាន្តស្ថិតនៅក្នុងទីបំផុតលោក បំផុតភពទាំង ៣ បើបុគ្គលទាំងឡាយមានប្រាថ្នានឹងត្រាច់ទៅកាន់មហានគរគឺព្រះនិព្វាននោះ ហើយវង្វេងជឿខុសកាន់យកវត្ថុដទៃជាខាងក្រៅព្រះពុទ្ធសាសនាមកជាទីពឹងទីរឭកមាំ ដែលជាយានជំនិះឥតរិទ្ធិប្រព្រឹត្តខុសទំនងសភាពធម៌ពិត បុគ្គលទាំងនោះមិនអាចនឹងត្រាច់ទៅកាន់មហានគរ គឺព្រះនិព្វាននោះបានឡើយ មុខជានឹងដល់

នូវសេចក្តីអន្តរាយសោយទុក្ខលំបាកតោកយ៉ាកជាទម្ងន់ ក្នុងទីពាក់កណ្តាលផ្លូវសង្សារវដ្តនោះពុំខាន លុះបានស្វែងជ្រើសរើសរកសរណវត្ថុដ៏ឧត្តមដែលខ្លាំងពូកែ មានមហិទ្ធានុភាពច្រើនជាយានគឺមានសទ្ធាជឿជាក់ក្នុងគុណព្រះពុទ្ធសាសនាហើយ បានបង្វែរកាយ ថ្វាយជីវិតខ្លួនចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និងស្តាប់ព្រះធម៌ជាទីពឹងទីរព្ញកមាំមួនមិនករក្រើក ជាយានជំនិះដ៏ឧត្តម ទើបអាចនឹងឡើងជិះត្រាច់ទៅកាន់មហានគរកែវ គឺព្រះនិព្វាននោះយ៉ាងឆាប់រហ័សបានដោយពិត មានសេចក្តីឧបមេយ្យដូច្នោះឯង ។

សេចក្តីនេះសមតាមពុទ្ធភាសិតក្នុងព្រះសូត្រថា យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ អាបទំ សោ ន គច្ឆេយ្យ អធិគច្ឆេយ្យ បទំ សិវុត្តិ ។ អធិប្បាយថា បុគ្គលឯណាមួយទោះបុរសក្តី ស្ត្រីក្តី មានសទ្ធាជឿមាំជាក់ច្បាស់ក្នុងគុណព្រះរតនត្រ័យមិនករក្រើកញាប់ញ័រឡើយ ហើយបានបង្វែរកាយថ្វាយជីវិតខ្លួនចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរព្ញកមាំជាឧត្តមយានហើយ បុគ្គលទាំងនោះពុំបានដល់នូវសេចក្តីអន្តរាយក្នុងសង្សារវដ្តឡើយ ទៀងតែនឹងត្រាស់ដឹងនូវព្រះអមតមហានិព្វានជាចំណែកលោកុត្តរធម៌ មានខ្លឹមយ៉ាងឧត្តម ជា

សុខក្សេមក្សាន្តដោយចំណែកមួយពិត ។

បពិត្រធម្មវាទី ខ្ញុំអត្តវាទី បានវិសជ្ជនាប្រស្នាជាគម្រប់ ១០៤ នេះ ដោយសេចក្ដីសង្ខេបតែប៉ុណ្ណោះឯង ។

សម្ដែងបុច្ឆា-វិសជ្ជនា នូវសេចក្ដីអធិប្បាយអត្ថរសចំពោះបរមត្ថ ព្រះអភិធម្មសង្គណី អំពីរឿងនិទាន-ចិត្ត-ចេតសិក-រូប-និព្វាន បានចងក្រងជាពាក្យ បុច្ឆា វិសជ្ជនា ចំនួន ១០៤ បញ្ហា រៀបរៀងសេចក្ដីតាំងព្រះពុទ្ធសករាជ ២៤៨៣ មកដល់ ព.ស. ២៤៨៤ ថ្ងៃសុក្រ ១១ រោច ខែកត្តិក ឆ្នាំម្សាញ់ត្រីស័ក ទើបចប់ស្រេចបរិបូណ៌ហោង ។

អភិធម្មត្ថាធិប្បាយកថា និដ្ឋិតា ។

ពិនិត្យកែសម្រេចចុងក្រោយចប់ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៨